គឺជាចម្លើយទូទៅនៃសមីការ។ ចំពោះតម្លៃមួយចំនួននៃ $c$ សមីការ $(36)$ អាំងតេក្រាលខ្សែកោង (Integral curves) ដូចរូប (2.1.4)។ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង យើងត្រូវឱ្យតម្លៃ $c=1$ នោះ

$$y = t^2 + \frac{1}{t^2}, \qquad t > 0 \qquad (41)$$

គឺជាចម្លើយនៃតម្លៃដើមឬចម្លើយពិសេស។ ចម្លើយនេះបានបង្ហាញថាកោងខ្លាំងដូចរូបភាព (1.1.4) ។ ចំណាំថា វាគ្មានដែនកំណត់និងអាស៊ីមតូតចំពោះផ្នែកវិជ្ជមាននៃអ័ក្ស $y$ ទេ ដូច $t \to 0$ ពីខាងស្តាំ។ នេះគឺដោយសារគ្មានដែនកំណត់ក្នុងមេគុណ $p(t)$ ។ អនុគមន៍ $y = t^2 + \left(1/t^2\right)$ ចំពោះ $t < 0$ មិនមែនផ្នែកនៃចម្លើយនៃតម្លៃដើមនេះទេ




រូបភាព 1.1.4

នេះគឺឧទាហរណ៍ដំបូងដែលចម្លើយមិនអាចកំណត់បានចំពោះតម្លៃ $t$ មួយចំនួន។ ជាថ្មីម្តងទៀត នេះដោយសារតែគ្មានដែនកំណត់ក្នុង $p(t)$ ពេល $t=0$ ដែលចម្លើយរួមនៅចម្លោះ $0<t<\infty$ ។

## ២.១.២ វិធីបម្រែបម្រួលនៃប៉ារ៉ាម៉ែត្រ

ពិចារណាតាមវិធីសាស្ត្រដោះស្រាយទូទៅសមីការលីនេអ៊ែរលំដាប់១។

$$y' + p(t)y = g(t) \qquad (i)$$

$(a)$. បើ $g(t)=0$ ដំណោះស្រាយបង្ហាញតាម

$$y' + p(t)y = 0 \Leftrightarrow \quad \frac{dy}{dt} = -p(t)y$$

$$\int \frac{dy}{y} = -\int p(t)\,dt \qquad \Leftrightarrow \ln|y| = -\int p(t)\,dt + c$$

$$y = Ae^{\left[-\int p(t)dt\right]} \qquad (ii)$$

$(b)$. បើ $g(t) \neq 0$ សម្មត់ថាដំណោះស្រាយមានទម្រង់

$$y = A(t)\mathrm{e}^{\left(-\int p(t)dt\right)} \qquad (iii)$$

$$y' = A'(t)\mathrm{e}^{\left(-\int p(t)dt\right)} - A(t)p(t)e^{-\int p(t)dt}$$

ដោយជំនួស $y, y'$ ក្នុងសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឱ្យ បញ្ជាក់ថា $A(t)$ បំពេញលក្ខខណ្ឌ

$$A'(t)\mathrm{e}^{\left(-\int p(t)dt\right)} - A(t)p(t)e^{-\int p(t)dt} + p(t)A(t)e^{-\int p(t)dt} = g(t)$$

$$A'(t)e^{\left(-\int p(t)dt\right)} = g(t)$$

$$A'(t) = g(t)e^{\int p(t)dt}$$

$$A(t) = \int\left[g(t)e^{\int p(t)dt}\right]dt + c \qquad (iv)$$

$(c)$. យក $A(t)$ ពីសមីការ $(iv)$ ជំនួស $A(t)$ ក្នុងសមីការ $(iii)$ និងកំណត់ $y$

$$y = \left(\int\left[g(t)e^{\int p(t)dt}\right]dt + c\right)e^{-\int p(t)dt}; \quad c \in \mathbb{R}$$

ផ្ទៀងផ្ទាត់ដំណោះស្រាយដែលបានរកជាមួយសមីការនោះ។

ឧទាហរណ៍១ រកចម្លើយសមីការខាងក្រោមតាមវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ $y'-2y = t^2e^{2t}$

សម្រាយបញ្ជាក់

យើងរកចម្លើយទូទៅនៃសមីការលីនេអ៊ែរអូម៉ូហ្សែន $y'-2y=0$

$$\frac{dy}{dt} - 2y = 0 \quad ; \quad \frac{dy}{y} = 2dt$$

$$\int\frac{dy}{y} = \int 2dt \quad ; \quad \ln|y| = 2t + c$$

$$y = Ae^{2t} \quad ; \quad A = \pm e^{c}$$

យើងរកចម្លើយទូទៅនៃសមីការលីនេអ៊ែរមិនអូម៉ូហ្សែន $y'-2y = t^2e^{2t}$ ដោយសន្មតយក

$y = A(t)e^{2t}$ ; $y' = A'(t)e^{2t} + 2A(t)e^{2t}$ យកជំនួសក្នុងសមីការដើមគេបាន

$$A'(t)e^{2t} + 2A(t)e^{2t} - 2A(t)e^{2t} = t^2e^{2t}$$

$$A(t) = \int t^2dt = \frac{t^3}{3} + c$$

អនុគមន៍ចម្លើយ $y(t) = \left(\frac{t^3}{3} + c\right)e^{2t} = ce^{2t} + \frac{1}{3}t^3e^{2t} \qquad c \in \mathbb{R}$

ឧទាហរណ៍២៖ រកចម្លើយសមីការខាងក្រោមតាមវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ

$$y' + \left(\frac{1}{t}\right)y = 3\cos 2t \quad ,t>0$$

សម្រាយបញ្ជាក់

យើងរកចម្លើយទូទៅនៃសមីការលីនេអ៊ែរអូម៉ូហ្សែន $y' + \left(\frac{1}{t}\right)y = 0$

$$\frac{dy}{dt} + \frac{1}{t}y = 0 \quad ; \quad \frac{dy}{y} = -\frac{1}{t}dt$$

$$\int\frac{dy}{y} = \int\frac{1}{t}dt \quad ; \quad \ln|y| = -\ln|t| + \ln|A|$$

$$y = A\frac{1}{t}; \quad A \in \mathbb{R}$$

យើងរកចម្លើយទូទៅនៃសមីការលីនេអ៊ែរមិនអូម៉ូហ្សែន $y' + \left(\frac{1}{t}\right)y = 3\cos 2t \quad ,t>0$ ដោយសន្មតយក

$y = A(t)\frac{1}{t}$ ; $y' = A'(t)\frac{1}{t} - A(t)\frac{1}{t^2}$ យកជំនួសក្នុងសមីការដើមគេបាន

$A'(t)\frac{1}{t} - A(t)\frac{1}{t^2} + A(t)\frac{1}{t}\cdot\frac{1}{t} = 3\cos 2t$

$A(t) = \int 3t\cos 2t dt = \frac{3t}{2}\sin 2t + \frac{3}{4}\cos 2t + c$

អនុគមន៍ចម្លើយ $y(t) = \left(\frac{3t}{2}\sin 2t + \frac{3}{4}\cos 2t + c\right)\frac{1}{t} = \frac{3}{2}\sin 2t + \frac{3}{4t}\cos 2t + c\frac{1}{t} \quad c \in \mathbb{R}$

## លំហាត់

ក្នុងលំហាត់1-12 ចូររកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ

| | |
|---|---|
| $1. y' + 3y = te^{-2t}$ | $2. y' - 2y = t^2e^{2t}$ |
| $3. y + y = te^{-t} + 1$ | $4. y' + \frac{1}{t}y = 3\cos 2t, \quad t > 0$ |
| $5. y' - 2y = 3e^t$ | $6. ry' + 2y = \sin t, \quad t > 0$ |
| $7. y + 2ty = 2te^{-t^2}$ | $8. (1+t^2)y' + 4ty = (1+t^2)^{-2}$ |
| $9. 2y' + y = 3t$ | $10. ty' - y = t^2e^{-t}$ |
| $11. y' + y = 5\sin 2t$ | $12. 2y' + y = 3t^2$ |

ក្នុងលំហាត់13-20 ចូររកចម្លើយពិសេសនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរតាមបញ្ហាតម្លៃដើម

| | |
|---|---|
| $13. y' - y = 2te^{2t}, \quad y(0) = 1$ | $14. y' + 2y = te^{-2t}, \quad y(1) = 0$ |
| $15. ty' + 2y = t^2 - t + 1, \quad y(1) = \frac{1}{2}, t > 0$ | $16. y + \left(\frac{2}{t}\right)y = \frac{\cos t}{t^2}, \quad y(\pi) = 0, \quad t > 0$ |
| $17. y' - 2y = e^{2t}, \quad y(0) = 2$ | $18. ty' + 2y = \sin t, \quad y\left(\frac{\pi}{2}\right) = 1$ |
| $19. t^3y' + 4t^2y = e^{-t}, \quad y(-1) = 0$ | $20. ty' + (t+1)y = t, \quad y(\ln) = 1$ |

## ២.២. សមីការអាចញែកអថេរបាន

នៅក្នុងដំណោះស្រាយសមីការមុនៗដែលមានទម្រង់

$$\frac{dy}{dt} = ay + b \qquad (1)$$

ដែល $a$ និង $b$ ជាចំនួនអថេរ។ យើងបានបង្ហាញពីរបៀបដោះស្រាយសមីការដែលមាន $y$ ជាអថេរអាស្រ័យនិង $t$ ជាអថេឯករាជ្យ។ ប៉ុន្តែនៅក្នុងផ្នែកនេះយើងបន្តសិក្សាសមីការឌីផេរ៉ង់ស្យែលលំដាប់ទីមួយមានរាងទូទៅគឺ

$$\frac{dy}{dx} = f(x, y) \qquad (2)$$

ដែល $y$ ជាអថេរអាស្រ័យនិង $x$ ជាអថេឯករាជ្យ។ សមីការ $(2)$ មិនមែនជាសមីការលីនេអ៊ែរ នោះមិនអាចអនុវត្តន៍បានទេសម្រាប់ការដោះស្រាយសមីការនោះ។ យើងពិចារណាថ្នាក់រងនៃសមីការលំដាប់ទីមួយដើម្បីកំណត់ថ្នាក់នៃសមីការ។

យើងសរសេរសមីការ $(2)$ ឡើងវិញក្នុងទម្រង់៖

$$M(x,y)+N(x,y)\frac{dy}{dx}=0 \qquad (3)$$

កំណត់ $M(x,y)=-f(a,y)$ និង $N(x,y)=1$ ប៉ុន្តែអាចមានវិធីផ្សេងទៀត។ ក្នុងករណីដែល $M$ ជាអនុគមន៍ $x$ តែមួយគត់ និង $N$ ជាអនុគមន៍ $y$ តែមួយគត់ នោះសមីការ (3) ក្លាយជា

$$M(x)+N(y)\frac{dy}{dx}=0 \qquad (4)$$

សមីការនេះត្រូវបានហៅថា សមីការអាចញែកអថេរបាន ព្រោះវាអាចសរសេរក្នុងទម្រង់ឌីផេរ៉ង់ស្យែលបាន

$$M(x)dx+N(y)dy=0 \qquad (5)$$

ឧទាហរណ៍១ ដោះស្រាយសមីការញែកអថេរខាងក្រោម៖

$$\frac{dy}{dx}=\frac{x^2}{1-y^2}$$

សម្រាយបញ្ជាក់

មាន $\frac{dy}{dx}=\frac{x^2}{1-y^2}$

យើងបាន $-x^2+\left(1-y^2\right)\frac{dy}{dx}=0$

$$\Rightarrow -x^2dx=-\left(1-y^2\right)dy$$

$$-\int x^2dx=-\int\left(1-y^2\right)dy$$

$$-\frac{x^3}{3}=-\left(y-\frac{y^3}{3}\right)+c$$

$$-x^3+3y-y^3=c \qquad , \qquad c\in R$$

ចម្លើយសមីការគឺជាគ្រួសារខ្សែរកោង $-x^3+3y-y^3=c$ បង្ហាញដូចរូប( 1.2.1 )ក្រោម៖




រូបភាព 1.2. 1

ឧទាហរណ៍២ ៖ ដោះស្រាយសមីការព្រៀកអថេរខាងក្រោម៖

$$\frac{dy}{dx}=\frac{3x^2+4x+2}{2(y-1)}\ ,\ \ y(0)=-1$$

យើងបាន

$$2(y-1)dy=\left(3x^2+4x+2\right)dx$$

$$\Rightarrow 2\int(y-1)dy=\int\left(3x^2+4x+2\right)dx$$

$$2\left(\frac{y^2}{2}-y\right)=\left(x^3+2x^2+2x\right)+c$$

$$y^2-2y=x^3+2x^2+2x+c$$

ដោយ $y(0)=-1$

$$(-1)^2-2(-1)=(0)^3+2(0)^2+2(0)+c$$

$$1+2=c$$

$$c=3$$

ចម្លើយពិសេសនៃសមីការគឺ $y^2-2y=x^3+2x^2+2x+3$

ចម្លើយសមីការគឺជាគ្រួសារខ្សែកោង $y^2-2y=x^3+2x^2+2x+c$ បង្ហាញដូចរូប( 1.2.2 )ក្រោម៖




រូបភាព1.2.2

## លំហាត់

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល1ដល់8

1. $y'=\frac{x^2}{y}$ 2. $y'=\frac{x^2}{y\left(1+x^3\right)}$

3. $y'+y^2\sin x=0$ 4. $y'=\frac{\left(3x^2-1\right)}{(3+2y)}$

5. $y'=\left(\cos^2 x\right)\left(\cos^2 2y\right)$ 6. $xy'=\left(1-y^2\right)^{\frac{1}{2}}$

7. $\frac{dy}{dx}=\frac{x-e^{-x}}{y+e^{y}}$ 8. $\frac{dy}{dx}=\frac{x^2}{1+y^2}$

លំហាត់ទី 9 ដល់ 20 :

a. រកដំណោះស្រាយតាមតម្លៃដើម

b. គូសក្រាហ្វនៃដំណោះស្រាយ

c. កំណត់ចន្លោះចម្លើយដែលដំណោះស្រាយត្រូវបានកំណត់

9. $y'=(1-2x)y^2, y(0)=-\frac{1}{6}$ 10. $y'=\frac{(1-2x)}{y}, y(1)=-2$

11. $xdx+ye^{-x}dy=0, y(0)=1$ 12. $\frac{dr}{d\theta}=\frac{r^2}{\theta}\ , r(1)=2$

13. $y'=\frac{2x}{(y+x^2y)}, y(0)=-2$ 14. $y'=xy^3(1+x^2)^{\frac{-1}{2}}\ , y(0)=1$

15. $y'=\frac{2x}{(1+2y)}\ , y(2)=0$ 16. $y'=\frac{x(x^2+1)}{4y^3}, y(0)=\frac{-1}{\sqrt{2}}$

17. $y'=\frac{(3x^2-e^x)}{(2y-5)}, y(0)=1$ 18. $y'=\frac{(e^{-x}-e^x)}{(3+4y)}, y(0)=1$

19. $\sin 2xdx+\cos 3ydy=0,$ $y\left(\frac{\pi}{2}\right)=\frac{\pi}{3}$

20. $y^2(1-x^2)^{\frac{1}{2}}dy=\arcsin xdx$ ; $y(0)=0$

21. ដំណោះស្រាយតម្លៃដើម $y'=\frac{(1+3x^2)}{(3y^2-6y)}$ , $y(0)=1$ និងកំណត់ចន្លោះចម្លើយដែលដំណោះស្រាយមានសុពលភាព។ ជំនួយ៖ ដើម្បីរកចន្លោះចម្លើយនៃ រកចំណុចដែលខ្សែកោងអាំងតេក្រាលមានបន្ទាត់ប្រាប់ទិសបញ្ឈរ។

22. ដំណោះស្រាយតម្លៃដើម $y'=\frac{3x^2}{(3y^2-4)}$ , $y(1)=0$ និងកំណត់ចន្លោះចម្លើយដែលត្រឹមត្រូវ។ ជំនួយ៖ ដើម្បីរកចន្លោះចម្លើយនៃនិយមន័យ រកចំណុចដែលខ្សែកោងអាំងតេក្រាលមានបន្ទាត់ប្រាប់ទិសបញ្ឈរ។

## ២.៣. សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរមានទម្រង់៖

$$y'+p(t)y=g(t) \qquad (1)$$

ប្រសិនបើ $g(t)=0$ សមីការក្លាយជាទម្រង់

$$y'+p(t)y=0 \qquad (2)$$

សមីការ $(2)$ ត្រូវបានគេហៅថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូហ្សែន។ យើងធ្វើការដោះស្រាយសមីការ $(2)$ តាមវិធីខាងក្រោម៖

$y'+p(t)y=0$

$y'=-p(t)y$

$\frac{dy}{dt}=-p(t)y$

$\frac{dy}{y}=-p(t)dt$ ធ្វើអាំងតេក្រាលលើអង្គសងខាង

$\int\frac{dy}{y}=-\int p(t)dt$

$y=Ae^{-\int p(t)dt} \quad ,A\in R$ (3) ជាអនុគមន៍ចម្លើយទូទៅនៃសមីការ (2)

ឧទាហរណ៍១៖ ចូរដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$y'-3y=0$

ចម្លើយ

ដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$y'-3y=0$ ដែល $p(t)=-3$

អនុគមន៍ចម្លើយទូទៅនៃសមីការមានទម្រង់ $y=Ae^{-\int p(t)dt}$ (3)

$y=Ae^{-\int -3dr}=Ae^{3t} \quad ,A\in R$

ដូចនេះ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែនមានអនុគមន៍ចម្លើយទូទៅ $y=Ae^{3t} \quad ,A\in R$

ឧទាហរណ៍២៖ ចូរដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$x\frac{dy}{dx}-4y=0$

ចម្លើយ

ដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$x\frac{dy}{dx}-4y=0 \quad \Leftrightarrow \quad y'-\frac{4}{x}y=0$ ដែល $p(x)=-\frac{4}{x}$

អនុគមន៍ចម្លើយទូទៅនៃសមីការមានទម្រង់ $y=Ae^{-\int p(t)dt}$ (3)

$y=Ae^{-\int -\frac{4}{x}dx}=Ae^{4\ln x}=Ax^4 \quad ,A\in R$

ដូចនេះ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែនមានអនុគមន៍ចម្លើយទូទៅ $y=Ax^4 \quad ,A\in R$

**<u>ករណីពិសេស</u>**

សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន $y'+p(t)y=0$ ។បើអនុគមន៍ $p(t)=\alpha$ ជាចំនួនថេរ នោះ សមីការមានក្លាយជា $y'+\alpha y=0$ (4)

អនុគមន៍ចម្លើយទូទៅអនុគមន៍ចម្លើយទូទៅគឺ $y(t)=Ae^{-\alpha x} \quad ,A\in\mathbb{R}$

ឧទាហរណ៍៣៖ ចូរដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$2\frac{dy}{dx}-4y=0$

ចម្លើយ

ដោះស្រាយថាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែន

$$2\frac{dy}{dx}-4y=0 \quad \Leftrightarrow \quad y'-2y=0$$ ដែល $\alpha=-2$

អនុគមន៍ចម្លើយទូទៅនៃសមីការមានទម្រង់ $y(x)=Ae^{2x} \quad A\in\mathbb{R}$

ដូចនេះ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូសែនមានអនុគមន៍ចម្លើយទូទៅ $y=Ae^{2x} \quad ,A\in R$

## ២.៤. សមីការ ប៊ែនូយី (Bernoulli Equations)

ពេលខ្លះវាអាចធ្វើទៅបានដើម្បីដោះស្រាយសមីការមិនមែនលីនេអ៊ែរដោយធ្វើការផ្លាស់ប្តូរអថេរអាស្រ័យដែលបំប្លែងវាទៅជាសមីការលីនេអ៊ែរ។វាពិតជាសំខាន់បំផុតចំពោះសមីការមានទម្រង់៖

$$y'+p(t)y=q(t)y^n \qquad (1)$$

សមីការ $(1)$ គេហៅថាសមីការ ប៊ែនូយី ដែល $n$ ជាចំនួនពិតហើយ $n\neq\{0,1\}$ ។

**<u>វិធីសាស្ត្រដោះស្រាយសមីការនៃប្រភេទនេះ</u>**

តាង $w=y^{1-n}$ ធ្វើដេរីវេធៀបអថេរ $t$

$$\frac{dw}{dt}=(1-n)y^{-n}y' \qquad \Rightarrow y'=\frac{y^n}{(1-n)}\frac{dw}{dt}$$ យកទៅជំនួសសមីការ $(1)$

$$\frac{y^n}{(1-n)}\frac{dw}{dt}+p(t)y=q(t)y^n$$

$$\frac{dw}{dt}+p(t)(1-n)y^{1-n}=(1-n)q(t)$$

$$w'+p(t)(1-n)w=(1-n)q(t) \qquad (2)$$

សមីការ $(2)$ គឺជាសមីការ លីនេអ៊ែរលំដាប់មួយ ដូចនេះយើងដោះស្រាយបានដូចឧទាហរណ៍មុនៗ។

ឧទាហរណ៍១៖ ចូរដោះស្រាយសមីការឌីប៊ែនូយី $\frac{dy}{dt}+\frac{1}{t}y=ty^2$

ចម្លើយ

ដោះស្រាយសមីការឌីប៊ែនូយី

$\frac{dy}{dt}+\frac{1}{t}y=ty^2$ មាន $n=2$ , $q(t)=t$ , $p(t)=\frac{1}{t}$

យើងទទួលបាន

$$w'+p(t)(1-n)w=(1-n)q(t)$$

$$w'-\frac{1}{t}w=-t$$

អនុគមន៍ចម្លើយទូទៅនៃសមីការគឺ $y(t)=\frac{1}{-t^2+ct}, \qquad c\in\mathbb{R}$

ឧទាហរណ៍២៖ ចូរដោះស្រាយសមីការឌីប៊ែនូយី

$$y'+\frac{4}{x}y=x^3y^2 \qquad y(1)=-1 \qquad x>0$$

ចម្លើយ

ដោះស្រាយសមីការឌីប៉ែនូយី

$$y'+\frac{4}{x}y=x^3y^2 \qquad \text{មាន } n=2 \quad , \qquad q(x)=x^2 \quad , \qquad p(x)=\frac{4}{x}$$

យើងទទួលបាន

$$w'+p(x)(1-n)w=(1-n)q(x)$$

$$w'-\frac{4}{x}w=-x^3$$

អនុគមន៍ចម្លើយទូទៅនៃសមីការគឺ $y^{-1}=x^4(c-\ln x) \quad , \quad c\in\mathbb{R}$

ដោយលក្ខខណ្ឌដើម $y(1)=-1$ គេបាន

$$-1=1(c-\ln 1)\ \Rightarrow c=-1$$

អនុគមន៍ចម្លើយពិសេសនៃសមីការគឺ $y^{-1}=-x^4(1+\ln x)$

ឧទាហរណ៍៣ ៖ ដោះស្រាយសមីការញែកអថេរខាងក្រោមតាមលក្ខខណ្ឌដើម៖

$$\frac{dy}{dx}=\frac{y\cos x}{1+2y^2} \quad ; \quad y(0)=1$$

យើងបាន

$$(1+2y^2)dy=y\cos x dx$$

$$\left(\frac{1}{y}+2y\right)dy=\cos x dx$$

$$\Rightarrow\int\left(\frac{1}{y}+2y\right)dy=\int\cos x dx$$

$$\ln|y|+y^2=\sin x+c$$

ដោយ $y(0)=1$

យើងបាន

$$\ln|1|+(1)^2=\sin(0)+c$$

$$\Rightarrow c=1$$

$$\Leftrightarrow |y|+y^2=\sin x+1$$

ចម្លើយសមីការគឺជាគ្រួសារខ្សែកោង $\ln|y|+y^2=\sin x+c$

## ២.៥. សមីការប្រាកដ

សម្រាប់សមីការលំដាប់ទីមួយ មានវិធីសាស្ត្ររួមបញ្ចូលមួយចំនួនដែលអាចអនុវត្តបានចំពោះលំហាត់ថ្នាក់ផ្សេងៗ។អ្វីដែលសំខាន់បំផុតនោះគឺ សមីការលីនេអ៊ែរ ដែលយើងបានពិភាក្សាពីមុនមក។ នៅទីនេះយើងនិងគណនាថ្នាក់។

សមីការដែលគេស្គាល់ថាជាសមីការប្រាកដដែលមានវិធីសាស្ត្រគណនាយ៉ាងល្អនៃដំណោះស្រាយ។ ទោះជាយ៉ាងណាក៏ដោយ សមីការលំដាប់មួយទាំងនោះដែលអាចដោះស្រាយតាមវិធីសាស្ត្រនៃការគណនាបឋមគឺពិសេសជាង។ សមីការលំដាប់ទីមួយភាគច្រើនមិនអាចដោះស្រាយតាមវិធីនេះបានទេ។

ឧទាហរណ៍១ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $2x+y^2+2xyy'=0$ (1)

សមីការមិនមែនជាសមីការលីនេអ៊ែ ឬសមីការមិនអាចបំបែកបាន ដូច្នេះវិធីសាស្ត្រទាំងនេះមិនអាចគណនាបានទេ។ តែគេសង្កេតឃើញថាមានអនុគមន៍ $\psi(x,y)=x^2+xy^2$ មានលក្ខណៈដូចខាងក្រោម៖ $\frac{\partial \psi}{\partial x}=2x+y^2$ , $\frac{\partial \psi}{\partial y}=2xy$ (2)

ដូច្នេះ សមីការឌីផេរ៉ង់ស្យែលយើងអាចសរសេរជា $\frac{\partial \psi}{\partial x}+\frac{\partial \psi}{\partial y}\frac{dy}{dx}=0$ (3)

ដោយ $y$ ជាអនុគមន៍នៃ $x$ ហើយយើងអាចសរសេរសមីការតាមទម្រង់សមមូល

$$\frac{d\psi}{dx}=\frac{d}{dx}\left(x^2+xy^2\right)=0 \qquad (4)$$

ដូច្នេះ $$\psi(x,y)=x^2+xy^2=c \qquad (5)$$

ដែល $c$ ជាចំនួនពិតថេរ ហើយជាសមីការខាងលើជាចម្លើយនៃសមីការ(1)។

នៅក្នុងការដោះស្រាយសមីការ (1) មានជំហានសំខាន់គឺរកអនុគមន៍ $\psi(x,y)$ មានទំនាក់ទំនងជាមួយ(2)ជាទូទៅសមីការឌីផេរ៉ង់ស្យែលត្រូវបានសរសេរ

$$M(x,y)+N(x,y)y' \qquad (6)$$

ឧបមាថា $\psi(x,y)$ មានលក្ខណៈដូចខាងក្រោម៖

$$\frac{\partial \psi}{\partial x}=M(x,y),\quad \frac{\partial \psi}{\partial y}=N(x,y) \qquad (7)$$

ដូចនេះ $\psi(x,y)=c$ គឺជាអនុគមន៍អ៊ីមព្លីស៊ីត ជាចម្លើយសមីការ

$$M(x,y)+N(x,y)y'=\frac{\partial \psi}{\partial x}+\frac{\partial \psi}{\partial y}\bullet\frac{dy}{dx}=\frac{d}{dx}\left[\psi(x,y)\right]=0$$

ហើយសមីការឌីផេរ៉ង់ស្យែល(6)ក្លាយទៅជា $\frac{d}{dx}\left[\psi(x,y)\right]=0\Rightarrow\psi(x,y)=\int dx=c$ (8)

ក្នុងករណីនេះសមីការ (6) ត្រូវបានគេហៅថាជាសមីការឌីផេរ៉ង់ស្យែលប្រាកដ។ ចម្លើយសមីការ (6) ត្រូវបានផ្តល់ឱ្យក្នុងទម្រង់ $\psi(x,y)=c$ , $c\in R$ (9)

ក្នុងឧទាហរណ៍១ ខ្ញុំគិតថាវាមានភាពងាយស្រួលក្នុងការមើលថាសមីការឌីផេរ៉ង់ស្យែលជាសមីការប្រាកដហើយងាយស្រួលនៅក្នុងការដោះស្រាយតាមរយៈ $\psi$ សម្រាប់សមីការស្មុគស្មាញជាងនេះវាមិនអាចដោះស្រាយបានស្រួលនោះទេ។ វិធីជាទូទៅក្នុងការកំណត់ថាសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឱ្យជាសមីការប្រាកដត្រូវបានកំណត់តាមទ្រឹស្តីបទខាងក្រោម។

*ទ្រឹស្តីបទ១.៥.១* ៖គេតាងអនុគមន៍ $M, N, M_y, N_x$ មានដេរីវេទីមួយដោយផ្នែក ហើយជាប់នៅក្នុងដែនចតុកោណកែង $R: \alpha \prec x \prec \beta, \gamma \prec y \prec \delta$ នោះសមីការ $(6)$ មានទម្រង់៖

$$M(x,y)+N(x,y)y' = 0$$

សមីការខាងលើគឺជាសមីការឌីផេរ៉ង់ស្យែលប្រាកដនៅក្នុង $R$ ប្រសិនបើ

$$M_y(x,y)=N_x(x,y) \qquad (10)$$

នៅចំណុចនីមួយនៃ $R$ នោះគឺមានអនុគមន៍ $\psi$ បំពេញសមីការ $(7)$

$$\psi_x(x,y)=M(x,y), \quad \psi_y(x,y)=N(x,y)$$

ប្រសិនបើ $M$ និង $N$ បំពេញសមីការ $(10)$ ។

ទ្រឹស្តីនេះត្រូវបានបង្ហាញជា២ផ្នែក ដំបូងយើងនឹងបង្ហាញថាប្រសិនបើអនុគមន៍ $\psi$ បំពេញសមីការ $(7)$ នោះវាធ្វើតាមសមីការ $(10)$ គណនា $M$ និង $N$ ពីសមីការ $(10)$ បន្ទាប់ $(6)$ ក្លាយជាសមីការប្រាកដ។ ការបង្ហាញពីភាពពាក់ព័ន្ធនៃអនុគមន៍ $\psi$ ត្រូវគ្នាជាមួយសមីការ $(7)$

$$\psi_x(x,y)=M(x,y), \quad \psi_y(x,y)=N(x,y)$$

អាំងតេក្រាលដំបូងនៃសមីការ $(7)$ ទាក់ទងទៅនឹង $x$ និង $y$ ថេរ យើងរកឃើញ

$$\psi(x,y)=\int M(x,y)dx+h(y) \qquad (12)$$

អនុមន៍ $h$ គឺអាស្រ័យទៅលើអនុគមន៍ $y$ ដែលវាមានភាពប្រែប្រួល។ ឥឡូវយើងនឹងបង្ហាញថាវាតែងតែងតែជ្រើសរើសបានជានិច្ចចំពោះ $h(y)$ ដូច្នេះ $\psi_y = N$ មកពីសមីការ $(12)$

$$\psi_y = \frac{\partial}{\partial y}\int M(x,y)dx+h'(y)$$

$$=\int M_y(x,y)dx+h'(y)$$

កំណត់ $\psi_y = N$ និងដោះស្រាយ $h'(y)$ យើងបាន

$$h'(y)=N(x,y)-\int M_y(x,y)dx \qquad (13)$$

ដើម្បីកំណត $h(y)$ ពីសមីការ $(13)$ វាចាំបាច់ណាស់ទោះបីវាមានរាងដោយផ្នែកក៏ដោយក៏វានៅតែជាអនុគមន៍នៃ $y$ គ្រប់ពេល។ ដើម្បីដោះស្រាយយើងអាចបែងចែកបរិមាណនៅក្នុងសំណួរទាក់ទងនឹង $x$ ដោយទទួលបាន

$$N(x,y)-M(x,y)$$

ដែលជាលេខសូន្យនៅក្នុងសមីការ $(10)$ ដូច្នេះទោះបីជាទម្រង់ជាក់ស្តែងរបស់វាក៏ដោយក៏ផ្នែកខាងស្តាំនៃសមីការ $(13)$ មិនអាស្រ័យលើ $x$ ហើយក៏បូកបញ្ចូលគ្នាតែមួយបន្ទាប់មកបាន $h(y)$ ។ ការជំនួស $h(y)$ នៅក្នុងសមីការ $(12)$ យើងទទួលបានដំណោះស្រាយនៃសមីការ $(7)$ គឺ

$$\psi(x,y)=\int M(x,y)dx+\int\left[N(x,y)-\int M_y(x,y)dx\right]dy \qquad (14)$$

ឧទាហរណ៍២៖ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(y\cos x+2xe^{y}\right)+\left(\sin x+x^{2}e^{y}-1\right)y'=0 \quad (15)$

ចម្លើយ

យើងដឹងថា $M\left(x,y\right)=y\cos x+2xe^{y}$ , $N\left(x,y\right)=\sin x+x^{2}e^{y}-1$

នោះ $M_{y}\left(x,y\right)=\dfrac{dM}{dy}=\cos x+2xe^{y}=N_{x}\left(x,y\right)=\dfrac{dN}{dx}$

ដូច្នេះសមីការដែលផ្ដល់គឺជាសមីការប្រាកដ ដូច្នេះមាន $\psi\left(x,y\right)$

$$\psi_{x}\left(x,y\right)=\frac{d\psi}{dx}=y\cos x+2xe^{y}=M\left(x,y\right) \qquad (*)$$

$$\psi_{y}\left(x,y\right)=\frac{d\psi}{dy}=\sin x+x^{2}e^{y}-1=N\left(x,y\right) \qquad (**)$$

គណនាអាំងតេក្រាល $(*)$ យើងបាន

$$\psi\left(x,y\right)=\int\left(y\cos x+2xe^{y}\right)dx=y\sin x+x^{2}e^{y}+h\left(y\right) \qquad (16)$$

យកសមីការ $(16)$ មកដេរីវេធៀបអថេរ $y$ គេបាន៖

$$\psi_{y}=\left(x,y\right)=\sin x+x^{2}e^{y}+h'\left(y\right)=N\left(x,y\right)$$

$$\sin x+x^{2}e^{y}+h'\left(y\right)=\sin x+x^{2}e^{y}-1$$

$$h'\left(y\right)=-1 \qquad \Rightarrow h\left(y\right)=-y$$

ដូច្នេះ ជំនួស $h\left(y\right)=-y$ នៅក្នុងសមីការ $(16)$

$$\psi=\left(x,y\right)=\sin x+x^{2}e^{y}-y$$

ដូច្នេះ អនុគមន៍ចម្លើយរបស់សមីការ $(15)$ គឺ $y\sin x+x^{2}e^{y}-y=c \qquad (17)$

***ប្រតិបត្តិ***

1. $2xy-9x^{2}+\left(2y+x^{2}+1\right)\dfrac{dy}{dx}=0$ $\qquad \left(y^{2}+\left(x^{2}+1\right)y-3x^{3}=c\right)$
2. $2xy^{2}+4=2\left(3-x^{2}y\right)y'$ $\quad y\left(-1\right)=8$ $\qquad \left(x^{2}y^{2}-6y+4x-12=0\right)$
3. $3y^{3}e^{3xy}-1+\left(2ye^{3xy}+3xy^{2}e^{3xy}\right)y'=0$ $\quad y\left(0\right)=1$ $\qquad \left(y^{2}e^{3xy}-x-1=0\right)$

***✵ចំណាំ***

ចំពោះសមីការប្រាកដ យើងគណនាបានយ៉ាងរហ័សតាមវិធីខាងក្រោម៖

$$M(x,y)dx+N(x,y)dy=0$$

$$\int M(x,y)dx+\int N(x,y)dy=c$$

ដែល $N(x,y)$ ធ្វើតែតួណាមិនជាប់អញ្ញាត $x$ និងប្រាសមកវិញ។

ឧទាហរណ៍៣ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(x+y-10\right)dx+\left(x-y-2\right)dy=0$

$$\int\left(x+y-10\right)dx+\int\left(-y-2\right)dy=\int 0$$

$$\frac{x^{2}}{2}+yx-10x-\frac{y^{2}}{2}-2y=c$$

ឧទាហរណ៍៤៖ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(y^2-x^2\right)dx+2xydy=0$

$$\int\left(-x^2\right)dx+\int 2xydy=\int 0$$

$$-\frac{x^3}{3}+xy^2=c$$

## ២.៦ សមីការមិនប្រាកដ និងកត្តាអាំងតេក្រាល

### ២.៦.១ វិធីកត្តាអាំងតេក្រាល

ឧទាហរណ៍១ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(3xy+y^2\right)+\left(x^2+xy\right)y'=0$

$$M_y\left(x,y\right)=3x+2y,\quad N_x\left(x,y\right)=2x+y$$

ដោយ $M_y\neq N_x$ សមីការដែលផ្តល់ឱ្យមិនមែនជាសមីការប្រាកដ។

ពេលខ្លះយើងត្រូវការបំលែងសមីការឌីផេរ៉ង់ស្យែលមិនប្រាកដទៅជាសមីការប្រាកដ ដោយគុណសមីការនឹងកត្តាអាំងតេក្រាល។ សូមចាំថានេះជានីតិវិធីដែលបានប្រើក្នុងការដោះស្រាយសមីការលីនេអ៊ែនៅក្នុងផ្នែក1.1។ ដើម្បីអង្កេតពីលទ្ធផលនៃការអនុវត្តឱ្យទូលំទូលាយយើងនឹងគុណសមីការនឹងកត្តាអាំងតេក្រាល៖

$$M\left(x,y\right)dx+N\left(x,y\right)dy=0 \qquad (1)$$

ជ្រើសរើសអនុគមន៍ $\mu$ មួយដូច្នេះលទ្ធផលនៃសមីការ

$$\mu\left(x,y\right)M\left(x,y\right)dx+\mu\left(x,y\right)N\left(x,y\right)dy=0 \qquad (2)$$

ដោយទ្រឹស្តី 1.5.1 គឺជាសមីការប្រាកដប្រសិនបើ

$$\left(\mu M\right)_y=\left(\mu N\right)_x \qquad (3)$$

$M$ និង $N$ ជាអនុគមន៍ដែលបានផ្តល់ឱ្យដោយសមីការ $(3)$ ដែលហៅថាកត្តាអាំងតេក្រាល បំពេញសមីការដេរីវេដោយផ្នែកលំដាប់ទីមួយ

$$\left(\mu M\right)_y=\left(\mu N\right)_x$$

$$\mu_y M+\mu M_y=\mu_x N+\mu N_x$$

$$M\mu_y-N\mu_x+\left(M_y-N_x\right)\mu=0 \qquad (4)$$

***ករណីទី១***

បើសិនកត្តាអាំងតេក្រាល $\mu(x,y)$ មានតែអថេរមិនអាស្រ័យ $x$ នោះកន្សោម $M\mu_y=0$ សមីការ $(4)$ ក្លាយ

$$-N\mu_x+\left(M_y-N_x\right)\mu=0$$

$$\frac{d\mu}{dx}=\frac{\left(M_y-N_x\right)}{N}\mu$$

$$\frac{d\mu}{\mu}=\frac{\left(M_y-N_x\right)}{N}dx$$

$$\mu\left(x\right)=e^{\int\frac{\left(M_y-N_x\right)}{N}dx} \qquad (5)$$

***ករណីទី២***

បើសិនកត្តាអាំងតេក្រាល $\mu(x,y)$ មានតែអថេរមិនអាស្រ័យ $y$ នោះកន្សោម $M\mu_x=0$ សមីការ $(4)$ ក្លាយ

$$M\mu_y+\left(M_y-N_x\right)\mu=0$$

$$\frac{d\mu}{dy}=-\frac{\left(M_y-N_x\right)}{M}\mu$$

$$\frac{d\mu}{\mu}=\frac{\left(N_x-M_y\right)}{M}dy$$

$$\mu(y)=e^{\int\frac{\left(N_x-M_y\right)}{M}dy} \qquad (6)$$

ឧទាហរណ៍១៖ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(3xy+y^2\right)+\left(x^2+xy\right)y'=0$

ចម្លើយ

$M_y(x,y)=3x+2y, \quad N_x(x,y)=2x+y$

ដោយ $M_y\neq N_x$ សមីការដែលផ្ដល់ឱ្យមិនមែនជាសមីការប្រាកដ។

កត្តាអាំងតេក្រាល $\mu(x)=e^{\int\frac{M_Y-N_X}{N}dx}=e^{\int\frac{x+y}{x^2+xy}dx}=e^{\int\frac{1}{x}dx}=x$ យកគុណសមីការដើម

$\left(3x^2y+xy^2\right)+\left(x^3+x^2y\right)y'=0$

យើងដឹងថា $\quad M(x,y)=3x^2y+xy^2\ , \qquad N(x,y)=x^3+x^2y$

នោះ $\quad M_y(x,y)=\frac{dM}{dy}=3x^2+2xy=N_x(x,y)=\frac{dN}{dx}$

ដូច្នេះសមីការដែលផ្ដល់គឺជាសមីការប្រាកដ ដូច្នេះមាន $\psi(x,y)$

$$\psi_x(x,y)=\frac{d\psi}{dx}=3x^2y+xy^2=M(x,y) \qquad (*)$$

$$\psi_y(x,y)=\frac{d\psi}{dy}=x^3+x^2y=N(x,y) \qquad (**)$$

គណនាអាំងតេក្រាល $(**)$ យើងបាន $\psi(x,y)=\int\left(x^3+x^2y\right)dy=x^3y+\frac{1}{2}x^2y^2+h(x) \qquad (1)$

យកសមីការ $(1)$ មកដេរីវេធៀបអថេរ $x$ គេបាន៖

$$\frac{d\psi}{dx}=3x^2y+xy^2+h'(x)\Leftrightarrow M=3x^2y+xy^2+h'(x)\Leftrightarrow h'(x)=0\Rightarrow h(x)=c_1$$

ដូច្នេះ ជំនួស $h(x)=c_1$ នៅក្នុងសមីការ $(1)$

$$x^3y+\frac{1}{2}x^2y^2=c$$

ដូច្នេះ អនុគមន៍ចម្លើយរបស់សមីការ គឺ $x^3y+\frac{1}{2}x^2y^2=c$ ។

ឧទាហរណ៍២៖ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(x+y^2\right)dx-2xydy=0$

ចម្លើយ

$M_y(x,y)=2y, \quad N_x(x,y)=-2y$

ដោយ $M_y \neq N_x$ សមីការដែលផ្តល់ឱ្យមិនមែនជាសមីការប្រាកដ។

កត្តាអាំងតេក្រាល $\mu(x)=e^{\int\frac{M_Y-N_X}{N}dx}=e^{\int\frac{4y}{-2xy}dx}=e^{\int\frac{-2}{x}dx}=\frac{1}{x^2}$ យកគុណសមីការដើម

$$\left(\frac{1}{x}+\left(\frac{y}{x}\right)^2\right)dx-\frac{2y}{x}dy=0$$

យើងដឹងថា $M(x,y)=\frac{1}{x}+\left(\frac{y}{x}\right)^2 \quad , \qquad N(x,y)=-\frac{2y}{x}$

នោះ $M_y(x,y)=\frac{dM}{dy}=\frac{2y}{x^2}=N_x(x,y)=\frac{dN}{dx}$

ដូច្នេះសមីការដែលផ្តល់គឺជាសមីការប្រាកដ ដូច្នេះមាន $\psi(x,y)$

$$\psi_x(x,y)=\frac{d\psi}{dx}=\frac{1}{x}+\left(\frac{y}{x}\right)^2=M(x,y) \qquad (*)$$

$$\psi_y(x,y)=\frac{d\psi}{dy}=-\frac{2y}{x}=N(x,y) \qquad (**)$$

គណនាអាំងតេក្រាល $(**)$ យើងបាន $\psi(x,y)=\int\frac{-2y}{x}dy=-\frac{y^2}{x}+h(x) \qquad (1)$

យកសមីការ $(1)$ មកដេរីវេធៀបអថេរ $x$ គេបាន៖

$$\frac{d\psi}{dx}=\frac{y^2}{x^2}+h'(x) \Leftrightarrow M=\frac{y^2}{x^2}+h'(x) \Leftrightarrow h'(x)=\frac{1}{x} \Rightarrow h(x)=\ln|x|$$

ដូច្នេះ ជំនួស $h(x)=\ln|x|$ នៅក្នុងសមីការ $(1)$

$$-\frac{y^2}{x}+\ln|x|=c$$

ដូច្នេះ អនុគមន៍ចម្លើយរបស់សមីការ គឺ $-\frac{y^2}{x}+\ln|x|=c$

ប្រតិបត្តិ

1/ $\left(4xy+3y^2-x\right)dx+x(x+y)dy=0 \qquad \left(x^3\left(4xy+4y^2-x\right)=c\right)$

2/ $y(x+y+1)dx+x(x+3y+2)dy=0 \qquad \left(xy^2(x+2y+2)=c\right)$

## លំហាត់

តើលំហាត់ណាខ្លះ ជាសមីការប្រាកដ ?រួចដោះស្រាយសមីការប្រាកដនោះ។

1. $(2x+3)+(2y-2)y'=0$
2. $(2x+4y)+(2x-2y)y'=0$
3. $\left(3x^2-2xy+2\right)dx+\left(6x^2-x^2+3\right)dy=0$
4. $\left(2xy^2+2y\right)+\left(2x^2y+2x\right)y'=0$
5. $\frac{dy}{dx}=-\frac{ax+by}{bx+cy}$

6. $\frac{dy}{dx}=-\frac{ax-by}{bx-cy}$

7. $\left(e^x\sin y-2y\sin x\right)dx+\left(e^x\cos y-2\sin x\right)dy=0$

8. $\left(e^x\sin y+3y\right)dx-\left(3x-e^x\sin y\right)dy=0$

9. $\left(ye^{xy}\cos 2x-2e^{xy}\sin 2x+2x\right)dx+\left(xe^{xy}\cos 2x-3\right)dy=0$

10. $\left(\frac{y}{x}+6x\right)dx+\left(\ln x-2\right)dy=0,\ \ x\succ 0$

11. $\left(x\ln y+xy\right)dx+\left(y\ln x+xy\right)dy=0,\ \ x,y\succ 0$

12. $\frac{xdx}{\left(x^2+y^2\right)^{\frac{3}{2}}}+\frac{ydy}{\left(x^2+y^2\right)^{\frac{3}{2}}}=0$

នៅក្នុងលំហាត់នីមួយៗ 13 និង 14 ដោះស្រាយរកចម្លើយប្រាកដតាមបញ្ចូតម្លៃដើម

13. $\left(2x-y\right)dx+\left(2y-x\right)dy=0,\quad y\left(1\right)=3$

14. $\left(9x^2+y-1\right)dx-\left(4y-x\right)dy=0,\quad y\left(1\right)=0$

នៅក្នុងលំហាត់ទី 15 និង 16 ស្វែងរកតម្លៃ $b$ ដែលសមីការដែលផ្តល់ឱ្យគឺជាសមីការប្រាកដ បន្ទាប់មកដោះស្រាយសមីការដោយប្រើតម្លៃ $b$

15. $\left(xy^2+bx^2y\right)dx+\left(x+y\right)x^2dy=0$

16. $\left(ye^{2xy}+x\right)dx+bxe^{2xy}dy=0$

17. ពិចារណាទៅលើសមីការឌីផេរ៉ង់ស្យែលប្រាកដ $M\left(x,y\right)dx+N\left(x,y\right)dy=0$ ។
រករូបមន្តទម្រង់អ៊ីមព្លីស៊ីត $\psi\left(x,y\right)=c$ សម្រាប់ដំណោះស្រាយរកចម្លើយសមីការ $(14)$ ។ ប៉ុន្តែអាំងតេក្រាលនៃ $\psi_y=N$ បន្ទាប់មក $\psi_x=M$ ដូចនៅក្នុងអត្ថបទ។

18. បង្ហាញថាជាសមីការអាចបំបែកបាន $M\left(x\right)+N\left(y\right)y'=0$ ជាសមីការប្រាកដ។

បង្ហាញថាសមីការទី 19 ដល់ទី 22 គឺជាសមីកាមិនប្រាកដ ហើយក្លាយជាសមីការប្រាកដពេលគុណនឹងកត្តាអាំងតេក្រាល បន្ទាប់មកដោះស្រាយសមីការ។

19. $x^2y^3+x\left(1+y^2\right)y'=0,\quad \mu\left(x,y\right)=\frac{1}{xy^3}$

20. $\left(\frac{\sin y}{y}-2e^{-x}\sin x\right)dx+\left(\frac{\cos y+2e^{-x}\cos x}{y}\right)dy=0,\quad \mu\left(x,y\right)=ye^x$

21. $ydx+\left(2x-ye^x\right)dy=0,\quad \mu\left(x,y\right)=y$

22. $\left(x+2\right)\sin ydx+x\cos ydy=0,\quad \mu\left(x,y\right)=xe^x$

23. បង្ហាញថាប្រសិនបើ $\frac{N_x-M_y}{M}=Q$ នោះ $Q$ គឺជាអនុគមន៍មួយតែប៉ុណ្ណោះនៃ $y$ ហើយវាជាសមីការឌីផេរ៉ង់ស្យែល $M+Ny'=0$ ។

ហើយទម្រង់នៃកត្តាអាំងតេក្រាលគឺ 23. $\mu\left(y\right)=\exp\int Q\left(y\right)dy=e^{\int Q(y)dy}$ ។

24. បង្ហាញថាប្រសិនបើ $\frac{N_x - M_y}{xM - yN} = R$ ដែល $R$ អាស្រ័យលើ $x$ និង $y$ តែប៉ុណ្ណោះ។ ហើយបន្ទាប់មកវាជាសមីការឌីផេរ៉ង់ស្យែល $M + Ny' = 0$ ។

ហើយ $\mu(x,y)$ ជាទម្រង់នៃកត្តាអាំងតេក្រាល។ ស្វែងរកទម្រង់ទូទៅនៃកត្តាអាំងតេក្រាលនេះ។

នៅក្នុងលំហាត់ទី 25 ដល់ 31 រកកត្តាអាំងតេក្រាលដើម្បីដោះស្រាយសមីការដែលបានផ្តល់ឱ្យ។

25. $\left(3x^2y + 2xy + y^3\right)dx + \left(x^2 + y^2\right)dy = 0$

26. $y' = e^{2x} + y - 1$

27. $dx + \left(\frac{x}{y} - \sin y\right)dy = 0$

28. $ydx + \left(2xy + 2y\csc y\right)dy = 0$

29. $e^x dx + \left(e^x \cot y + 2y\csc y\right)dy = 0$

30. $\left[4\left(\frac{x^3}{y^2}\right) + \left(\frac{3}{7}\right)\right]dx + \left[3\left(\frac{x}{y^2}\right) + 4y\right]dy = 0$

31. $\left(3x + \frac{6}{y}\right) + \left(\frac{x^2}{y} + 3\frac{y}{x}\right)\frac{dy}{dx} = 0$

32. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $\left(3xy + y^2\right) + \left(x^2 + xy\right)y' = 0$ ប្រើកត្តាអាំងតេក្រាល $\mu(x,y) = \left[xy(2x+y)\right]^{-1}$ ។ ផ្ទៀងផ្ទាត់ថាដំណោះស្រាយគឺដូចគ្នាទៅនឹងអ្វីដែលទទួលបាននៅក្នុងឧទាហរណ៍ទី4 ជាមួយនឹងកត្តាអាំងតេក្រាលផ្សេងគ្នា។

## ២.៧. សមីការអូម៉ូហ្សែន

### ២.៧.១. អនុគមន៍អូម៉ូហ្សែន

***និយមន័យ៖*** បើអនុគមន៍ $f(x,y)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ $f(tx,ty) = t^n f(x,y)$, $n$ ជាចំនួនពិត នោះ $f(x,y)$ ហៅថាអនុគមន៍អូម៉ូហ្សែនដឺក្រេទី $n$ ។

ឧទាហរណ៍១៖ តើអនុគមន៍ខាងក្រោម ជាអនុគមន៍អូម៉ូហ្សែនឬទេ ?

1. $f(x,y) = x - 3\sqrt{xy} + 5y$

$\Rightarrow f(tx,ty) = tx - 3\sqrt{txty} + 5ty = t\left(x - 3\sqrt{xy} + 5y\right) = tf(x,y)$

ជាអនុគមន៍អូម៉ូហ្សែនដឺក្រេទី1។

2. $f(x,y) = \sqrt{x^3 + y^3}$

$\Rightarrow f(tx,ty) = \sqrt{(tx)^3 + (ty)^3} = t^{\frac{3}{2}}\left(\sqrt{x^3 + y^3}\right) = t^{\frac{3}{2}} f(x,y)$

ជាអនុគមន៍អូម៉ូហ្សែនដឺក្រេទី $\frac{3}{2}$ ។

3. $f(x,y) = x^2 + y^2 - 1$

$\Rightarrow f(tx,ty) = (tx)^2 + (ty)^2 - 1 \neq t^2 f(x,y)$

មិនមែនជាអនុគមន៍អូម៉ូហ្សែនទេ។

ប្រតិបត្តិ

តើអនុគមន៍ខាងក្រោម ជាអនុគមន៍អូម៉ូហ្សែនឬទេ ?

1. $f(x,y)=6xy^3-x^2y^2$

2. $f(x,y)=x^2-y$

## ២.៧.២. សមីការអូម៉ូហ្សែន

បើសមីការ $M(x,y)dx+N(x,y)dy=0$ មានលក្ខណៈខាងក្រោម៖

$M(tx,ty)=t^nM(x,y)$ និង $N(tx,ty)=t^nM(x,y)$ គេហៅថា មេគុណអូម៉ូហ្សែន ឬ ជាសមីការអូម៉ូហ្សែន។

## ២.៧.៣. វិធីសាស្ត្រដោះស្រាយ

បើសមីការ $M(x,y)dx+N(x,y)dy=0$ មានលក្ខណៈ:

$M(x,y)$ និង $N(x,y)$ អនុគមន៍អូម៉ូហ្សែនដឺក្រេដូចគ្នា នោះសមីការ $M(x,y)dx+N(x,y)dy=0$ ជាសមីការអូម៉ូហ្សែនយើងអាចបម្លែងវាទៅជាសមីការញែកអថេរបាន ដោយជំនួស $y=ux$ ឬ $x=vy$ ដែល $u$ និង $v$ ជាអថេរអាស្រ័យថ្មី។ គេបាន

$y=ux \Rightarrow dy=udx+xdu$ យកទៅជំនួសសមីការដើម

$$M(x,ux)dx+N(x,ux)(udx+xdu)=0$$

$$x^nM(1,u)dx+x^nN(1,u)(udx+xdu)=0$$

$$M(1,u)dx+uN(1,u)dx+N(1,u)xdu=0$$

$$[M(1,u)+uN(1,u)]dx+N(1,u)xdu=0$$

$$\frac{dx}{x}+\frac{N(1,u)}{[M(1,u)+uN(1,u)]}du=0$$

$$\int\frac{dx}{x}+\int\frac{N(1,u)}{[M(1,u)+uN(1,u)]}du=\int 0dx$$

ឧទាហរណ៍១៖ ដោះសមីការអូម៉ូហ្សែន $(x^2+y^2)dx+(x^2-xy)dy=0$។

ចម្លើយ

ដោះសមីការអូម៉ូហ្សែន $(x^2+y^2)dx+(x^2-xy)dy=0$

$M(x,y)$ និង $N(x,y)$ អនុគមន៍អូម៉ូហ្សែនដឺក្រេ 2 ដូចគ្នា

តាង $y=ux\Rightarrow u=\dfrac{y}{x}\Rightarrow dy=udx+xdu$ យកទៅជំនួសសមីការដើម

$$\left(x^2+(ux)^2\right)dx+\left(x^2-x^2u\right)(udx+xdu)=0$$

$$\left(1+u^2\right)dx+u(1-u)dx+x(1-u)du=0$$

$$\frac{dx}{x}+\frac{1-u}{1+u}du=0 \qquad \Rightarrow \int\frac{dx}{x}+\int\frac{1-u}{1+u}du=\ln c$$

$$\ln|x|+\int\frac{-(u+1)+2}{u+1}=\ln c$$

$$\ln|x|-u+2\ln|u+1|=\ln c \Rightarrow \ln|x|-\frac{y}{x}+2\ln\left|\frac{y}{x}+1\right|=\ln c$$

$$c(x+y)^2=xe^{\frac{y}{x}} \qquad c\in R$$

ដូចនេះ ចម្លើយសមីការគឺ $c(x+y)^2=xe^{\frac{y}{x}}$ $\qquad c\in R$

**ឧទាហរណ៍២៖** ដោះសមីការអូម៉ូហ្សែន $\left(2\sqrt{xy}-y\right)dx+xdy=0$ ។

ចម្លើយ

ដោះសមីការអូម៉ូហ្សែន $\left(2\sqrt{xy}-y\right)dx+xdy=0$

$M(x,y)$ និង $N(x,y)$ អនុគមន៍អូម៉ូហ្សែនដឺក្រេ $1$ ដូចគ្នា

តាង $\qquad y=ux\Rightarrow u=\frac{y}{x}\Rightarrow dy=udx+xdu \qquad$ យកទៅជំនួសសមីការដើម

$$\left(2\sqrt{x^2u}-ux\right)dx-x\left(udx+xdu\right)=0$$

$$\left(2\sqrt{u}-u\right)dx-udx-xdu=0$$

$$\left(2\sqrt{u}-2u\right)dx-xdu=0$$

$$\frac{dx}{x}+\frac{du}{2u+2\sqrt{u}}=0$$

$$\int\frac{dx}{x}+\int\frac{du}{2u+2\sqrt{u}}=c$$

$$\sqrt{xy}-x=c$$

**ឧទាហរណ៍៣៖** ដោះស្រាយសមីការអូម៉ូហ្សែន $\quad 2x^3ydx+\left(x^4+y^4\right)dy=0$ ។

ចម្លើយ

ដោះសមីការអូម៉ូហ្សែន $2x^3ydx+\left(x^4+y^4\right)dy=0$

$M(x,y)$ និង $N(x,y)$ អនុគមន៍អូម៉ូហ្សែនដឺក្រេ $4$ ដូចគ្នា

តាង $x=vy\Rightarrow v=\frac{x}{y}\Rightarrow dx=vdy+ydv$ យកទៅជំនួសសមីការដើម

$$2v^3y^4\left(vdy+ydv\right)+\left(v^4y^4+y^4\right)dy=0$$

$$2v^3ydv+(3v^4+1)dy=0$$

$$\Rightarrow\frac{2v^3dv}{3v^4+2}+\frac{dy}{y}=0$$

$$\Rightarrow\int\frac{2v^3dv}{3v^4+2}+\int\frac{dy}{y}=c \qquad \Leftrightarrow 6\ln\left|3v^4+2\right|+\ln|y|=\ln c_1$$

$\Leftrightarrow 3x^4y^2+y^6=c$ ជាអនុគមន៍ចម្លើយទូទៅរបស់សមីការ។

## ២.៨. ការជំនួស

ក្នុងការជនួស ជំហានដំបូងយើងត្រូវពិនិត្យសមីការឌីផេរ៉ង់ស្យែលលំដាប់ទីមួយមានទម្រង់៖

$$y' = F\left(\frac{y}{x}\right)$$

តាង $u = \frac{y}{x} \Leftrightarrow y = ux$ ហើយអនុគមន៍ $u$ និង $y$ មានអថេរអាស្រ័យ $x$ ។ ធ្វើដេរីវេអនុគមន៍អ៊ីមព្លីស៊ីត $y' = u + xu'$ ជំនួសសមីការខាងលើគេបាន៖

$u + xu' = F(u) \Leftrightarrow F(u) - u = xu' \quad \Leftrightarrow F(u) - u = x\frac{du}{dx}$

$\frac{du}{F(u) - u} = \frac{dx}{x}$

យើងគណនាគណនាបានព្រោះវាក្លាយជាសមីការ ញែកអថេរបាន។

**ឧទាហរណ៍១៖** ដោះស្រាយសមីការ $x\frac{dy}{dx} = y + xe^{\frac{y}{x}}$ , $\quad y(1) = 1$ ។

ចម្លើយ

$x\frac{dy}{dx} = y + xe^{\frac{y}{x}} \Rightarrow \frac{dy}{dx} = \frac{y}{x} + e^{\frac{y}{x}}$ តាង $u = \frac{y}{x} \quad \Leftrightarrow y = ux \Rightarrow \frac{dy}{dx} = u + x\frac{du}{dx}$ យើងបាន

$u + x\frac{du}{dx} = u + e^{u} \quad \Leftrightarrow \frac{du}{e^{u}} = \frac{dx}{x} \quad \Leftrightarrow -e^{-u} = \ln|x| + c \quad \Leftrightarrow -e^{-\frac{y}{x}} - \ln|x| = c$

តាមលក្ខខណ្ឌដើម $-e^{-\frac{1}{1}} = c \Rightarrow c = \frac{1}{e}$

ដូចនេះ អនុគមន៍ចម្លើយប្រាកដមួយរបស់សមីការគឺ $-e^{-\frac{y}{x}} = \ln|x| + \frac{1}{e}$

**ឧទាហរណ៍២៖** ដោះស្រាយសមីការ $xy' = y(\ln x - \ln y), \quad y(1) = 4, \quad x > 0$ ។

ចម្លើយ

$xy' = y(\ln x - \ln y)$

$y' = \frac{y}{x}\ln\left(\frac{x}{y}\right)$

$y' = -\frac{y}{x}\ln\left(\frac{y}{x}\right)$

តាង $u = \frac{y}{x} \Rightarrow y = ux \Rightarrow dy = u + x\frac{du}{dx}$ យកជំនួសសមីការ គេបាន

$u + x\frac{du}{dx} = -u\ln u \Rightarrow x\frac{du}{dx} = -u - u\ln u \Rightarrow \frac{dx}{x} = \frac{du}{-u(1+\ln u)} \Rightarrow \int\frac{dx}{x} = \int\frac{du}{-u(1+\ln u)}$

$\int\frac{dx}{x} = \int\frac{du}{u\left(\ln(\frac{1}{u}) - 1\right)}$ តាង $v = \ln\left(\frac{1}{u}\right) - 1$ យើងបាន

$$\ln x + c = -\ln\left(\ln\left(\frac{1}{u}\right) - 1\right) \Rightarrow c - \ln x = \ln\left(\ln\left(\frac{1}{u}\right) - 1\right)$$

$$\ln\left(\frac{1}{u}\right) - 1 = e^{c - \ln x} \Rightarrow \ln\left(\frac{1}{u}\right) - 1 = \frac{e^{c}}{e^{\ln x}}$$

$$\ln\left(\frac{1}{u}\right) - 1 = \frac{c}{x} \Leftrightarrow \ln\left(\frac{1}{u}\right) = \frac{c}{x} + 1$$

$$\frac{1}{u} = e^{\frac{c}{x} + 1} \Leftrightarrow u = e^{-\frac{c}{x} - 1}$$

តែតម្លៃ $u = \frac{y}{x}$ នោះទាញបាន

$$\frac{y}{x} = e^{-\frac{c}{x} - 1} \qquad \Leftrightarrow y = xe^{-\frac{c}{x} - 1} \quad c \in R$$

តាមលក្ខខ័ណ្ឌដើមយើងរកបាន $c = -(1 + \ln 4)$ នោះចម្លើយពិសេស

$$y = xe^{\frac{1 + \ln 4}{x} - 1}$$




## ២.៨. វិធីពីកាត( Picard′s Method )

ក្នុងការរកចម្លើយសមីការឌីផេរ៉ង់ស្យែ $y' = f(x, y)$ (1)
មានលក្ខខណ្ឌដើម $y(x_0) = y_0$ ដោយធ្វើអាំងតេក្រាលអង្គសងខាងធៀបអថេរ $x$ គេបាន៖

$$y(x) = \int_{x_0}^{x} f(t, y(t))\,dt + c$$ លក្ខខណ្ឌដើម $y(x_0) = y_0$ យើហបាន៖

$$y(x_0) = c + \int_{x_0}^{x_0} f(t, y(t))\,dt \Leftrightarrow c = y(x_0) = y_0$$

ដូចនេះ $y(x) = y_0 + \int_{x_0}^{x} f(t, y(t))\,dt$ (2)

យើងធ្វើការដោះស្រាយសមីការ $(2)$ តាមវិធីប៉ាន់ស្មានបន្តបន្ទាប់។

ឧបមាថា $y_0(x)$ ជាអនុគមន៍ជាប់ទូទៅណាមួយ ដែលតាងឲ្យចំនួនប៉ាន់ស្មានណាមួយនៃសមីការ$(2)$ហើយ $f(x, y(x_0))$ ជាអុគមន៍ដោយស្គាល់ អាស្រ័យជាមួយអថេរ $x$ ហើយអនុគមន៍នេះត្រូវបានគណនាបានតាមអាំងតេក្រាល។ ជាមួយ $y(t)$ គេជំនួសដោយ $y_0(t)$អង្គខាងស្តាំនៃសមីការ $(2)$

$y_1(x)=y_0+\int_{x_0}^{x} f(t,y_0(t))dt$ ដោយធ្វើបន្តបន្ទាប់ យើងបាន៖

$$y_2(x)=y_0+\int_{x_0}^{x} f(t,y_1(t))dt$$

$$y_3(x)=y_0+\int_{x_0}^{x} f(t,y_2(t))dt$$

..............................................

$$y_n(x)=y_0+\int_{x_0}^{x} f(t,y_{n-1}(t))dt \qquad n=1,2,3,4,5.....................(3)$$

ទម្រង់ $(3)$ ហៅថា វិធីពីកាតនៃអ៊ីតេរ៉ាស្យុង $(Picard's\ Method\ of\ Iteration)$

ឧទាហរណ៍១៖ដោះស្រាយសមីការ $y'=y-1 \qquad y(0)=2$

ចម្លើយ

យើងមាន $x_0=0 \qquad y_0=2 \qquad f(t,y_{n-1}(t))=y_{n-1}(t)-1$ នោះសមីការ $(3)$ គឺ

$$y_n(t)=2+\int_0^x (y_{n-1}(t)-1)dt \qquad n=1,2,3....$$

ធ្វើការអាំងតេក្រាលបន្តបន្ទាប់

$$y_1(t)=2+\int_0^x (y_0(t)-1)dt \quad \Leftrightarrow y_1(t)=2+\int_0^x (2-1)dt=2+x$$

$$y_2(t)=2+\int_0^x (y_1(t)-1)dt \quad \Leftrightarrow y_2(t)=2+\int_0^x (2+t-1)dt=2+x+\frac{x^2}{2}$$

$$y_3(t)=2+\int_0^x (y_2(t)-1)dt \quad \Leftrightarrow y_3(t)=2+\int_0^x \left(2+t+\frac{t^2}{2}-1\right)dt=2+x+\frac{x^2}{2}+\frac{x^3}{2.3}$$

$$y_4(t)=2+\int_0^x (y_3(t)-1)dt \quad \Leftrightarrow y_3(t)=2+\int_0^x \left(2+t+\frac{t^2}{2}+\frac{x^3}{2.3}-1\right)dt=2+x+\frac{x^2}{2}+\frac{x^3}{2.3}+\frac{x^4}{2.3.4}$$

..........................................................................................................................................

..........................................................................................................................................

$$y_n(t)=2+x+\frac{x^2}{2!}+\frac{x^3}{2.3}+\frac{x^4}{2.3.4}+....+\frac{x^n}{n!}=1+\sum_{k=0}^{n}\frac{x^k}{k!}$$

បើ $n\to+\infty$ នោះយើងបាន $y(t)=1+e^x$ ពីព្រោះ $e^x=\sum_{k=0}^{n}\frac{x^n}{n!}$

ដូចនេះ ចម្លើយសមីការគឺ $y(t)=1+e^x$



លំហាត់

ក្នុងបញ្ហានីមួយៗ 1 ដល់ 32 បង្ហាញសមីការឌីផេរ៉ង់ស្យែលដែលផ្តល់ឱ្យ។ ប្រសិនបើមានលក្ខខណ្ឌដំបូង ចូររកដំណោះស្រាយដែលបំពេញឱ្យវា។

$\frac{dy}{dx}=\frac{x^3-2y}{x}$

2. $(x+y)dx-(x-y)dy=0$

$\frac{dy}{dx}=\frac{2x+y}{3+3y^2-x}, \quad y(0)=0$

4. $(x+e^y)dy-dx=0$

5. $\frac{dy}{dx}=-\frac{2xy+y^2+1}{x^2+2xy}$

6. $x\frac{dy}{dx}+xy=1-y, \quad y(1)=0$

7. $\frac{dy}{dx}=\frac{x}{x^2y+y^3} \quad Hin:Let u=x^2$

8. $x\frac{dy}{dx}+2y=\frac{\sin x}{x}, \quad y(2)=1$

9. $\frac{dy}{dx}=-\frac{2xy+1}{x^2+2y}$

10. $(3y^2+2xy)dx-(2xy+x^2)dy=0$

11. $(x^2+y)dx+(x+e^y)dy=0$

12. $\frac{dy}{dx}+y=\frac{1}{1+e^x}$

13. $xdy-ydx=(xy)^{1/2}dx$

14. $(x+y)dx+(x+2y)dy=0, \quad y(2)=3$

15. $(e^x+1)\frac{dy}{dx}=y-ye^x$

16. $\frac{dy}{dx}=\frac{x^2+y^2}{x^2}$

17. $\frac{dy}{dx}=e^{2x}+3y$

18. $(2y+3x)dx=-xdy$

19. $xdy-ydx=2x^2y^2dy, \quad y(1)=-2$

20. $y'=e^{x+y}$

21. $xy'=y+xe^{y/x}$

22. $\frac{dy}{dx}=\frac{x^2-1}{y^2+1}, \quad y(-1)=1$

23. $xy'+y-y^2e^{2x}=0$

24. $2\sin y\cos xdx+\cos y\sin xdy=0$

25. $\left(2\frac{x}{y}-\frac{y}{x^2+y^2}\right)dx+\left(\frac{x}{x^2+y^2}-\frac{x^2}{y^2}\right)dy=0$

26. $(2y+1)dx+\left(\frac{x^2-y}{x}\right)dy=0$

27. $(\cos 2y-\sin x)dx-2\tan x\sin 2ydy=0$

28. $\frac{dy}{dx}=\frac{3x^2-2y-y^3}{2x+3xy^2}$

29. $\frac{dy}{dx}=\frac{2y+\sqrt{x^2-y^2}}{2x}$

30. $\frac{dy}{dx}=\frac{y^3}{1-2xy^2}, \quad y(0)=1$

31. $(x^2y+xy-y)dx+(x^2y-2x^2)dy=0$

32. $\frac{dy}{dx}=-\frac{3x^2y+y^2}{2x^3+3xy}, \quad y(1)=-2$ ។

33. រកចំណូលប្រចាំឆ្នាំនៃគណនីធនាគារមួយដែលបង់ការប្រាក់ក្នុងអត្រា 7% ជារៀងរាល់ថ្ងៃដែលសមមាត្រនៃភាពខុសគ្នារវាងប្រាក់បង់ចុងក្រោយនិងប្រាក់ដំបូងត្រូវបានបែងចែកដោយប្រាក់ដំបូង។

34. វិនិយោគិនម្នាក់បានដាក់ប្រាក់ $1000 នៅក្នុងគណនីបង់ការប្រាក់ក្នុងអត្រា 8% ជារៀងរាល់ខែនិងដាក់ប្រាក់បន្ថែម $25 ក្នុងមួយខែ។ រកប្រាក់នៅក្នុងគណនីបន្ទាប់ពីដាក់បាន 3ឆ្នាំ។

35. និស្សិតមហាវិទ្យាល័យបានខ្ចីប្រាក់ $8000 ដើម្បីទិញឡានមួយ។ អ្នកណែនាំគិតការប្រាក់តាមអត្រាប្រចាំឆ្នាំ 10%។ តើអត្រាការបង់ប្រាក់ប្រចាំខែប៉ុន្មានដែលត្រូវបង់ក្នុងរយៈពេល 3ឆ្នាំ? ប្រៀបធៀបលទ្ធផលរបស់អ្នកនឹងបញ្ហា 9 ក្នុងផ្នែក 2.3។

36. អ្នកទិញផ្ទះម្នាក់ចង់បង់រំលស់ $100,000 ក្នុងរយៈពេល 30 ឆ្នាំ។ តើត្រូវបង់ប្រាក់ប្រចាំខែប៉ុន្មានបើអត្រាការប្រាក់គឺ (a)9%, (b)10%, (c)12%?

37. អ្នកទិញផ្ទះម្នាក់ចង់បង់រំលស់ $100,000 ដែលមានអត្រាការប្រាក់ 9%។ តើត្រូវបង់ប្រាក់ប្រចាំខែប៉ុន្មានដើម្បីសងប្រាក់កម្ចីក្នុងរយៈពេល30ឆ្នាំ? 20ឆ្នាំ? តើប្រាក់សរុបដែលត្រូវបង់មានចំនួនប៉ុន្មាននៃប្រាក់កម្ចីក្នុងករណីនីមួយៗ។

38. ប្រសិនបើអត្រាការប្រាក់លើការបញ្ចាំរយៈពេល 20ឆ្នាំគឺ 10% និងការទូទាត់ប្រាក់ $1000 ប្រចាំខែដែលអ្នកទិញអាចមានលទ្ធភាពទិញបាន តើប្រាក់បង់រំលស់អតិបរមាចំនួនប៉ុន្មានដែលត្រូវបង់បង់ក្រោមលក្ខខណ្ឌទាំងនេះ?

39. អ្នកទិញផ្ទះម្នាក់ចង់បានតម្លៃនៃការទិញដោយបានបញ្ចាំ $95,000 ក្នុងរយៈពេល 20ឆ្នាំ។ តើអត្រាការប្រាក់អតិបរមាចំនួនប៉ុន្មានដែលអ្នកទិញអាចមានលទ្ធភាពទិញបាន បើប្រាក់ដែលត្រូវបង់ប្រចាំខែមិនលើសពី $900?

# ជំពូកទី៣ សមីការលីនេអ៊ែលំដាប់ពីរ

សមីការលីនេអ៊ែលំដាប់២គឺមានសារៈសំខាន់យ៉ាងសំខាន់ក្នុងការសិក្សាអំពីសមីការឌីផេរ៉ង់ស្យែល សម្រាប់ហេតុផលសំខាន់ពីរ។ ទីមួយគឺថាសមីការលីនេអ៊ែរមានទ្រឹស្តីសម្បូរបែបរចនាសម្ព័ន្ធដែលផ្អែកលើវិធីសាស្ត្រជាប្រព័ន្ធមួយចំនួននៃដំណោះស្រាយ។ លើសពីនេះខ្លឹមសារមួយផ្នែកសំខាន់នៃទម្រង់នេះ និងវិធីសាស្ត្រទាំងនេះគឺអាចយល់បាននៅគណិតវិទ្យាកម្រិតដំបូង។ ដើម្បីបង្ហាញគំនិតសំខាន់ៗក្នុងបរិបទសាមញ្ញបំផុតដែលអាចធ្វើទៅបាន។ យើងពិពណ៌នាពួកវានៅក្នុងជំពូកនេះសម្រាប់សមីការលំដាប់ទីពីរ។ហេតុផលមួយទៀតដើម្បីសិក្សាសមីការលីនេអ៊ែរលំដាប់ទីពីរគឺវាមានសារៈសំខាន់ម្រាប់ការស្រាវជ្រាវណាមួយដែលពិបាកនៃតំបន់បុរាណនៃរូបវិទ្យាគណិតវិទ្យា។មនុស្សម្នាក់មិនអាចទៅឆ្ងាយទេក្នុងការអភិវឌ្ឍន៍ មេកានិចរាវ ចរន្តកំដៅ ចលនារលក ឬបាតុភូតអេឡិចត្រូម៉ាញ៉េទិចដោយគ្មានការស្វែងរកវាចាំបាច់ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទីពីរ។ជាឧទាហរណ៍យើងពិភាក្សាអំពីលំយោលនៃប្រព័ន្ធមេកានិចនិងអគ្គិសនីជាមូលដ្ឋានមួយចំនួននៅចុងបញ្ចប់នៃជំពូក។

## ៣.១ សមីការអូម៉ូហ្សែនជាមួយមេគុណថេរ

សមីការឌីផេរ៉ង់ស្យែលលំដាប់ពីរមានលក្ខណៈដូចខាងក្រោម៖

$$\frac{d^2y}{dt^2} = f\left(t, y, \frac{dy}{dt}\right) \qquad (1)$$

ដែល $f$ ជាអនុគមន៍ជាធម្មតាយើងកំណត់អថេរមិនអាស្រ័យដោយ $t$ ចាប់ពីពេលដែលអថេរមិនអាស្រ័យមានបញ្ហាក្នុងការដោះស្រាយ។ប៉ុន្តែពេលខ្លះយើងប្រើ $x$ ជំនួសវិញ។យើងប្រើ $y$ រឺអថេរដទៃទៀត ដើម្បីជំកំណត់អថេរអាស្រ័យ។សមីការ (1) ត្រូវបានគេហៅថាជាសមីការលីនេអ៊ែប្រសិនបើអនុគមន៍ $f$ មានទម្រង់៖

$$f\left(t, y, \frac{dy}{dt}\right) = g(t) - p(t)\left(\frac{dy}{dt}\right) - q(t)y, \qquad (2)$$

នោះប្រសិនបើ $f$ ជាអនុគមន៍លីនេអ៊ែរនៅក្នុង $y$ និង $y'$ ។សមីការ(2) $g$ , $p$ និង $q$ ជាអនុគមន៍ជាក់លាក់នៃអថេរមិនអាស្រ័យ $(t)$ ប៉ុន្តែមិនអាស្រ័យលើ $y$ ក្នុងករណីនេះយើងសរសេរសមីការ(1)៖

$$y'' + p(t)y' + q(t)y = g(t) \qquad (3)$$

ដែលបឋមបង្ហាញពីភាពខុសគ្នាទាក់ទងនិង $(t)$ ជំនួសក្នុងសមីការ (3) ហើយបាន៖

$$P(t)y'' + Q(t)y' + R(t)y = G(t) \qquad (4)$$

ករណីប្រសិនបើ $P(t) \neq 0$ យើងអាចចែកសមីការ (4) ដោយ $P(t)$ ដោយហេតុនេះយើងទទួលបានសមីការ ៖

$$p(t) = \frac{Q(t)}{P(t)}, \quad q(t) = \frac{R(t)}{P(t)}, \quad g(t) = \frac{G(t)}{P(t)} \qquad (5)$$

ក្នុងការពិភាក្សាសមីការ(3) ហើយនិងដំណោះស្រាយ យើងនិងដាក់វានៅក្នុង $g$ , $p$ និង $q$ ជាអនុគមន៍បន្តបន្ទាប់។

បញ្ហាតម្លៃដើមនៃសមីការឌីផេរ៉ង់ស្យែលដូចជាសមីការ (1) (3) ឬ(4)រួមជាមួយលក្ខខណ្ឌដូចជា៖

$$y(t_0)=y_0 \qquad y'(t_0)=y_0' \qquad (6)$$

សមីការលីនេអ៊ែលំដាប់២ជាសមីការអូម៉ូហ្សែនប្រសិនបើក្រុម $g(t)$ នៅសមីការ(3)ឬក្រុម $G(t)$ នៅសមីការ (4)គឺស្មើរសូន្យទាំងអស់នៃ $t$ ។បើមិនដូចច្នេះទេវាមិនមែនជាសមីការអូម៉ូហ្សែនទេ។ដូចហេតុនេះចឹង ក្រុម $g(t)$ ឬ $G(t)$ ពេលខ្លះវាជាក្រុមមិនអូម៉ូហ្សែនទេ។យើងចាប់ផ្តើមពិភាក្សាពីសមីការអូម៉ូហ្សែន ដែលយើងនិងសរសេរក្រោមទម្រង់៖

$$P(t)y''+Q(t)y'+R(t)y=0 \qquad (7)$$

### ៣.១.១ និយមន័យ

នៅជំពូកនេះយើងនឹងផ្តោតលើសមីការនៅក្នុងអនុគមន៍ $P,Q$ និង $R$ ។ក្នុងសមីការ(7)បានក្លាយជា៖

$$ay''+by'+cy=0 \qquad (8)$$

ពេល $a,b$ និង $c$ ជាចំនួនថេរ។វាជាសមីការអូម៉ូហ្សែនជាមួយមេគុណថេរ (8)តែងតែត្រូវបានដោះស្រាយយ៉ាងងាយស្រួលក្នុងលក្ខខណ្ឌនៃរបៀបនៃការគណនា។វាកាន់តែពិបាកក្នុងការដោះស្រាយសមីការ(7)ប្រសិនបើមេគុណមិនមែនជាចំនួនថេរ ហើយការទទួលបាននៃករណីនេះ ត្រូវបានពន្យាក្នុងការដោះស្រាយរហូតដល់ជំពូកបន្ត។

បន្ទាប់ពីវែកញែកសមីការ(8)ចូលយើងទទួលបទពិសោធន៍ខ្លះៗជាមុនសិនតាមរយៈ

ឧទាហរណ៍១៖ ពិនិត្យសមីការ៖

$$y''-y=0 \qquad (9)$$

ដោយ $a=1,b=0$ និង $c=-1$ នៅសមីការ(9) យើងអាចនិយាយបានថាអនុគមន៍មួយមានលក្ខណៈជាអនុគមន៍ដេរីវេទី២ ដែលជាអនុវត្តន៍ចំពោះខ្លួនឯង។គំនិតតូចមួយប្រហែលជា អនុគមន៍ដែលគេស្គាល់ពីការដោះស្រាយគឺ $y_1(t)=e^t$ ជាអនុគមន៍អិចស្ប៉ូណង់ស្យែល។ការគិតបន្តិចបន្តួចក៏អាចបង្កើតបានអនុគមន៍ទី២ គឺ $y_2(t)=e^{-t}$ ។ពេលខ្លះការស្រាវជ្រាវបន្ថែមទៀតបង្ហាញថាមេគុណថេរនៃដំណោះស្រាយទាំងនេះ។ ឧទាហរណ៍អនុគមន៍ $2e^t$ និង $5e^{-t}$ ជាជំនួសសមីការ(9)អាចឲ្យអ្នកផ្ទៀងផ្ទាត់បានដោយការគណនាដេរីវេទី២។ដូចគ្នានេះដែរអនុគមន៍ $c_1y_1(1)=c_1e^t$ និង $c_2y_2(t)=c_2e^{-t}$ ជាចម្លើយសមីការឌីផេរ៉ង់ស្យែល(9)សម្រាប់គ្រប់តម្លៃថេរទាំងអស់ $c_1,c_2$ ។ជាងនេះទៅទៀតវាមានសារៈសំខាន់ក្នុងការកត់សំគាល់ផលបូកនៃដំណោះស្រាយសមីការ(9)។ពេលដែល $c_1y_1(t)$ និង $c_2y_2(t)$ ដំណោះស្រាយសមីការ (9)ដូចនេះមានអនុគមន៍៖

$$y=c_1y_1(t)+c_2y_2(t)=c_1e^t+c_2e^{-t} \qquad (10)$$

សម្រាប់តម្លៃ $c_1,c_2$ អាចធ្វើការគណនាដោយដេរីវេទី $y''$ ដោយសមីការ(10)។យើងមាន $y'=c_1e^t-c_2e^{-t}$ និង $y''=c_1e^t+c_2e^{-t}$ នោះ $y''$ គឺដូច $y$ ចំពោះសមីការ(9)ត្រូវបានបកស្រាយ។

សរុបមក ចូរសង្ខេបនូវអ្វីដែលយើងបានធ្វើកន្លងមកក្នុងឧទាហរណ៍នេះ។យើងកត់សំគាល់ពីអនុគមន៍ $y_1(t)=e^t$ និង $y_2(t)=e^{-t}$ ដំណោះស្រាយនៅសមីការ(9)។វាជាទូទៅជាបន្សំលីនេអ៊ែ(10)

ហើយអនុគមន៍ទាំងនេះក៏ជាដំណោះស្រាយផងដែរ។ពេលដែល មេគុណ $c_1, c_2$ ក្នុងសមីការ(10) ទាំងនេះជាគ្រួសារអនុគមន៍ជាច្រើន សមីការ(9)។

ឥឡូវនេះយើងអាចគិតពីការជ្រើសរើសដំណោះស្រាយជាក់លាក់ក្នុងការយកមកដោះស្រាយដែលបំពេញតាមលក្ខខណ្ឌ។ឧបមាថាចង់ដោះស្រាយសមីការ(9) ដែលបំពេញលក្ខខណ្ឌដំបូង៖

$$y(0)=2 \qquad y'(0)=-1 \qquad (11)$$

ពាក្យផ្សេងទៀតយើងស្វែងរកដំណោះស្រាយកាត់តាមចំណុច $(0,2)$ ដែលមានមេគុណប្រាប់ទិស $-1$ ។ដំបូងយើងអោយ $t=0$ ហើយ $y=2$ ក្នុងសមីការ(10) គេបាន៖

$$c_1 + c_2 = 2 \qquad (12)$$

តាមសមីការឌីផេរ៉ង់ស្យែល(10)នោះ៖

$$y' = c_1 e^t - c_2 e^{-t}$$

ដោយអោយ $t=0$ និង $y'=-1$ យើងបាន៖

$$c_1 - c_2 = -1 \qquad (13)$$

ដោយការដោះស្រាយសមីការ (12)និង(13)ក្នុងពេលរៀងគ្នា ចំពោះ $c_1$ និង $c_2$នោះ៖

$$c_1 = \frac{1}{2}, \qquad c_2 = \frac{3}{2} \qquad (14)$$

ជំនួសក្នុងសមីការ(10)៖

$$y = \frac{1}{2}e^t + \frac{3}{2}e^{-t} \qquad (15)$$

នៅក្នុងដំណោះស្រាយនេះយើងសិក្សាពីបញ្ហាសមីការឌីផេរ៉ង់ស្យែល(9)ដោយនិងលក្ខខណ្ឌដំបូង(11)

### ៣.១.២ វិធីសាស្ត្រដោះស្រាយ

ឥឡូវនេះយើងមានសមីការទូទៅ(8)៖

$$ay'' + by' + cy = 0$$

ដែលមានគុណថេរ។ផ្អែកលើការស្រាវជ្រាវកន្លងមកជាមួយសមីការ (9) អាចឱ្យយើងរកដំណោះស្រាយសមីការ(8)។នោះយើងសន្មតថា $y=e^{rt}$ ពេល $r$ ជាប៉ារ៉ាម៉ែត្របង្កើតបានជាចំនួនកំណត់។ បន្ទាប់មកធ្វើតាម $y' = re^{rt}$ និង $y'' = r^2 e^{rt}$ ដោយជំនួសសមីការទាំងនេះដោយ $y, y'$ និង $y''$ ក្នុងសមីការ (8) យើងបាន៖

$$(ar^2 + br + c)e^{rt} = 0 \text{ ដែល } e^{rt} \neq 0$$

$$ar^2 + br + c = 0 \qquad (16)$$

សមីការ(16)ហៅថា**សមីការសម្គាល់** របស់សមីការឌីផេរ៉ង់ស្យែល(8)។ហើយវាចំបាច់ប្រសិនបើ $r$ ជាឫសនៃសមីការ (16)។ពេលសមីការ(16) ជាមួយមេគុណជាចំនួនពិត ដែលមានឫសពីរ ដែលអាចជាផ្នែកពិត ឬជាឫសឌុប ឬក៏ជាចំនួនកុំផ្លិចឆ្លាស់។យើងពិចារណាករណី ទីមួយនៅទីនេះ និងករណីទី ២ នៅក្នុងផ្នែក ២.៤ និង ២.៥។

សន្មត់ថាឫសនៃសមីការ(16)ជាផ្នែកពិតតាងដោយ $r_1$ និង $r_2$ ដែល $r_1 \neq r_2$ ។នោះ $y_1(t) = e^{r_1 t}$ និង $y_2(t) = e^{r_2 t}$ ដែលមានដំណោះស្រាយពីរ(8)។យើងបាន៖

$$y = c_1 y_1(t) + c_2 y_2(t) = c_1 e^{r_1 t} + c_2 e^{r_2 t} \qquad (17)$$

ដំណោះស្រាយសមីការ(8)ត្រូវបានដោះស្រាយ ដូច្នេះយើងអាចសរសេរសមីការឌីផេរ៉ង់ស្យែល(17)នោះ៖

$$y' = c_1 r_1 e^{r_1 t} + c_2 r_2 e^{r_2 t} \qquad (18)$$

$$y'' = c_1 r_1^2 e^{r_1 t} + c_2 r_2^2 e^{r_2 t} \qquad (19)$$

ជំនួស $y, y'$ និង $y''$ ក្នុងសមីការ(8)យើងទទួលបាន៖

$$ay'' + by' + cy = c_1\left(ar_1^2 + br_1 + c\right)e^{r_1 t} + c_2\left(ar_2^2 + br_2 + c\right)e^{r_2 t} \qquad (20)$$

កន្សោមដែលនៅក្នុងវង់ក្រចកនៃសមីការ(20)ស្មើ 0 ព្រោះ $r_1$ និង $r_2$ ជាឫសនៃសមីការ(16)នោះ $y$ ត្រូវបានផ្តល់ដោយសមីការ(17)ជាដំណោះស្រាយមួយនៃសមីការ(8)ដូចដែលយើងបានផ្ទៀងផ្ទាត់។

ឥឡូវនេះឧបមាថាយើងចង់រកចម្លើយមួយនៃគ្រួសារចម្លើយសមីការ(17)ដែលបំពេញលក្ខខណ្ឌដំបូង(6)គឺ៖

$$y(t_0) = y_0, \qquad y'(t_0) = y'_0$$

ដោយជំនួស $t = t_0$ និង $y' = y'_0$ នៅសមីការ(17);យើងបាន៖

$$c_1 e^{r_1 t_0} + c_2 e^{r_2 t_0} = y_0 \qquad (21)$$

ដូចគ្នាដែលជំនួស $t = t_0$ និង $y' = y'_0$ នៅសមីការ(18);យើងបាន៖

$$c_1 r_1 e^{r_1 t_0} + c_2 r_2 e^{r_2 t_0} = y'_0 \qquad (22)$$

លើដំណោះស្រាយសមីការ(21)និង (22)ដែលមានចំនួនថេររៀងគ្នា $c_1$ និង $c_2$ យើងឃើញថា៖

$$c_1 = \frac{y'_0 - y_0 r_2}{r_1 - r_2} e^{-r_1 t_0}, \qquad c_2 = \frac{y_0 r_1 - y'_0}{r_1 - r_2} e^{-r_2 t_0}, \qquad (23)$$

ដូច្នេះមិនថាលក្ខខណ្ឌដំបូងត្រូវបានកំណត់បែបណាទេ នោះគឺមិនគិតពីតម្លៃនៃ $t_0, y_0,$ និង $y'_0$ សមីការ(6) វាជាចំនួនកំណត់ $c_1$ និង $c_2$ ដោយសមីការ(23) បង្ហាញសមីការ(17)នេះជាដំណោះស្រាយនៃបញ្ហាតម្លៃដើម

$$ay'' + by' + cy = 0\ , \qquad y(t_0) = y_0, \qquad y'(t_0) = y'_0 \qquad (24)$$

វាអាចដោះស្រាយបានដើម្បីបង្ហាញទ្រឹស្តីបទមូលដ្ឋានដែលបានលើកឡើងនៅផ្នែកបន្ទាប់នៃដំណោះស្រាយទាំងអស់ទាំងអស់សមីការ(8) ត្រូវបានបង្ហាញសមីការ(17) យ៉ាងហោចណាស់ករណីដែល ឫសនៃសមីការ(16)ជាចំនួនពិតឬនិម្មិត ។ដូច្នេះយើងហៅសមីការ(17)ជាដំណោះស្រាយទូទៅនៃសមីការ (8)។ជាការពិតដែលថាលក្ខខណ្ឌដំបូងត្រូវបានគេជ្រើសយកជាជម្រើសត្រឹមត្រូវនៃអថេរក្នុងសមីការ (17) ធ្វើអោយគំនិតនេះកាន់តែជឿទុកចិត្តបាន ។កន្សោមនេះបញ្ចូលដំណោះស្រាយបញ្ចូលគ្នានៃសមីការ (8)។

ឧទាហរណ៍១៖ រកចម្លើយទូទៅនៃសមីការអូម៉ូហ្សែន

$$y'' + 5y' + 6y = 0 \qquad (25)$$

ចម្លើយ

ដោយ $y = e^{rt}$ ហើយអោយ $r$ ជាឫសនៃសមីការ

$$r^2 + 5r + 6 = (r+2)(r+3) = 0$$

នោះតម្លៃនៃ $r$ មាន $r_1 = -2$ និង $r_2 = -3$ ចម្លើយទូទៅនៃសមីការគឺមានទម្រង់៖

$$y = c_1 e^{-2t} + c_2 e^{-3t} \qquad (26)$$

ឧទាហរណ៍២៖ រកចម្លើយមួយនៃសមីការអូម៉ូហ្សែនតាមលក្ខខណ្ឌ

$$y'' + 5y' + 6y = 0, \qquad y(0) = 2 \qquad y'(0) = 3 \qquad (27)$$

ចម្លើយ

ដំណោះស្រាយទូទៅនៃសមីការឌីផេរ៉ង់ស្យែល បានបង្កើតនៅឧទាហរណ៍ទី១ លក្ខខណ្ឌដំបូងយើងអោយ $t = 0$ និង $y = -2$ នៅសមីការ(26)

នោះ $c_1$ និង $c_2$ កំណត់ដោយ៖

$$c_1 + c_2 = 2 \qquad (28)$$

ដោយប្រើលក្ខខណ្ឌទី២មុនដំបូងយើងត្រូវ ឌីផេរ៉ង់ស្យែលសមីការ(26)។អោយ $y' = -c_1 e^{-2t} - 3c_2 e^{-3t}$ នោះ $t = 0; y' = 3$ យើងបាន៖

$$-2c_1 - 3c_2 = 3 \qquad (29)$$

ដំណោះស្រាយសមីការ(28) និង (29)យើងឃើញថា $c_1 = 9$ និង $c_2 = -7$ នោះតម្លៃដែលបង្កើតបាននៅសមីការ(26) យើងបានដំណោះស្រាយ៖

$$y = 9e^{-2t} - 7e^{-3t} \qquad (30)$$

នៅបញ្ហាតម្លៃដើម(27) ក្រាបត្រូវបានបកស្រាយនៅរូប 2.1.1




រូបភាព 2.1.1

ឧទាហរណ៍៣៖ រកចម្លើយមួយនៃសមីការអូម៉ូហ្សែនតាមលក្ខខណ្ឌ

$$4y'' - 8y' + 3y = 0, \qquad y(0) = 2, \qquad y'(0) = \frac{1}{2} \qquad (31)$$

ចម្លើយ

ប្រសិនបើ $y = e^{rt}$ នោះសមីការ $4r^2 - 8r + 3 = 0$

មានឫស $r = 3/2$ ហើយ $r = 1/2$ ទាំងនេះជាដំណោះស្រាយទូទៅនៃសមីការឌីផេរ៉ង់ស្យែល

$$y = c_1 e^{3t/2} + c_2 e^{t/2} \qquad (32)$$

តាមលក្ខខណ្ឌ យើងបានពីរសមីការសម្រាប់ $c_1$ និង $c_2$ ៖ $c_1 + c_2 = 2, \qquad \frac{3}{2}c_1 + \frac{1}{2}c_2 = \frac{1}{2}$

ដំណោះស្រាយសមីការនេះគឺ $c_1 = -\frac{1}{2}, c_2 = \frac{5}{2}$ និងដំណោះស្រាយនៃបញ្ហា សមីការ $(31)$

$$y = -\frac{1}{2}e^{3t/2} + \frac{5}{2}e^{t/2}$$




រូបភាព 2.2.2

## លំហាត់

លំហាត់ពី 1ដល់ 8 រកដំណោះស្រាយទូទៅនៃសមីការឌីផេរ៉ង់ស្យែល

1. $y'' + 2y' - 3y = 0$
2. $y'' + 3y' + 2y = 0$
3. $6y'' - y' - y = 0$
4. $2y'' - 3y' + y = 0$
5. $y'' + 5y' = 0$
6. $4y'' - 9y = 0$
7. $y'' - 9y' + 9y = 0$
8. $y'' - 2y' - 2y = 0$

នៅលំហាត់ទី 9 ដល់ 16 រកចម្លើយមួយ រួចគូសក្រាហ្វ នៃដំណោះស្រាយតាមលក្ខខណ្ឌសមស្រប ករណី $t$ កើនឡើង។

9. $y''+y'-2y=0,\quad y(0)=1,\quad y'(0)=1$

10. $y''+4y'+3y=0,\quad y(0)=2,\quad y'(0)=-1$

11. $6y''-5y'+y=0,\quad y(0)=4,\quad y'(0)=0$

12. $y''+3y'=0,\quad y(0)=-2,\quad y'(0)=3$

13. $y''+5y'+3y=0,\quad y(0)=1,\quad y'(0)=0$

14. $2y''+y'-4y=0,\quad y(0)=0,\quad y'(0)=1$

15. $y''+8y'-9y=0,\quad y(1)=1,\quad y'(1)=0$

16. $4y''-y=0, y(-2)=1,\quad y'(-2)=-1$

17.រកសមីការឌីផេរ៉ង់ស្យែលនិងដំណោះស្រាយទូទៅ $y=c_1e^{2t}+c_2e^{-3t}$

18.រកសមីការឌីផេរ៉ង់ស្យែលនិងដំណោះស្រាយទូទៅ $y=c_1e^{-t/2}+c_2e^{-2t}$

19.រកដំណោះស្រាយនៃ បញ្ហាតម្លៃដើម

$$y''-y=0,\qquad y(0)=\frac{5}{4},\qquad y'(0)=-\frac{3}{2}\quad ,$$

សង់ក្រាហ្វសម្រាប់ $0\le t\le 2$ និងកំណត់តម្លៃអប្បបរិមា

20.រកដំណោះស្រាយនៃ បញ្ហាតម្លៃដើម

$$2y''-3y+y=0,\qquad y(0)=2,\qquad y'(0)=\frac{1}{2}\ ,$$

កំណត់តម្លៃអតិបរិមា និងរកចំណុចដែលធ្វើអោយតម្លៃអនុគមន៍ស្មើ0។

21.ដំណោះស្រាយបញ្ហាតម្លៃដើម $y''-y'-2y=0\quad ,\quad y(0)=\alpha,\quad y'(0)=-2$ រកតម្លៃ $\alpha$ តម្លៃអនុគមន៍ខិតទៅរក0 ដែល $t\to\infty$

22.ដំណោះស្រាយនៃ បញ្ហាតម្លៃដើម $4y''-y=0\quad ,\quad y(0)=2,\quad y'(0)=\beta$ រកតម្លៃ $\alpha$ តម្លៃអនុគមន៍ខិតទៅរក0 ដែល $t\to\infty$

នៅក្នុងលំហាត់ 23 និង24 កំណត់តម្លៃនៃ $\alpha$ ប្រសិនបើដំណោះស្រាយទាំងមូលខិតទៅជិត0។

## ៣.២ ដំណោះស្រាយគ្រឹះនៃសមីការលីនេអ៊ែរអូម៉ូហ្សែន

នៅក្នុងផ្នែកមុន យើងបានបង្ហាញពីរបៀបដោះស្រាយសមីការឌីផេរ៉ង់ស្យែលដែលមានទម្រង់

$$ay''+by'+cy=0$$

ដែល $a,b,c$ ជាចំនួនថេរ។ ឥឡូវនេះយើងធ្វើលទ្ធផលទាំងនោះ ដើម្បីផ្តល់នូវរូបភាពជាក់លាក់មួយក្នុងការរកដំណោះស្រាយនៃគ្រប់សមីការលីនេអ៊ែរលំដាប់ពីរអូម៉ូហ្សែន។ ការយល់ដឹងនេះនឹងជួយយើងក្នុងការស្វែងរកដំណោះស្រាយបញ្ហាផ្សេងទៀតដែលយើងនឹងជួបនៅពេលក្រោយ។

ក្នុងការអភិវឌ្ឍទ្រឹស្តីសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ វាមានសារប្រយោជន៍ក្នុងការណែនាំសញ្ញាណការីឌីផេរ៉ង់ស្យែល។ តាង $p$ និង $q$ ជាអនុគមន៍ជាប់នៅលើចន្លោះបើក $I$ សម្រាប់ $\alpha<t<\beta$ ។ ករណី $\alpha=-\infty,\beta=\infty$ ឬទាំងពីរនឹងគឺនៅក្នុង នោះសម្រាប់អនុគមន៍ណាមួយណា $\phi$ ដែលឌីផេរ៉ង់ស្យែលពីរដងនៅលើ $I$ យើងកំណត់ការីឌីផេរ៉ង់ស្យែល $L$ ដោយសមីការ

$$L(\phi)=\phi''+p\phi'+q\phi \qquad (1)$$

ចំណាំថា $L[\phi]$ ជាអនុគមន៍បើកលើ $I$ ។ តម្លៃនៃ $L[\phi]$ នៅត្រង់ចំណុច $t$ គឺ

$L[\phi](t)=\phi''(t)+p(t)\phi'(t)+q(t)\phi(t)$

ជាឧទាហរណ៍ បើ $p(t)=t^2, q(t)=1+t, \phi(t)=\sin 3t$ នោះ

$$L[\phi](t)=(\sin 3t)''+t^2(\sin 3t)'+(1+t)\sin 3t$$
$$=-9\sin 3t+3t^2\cos 3t+(1+t)\sin 3t$$

ការី $L$ គេច្រើនសរសេរ $L=D^2+pD+q$ ដែល $D$ ដេរីវេ។

នៅក្នុងផ្នែកនេះយើងនឹងសិក្សាពីរសមីការឌីផេរ៉ង់ស្យែលលំដាប់ពីរអូម៉ូហ្សែន $L[\phi](t)=0$ ។ យើងទម្លាប់ប្រើប្រាស់និមិត្តសញ្ញា $y$ សម្គាល់ $\phi(t)$ ដែលយើងនឹងប្រើប្រាស់ការសរសេរសមីការនេះជាទម្រង់

$L[y]=y''+p(t)y'+q(t)y=0$ (2)

ជាមួយនឹងសមីការ(2) យើងនឹងផ្តុំសំណុំនៃលក្ខខណ្ឌដំបូង

$y(t_0)=y_0, y'(t_0)=y'_0$ (3)

ដែល $t_0$ ជាចំណុចណាមួយនៅចន្លោះ $I$ និង $y_0$ , $y'_0$ ជាចំនួនពិត។ យើងចង់ដឹងថា តម្លៃដំបូងក្នុងបញ្ហា(២) ,(៣) តែងតែមានដំណោះស្រាយ ហើយវាប្រហែលជាមានដំណោះស្រាយលើសពីមួយ។ យើងក៏ចង់ដឹងថា ទម្រង់និង វិធីដោះស្រាយដែលមានសារប្រយោជន៍ នៅក្នុងការស្វែងរកដំណោះស្រាយនៃបញ្ហាពិសេស។ ចម្លើយនៃសំណួរទាំងនេះគឺមាននៅក្នុងទ្រឹស្តីបទនៅក្នុងផ្នែកនេះ។

ទ្រឹស្តីបទ ២.២.១ ពិចារណាតម្លៃបញ្ហាតម្លៃដើម

$y''+p(t)y'+q(t)y=g(t)$ $y(t_0)=y_0, y'(t_0)=y'_0$ (4)

ដែល $p,q$ និង $g$ ជាអនុគមន៍លើចន្លោះបើក $I$ នោះមានចម្លើយប្រាកដមួយគឺ $y=\phi(t)$ ក៏ជាប់នៅចន្លោះបើក $I$ ដែរ។

សម្រាប់បញ្ហាមួយចំនួន ការអះអាងមួយចំនួន គឺងាយស្រួលក្នុងការដោះស្រាយ។ ជាទាហរណ៍ យើងបានរកឃើញនៅក្នុងផ្នែក ២.១ ដែលបញ្ហាតម្លៃដំបូង

$y''-y=0$ $y(0)=2$ $y'(0)=-1$ (5)

មានចម្លើយ $y=\frac{1}{2}e^t+\frac{3}{2}e^{-t}$ (6)

ឧទាហរណ៍១៖រកចន្លោះដែលវែងជាងគេនៅក្នុងដំណោះស្រាយនៃតម្លៃបញ្ហាដំបូង

$(t^2-3t)y''+ty'-(t+3)y=0$ $y(1)=2,$ $y'(1)=1$

គឺប្រាកដជាមានប្រសិនបើសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឱ្យគឺ សរសេរក្នុងទម្រង់នៃសមីការ(៤) នោះ $p(t)=1/(t-3), q(t)=-(t+3)/t(t-3), g(t)=0$ ។ ចំណុចតែមួយគត់នៃភាពមិនជាប់នៃមេគុណគឺ $t=0$ , $t=3$ ។ ដូច្នេះបើកដែលវែងជាងគេ មានចំណុចដំបូង $t=1$ ដែលគ្រប់មេគុណទាំងអស់គឺជាប់ក្នុងចន្លោះ $0<t<3$។ ដូចនេះ នេះគឺជាចន្លោះដែលវែងជាងគេនៅក្នុងទ្រឹស្តីបទ ២.២.១ ធានាថា ដំណោះស្រាយគឺមាន។

ឧទាហរណ៍២៖រកចម្លើយតែមួយគត់នៃយម្លៃបញ្ហាដំបូង

$y'' + p(t)y' + q(t) = 0$ , $y(t_0) = 0$ , $y'(t_0) = 0$

ដែល $p$ និង $q$ ជាប់នៅចន្លោះបើក $I$ មាន $t_0$ ។

អនុគមន៍ $y = \phi(t) = 0$ សម្រាប់គ្រប់ $t$ នៅក្នុង $I$ ផ្ទៀងផ្ទាត់សមីការឌីផេរ៉ង់ស្យែល និងលក្ខខណ្ឌដំបូង។ តាមផ្នែកតែមួយគត់នៃទ្រឹស្តីបទ ២.២.១ វាគឺមានចម្លើយតែមួយគត់។យើងសន្មតថា $y_1$ និង $y_2$ ជាបីរចម្លើយនៃសមីការ(2) ឬអាចសរសេរបានថា

$$L[y_1] = y_1'' + py_1' + qy_1 = 0 \qquad (7)$$

និងស្រដៀងគ្នាសម្រាប់ $y_2$ ។ នោះ ដូចនៅក្នុងឧទាហរណ៍នៅក្នុងផ្នែក ២.១ យើងអាចបង្កើតចម្លើយថែមទៀតតាមទម្រង់ការរួមបញ្ចូលលីនេអ៊ែរនៃ $y_1$ និង $y_2$ ។ យើងបញ្ជាក់លទ្ធផលនេះដូចទ្រឹស្តី។

ទ្រឹស្តីបទ ២.២.២៖ បើ $y_1$ និង $y_2$ ជាពីរចម្លើយនៃសមីការឌីផេរ៉ង់ស្យែល(2)

$L[y]] = y'' + p(t)y' + q(t)y = 0$

នោះបន្សំលីនេអ៊ែរ $c_1y_1 + c_2y_2$ ក៏ជាចម្លើយសមីការ(2)ដែរ គ្រប់ចំនួនថេរ $c_1, c_2$ ។

ករណីពិសេសនៃទ្រឹស្តីបទ ២.២.២ កើតឡើងប្រសិនបើ $c_1$ ឬ $c_2$ ស្មើសូន្យ។ នោះយើងអាចសរុបបានថា ផលគុណណាមួយនៃដំណោះស្រាយមួយនៃសមីការ(2) ក៏មានចម្លើយ។

ដើម្បីសម្រាយបញ្ជាក់ទ្រឹស្តីបទ ២.២.២ យើងត្រូវជំនួសតែមួយគត់

$$y = c_1y_1(t) + c_2y_2(t) \qquad (8)$$

សម្រាប់ $y$ នៅក្នុងសមីការ(2) ចម្លើយគឺ

$$\begin{aligned} L[c_1y_1 + c_2y_2] &= [c_1y_1 + c_2y_2]'' + p[c_1y_1 + c_2y_2]' + q[c_1y_1 + c_2y_2] \\ &= c_1y_1'' + c_2y_2'' + c_1py_1' + c_2py_2' + c_1qy_1 + c_2qy_2 \\ &= c_1[y_1'' + py_1' + qy_1] + c_2[y_2'' + py_2' + qy_2] \\ &= c_1L[y_1] + c_2L[y_2] \end{aligned}$$

ដោយ $L[y_1] = 0$ និង $L[y_2] = 0$ នោះ $L[c_1y_1 + c_2y_2] = 0$ ។ ដូច្នេះ ដោយមិនគិតពីតម្លៃនៃ $c_1$ ,$c_2$ , $y$ បានផ្តល់ដោយសមីការ(8)ផ្ទៀងផ្ទាត់សមីការឌីផេរ៉ង់ស្យែល(2)និង ភស្តុតាងនៃទ្រឹស្តីបទ២.២.២ ។

ទ្រឹស្តីបទ ២.២.២ បញ្ជាក់ថា ការចាប់ផ្តើមជាមួយចម្លើយតែពីរគត់នៃសមីការ(២)យើងអាចបង្កើតគ្រួសារនៃចម្លើយទ្វេដងគ្មានដែនកំណត់ ដោយតាមរយៈសមីការ(៨)។ សំណួរបន្ទាប់គឺ គ្រប់ចម្លើយទាំងអស់នៃសមីការ(2) គឺត្រូវបានបញ្ចូលនៅក្នុងសមីការ(8) ឬ ប្រហែលជាមានដំណោះស្រាយផ្សេងទៀតនៃទម្រង់ផ្សេង។ យើងចាប់ផ្តើមកំណត់សំណួរនេះដោយពិនិត្យមើលចំនួនថេរ $c_1$ ,$c_2$ នៅក្នុងសមីការ(8) អាចត្រូវបានជ្រើសរើស ដូចនេះដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង(3)។ លក្ខខណ្ឌដំបូងទាំងនេះតម្រូវឲ្យ $c_1$ ,$c_2$ ផ្ទៀងផ្ទាត់សមីការ

$$\begin{aligned} c_1y_1(t_0) + c_2y_2(t_0) &= y_0 \\ c_1y_1'(t_0) + c_2y_2'(t_0) &= y_0' \end{aligned} \qquad (9)$$

នៅពេលដោះស្រាយប្រព័ន្ធសមីការ(9) សម្រាប់ $c_1$ ,$c_2$ យើងស្វែងរក

$$c_1 = \frac{y_0 y_2'(t_0) - y_0 y_2'(t_0)}{y_1(t_0)y_2'(t_0) - y_1'(t_0)y_2(t_0)}, \quad c_2 = \frac{-y_0 y_1'(t_0) + y_0' y_1(t_0)}{y_1(t_0)y_2'(t_0) - y_1'(t_0)y_2(t_0)} \qquad (10)$$

ឬក្នុងលក្ខខណ្ឌនៃឌីទែមីណង់

$$c_1 = \frac{\begin{vmatrix} y_0 & y_2(t_0) \\ y_0' & y_2'(t_0) \end{vmatrix}}{\begin{vmatrix} y_1(t_0) & y_2(t_0) \\ y_1'(t_0) & y_2'(t_0) \end{vmatrix}}, \quad c_2 = \frac{\begin{vmatrix} y_1(t_0) & y_0 \\ y_1'(t_0) & y_0' \end{vmatrix}}{\begin{vmatrix} y_1(t_0) & y_2(t_0) \\ y_1'(t_0) & y_2'(t_0) \end{vmatrix}} \qquad (11)$$

ជាមួយនឹងតម្លៃទាំងនេះសម្រាប់ $c_1, c_2$ កន្សោម(8) ផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង(៣) ដូចនឹងសមីការឌីផេរ៉ង់ស្យែល(2)។

នៅក្នុងលំដាប់កន្សោមសម្រាប់ $c_1, c_2$ នៅក្នុងសមីការ(10) ឬ (11) ដើម្បីធ្វើឲ្យយល់ វាមានសារៈសំខាន់ដែលភាគបែងមិនសូន្យ។ ទាំង $c_1, c_2$ ភាគបែងគឺដូចគ្នា ពោលគឺ ឌីទែមីណង់

$$W(y_1, y_2)(t_0) = \begin{vmatrix} y_1(t_0) & y_2(t_0) \\ y_1'(t_0) & y_2'(t_0) \end{vmatrix} = y_1(t_0)y_2'(t_0) - y_1'(t_0)y_2(t_0) \qquad (12)$$

$W$ ហៅថា ដេទែមីណង់ហ្វ្រង់ស្គៀន (*Wronskian*)

**ទ្រឹស្តីបទ២.២.៣៖** សន្មត់ថា $y_1, y_2$ ជាពីរចម្លើយនៃសមីការ (2) ដែល

$$L[y] = y'' + p(t)y' + q(t)y = 0$$

នោះហ្វ្រង់ស្គៀន $W = y_1 y' - y_1' y_2$

គឺមិនសូន្យត្រង់ចំណុច $t_0$ ដែលជាលក្ខខណ្ឌដំបូង(3)

$$y(t_0) = y_0, \quad y'(t_0) = y_0'$$

គឺត្រូវបានកំណត់។ នោះមានជម្រើសនៃ ចំនួនថេរ $c_1, c_2$ សម្រាប់ $y = c_1 y_1(t) + c_2 y_2(t)$ ផ្ទៀងផ្ទាត់សមីការឌីផេរ៉ង់ស្យែល(2) និងលក្ខខណ្ឌដំបូង(3)។

**ឧទាហរណ៍៣៖** នៅក្នុងឧទាហរណ៍១ ក្នុងផ្នែក ២.១ យើងបានរកឃើញ $y_1(t) = e^{-2t}, \ y_2(t) = e^{-3t}$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល

$y'' + 5y' + 6y = 0$ ចូររកហ្វ្រង់ស្គៀននៃ $y_1, y_2$ ។

ហ្វ្រង់ស្គៀននៃអនុគមន៍ទាំងនេះគឺ

$$W = \begin{vmatrix} e^{-2t} & e^{-3t} \\ -2e^{-2t} & -3e^{-3t} \end{vmatrix} = -e^{-5t}$$

ដោយ $W$ មិនសូន្យសម្រាប់គ្រប់តម្លៃ $t$ អនុគមន៍ $y_1, y_2$ អាចត្រូវបានប្រើប្រាស់ដើម្បីបង្កើតដំណោះស្រាយនៃសមីការឌីផេរ៉ង់ស្យែលដែលផ្តល់ឲ្យ ដែលជាមួយលក្ខខណ្ឌដំបូងត្រូវបានបញ្ជាក់នៃ $t$ ។

**ទ្រឹស្តីបទ២.២.៤៖** បើ $y_1, y_2$ ជាពីរចម្លើយនៃសមីការឌីផេរ៉ង់ស្យែល

$$L[y] = y'' + p(t)y' + q(t)y = 0$$

ហើយបើមានគ្រប់ចំណុច $t_0$ ដែល $W(y_1, y_2)$ មិនសូន្យ នោះគ្រួសារនៃចម្លើយគឺ

$y = c_1 y_1(t) + c_2 y_2(t)$ មេគុណណាមួយ $c_1, c_2$ ជាចម្លើយនៃសមីការ។

ឧទាហរណ៍៤៖ យើងគណនាប្រូង់ស្គៀននៃ $y_1,\ y_2$

$$W=\begin{vmatrix} e^{r_1t} & e^{r_2t} \\ r_1e^{r_1t} & r_2e^{r_2t}\end{vmatrix}=(r_1-r_2)\exp[(r_1-r_2)t]$$

ដោយនិទស្សន្តអនុគមន៍មិនសូន្យ ហើយ $r_1-r_2\neq 0$ តាមលំនាំនៃបញ្ហា វាដើតាម $W$ គឺមិនសូន្យគ្រប់តម្លៃនៃ $t$ ។ ជាលទ្ធផល $y_1,\ y_2$ បង្កើតបានសំណុំចម្លើយគ្រឹះមួយ។

ឧទាហរណ៍៥៖ បង្ហាញថា $y_1(t)=t^{1/2},\ y_2(t)=t^{-1}$ បង្កើតបានសំណុំចម្លើយគ្រឹះមួយនៃ

$$2t^2y''+3ty'-y=0,\quad t>0 \qquad (14)$$

យើងនឹងបង្ហាញនៅក្នុងផ្នែកបន្ត របៀបក្នុងការដោះស្រាយសមីការនេះទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះយើងនឹងផ្ទៀងផ្ទាត់ដោយជំនួសផ្ទាល់ ដែល $y_1,\ y_2$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល។ ដោយ $y_1'(t)=\frac{1}{2}t^{-1/2},\quad y_1''(t)=-\frac{1}{4}t^{-3/2}$ យើងមាន

$$2t^2(-\frac{1}{4}t^{-3/2})+3t(\frac{1}{2}t^{-1/2})-t^{1/2}=\left(-\frac{1}{2}+\frac{3}{2}-1\right)t^{1/2}=0$$

ស្រដៀងគ្នា $y_2'(t)=-t^{-2},\quad y_2''(t)=2t^{-3}$ ដូច្នេះ

$$2t^2(2t^{-3})+3t(-t^{-2})-t^{-1}=(4-3-1)t^{-1}=0$$

បន្ទាប់មកយើងគណនាប្រូនស្គែននៃ $y_1,\ y_2$

$$W=\begin{vmatrix} t^{1/2} & t^{-1} \\ \frac{1}{2}t^{-1/2} & -t^{-2}\end{vmatrix}=-\frac{3}{2}t^{-3/2}$$

ដោយ $W\neq 0$ សម្រាប់ $t>0$ យើងសន្និដ្ឋានថា $y_1,\ y_2$ បង្កើតបានសំណុំចម្លើយគ្រឹះមួយ។

ទ្រឹស្តីបទ២.២.៥ ពិចារណាសមីការឌីផេរ៉ង់ស្យែល $L[y]=y''+p(t)y'+q(t)y=0$ ដែលមេគុណ $p$ និង $q$ ជាប់នៅចន្លោះបើកណាមួយ $I$ ។ ជ្រើសរើសចំណុច $t_0$ នៅក្នុង $I$ ។ តាង $y_1$ ជាចម្លើយនៃសមីការ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង

$y(t_0)=1,\quad y'(t_0)=0$

ហើយតាង ជាចម្លើយនៃសមីការ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង

$y(t_0)=0,\quad y'(t_0)=1$

នោះ $y_1,\ y_2$ បង្កើតបានសំណុំចម្លើយគ្រឹះនៃសមីការ។

## លំហាត់

នៅក្នុងលំហាត់ពី១ ដល់ ៦ចូររកប្រូនស្គែននៃគូរអនុគមន៍ដែលបានផ្តល់ឲ្យដូចខាងក្រោម៖

1. $e^{2t}\quad e^{-3t/2}$
2. $\cos t,\quad \sin t$
3. $e^{-2t},\quad te^{-2t}$
4. $x,\quad xe^{x}$
5. $e^{t}\sin t,\quad e^{t}\cos t$
6. $\cos^2\theta,\quad 1+\cos 2\theta$

នៅក្នុងលំហាត់ពី ៧ ដល់ ១២ កំណត់ចន្លោះវែងបំផុតនៅក្នុងតម្លៃបញ្ហាដំបូងដែលបានផ្តល់ឱ្យ គឺមានចម្លើយឌីផេរ៉ង់ស្យែលតែពីរគត់។

7. $ty''+3y=t, \quad y(1)=1 \quad y'(1)=2$

8. $(t-1)y''-3ty'+4y=\sin t, \quad y(-2)=2, \quad y'(-2)=1$

9. $t(t-4)y''+3ty'+4y=2, \quad y(3)=0, \quad y'(3)=-1$

10. $y''+(\cos t)y'+3(\ln|x|)y=0, \; y(2)=3, \; y'(2)=1$

11. $(x-3)y''+xy'+(\ln|x|)y=0, \; y(1)=0, \; y'(1)=1$

12. $(x-2)y''+y'+(x-2)(\tan x)y=0, \; y(3)=1, \; y'(3)=2$

13. ផ្ទៀងផ្ទាត់ថា $y_1(t)=t^2$ និង $y_2(t)=t^{-1}$ ជាពីរចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $t^2y''-2y=0$ សម្រាប់ $t>0$ ។បន្ទាប់មកបង្ហាញថា $c_1t^2+c_2t^{-1}$ ក៏ជាចម្លើយនៃសមីការសម្រាប់ $c_1, c_2$ ។

14. ផ្ទៀងផ្ទាត់ថា $y_1(t)=1$ និង $y_2(t)=t^{1/2}$ ចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $yy''+(y')^2=0$ សម្រាប់ $t>0$ ។បន្ទាប់មកបង្ហាញថា $c_1+c_2t^{1/2}$ មិនមែនជាចម្លើយទូទៅនៃសមីការនេះ។ ចូរពន្យល់ហេតុអ្វីបានជាលទ្ធផលនេះមិនផ្ទុយទ្រឹស្តីបទ៣.២.២។

15.បង្ហាញថា ប្រសិនបើ $y=\phi(t)$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $y''+p(t)y'+q(t)y=g(t)$ ដែល $g(t)$ មិនសូន្យជានិច្ច នោះ $y=c\phi(t)$ ដែល $c$ ជាចំនួនថេរណាមួយក្រៅពី 1 គឺមិនមែនជាចម្លើយ។ ចូរពន្យល់ថា ហេតុអ្វីបានជាចម្លើយនេះមិនផ្ទុយពីការកំណត់ចំណាំក្នុងទ្រឹស្តីបទ៣.២.២។

16.តើ $y=\sin(t^2)$ ជាចម្លើយនៅចន្លោះដែលមាន $t=0$ នៃសមីការ $y''+p(t)y'+q(t)y=0$ ជាមួយនឹងមេគុណជាប់? ពន្យល់ចម្លើយរបស់អ្នក។

17. បើហ្វ្រន់ស្គេន $W$ នៃ $f$ និង $g$ គឺ $3e^{4t}$, ហើយបើ $f(t)=e^{2t}$ ចូររក $g(t)$ ។

18. បើហ្វ្រន់ស្គេន $W$ នៃ $f$ និង $g$ គឺ $t^2e^t$, ហើយបើ $f(t)=t$ ចូររក $g(t)$ ។

19.បើ $W(f,g)$ ជាហ្វ្រន់ស្គេននៃ $f,g$ ហើយបើ $u=2f-g, \; v=f-g$ ចូររកហ្វ្រន់ស្គេននៃ $u,v$ នៅរយៈនៃ $W(f,g)$ ។

20. បើហ្វ្រន់ស្គេននៃ $f,g$ គឺ $t\cos t-\sin t$ ហើយបើ $u=f+3g, \; v=f-g$ ចូររកហ្វ្រន់ស្គេននៃ $u, v$ ។

21. $y''+y'-2y=0, \; t_0=0$

22. $y''+4y'+3y=0, \; t_0=1$

ពីលំហាត់ ២៣ ដល់ ២៦ ផ្ទៀងផ្ទាត់អនុគមន៍ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឲ្យ។ តើលំហាត់ខាងក្រោមនេះបង្កើតបានសំណុំចម្លើយគ្រឹះដែរឬទេ?

23. $y''+4y=0, \; y_1(t)=\cos 2t, \quad y_2(t)=\sin 2t$

24. $y''-2y'+y=0, \; y_1(t)=e^t, \quad y_2(t)=te^t$

25. $xy''-x(x+2)y'+(x+2)y=0, \; x>0, \; y_1(x)=x, \quad y_2(x)=xe^x$

26. $(1-x\cot x)y''-xy'+y=0, \; 0<x<\pi, \; y_1(x)=x, \quad y_2(x)=\sin x$

27.**សមីការប្រាកដ** ។ សមីការ $P(x)y''+Q(x)y'+R(x)y=0$ គឺបាននិយាយថា ដើម្បីក្លាយទៅថា ប្រាកដ បើវាអាចសរសេរក្នុងទម្រង់ $\left[P(x)y'\right]'+\left[f(x)y\right]'=0$ ដែល $f(x)$ គឺដើម្បីកំណត់នៅក្នុង $P(x),Q(x),R(x)$ ។សមីការក្រោយ អាចជាការរួមបញ្ចូលតែម្តងភ្លាមៗ ដែលលទ្ធផលនៅក្នុងសមីការលីនេអ៊ែរលំដាប់មួយសម្រាប់ $y$ ដែលអាចត្រូវបានដោះស្រាយដូចនៅក្នុងផ្នែក២.១។ ដោយសមីការមេគុណនៃសមីការមុន ហើយលុបបំបាត់ $f(x)$ ចូរបង្ហាញថាលក្ខខណ្ឌចាំបាច់សម្រាប់ភាពប្រាកដគឺ $P''(x)+Q'(x)+R(x)=0$ ។ វាត្រូវបានបង្ហាញដែលនេះក៏ជាលក្ខខណ្ឌគ្រប់គ្រាន់មួយដែរ។

ពីលំហាត់២៨ ដល់ ៣១ ប្រើប្រាស់លទ្ធផលពីលំហាត់ ២៧ ដើម្បីកំណត់សមីការដែលបានផ្តល់ឲ្យ គឺប្រាកដ។ បើដូច្នេះ ចូរដោះស្រាយសមីការ

28. $y''+xy'+y=0$

29. $y''+3x^2y'+xy=0,$

30. $xy''-(\cos x)y'+(\sin x)y=0, \quad x>0$

31. $x^2y''+xy'-y=0, \quad x>0$

32. **សមីការអែតច័ន (The Adjoint Equation)**។ បើសមីការលីនេអ៊ែរលំដាប់ពីរអូម៉ូហ្សែន មិនប្រាកដ យើងអាចបង្កើតប្រាកដ ដោយគុណបញ្ចូលសមីការជាមួយនឹងកត្តា $\mu(x)$ ។ នោះយើងតម្រូវ $\mu(x)$ យើងបាន៖

$$\mu(x)P(x)y''+\mu(x)Q(x)y'+R(x)y=0$$

អាចសរសេរក្នុងទម្រង់ $\left[\mu(x)P(x)y'\right]'+\left[f(x)y\right]'=0$ ។

ដោយមេគុណសមីការនៅក្នុងសមីការទាំងពីរ ហើយបំបាត់បង្ហាញថាអនុគមន៍ $f(x)$ ត្រូវតែផ្ទៀងផ្ទាត់

$$P\mu''+(2P'-Q)\mu'+(P''-Q'+R)\mu=0$$

សមីការនេះគឺបានស្គាល់ថាជាអែតច័ននៃសមីការដើម និងមានសារៈសំខាន់នៅក្នុងទ្រឹស្តីបទកម្រិតខ្ពស់នៃសមីការឌីផេរ៉ង់ស្យែល។ ជាទូទៅ លំហាត់ក្នុងការដោះស្រាយ សមីការឌីផេរ៉ង់ស្យែលអែតច័ន គឺពិបាកដូចគ្នាទៅនឹងដោះស្រាយសមីការដើម ដូច្នេះមានតែម្តងម្កាលប៉ុណ្ណោះដែលអាចទៅរួចក្នុងការរកកត្តាសមីការសម្រាប់សមីការលំដាប់ពីរ។

ពីលំហាត់ ៣៣ ដល់ ៣៥ ប្រើប្រាស់លទ្ធផលពីលំហាត់៣២ ដើម្បីរក អែតច័ននៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឲ្យ។

33. $x^2y''+xy'+\left(x^2-v^2\right)y=0$ , *Bessel's equation*

34. $\left(1-x^2\right)y''-2xy'+\alpha(\alpha+1)y=0,$ *Legendre's equation*

35. $y''-xy'=0,$ *Airy's equation*

36.សម្រាប់សមីការលីនេអ៊ែរលំដាប់ពីរ $P(x)y''+Q(x)y'+R(x)y=0$ បង្ហាញថាអែតច័ននៃសមីការអែតច័នគឺជាសមីការដើម។

37. សម្រាប់សមីការលីនេអ៊ែរលំដាប់ពីរ $P(x)y''+Q(x)y'+R(x)y=0$ បាននិយាយថា ដើម្បីក្លាយជាស្វ័យអែតច័នបាន ប្រសិនបើ អែតច័នរបស់វាដូចគ្នាទៅនឹងសមីការដើម។ បង្ហាញថាលក្ខខណ្ឌ

ចាំបាច់សម្រាប់សមីការនេះជាស្វ័យអែតច័នគឺ $P'(x)=Q(x)$ ។កំណត់សមីការនៅក្នុងលំហាត់ ៣៣ ដល់ ៣៥គឺជាស្វ័យអែតច័ន។

## ៣.៣ ភាពអាស្រ័យលីនេអ៊ែរ និងដេទែមីណង់ (Wronskian)

ការបង្ហាញចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរអូម៉ូហ្សែនលំដាប់ទី២ ពីព្រោះមានបន្សំលីនេអ៊ែរនៃចម្លើយចំនួនពីរដែល ដេទែមីណង់Wronskian មិនសូន្យ គឺទាក់ទងយ៉ាងខ្លាំងទៅនឹងការបង្ហាញភាពអាស្រ័យលីនេអ៊ែរនៃអនុគមន៍ពីរ។ វាមានសារៈសំខាន់ក្នុងកន្សោមពីជគណិត និងក្នុងបរិបទបច្ចុប្បន្ន ។ យើងនឹងពិភាក្សាយ៉ាងខ្លីនៅក្នុងចំណុចនេះ ។

ទ្រឹស្តីបទ២.៣.១ ប្រសិនបើ $f$ និង $g$ ជាអនុគមន៍មានឌីផេរ៉ង់ស្យែលលើចន្លោះបើក $I$ ។ ប្រសិនបើ $W(f,g)(t_0)\neq 0$ សម្រាប់ចំណុច $t_0$ មួយចំនួនក្នុង $I$ នោះ $f$ និង $g$ មានភាពមិនអាស្រ័យលីនេអ៊ែរលើ $I$ ។ ហើយបើ $f$ និង $g$ មានភាពអាស្រ័យលីនេអ៊ែរលើ $I$ នោះ $W(f,g)(t_0)=0$ សម្រាប់គ្រប់តម្លៃ $t_0$ ក្នុង $I$ ។

យើងអាចអនុវត្តន៍ទៅលើអនុគមន៍ $f(t)=e^t$ និង $g(t)=e^{2t}$ ដែលបានពិភាក្សាក្នុងឧទាហរណ៍២ ។ សម្រាប់គ្រប់ចំណុច $t_0$ ណាមួយ យើងបាន

$$W(f,g)(t_0)=\begin{vmatrix} e^{t_0} & e^{2t_0} \\ e^{t_0} & 2e^{2t_0} \end{vmatrix}=e^{3t_0}\neq 0$$

ដូចនេះ អនុគមន៍ $e^t$ និង $e^{2t}$ គឺមានភាពមិនអាស្រ័យលីនេអ៊ែរនៅលើចន្លោះណាមួយ ។

ទ្រឹស្តីបទ២.៣.២ (ទ្រឹស្តីបទ Abel)ប្រសិនបើ $y_1$ និង $y_2$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល

$$L[y]=y''+p(t)y'+q(t)y=0,$$

ដែល $p$ និង $q$ គឺជាប់នៅលើចន្លោះបើក $I$ នោះដេទែមីណង់វ៉ុងគៀន $W(y_1,y_2)(t)$ ត្រូវបានកំណត់ដោយៈ

$$W(y_1,y_2)(t)=c\exp\left[-\int p(t)dt\right]$$

ដែល $c$ ជាចំនួនថេរមួយដែលអាស្រ័យលើ $y_1$ និង $y_2$ ប៉ុន្តែមិនមែនអាស្រ័យលើ $t$ ។ បន្ថែមពីនេះ $W(y_1,y_2)(t)$ គឺអាចស្មើសូន្យសម្រាប់គ្រប់ $t$ នៅក្នុង $I$ (ប្រសិនបើ $c=0$ ) រឺក្រៅពីសូន្យក្នុង $I$ (ប្រសិនបើ $c\neq 0$) ។

ដើម្បីបង្ហាញទ្រឹស្តីបទ Abel យើងចាប់ផ្តើមដោយកត់សម្គាល់ឃើញថា $y_1$ និង $y_2$ ផ្ទៀងផ្ទាត់

$$y_1''+p(t)y_1'+q(t)y_1=0,$$
$$y_2''+p(t)y_2'+q(t)y_2=0,$$

ប្រសិនបើយើងគុណសមីការទី១នឹង $-y_2$ សមីការទី២នឹង $y_1$ ហើយបូកលទ្ធផលនៃសមីការទាំងពីរនោះ យើងបាន

$$(y_1y_2''-y_1''y_2)+p(t)(y_1y_2'-y_1'y_2)=0$$

បន្ទាប់មក យើងតាង $W(t)=W(y_1,y_2)(t)$ ហើយសង្កេតឃើញថា

$$W'=y_1y_2''-y_1''y_2$$

រួចយើងអាចសរសេរសមីការ (10) ជាទម្រង់

$$W' + p(t)W = 0$$

សមីការ (12) អាចដោះស្រាយយ៉ាងលឿនពីព្រោះតែវាជាសមីការលីនេអ៊ែរលំដាប់ទី១ (ចំណុច ២.១) សមីការត្រូវបានបំបែក (ចំណុច២.២) ។ ដូចនេះ

$$W(t) = c\exp\left[-\int p(t)dt\right],$$

ដែល $c$ ថេរ ។ តម្លៃ $c$ អាស្រ័យលើគូចម្លើយនៃសមីការណាមួយដែលជាប់ទាក់ទង ។ ទោះជាយ៉ាងណាក៏ដោយ ពីព្រោះតែអនុគមន៍ឪផេរ៉ង់ស្យែលគឺមិនសូន្យ នោះ $W(t)$ គឺមិនសូន្យប្រសិនបើ $c \neq 0$ ។ ក្នុងករណីខ្លះ $W(t)$ គឺសូន្យសម្រាប់គ្រប់ $t$ ដែលបំពេញភស្តុតាងនៃទ្រឹស្តីបទ៣.៣.២ ។

កំណត់ចំណាំថាដេទែមីណង់Wronskian នៃសំណុំចម្លើយគ្រឹះពីរណាមួយនៃដំណោះស្រាយសមីការឌីផេរ៉ង់ស្យែលតែមួយអាចខុសត្រឹមតែផលគុណចំនួនថេរ នោះដេទែមីណង់Wronskian នៃសំណុំចម្លើយគ្រឹះណាមួយដែលត្រូវបានកំណត់ បង្កើនផលគុណចំនួនថេរដោយមិនចាំបាច់ដោះស្រាយសមីការឌីផេរ៉ង់ស្យែល ។

**ឧទាហរណ៍៣៖** បង្ហាញថា $y_1(t) = t^{\frac{1}{2}}$ និង $y_2(t) = t^{-1}$ ជាចម្លើយនៃសមីការ

$$2t^2y'' + 3ty' - y = 0, \qquad t > 0 \qquad (14)$$

សន្មត់ថាដេទែមីណង់Wronskian នៃ $y_1$ និង $y_2$ ត្រូវបានផ្តល់អោយដោយសមីការ ។

ពីឧទាហរណ៍ដែលទើបតែលើកឡើង យើងដឹងថា $W(y_1,y_2)(t) = -\left(\frac{3}{2}\right)t^{-\frac{3}{2}}$

ដូចនេះ យើងបាន

$$y'' + \frac{3}{2t}y' - \frac{1}{2t^2}y = 0,$$

ដូច្នេះ $p(t) = \frac{3}{2t}$ ។ គេបាន

$$W(y_1,y_2)(t) = c\exp\left[-\int \frac{3}{2t}dt\right] = c\exp\left(-\frac{3}{2}\ln t\right) = ct^{-\frac{3}{2}}$$

សម្រាប់ចម្លើយជាក់លាក់ដែលត្រូវបានផ្តល់ឱ្យនៅក្នុងឧទាហរណ៍នេះ យើងត្រូវជ្រើសរើស $c = -\frac{3}{2}$ ។

> **ទ្រឹស្តីបទ២.៣.៣៖** តាង $y_1$ និង $y_2$ ជាចម្លើយនៃសមីការ $L[y] = y'' + p(t)y' + q(t)y = 0,$ ដែល $p$ និង $q$ ជាប់នៅលើចន្លោះបើក $I$ ។ នោះ $y_1$ និង $y_2$ មានភាពអាស្រ័យលីនេអ៊ែរលើ $I$ លុះត្រាតែ $W(y_1,y_2)(t)$ គឺសូន្យសម្រាប់គ្រប់ $t$ ក្នុង $I$ ។ម្យ៉ាងទៀត $y_1$ និង $y_2$ មិនមានភាពអាស្រ័យលីនេអ៊ែរលើចន្លោះ $I$ លុះត្រាតែ $W(y_1,y_2)(t)$ គឺមិនសូន្យក្នុង $I$ ។

ក្នុងការបង្ហាញទ្រឹស្តីបទ៣.៣.២ សង្កេតដំបូងថា បើ $y_1$ និង $y_2$ មានភាពអាស្រ័យលីនេអ៊ែរ នោះ $W(y_1,y_2)(t)$ គឺសូន្យសម្រាប់គ្រប់ $t$ ក្នុង $I$ បានបង្ហាញក្នុងទ្រឹស្តីបទ៣.៣.១ ។ វានៅតែត្រូវបង្ហាញផ្ទុយ ដែលថាបើ $W(y_1,y_2)(t)$ គឺសូន្យតាមរយៈ $I$ នោះ $y_1$ និង $y_2$ មានភាពអាស្រ័យលីនេអ៊ែរ ។ តាង $t_0$ ជាចំណុចណាមួយនៅក្នុង $I$ នោះចាំបាច់ឱ្យ $W(y_1,y_2)(t_0) = 0$ ។ ហេតុនេះហើយប្រព័ន្ធសមីការ

$$c_1y_1(t_0)+c_2y_2(t_0)=0,$$
$$c_1y_1'(t_0)+c_2y_2'(t_0)=0$$

សម្រាប់ $c_1$ និង $c_2$ ដែលមិនមែនជាចម្លើយ ។ ដោយប្រើប្រាស់តម្លៃនៃ $c_1$ និង $c_2$ តាង $\phi(t)=c_1y_1(t)+c_2y_2(t)$ ។ នោះ $\phi$ ជាចម្លើយនៃសមីការ និងដោយសមីការ $\phi$ ក៏ផ្ទៀងផ្ទាត់លក្ខខណ្ឌដើម $\phi(t_0)=0,\quad \phi'(t_0)=0$

ដូចនេះ ដោយផ្អែកតែមួយនៃទ្រឹស្តីបទ២.២.១ ឬដោយឧទាហរណ៍២ក្នុងចំណុច៣.២ $\phi(t)=0$ សម្រាប់គ្រប់ $t$ ក្នុង $I$ ។ ពីព្រោះតែ $\phi(t)=c_1y_1(t)+c_2y_2(t)$ ដែល $c_1$ និង $c_2$ មិនសូន្យ នេះមានន័យថា $y_1$ និង $y_2$ មានភាពអាស្រ័យលីនេអ៊ែរ ។

ឥឡូវយើងសង្ខេបការពិតអំពីសំណុំចម្លើយគ្រឹះ ដេទែមីណង់Wronskian និងភាពមិនអាស្រ័យលីនេអ៊ែរតាមវិធីខាងក្រោម ។ តាង $y_1$ និង $y_2$ ជាចម្លើយនៃសមីការ

$$y''+p(t)y'+q(t)=0,$$

ដែល $p$ និង $q$ ជាប់លើចន្លោះបើក $I$ ។ នោះដំហានទាំង៤ខាងក្រោម

១. អនុគមន៍ $y_1$ និង $y_2$ គឺជាសំណុំចម្លើយគ្រឹះលើ $I$ ។

២. អនុគមន៍ $y_1$ និង $y_2$ គឺមិនមានភាពអាស្រ័យលីនេអ៊ែរលើ $I$ ។

៣. $W(y_1,y_2)(t_0)\neq 0$ ចំពោះ $t_0$ មួយចំនួនក្នុង $I$ ។

៤. $W(y_1,y_2)(t)\neq 0$ ចំពោះគ្រប់ $t$ ក្នុង $I$ ។

## លំហាត់

ក្នុងលំហាត់ទី១ ដល់ទី៨ខាងក្រោម កំណត់ថាតើគូនៃអនុគមន៍ដែលឱ្យមានភាពអាស្រ័យលីនេអ៊ែរ ឬមានភាពមិនអាស្រ័យលីនេអ៊ែរ ។

1. $f(t)=t^2+5t,\qquad g(t)=t^2-5t$

2. $f(\theta)=\cos 3\theta,\qquad g(\theta)=4\cos^3\theta-3\cos\theta$

3. $f(t)=e^{\lambda t}\cos\mu t,\qquad g(t)=e^{\lambda t}\sin\mu t,\qquad \mu\neq 0$

4. $f(x)=e^{3x},\qquad g(x)=e^{3(x-1)}$

5. $f(t)=3t-5,\qquad g(t)=9t-15$

6. $f(t)=t,\qquad g(t)=t^{-1}$

7. $f(t)=3t,\qquad g(t)=|t|$

8. $f(x)=x^3,\qquad g(x)=|x|^3$

9. ដេទែមីណង់Wronskian នៃអនុគមន៍ពីរគឺ $W(t)=t\sin^2 t$ ។ តើអនុគមន៍នេះមានភាពអាស្រ័យលីនេអ៊ែរ រឺមានភាពមិនអាស្រ័យលីនេអ៊ែរ? ហេតុអ្វី?

10. ដេទែមីណង់Wronskian នៃអនុគមន៍ពីរគឺ $W(t)=t^2-4$ ។ តើអនុគមន៍នេះមានភាពអាស្រ័យលីនេអ៊ែរ រឺមានភាពមិនអាស្រ័យលីនេអ៊ែរ? ហេតុអ្វី?

11. ប្រសិនបើអនុគមន៍ $y_1$ និង $y_2$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃ $y''+p(t)y'+q(t)y=0$ បង្ហាញថា $c_1y_1$ និង $c_2y_2$ ក៏ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរដែរ ។ ដោយ $c_1$ និង $c_2$ ខុសពីសូន្យ ។

12. ប្រសិនបើអនុគមន៍ $y_1$ និង $y_2$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃ $y''+p(t)y'+q(t)y=0$ បង្ហាញថា $y_3=y_1+y_2$ និង $y_4=y_1-y_2$ ក៏មានទម្រង់សំណុំចម្លើយភាពមិនអាស្រ័យលីនេអ៊ែរដែរ ។

13. ប្រសិនបើ $y_3$ និង $y_4$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃសមីការឌីផេរ៉ង់ស្យែល បង្ហាញថា $y_1$ និង $y_2$ ក៏ដូច្នឹងដែរ ។

14. ប្រសិនបើអនុគមន៍ $y_1$ និង $y_2$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃ $y''+p(t)y'+q(t)y=0$ កំណត់ថាតើលក្ខខណ្ឌអ្វីដែលធ្វើឱ្យអនុគមន៍ $y_3=a_1y_1+a_2y_2$ និង $y_4=b_1y_1+b_2y_2$ ក៏ជាទម្រង់សំណុំចម្លើយភាពមិនអាស្រ័យលីនេអ៊ែរ ?

$(a)$ បង្ហាញថាវ៉ិចទ័រទំហំពីរណាមួយអាចសរសេរជាបន្សំលីនេអ៊ែរនៃ $i+j$ និង $i-j$ ។

$(b)$ បង្ហាញថាបើវ៉ិចទ័រ $X=x_1i+x_2j$ និង $Y=y_1i+y_2j$ មានភាពមិនអាស្រ័យលីនេអ៊ែរ នោះមានវ៉ិចទ័រ $z=z_1i+z_2j$ ណាមួយដែលអាចចាត់ទុកជាបន្សំលីនេអ៊ែរនៃ $X$ និង $Y$ ។ កំណត់ចំណាំថា៖បើ $X$ និង $Y$ មានភាពមិនអាស្រ័យលីនេអ៊ែរ នោះ $x_1y_2-x_2y_1\neq 0$ ។ ហេតុអ្វី ?

នៅក្នុងលំហាត់ពីទី១៥ ដល់ទី១៨ រកដេទែមីណង់Wronskian នៃគូចម្លើយនៃសមីការឌីផេរ៉ង់ស្យែល ដែលឱ្យដោយមិនចំបាច់ដោះស្រាយសមីការនោះទេ ។

15.$t^2y''-t(t+2)y'+(t+2)y=0$

16.$(\cos t)y''+(\sin t)y'-ty=0$

17.$x^2y''+xy'+\left(x^2-v^2\right)y=0,$ សមីការរបស់ *Bessel*

18.$\left(1-x^2\right)y''-2xy'+\alpha(\alpha+1)y=0,$ សមីការរបស់ *Legendre*

19.បង្ហាញថាប្រសិនបើ $p$ មានឌីផេរ៉ង់ស្យែល ហើយ $p(t)>0$ នោះដេទែមីណង់Wronskian $W(t)$ ជាចម្លើយពីរនៃ $\left[p(t)y'\right]'+q(t)y=0$ គឺ $W(t)=\dfrac{c}{p(t)}$ ដែល $c$ ជាចំនួនថេរ ។

20. ប្រសិនបើ $y_1$ និង $y_2$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃ $ty''+2y'+te^ty=0$ ហើយបើ $W(y_1,y_2)(1)=2$ ។ រកតម្លៃនៃ $W(y_1,y_2)(5)$ ។

21.ប្រសិនបើ $y_1$ និង $y_2$ ជាចម្លើយភាពមិនអាស្រ័យលីនេអ៊ែរនៃ $ty''-2y'+(3+t)y=0$ ហើយបើ $W(y_1,y_2)(2)=3$ ។ រកតម្លៃនៃ $W(y_1,y_2)(4)$ ។

22. ប្រសិនបើដេទែមីណង់ Wronskian នៃចម្លើយពីរណាមួយនៃ $y''+p(t)y'+q(t)y=0$ ជាចំនួនថេរ តើអ្វីនឹងកំណត់អំពីមេគុណ $p$ និង $q$ ?

23.ប្រសិនបើ $f, g$ និង $h$ ជាអនុគមន៍មានឌីផេរ៉ង់ស្យែល បង្ហាញថា $W(fg,\, fh)=f^2W(g,h)$ ។

នៅក្នុងលំហាត់ទី២៤ ដល់ទី២៦ សន្មត់ថា $p$ និង $q$ ជាប់ ហើយអនុគមន៍ $y_1$ និង $y_2$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $y''+p(t)y'+q(t)=0$ លើចន្លោះបើក $I$ មួយ

24. បង្ហាញថា $y_1$ និង $y_2$ ស្មើសូន្យនៅចំណុចដូចគ្នានៅក្នុង $I$ ដែលមិនមែនជាសំណុំគ្រឹះនៃចម្លើយនៅចន្លោះនោះ។

25. បង្ហាញថា $y_1$ និង $y_2$ មានអតិបរមាឬអប្បបរមានៅចំណុចដូចគ្នាក្នុង $I$ ដែលមិនមែនជាសំណុំគ្រឹះនៃចម្លើយលើចន្លោះនោះ។

26. បង្ហាញថា $y_1$ និង $y_2$ មានចំណុចរួមមួយនៃធ្មិតឆ្លុះ $t_0$ ក្នុង $I$ ដែលមិនមែនជាសំណុំគ្រឹះនៃចម្លើយលើ $I$ លុះត្រាតែ $p$ និង $q$ ស្មើសូន្យនៅខណៈ $t_0$ ។

27. បង្ហាញថា $t$ និង $t^2$ ជាភាពមិនអាស្រ័យលីនេអ៊ែរលើចន្លោះ $-1<t<1,$ ជាកាពិត វាជាភាពមិនអាស្រ័យលីនេអ៊ែរគ្រប់ចន្លោះ។ រួចបង្ហាញថា $w(t,t^2)$ ស្មើសូន្យនៅខណៈ $t=0$។ តើអ្នកអាចសន្និដ្ឋានអ្វីខ្លះ អំពីលទ្ធភាពដែល $t$ និង $t^2$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $y''+p(t)y'+q(t)y=0$ ? ផ្ទៀងផ្ទាត់ថា $t$ និង $t^2$ ជាចម្លើយនៃសមីការ $t^2y''-2ty'+2y=0$ ។ តើផ្ទុយពីការសន្និដ្ឋានរបស់អ្នកដែរឬទេ ?តើលក្ខណៈនៃ *Wronskian* នៃ $t$ និង $t^2$ ផ្ទុយពីទ្រឹស្តីបទ3.3.2 ដែរឬទេ ?

28. បង្ហាញថាអនុគមន៍ $f(t)=t^2|t|$ និង $g(t)=t^3$ មានភាពអាស្រ័យលីនេអ៊ែរលើចន្លោះ $0<t<1$ និង $-1<t<0$ ។ ប៉ុន្តែមានភាពមិនអាស្រ័យលីនេអ៊ែរលើចន្លោះ $-1<t<1$។ ទោះបីជា $f$ និង $g$ មានភាពមិនអាស្រ័យលីនេអ៊ែរ ចូរបង្ហាញថា $w(f,g)$ ស្មើសូន្យគ្រប់ $t$ ក្នុងចន្លោះ $-1<t<1$។ ដូច្នេះ $f$ និង $g$ មិនមែនជាចម្លើយនៃសមីការ $y''+p(t)y'+q(t)y=0$ ដែល $p$ និង $q$ ជាប់លើចន្លោះ $-1<t<1$។

## ៣.៤ ឫសកុំផ្លិចនៃសមីការសម្គាល់

យើងមានសមីការ $ay''+by'+cy=0$ (1) ដែល $a,b$ និង $c$ ជាចំនួនពិត។ ក្នុងផ្នែក 3.1 យើងឃើញថា បើយើងស្វែងរកចម្លើយនៃទម្រង់ $y=e^{rt}$ ហើយ $r$ ត្រូវតែជាឫសនៃសមីការសម្គាល់

$$ar^2+br+c=0 \quad (2)$$

បើឫស $r_1$ និង $r_2$ ជាចំនួនពិតខុសគ្នាដែលជាចម្លើយនៃឌីសគ្រីមីណង់ $b^2-4ac>0$ នោះចម្លើយទូទៅនៃសមីការ( 1 )គឺ $y=c_1e^{r_1t}+c_2e^{r_2t}$ (3)

បើ $b^2-4ac<0$ នោះឫសនៃសមីការ (2) ជាចំនួនកុំផ្លិចឆ្លាស់ យើងកំណត់សរសេរ

$$r_1=\lambda+i\mu,\ r_2=\lambda-i\mu \quad (4)$$

ដែល $\lambda$ និង $\mu$ ជាចំនួនពិត។ការបង្ហាញដែលត្រូវគ្នាសម្រាប់ $y$ គឺ

$$y_1(t)=\exp[(\lambda+i\mu)t], \qquad y_2(t)=\exp[(\lambda-i\mu)t] \quad (5)$$

ប្រសិនបើ $\lambda=-1$ , $\mu=2$ និង $t=3$ នោះពីសមីការ (5) ខាងលើគឺ $y_1(3)=e^{-3+6i}$ $(6)$ ។

រំលឹកឡើងវិញពីការគណនាស៊េរី *Taylor* សម្រាប់ $e^t$ បើ $t=0$ គឺ

$$e^t=\sum_{n=0}^{\infty}\frac{t^n}{n!},-\infty<t<\infty \quad (7)$$

សន្មតបានថាយើងអាចជំនួស $t$ ដោយ $it$ ក្នុងសមីការ (7) នោះយើងបាន៖

$$e^{it}=\sum_{n=0}^{\infty}\frac{(it)^n}{n!}=\sum_{n=0}^{\infty}\frac{(-1)^n t^{2n}}{(2n)!}+i\sum_{n=1}^{\infty}\frac{(-1)^{n-1}t^{2n-1}}{(2n-1)!}\ , \qquad (8)$$

ចំពោះចំណុចដែលយើងបានបំបែកផលបូកទៅជាផ្នែកនិមិត្តនិងផ្នែកពិត។ ការបង្កើតការប្រើប្រាស់នៃភាពពិតដែល $i^2=-1,\ i^3=-i\ ,\ i^4=1$ ជាដើម។ ស៊េរីដំបូងក្នុងសមីការ (8) គឺយ៉ាងជាក់លាក់ស៊េរី *taylor* សម្រាប់ $\cos t$ បើ $t=0$ និងទី 2 ជាស៊េរី *taylor* សម្រាប់ $\sin t$ បើ $t=0$ ដូច្នេះយើងបាន:

$$e^{it}=\cos t+i\sin t \qquad (9)$$

$$e^{-it}=\cos t-i\sin t \qquad (10)$$

បន្ថែមពីនេះបើ $t$ ត្រូវបានជំនួសដោយ $\mu t$ ក្នុងសមីការ (9) នោះយើងទទួលបានសមីការទូទៅនៃរូបមន្ត *Euler* គឺ

$$e^{i\mu t}=\cos\mu t+i\sin\mu t \qquad (11)$$

បន្ទាប់ទៀត យើងចង់ពង្រីកនិយមន័យនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលទៅជានិទស្សន្តកុំផ្លិចនៃទម្រង់ $(\lambda+i\mu)t$ ។ នៅពេលដែលយើងចង់បានលក្ខណៈទូទៅនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលដែលមាននិទស្សន្តជាចំនួនកុំផ្លិច។ យើងត្រូវការ $e^{(\lambda+i\mu)t}$ ដើម្បីបំពេញ

$$e^{(\lambda+i\mu)t}=e^{\lambda t}e^{i\mu t} \qquad (12)$$

បន្ទាប់មកជំនួស $e^{i\mu t}$ ដោយ $e^{(\lambda+i\mu)t}$ ក្នុងសមីការ (11) យើងទទួលបាន

$$e^{(\lambda+i\mu)t}=e^{\lambda t}(\cos\mu t+i\sin\mu t)=e^{\lambda t}\cos\mu t+ie^{\lambda t}\sin\mu t \qquad (13)$$

ចម្លើយទូទៅ អនុគមន៍ $y_1(t)$ និង $y_2(t)$ ត្រូវបានផ្តល់ដោយសមីការ (5) ដែលអត្ថន័យបានបង្ហាញដោយសមីការ (13) ជាចម្លើយនៃសមីការ (1) នៅពេលដែលឫសនៃសមីការសម្គាល់ (2) ជាចំនួនកុំផ្លិច $\lambda\pm i\mu$ ។ ផ្ទុយទៅវិញចម្លើយ $y_1$ និង $y_2$ ជាអនុគមន៍តម្លៃកុំផ្លិចដែលជាទូទៅយើងគួរតែមានចម្លើយតម្លៃពិតបើអាចទៅរួច ពីព្រោះសមីការឌីផេរ៉ង់ស្យែលមានមេគុណពិត។ ចម្លើយផ្សេងទៀតអាចត្រូវបានរកឃើញជាការសន្និដ្ឋានមួយនៃទ្រឹស្តីបទ២.២.២ដែលបានបង្ហាញថាបើ $y_1$ និង $y_2$ ជាចម្លើយនៃសមីការ (1) នោះបន្សំលីនេអ៊ែរនៃ $y_1$ និង $y_2$ ក៏ជាចម្លើយមួយរបស់សមីការផងដែរ។ ជាពិសេស ចូរយើងបង្កើតផលបូកនិងផលដកនៃ $y_1$ និង $y_2$ ។

យើងមាន $y_1(t)+y_2(t)=e^{\lambda t}(\cos\mu t+i\sin\mu t)+e^{\lambda t}(\cos\mu t-i\sin\mu t)=2e^{\lambda t}\cos\mu t$

និង $y_1(t)-y_2(t)=e^{\lambda t}(\cos\mu t+i\sin\mu t)-e^{\lambda t}(\cos\mu t-i\sin\mu t)=2ie^{\lambda t}\sin\mu t$ ។ យើងអាចដកចេញមេគុណ 2 និង $2i$ រៀងគ្នា បន្ទាប់មកយើងសរសេរបានគូនៃចម្លើយតម្លៃពិត

$$u(t)=e^{\lambda t}\cos\mu t\ ,\ v(t)=e^{\lambda t}\sin\mu t \ (15)$$

សង្កេតថា $u$ និង $v$ ជាផ្នែកនិមិត្តនិងផ្នែកពិតរៀងគ្នានៃ $y_1$ ។ ការគណនាដោយផ្ទាល់អ្នកអាចបង្ហាញថា *Wronskian* នៃ $u$ និង $v$ គឺ

$$W(u,v)(t)=\mu e^{2\lambda t} \qquad (16)$$

**ចម្លើយទូទៅគឺ** $y=c_1e^{\lambda t}\cos\mu t+c_2e^{\lambda t}\sin\mu t$ (17)

ដែល $c_1$ និង $c_2$ ជាចំនួនថេរ។

**ឧទាហរណ៍ទី១៖** រកចម្លើយទូទៅនៃសមីការ $y''+y'+y=0$

ចម្លើយ

គេបានសមីការសម្គាល់គឺ $r^2+r+1=0$

នោះ $r=\dfrac{-1\pm(1-4)^{\frac{1}{2}}}{2}=-\dfrac{1}{2}\pm i\dfrac{\sqrt{3}}{2}$ នាំឲ្យ $\lambda=-\dfrac{1}{2}$ និង $\mu=\dfrac{\sqrt{3}}{2}$

ដូច្នេះ ចម្លើយទូទៅនៃសមីការ (18) គឺ $y=c_1e^{-\frac{t}{2}}\cos(\sqrt{3}t/2)+c_2e^{-\frac{t}{2}}\sin(\sqrt{3}t/2)$ ។




**រូបភាព** 3.4.1: ចម្លើយទូទៅនៃ $y''+y'+y=0$

**ឧទាហរណ៍ទី២៖** ស្វែងរកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល $y''+9y=0$

ចម្លើយ

សមីការសម្គាល់គឺ $r^2+9=0$

$r^2=-9$

$r=\pm\sqrt{-9}$

$r=\pm3i=0\pm3i$

នោះ $\lambda=0$ និង $\mu=3$

ដូច្នេះចម្លើយទូទៅគឺ $y=c_1\cos3t+c_2\sin3t$




**រូបភាព** 2.4.2 : ចម្លើយទូទៅនៃ $y''+9y=0$

**ឧទាហរណ៍ទី៣៖** រកចម្លើយប្រាកដនៃសមីការឌីផេរ៉ង់ស្យែលមានលក្ខខណ្ឌ

$16y''-8y'+145y=0$ , $y(0)=-2$ , $y'(0)=1$

ចម្លើយ

សមីការសម្គាល់គឺ $16r^2-8r+145=0$ ហើយឫសរបស់វាគឺ $r=\frac{1}{4}\pm 3i$ ។

ដូច្នេះចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលគឺ $y=c_1e^{\frac{t}{4}}\cos 3t+c_2e^{\frac{t}{4}}\sin 3t$

ដើម្បីដាក់លក្ខខណ្ឌដំបូងយើងឲ្យ យើងទទួល $y=-2e^{\frac{t}{4}}\cos 3t+\frac{1}{2}e^{\frac{t}{4}}\sin 3t$ (24) បានជាចម្លើយនៃសមីការមានលក្ខខណ្ឌ




**រូបភាព** 2.4.3: ចម្លើយទូទៅនៃ $16y''-8y'+145y=0$ , $y(0)=-2$ , $y'(0)=1$

## លំហាត់

ក្នុងលំហាត់នីមួយៗពី 1 ដល់ 6 ប្រើរូបមន្តរបស់ *Euler* ដើម្បីសរសេរកន្សោមដែលផ្ដល់ឲ្យក្នុងទម្រង់ $a+ib$ ។

1. $e^{1+2i}$ 2. $e^{2-3i}$

3. $e^{i\pi}$ 4. $e^{2-(\frac{\pi}{2})i}$

5. $2^{1-i}$ 6. $\pi^{-1+2i}$

ក្នុងលំហាត់នីមួយៗពី 7 ដល់ 16 ។ រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល

7. $y''-2y'+2y=0$
8. $y''-2y'+6y=0$
9. $y''+2y'-8y=0$
10. $y''+2y'+2y=0$
11. $y''+6y'+13y=0$
12. $4y''+9y=0$
13. $y''+2y'+1.25y=0$
14. $9y''+9y'-4y=0$
15. $y''+y'+1.25y=0$
16. $y''+4y'+6.25y=0$

ក្នុងលំហាត់នីមួយៗពី 17 ដល់ 22 ។ រកចម្លើយនៃសមីការដែលមានលក្ខខណ្ឌ។ គូសក្រាបនៃចម្លើយនិងពណ៌នាពីលក្ខណៈរបស់វាសម្រាប់ការកើនឡើង $t$ ។

17. $y''+4y=0$ , $y(0)=0,\ y'(0)=1$

18. $y''+4y'+5y=0$ , $y(0)=1,\ y'(0)=0$

19. $y''-2y'+5y=0$ , $y(\frac{\pi}{2})=0$ , $y'(\frac{\pi}{2})=2$

20. $y''+y=0,\ y(\frac{\pi}{3})=2$ , $y'(\frac{\pi}{3})=-4$

21. $y''+y'+1.25y=0$ , $y(0)=3$ , $y'(0)=1$

22. $y''+2y'+2y=0$ , $y(\frac{\pi}{4})=2,\ y'(\frac{\pi}{4})=-2$

23. គេមានសមីការមានលក្ខខណ្ឌ: $3u''-u'+2u=0$ , $u(0)=2$ , $u'(0)=0$

$a)$ រកចម្លើយ $u(t)$ នៃលំហាត់នេះ

$b)$ រកពេលដំបូងពេលដែល $|u(t)|=10$ ។

24. គេឱ្យសមីការមានលក្ខខណ្ឌ : $5u''+2u'+7u=0$ , $u(0)=2$ , $u'(0)=1$

$a)$ រកចម្លើយ $u(t)$ លំហាត់នេះ

$b)$ រក $T$ តូចបំផុតដែល $|u(t)|\le 0.1$ គ្រប់ $t>T$ ។

25. គេឱ្យសមីការមានលក្ខខណ្ឌ: $y''+2y'+6y=0$ , $y(0)=2$ , $y'(0)=\alpha\ge 2$

$a)$ រកចម្លើយ $y(t)$ នៃលំហាត់នេះ

$b)$ រក $\alpha$ ដើម្បីឱ្យ $y=0$ នៅពេល $t=1$ ។

$c)$ រកអនុគមន៍មួយនៃ $\alpha$ តម្លៃវិជ្ជមានតូចបំផុតនៃ $t$ ដែល $y=0$

$d)$ កំណត់លីមីតនៃកន្សោមដែលបានរកឃើញក្នុងផ្នែក $(c)$ ពេល $\alpha\to\infty$ ។

26. គេមានសមីការមានលក្ខខណ្ឌដូចខាងក្រោម៖

$y''+2ay'+(a^2+1)y=0$ , $y(0)=1$ , $y'(0)=0$

$a)$ រកចម្លើយ $y(t)$ នៃលំហាត់នេះ

$b)$ បើ $a=1$ រក $T$ តូចបំផុតពេលដែល $|y(t)|<0.1$ ដែល $t>T$

$c)$ ជួសក្នុងផ្នែក $(b)$ បើ $a=\frac{1}{4}$ , $\frac{1}{2}$ និង $2$

$d)$ ប្រើលទ្ធផលក្នុងផ្នែក $(b)$ និង $(c)$ ចូរប្រៀបធៀប $T$ និង $a$ ហើយពិពណ៌នាពីទំនាក់ទំនងរវាង $T$ និង $a$ ។

27. បង្ហាញថា $W(e^{\lambda t}\cos\mu t, e^{\lambda t}\sin\mu t)=\mu e^{2\lambda t}$ ។

28. ក្នុងលំហាត់នេះយើងនឹងធ្វើផលដកដេរីវេនៃរូបមន្តរបស់ $Euler$ ។

$a)$ បង្ហាញថា $y_1(t)=\cos t$ និង $y_2(t)=\sin t$ ជាសំណុំគ្រឹះនៃចម្លើយរបស់សមីការ $y''+y=0$ ហើយបង្ហាញថាវាជាចម្លើយនិង $Wronskian$ របស់វាមិនស្មើសូន្យនោះទេ។

$b)$ បង្ហាញថា $y=e^{it}$ ជាចម្លើយនៃសមីការ $y''+y=0$ នាំឲ្យ $e^{it}=c_1\cos t+c_2\sin t$ $(i)$ សម្រាប់ចំនួនពិត $c_1$ និង $c_2$ ។ ហេតុអ្វីដូច្នោះ ?

$c)$ បើ $t=0$ ក្នុងសមីការ $(i)$ ដើម្បីបង្ហាញថា $c_1=1$ ។

$d)$ សន្មតថាសមីការ (14) គឺពិតដោយបែងចែកសមីការ $(i)$ និងឲ្យ $t=0$ ដើម្បីសន្និដ្ឋានថា $c_2=i$ ។ ប្រើតម្លៃ $c_1$ និង $c_2$ ក្នុងសមីការ $(i)$ ឆ្ពោះទៅរករូបមន្តរបស់ $Euler$ ។

29. ប្រើរូបមន្ត $Euler$ បង្ហាញថា: $\cos t=(e^{it}+e^{-it})/2$ , $\sin t=(e^{it}-e^{-it})/2i$

30. បើ $e^{rt}$ ត្រូវបានផ្តល់ដោយសមីការ (13) បង្ហាញថា $e^{(r_1+r_2)t}=e^{r_1t}e^{r_2t}$ សម្រាប់ចំនួនកុំផ្លិច $r_1$ និង $r_2$ ។

31. បើ $e^{rt}$ ត្រូវបានផ្តល់ដោយសមីការ (13) បង្ហាញថា $\frac{d}{dt}e^{rt}=re^{rt}$ សម្រាប់ចំនួនកុំផ្លិច $r$ ។

32. តាងអនុគមន៍មានតម្លៃពិត $p$ និង $q$ ជាប់លើចន្លោះបើក $I$ និងតាង $y=\phi(t)=u(t)+iv(t)$ ជាចម្លើយមានតម្លៃជាកុំផ្លិចនៃសមីការ $y''+p(t)y'+q(t)y=0$ $(i)$ ដែល $u$ និង $v$ ជាអនុគមន៍មានតម្លៃពិត។ បង្ហាញថា $u$ និង $v$ ក៏ជាចម្លើយនៃសមីការ $(i)$ ។

គន្លឹះដំណោះស្រាយ៖ ជំនួស $y=\phi(t)$ ក្នុងសមីការ $(i)$ និងបែងចែកផ្នែកពិតនិងផ្នែកនិមិត្ត។

33. បើអនុគមន៍ $y_1$ និង $y_2$ ជាចម្លើយមិនអាស្រ័យលីនេអ៊ែរនៃសមីការ $y''+p(t)y'+q(t)y=0$ ។ បង្ហាញថារវាងសូន្យជាប់គ្នានៃ $y_1$ មានមួយនិងសូន្យតែមួយនៃ $y_2$ ។ សម្គាល់ថាលទ្ធផលនេះត្រូវបានបង្ហាញដោយចម្លើយ $y_1(t)=\cos t$ និង $y_2(t)=\sin t$ នៃសមីការ $y''+y=0$ ។

**បម្រែបម្រួលអថេរ**

គេមានសមីការឌីផេរ៉ង់ស្យែលជាមួយនឹងមេគុណអថេរ

$$y''+p(t)y'+q(t)y=0 \qquad (i)$$

អាចដាក់បានក្នុងទម្រង់សមស្របច្រើនសម្រាប់ការស្វែងរកចម្លើយដោយធ្វើឲ្យមានការប្តូរអថេរឯករាជ្យ និងឬក៏អថេរមិនឯករាជ្យ។ យើងបង្ហាញគំនិតទាំងនេះក្នុងលំហាត់ 34 ដល់ 42 ។ ជាពិសេសក្នុងដំណោះស្រាយលំហាត់ 34 យើងកំណត់លក្ខខណ្ឌដែលសមីការ $(i)$ អាចបម្លែងទៅជាសមីការឌីផេរ៉ង់ស្យែលមួយដែលមានមេគុណជាចំនួនថេរនិងដោយហេតុនេះវាមានភាពងាយស្រួលក្នុងការដោះស្រាយ។ លំហាត់ 35 ដល់ 42 ផ្តល់ការអនុវត្តនៃវិធីសាស្ត្រនេះ។

34. ក្នុងលំហាត់នេះយើងកំណត់លក្ខខណ្ឌនៅលើ $p$ និង $q$ ដូចដែលសមីការ $(i)$ អាចបម្លែងទៅជាសមីការមួយដែលមានមេគុណជាចំនួនថេរដោយផ្លាស់ប្តូរនៃអថេរឯករាជ្យ។ តាង $x=u(t)$ ជាអថេរឯករាជ្យថ្មីដែលទំនាក់ទំនងរវាង $x$ និង $t$ នឹងត្រូវបានបញ្ជាក់នៅពេលក្រោយ។

$a)$ បង្ហាញថា

$$\frac{dy}{dt}=\frac{dx}{dt}\frac{dy}{dx}\ ,\ \frac{d^2y}{dt^2}=\left(\frac{dx}{dt}\right)^2\frac{d^2y}{dx^2}+\frac{d^2x}{dt^2}\frac{dy}{dx}$$

$b)$ បង្ហាញថាសមីការឌីផេរ៉ង់ស្យែល $(i)$ មានទម្រង់

$$\left(\frac{dx}{dt}\right)^2\frac{d^2y}{dx^2}+\left(\frac{d^2x}{dt^2}+p(t)\frac{dx}{dt}\right)\frac{dy}{dx}+q(t)y=0 \qquad (ii)$$

$c)$ ក្នុងលំដាប់សម្រាប់សមីការ $(ii)$ មានមេគុណជាចំនួនថេរ មេគុណនៃ $\frac{d^2y}{dx^2}$ ហើយត្រូវតែសមាមាត្រ។ បើ $q(t)>0$ នោះយើងអាចជ្រើសរើសយកចំនួនពិតនៃសមាមាត្រទៅនឹង $1$ ដូច្នេះ

$$x=u(t)=\int [q(t)]^{\frac{1}{2}}dt \qquad (iii)$$

$d)$ តម្លៃ $x$ ដែលបានជ្រើសរើសក្នុងផ្នែក $(c)$ បង្ហាញថាមេគុណនៃ $\frac{dy}{dx}$ ក្នុងសមីការ $(ii)$ ក៏ជាចំនួនថេរ ដែលបានផ្តល់ជាកន្សោមៈ

$$\frac{q'(t)+2p(t)q(t)}{2[q(t)]^{\frac{3}{2}}} \qquad (iv)$$

ជាចំនួនថេរមួយ។ ដូច្នេះសមីការ $(i)$ អាចបម្លែងទៅជាសមីការមួយដែលមានមេគុណជាចំនួនថេរដោយផ្លាស់ប្តូរអថេរឯករាជ្យដែលផ្តល់ថាអនុគមន៍ៈ $(q'+2pq)/q^{\frac{3}{2}}$ ជាចំនួនថេរមួយ។

តើលទ្ធផលនេះត្រូវកែប្រែយ៉ាងដូចម្តេចបើ $q(t)<0$ ?

ក្នុងលំហាត់នីមួយៗ 35 ដល់ 37 បម្លែងសមីការដែលផ្តល់ឲ្យទៅជាសមីការមួយដែលមានមេគុណជាចំនួនថេរដោយវិធីសាស្ត្រនៃលំហាត់ទី 34។ បើវាអាចទៅរួច រកចម្លើយទូទៅនៃសមីការដែលគេឲ្យ:

35. $y''+y'+e^{-t^2}y=0 \quad -\infty<t<\infty$

36. $y''+3ty'+t^2y=0 \quad -\infty<t<\infty$

37. $ty''+(t^2-1)y'+t^3y=0 \quad 0<t<\infty$

**សមីការ Euler :**

38 គេមានសមីការមួយនៃទម្រង់ $t^2y''+\alpha ty'+\beta y=0$ , $t>0$ ដែល $\alpha,\beta$ ជាចំនួនថេរត្រូវបានគេហៅថាសមីការ *Euler* ។ បង្ហាញថាការជំនួស $x=\ln t$ បម្លែងសមីការ *Euler* មួយទៅជាសមីការដែលមានមេគុណថេរមួយ។ សមីការ *Euler* ត្រូវបានគេសិក្សាស៊ីជម្រៅក្នុងផ្នែកបន្ត។

ក្នុងលំហាត់នីមួយៗពី 39 ដល់ 42 ។ប្រើលទ្ធផលនៃលំហាត់ 38 ដើម្បីដោះស្រាយសមីការដែលឱ្យសម្រាប់ $t>0$ ។

39. $t^2y''+ty'+y=0$

40. $t^2y''+4ty'+2y=0$

41. $t^2y''+3ty'+1.25y=0$

42. $t^2y''-4ty'-6y=0$

## ៣.៥ ឫសឌុប និង ការបន្ថយលំដាប់

ក្នុងផ្នែកដំបូង យើងបង្ហាញពីរបៀបដោះស្រាយនៃសមីការ

$$ay''+by'+cy=0 \qquad (1)$$

នៅពេលឫសនៃសមីការសម្គាល់

$$ar^2+br+c=0 \qquad (2)$$

អាចជាចំនួនពិតខុសគ្នា ឬជាចំនួនកុំផ្លិចឆ្លាស់ ។ ឥឡូវយើងគិតករណីទីបីដែលអាចទៅរួច ពេលគឺថាឫសទាំងពីរ $r_1$ និង $r_2$ គឺស្មើគ្នា ។ ករណីនេះអាចកើតឡើង ពេលឌីគ្រីមីណង់ $b^2-4ac=0$ ហើយវាធ្វើតាមរូបមន្តកាដ្រាទីក

$$r_1=r_2=\frac{-b}{2a} \qquad (3)$$

ឫសទាំងពីរផ្តល់ចម្លើយដូចគ្នា

$$y_1(t)=e^{-bt/2a} \qquad (4)$$

នៃសមីការឌីផេរ៉ង់ស្យែល (1) ហើយវា អាចរកចម្លើយទីពីរបាន $y_2=y_1\int\frac{e^{-\int Pdx}}{y_1^2}dx$

$y_2(t)=te^{-bt/2a}$ ។

**ឧទាហរណ៍ទី១៖** ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

$$y''+4y'+4y=0 \qquad (5)$$

សមីការសម្គាល់

$$r^2+4r+4=(r+2)^2=0$$

ដូចនេះ $r_1=r_2=-2$ ។ ដូច្នេះចម្លើយមួយនៃសមីការ $(5)$ គឺ $y_1(t)=e^{-2t}$ ។ ដើម្បីរកចម្លើយទូទៅនៃសមីការ $(5)$ យើងត្រូវរកចម្លើយលើកទីពីរដែលមិនមែនជាពហុគុណនៃ $y_1$ ។ ចម្លើយទីពីរអាចរកបានតាមដោះស្រាយជំនួស $y=v(t)y_1(t)$ ក្នុងសមីការ $(1)$ ហើយប្រើចម្លើយសមីការដើម្បីរក $v(t)$ ដោយចាប់ផ្តើម

$$y=v(t)y_1(t)=v(t)e^{-2t} \qquad (6)$$

យើងមាន

$$y'=v'(t)e^{-2t}-2v(t)e^{-2t} \qquad (7)$$

និង

$$y''=v''(t)e^{-2t}-4v'(t)e^{-2t}+4v(t)e^{-2t} \qquad (8)$$

ដោយជំនួសកន្សោម $(6)$,$(7)$& $(8)$ ក្នុងសមីការ $(5)$ យើងទទួលបាន

$$\left[v''(t)-4v'(t)+4v'(t)-8v(t)+4v(t)\right]e^{-2t}=0$$

ដែលផ្ទៀងផ្ទាត់បាន

$$v''(t)=0 \qquad (9)$$

ដូច្នេះ $v'(t)=c_1$

និង $v(t)=c_1t+c_2$ (10)

ដែល $c_1 \& c_2$ ជាចំនួនថេរណាមួយ ។ ចុងក្រោយ ជំនួស $v(t)$ ក្នុងសមីការ $(6)$ យើងមាន

$$y=c_1te^{-2t}+c_2e^{-2t} \qquad (11)$$

ក្នុងផ្នែកទីពីរ នៅខាងស្តាំនៃសមីការ (11) ដែលចម្លើយត្រូវគ្នានឹង $y_1(t)=\exp(-2t)$ ប៉ុន្តែចម្លើយទីមួយកើតឡើងពីចម្លើយទីពីរ ពោលគឺ $y_2(t)=t\exp(-2t)$ ។ ចម្លើយទាំងពីរជាក់ស្តែងគឺមិនសមាមាត្រ ប៉ុន្តែយើងអាចផ្ទៀងផ្ទាត់ថាចម្លើយទាំងពីរជាលីនេអ៊ែរមិនអាស្រ័យ ដោយគណនាតាម Wronskian

$$W(y_1,y_2)(t)=\begin{vmatrix} e^{-2t} & te^{-2t} \\ -2e^{-2t} & (1-2t)e^{-2t} \end{vmatrix}=e^{-4t}-2te^{-4t}+2te^{-4t}=e^{-4t}\neq 0$$

ដូច្នេះ $y_1(t)=e^{-2t}$ , $y_2(t)=te^{-t}$ (12)

ទម្រង់បង្កើតជាសំណុំនៃចម្លើយគ្រឹះនៃសមីការ $(5)$ ហើយចម្លើយទូទៅនៃសមីការផ្តល់ដោយ សមីការ $(11)$ ។ ចំណាំថា $y_1(t)$ និង $y_2(t)$ ទាំងពីរខិតជិតសូន្យ កាលណា $t\to\infty$ ជាលទ្ធផលគ្រប់ចម្លើយទាំងអស់នៃសមីការ $(5)$ មានក្នុងវិធីធ្វើនេះ។ ក្រាបនៃចម្លើយគឺបង្ហាញក្នុងរូប 2.5.1




រូបភាព 2.5.1

## ៣.៥.១ វិធីសាស្រ្តដោះស្រាយទូទៅ

វិធីដែលប្រើក្នុងឧទាហរណ៍១ អាចត្រូវបានប្រើក្នុងចម្លើយទូទៅដែលមានសមីការសម្គាល់មានឫសឌុប ។ នេះយើងអាចសន្មតថា មេគុណក្នុងសមីការ $(1)$ ផ្ទៀងផ្ទាត់ $b^2-4ac=0$ ក្នុងករណីដែល

$$y_1(t)=e^{-bt/2a}$$

គឺជាចម្លើយមួយ ។ បន្ទាប់មកយើងសន្មតថា

$$y=v(t)y_1(t)=v(t)e^{-bt/2a} \qquad (13)$$

និងជំនួសក្នុងសមីការ $(1)$ ដើម្បីកំណត់ $v(t)$ ។ យើងមាន

$$y'=v'(t)e^{-bt/2a}-\frac{b}{2a}v(t)e^{-bt/2a} \qquad (14)$$

និង

$$y''=v''(t)e^{-bt/2a}-\frac{b}{a}v'(t)e^{-bt/2a}+\frac{b^2}{4a^2}v(t)e^{-bt/2a} \qquad (15)$$

បន្ទាប់មក ជំនួសក្នុងសមីការ $(1)$ ។ យើងមាន

$$\left\{a\left[v''(t)-\frac{b}{a}v'(t)+\frac{b^2}{4a^2}v(t)\right]+b\left[v'(t)-\frac{b}{2a}v(t)\right]+cv(t)\right\}e^{-bt/2a}=0 \qquad (16)$$

លុបចោលកត្តា $e^{-bt/2a}$ ដែលមិនសូន្យ ហើយយើងទទួលបាន

$$av''(t)+(-b+b)v'(t)+\left(\frac{b^2}{4a}-\frac{b^2}{2a}+c\right)v(t)=0 \qquad (17)$$

តួទាក់ទង $v'(t)$ គឺច្បាស់ជាសូន្យ ។ ម្យ៉ាងទៀត មេគុណនៃ $v(t)$ គឺ $c-(b^2/4a)$ គឺសូន្យផងដែរ ព្រោះ $b^2-4ac=0$ ក្នុងលំហាត់ដែលយើងដោះស្រាយ ។ នោះគ្រាន់តែជា**ឧទាហរណ៍១**សមីការ $(17)$ ទទួលបាន

$$v''(t)=0$$

ដូច្នេះ $\qquad v(t)=c_1t+c_2$

តាមសមីការ $(13)$ យើងមាន

$$y=c_1te^{-bt/2a}+c_2e^{-bt/2a} \qquad (18)$$

នោះ $y$ គឺជាលីនេអ៊ែរបន្សំនៃពីរចម្លើយ

$$y_1(t)=e^{-bt/2a} \quad , \quad y_2(t)=te^{-bt/2a} \qquad (19)$$

Wronskian នៃពីរចម្លើយនេះគឺ

$$W(y_1,y_2)(t)=\begin{vmatrix} e^{-bt/2a} & te^{-bt/2a} \\ -\frac{b}{2a}e^{-bt/2a} & \left(1-\frac{bt}{2a}\right)e^{-bt/2a}\end{vmatrix}=e^{-bt/a} \qquad (20)$$

តាម $W(y_1,y_2)(t)$ គឺមិនសូន្យ ចម្លើយ $y_1$ និង $y_2$ ផ្តល់ដោយសមីការ $(19)$ គឺជាសំណុំចម្លើយគ្រឹះ ។ ម្យ៉ាងវិញទៀត សមីការ $(18)$ គឺជាចម្លើយទូទៅនៃសមីការ $(1)$ ពេលឫសនៃសមីការសម្គាល់គឺស្មើគ្នា។

**ឧទាហរណ៍ទី២៖** រកចម្លើយនៃតម្លៃដំបូង ដែលផ្តល់ឱ្យក្នុងលំហាត់

$$y''-y'+0.25y=0, \quad y(0)=2, \quad y'(0)=\frac{1}{3} \qquad (21)$$

សមីការសម្គាល់ $\qquad r^2-r+0.25=0$

ដូចនេះឫសគឺ $r_1=r_2=1/2$ ។ នោះចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលគឺ

$$y=c_1e^{t/2}+c_2e^{t/2} \qquad (22)$$

លក្ខខណ្ឌតម្លៃដំបូងគឺ

$$y(0)=c_1=2$$

លក្ខខណ្ឌទីពីរ ដំបូងយើងឌីផេរ៉ង់ស្យែលសមីការ $(22)$ ហើយបន្ទាប់មកកំណត់ $t=0$

នេះបាន $\qquad y'(0)=\frac{1}{2}c_1+c_2=\frac{1}{3}$

ដូចនេះ $c_2=-2/3$ ។ នោះ ចម្លើយនៃតម្លៃដំបូងនៃលំហាត់គឺ $\qquad y=2e^{t/2}-\frac{2}{3}te^{t/2} \qquad (23)$

ក្រាបនៃចម្លើយបង្ហាញក្នុងរូបភាព 2.5.2




រូបភាព 2.5.2

**សង្ខេបខ្លឹមសារ**

យើងអាចសង្ខេបលទ្ធផលដែលយើងមានសម្រាប់សមីការលីនេអ៊ែរអូម៉ូសែនលំដាប់ពីរដែលមានមេគុណជាចំនួនថេរ $ay'' + by' + cy = 0$ (1)

តាង $r_1, r_2$ ជាឫសនៃសមីការសម្គាល់ពហុធា

$$ar^2 + br + cy = 0 \qquad (2)$$

បើ $r_1, r_2$ ជាចំនួនពិតប៉ុន្តែមិនស្មើគ្នា នោះចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល $(1)$ គឺ

$$y = c_1e^{r_1t} + c_2e^{r_2t} \qquad (24)$$

បើ $r_1, r_2$ ជាចំនួនកុំផ្លិចឆ្លាស់ $\lambda \pm i\mu$ នោះចម្លើយទូទៅគឺ

$$y = c_1e^{\lambda t}\cos\mu t + c_2e^{\lambda t}\sin\mu t \qquad (25)$$

បើ $r_1 = r_2$ នោះចម្លើយទូទៅគឺ

$$y = c_1e^{r_1t} + c_2te^{r_1t} \qquad (26)$$

## ៣.៥.២ បន្ថយលំដាប់

វិធីប្រើពីមុន នៅក្នុងផ្នែកសម្រាប់សមីការមានមេគុណថេរ គឺជាវិធីធម្មតា ។ សន្មតថាយើងដឹងចម្លើយមួយ $y_1(y)$ ដែលមិនសូន្យនៃ

$$y'' + p(t)y' + q(t)y = 0 \qquad (27)$$

ដើម្បីរកចម្លើយទីពីរ តាង

$$y = v(t)y_1(t); \qquad (28)$$

នោះ

$$y' = v'(t)y_1(t) + v(t)y_1'(t)$$

និង

$$y'' = v''(t)y_1t + 2v'(t)y_1'(t) + v(t)y_1''(t)$$

ជំនួស $y, y', y''$ ក្នុងសមីការ $(27)$ មេគុណនៃ ក្នុងសមីការ គឺសូន្យ ដូចនេះសមីការទទួលបាន

$$y_1v'' + (2y_1' + py_1)v' + (y_1'' + py_1' + qy_1)v = 0 \qquad (29)$$

ដែល $y_1$ ជាចម្លើយមួយនៃសមីការ $(27)$ មេគុណនៃ $v$ ក្នុងសមីការ $(29)$ គឺសូន្យ ដូចនេះសមីការ $(29)$ ក្លាយជា

$$y_1v'' + (2y_1' + py_1)v' = 0 \qquad (30)$$

ផ្ទុយពីការបង្ហាញ សមីការ $(30)$ គឺពិតជាសមីការលំដាប់មួយ សម្រាប់អនុគមន៍ $v'$ ហើយអាចដោះស្រាយបានទាំងសមីការលីនេអ៊ែរតាមលំដាប់ ឬសមីការញែកចេញ ។ មួយទៀត $v'$ ត្រូវបានរកឃើញ ហើយ $v$ គឺមានដោយការធ្វើអាំងតេក្រាល ។ ចុងក្រោយ $y$ គឺកំណត់ដោយសមីការ $(28)$ ។ វិធិនេះគឺហៅថាវិធីនៃការបង្រួមលំដាប់ ព្រោះជំហានសំខាន់គឺ ចម្លើយនៃសមីការឌីផេរ៉ង់ស្យែលលំដាប់មួយសម្រាប់ $v'$ ជាជាងសមីការដើមលំដាប់ពីរសម្រាប់ $y$ ។ ទោះបីជាយ៉ាងណា វាអាចទៅរួចក្នុងការសរសេរទម្រង់សម្រាប់ $v(t)$ យើងនឹងជំនួសដោយបង្ហាញពីរបៀបដែលវិធិដោះស្រាយដោយឧទាហរណ៍។

**ឧទាហរណ៍ទី៣** ដោយថា $y_1(t) = t^{-1}$ គឺជាចម្លើយមួយនៃ

$$2t^2y'' + 3ty' - y = 0, \qquad t > 0 \qquad (31)$$

ចូររកចម្លើយមិនអាស្រ័យលីនេអ៊ែរទីពីរ

យើងកំណត់ $y = v(t)t^{-1}$ នោះ

$$y' = v't^{-1} - vt^{-2}, \qquad y'' = v''t^{-1} - 2v't^{-2} + 2vt^{-3}$$

ជំនួស $y, y'$ & $y''$ ក្នុងសមីការ $(31)$ ហើយផ្តុំតួ យើងបាន

$$2t^2\left(v''t^{-1} - 2v't^{-2} + 2vt^{-3}\right) + 3t\left(v't^{-1} - vt^{-2}\right) - vt^{-1}$$

$$= 2tv'' + (-4+3)v' + \left(4t^{-1} - 3t^{-1} - t^{-1}\right)v$$

$$= 2tv'' - v' = 0 \qquad (32)$$

ចំណាំថា មេគុណនៃ $v$ គឺសូន្យ វាអាចទៅរួច នេះផ្តល់នូវការពិនិត្យដ៏មានប្រយោជន៍លើពីជគណិតរបស់អ្នក។

ញែកចេញពីអថេរក្នុងសមីការ $(32)$ និងរក $v'(t)$ យើងឃើញថា

$$v'(t) = ct^{1/2}$$

នោះ $$v(t) = \frac{2}{3}ct^{3/2} + k$$

យើងបាន $y=\frac{2}{3}ct^{1/2}+kt^{-1}$ (33)

ដែល $c,k$ ជាចំនួនថេរណាមួយ ។ ហើយផ្នែកទីពីរ នៅខាងស្តាំនៃសមីការ (33) គឺជាពហុគុណនៃ $y_1(t)$ ហើយអាចធ្លាក់ចុះ ប៉ុន្តែតួដំបូងផ្តល់ចម្លើយមិនអាស្រ័យថ្មីមួយ ។ ការជ្រើសប្រហែសគុណនឹងចំនួនថេរ យើងមាន $y_2(t)=t^{1/2}$

## លំហាត់

នៅក្នុងលំហាត់ 1 ដល់ 12 ចូររកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលដែលផ្តល់ឱ្យ និងមានសុពលភាពក្នុងចន្លោះពេលណាមួយ មិនរាប់បញ្ចូលចំណុចឯកតា

1. $y''-2y'+y=0$
2. $y''+6y'+y=0$
3. $4y''-4y'-3y=0$
4. $4y''+12y'+9y=0$
5. $y''-2y'+10y=0$
6. $y''-6y'+9y=0$
7. $4y''+17y'+4y=0$
8. $16y''+24y'+9y=0$
9. $25y''-20y'+4y=0$
10. $2y''+2y'+y=0$

ក្នុងលំហាត់ 11ដល់14 ចូរដោះស្រាយលំហាត់ចំពោះតម្លៃដំបូងដែលផ្តល់ឱ្យ។ គូរក្រាបនៃចម្លើយ និងពណ៌នាពេល $t$ កើន

11. $9y''-12y'+4y=0,\quad y(0)=2,\quad y'(0)=-1$
12. $y''-6y'+9y=0,\quad y(0)=0,\quad y'(0)=2$
13. $9y''+6y'+82y=0,\quad y(0)=-1,\quad y'(0)=2$
14. $y''+4y'+4y=0,\quad y(-1)=2,\quad y'(-1)=1$
15. គិតពីតម្លៃដំបូងនៃលំហាត់

$$4y''+12y'+9y=0,\quad y(0)=1,\quad y'(0)=-4$$

ចូរដោះស្រាយតម្លៃដំបូងលំហាត់ និងដៅចំណុចរបស់វាចំពោះ $0\le t\le 5$

B...កំណត់ទីតាំងនៃចម្លើយមានតម្លៃសូន្យ

កំណត់កូអរដោនេ $(t_0,y_o)$ នៃចំណុចអប្បបរមា

ប្តូរតម្លៃលក្ខខណ្ឌទីពីរនៃ $y'(0)=b$ ហើយរកចម្លើយនៃអនុគមន៍ $b$ ។ បន្ទាប់មករកតម្លៃសំខាន់នៃ $b$ ដែលញែកចម្លើយតែងតែវិជ្ជមានដល់អវិជ្ជមាន។

16. គិតពីការប្រែប្រួលខាងក្រោម នៃតម្លៃលំហាត់ ក្នុងឧទាហរណ៍ 2

$$y''-y'+0.25y=0,\quad y(0)=2,\quad y'(0)=b$$

រកចម្លើយនៃអនុគមន៍ និងកំណត់តម្លៃសំខាន់នៃ ដែលញែកចម្លើយពីវិជ្ជមានដល់អវិជ្ជមាន ។

17. គិតពីតម្លៃដំបូងនៃលំហាត់

$$4y''+4y'+y=0,\quad y(0)=1,\quad y'(0)=b$$

ដោះស្រាយតម្លៃដំបូងលំហាត់ និងដៅចម្លើយ

កំណត់កូអរដោនេ $(t_0, y_o)$ នៃចំណុចអតិបរមា

a) ប្តូរលក្ខខណ្ឌដំបូងទីពីរ $y'(0)=b>0$ ហើយរកចម្លើយនៃអនុគមន៍ $b$

b) រកកូអរដោនេ $(t_M, y_M)$ នៃចំណុចអតិបរមាក្នុងតួនៃ $b$ ។ ពិពណ៌នាចំណុចអាស្រ័យ $t_M$ និង $y_M$ លើ $b$ កាលណា $b$ កើន ។

18. គិតពីតម្លៃដំបូងនៃលំហាត់

$$9y''+12y'+4y=0, \quad y(0)=a>0, \quad y'(0)=-1$$

ដោះស្រាយតម្លៃដំបូងលំហាត់

ចូររកតម្លៃសំខាន់នៃ $a$ ដែលញែកចម្លើយពីអវិជ្ជមាន ទៅវិជ្ជមាន

19. បើឫសនៃសមីការសម្គាល់ជាចំនួនពិត បង្ហាញថាចម្លើយនៃ $ay''+by'+cy=0$ អាចយកតម្លៃសូន្យបានច្រើនបំផុតតែម្តង ។

លំហាត់ 20 ដល់ 22 បង្ហាញពីវិធីផ្សេងៗនៃការរកចម្លើយទីពីរ នៅពេលសមីការសម្គាល់មាន ឫសឌុប

20. គិតពីសមីការ $y''+2ay'+a^2y=0$ ។ បង្ហាញថាឫសនៃសមីការសម្គាល់គឺ $r_1=r_2=-a$ ដូចនេះចម្លើយមួយនៃសមីការគឺ $e^{-at}$

ប្រើរូបមន្តAbel ចូរបង្ហាញថា Wronskian នៃចម្លើយពីរនៃសមីការផ្តល់ឱ្យគឺ

$W(t)=y_1(t)y_2'(t)-y_1'(t)y_2(t)=c_1e^{-2at}$ ដែល $c_1$ ជាចំនួនថេរ។

តាង $y_1(t)=e^{-at}$ និងចម្លើយនៃផ្នែក $(b)$ បង្ហាញថាចម្លើយពីរគឺ $y_2(t)=te^{-at}$

21. ឧបមាថា $r_1$ និង $r_2$ ជាឫសនៃ $ar^2+br+c=0$ និង $r_1\neq r_2$ ហើយ $e^{r_1t}$ និង $e^{r_2t}$ ជាចម្លើយសមីការឌីផេរ៉ង់ស្យែល $ay''+by'+cy=0$ ។ បង្ហាញថា $\phi(t;r_1,r_2)=\left[\exp(r_2t)-ext(r_1t)\right]/(r_2-r_1)$ ជាចម្លើយនៃសមីការផងដែរ ចំពោះ $r_1\neq r_2$ ។ បន្ទាប់មកគិតចំពោះ $r_1$ គឺជាចំណុចនឹង និងប្រើច្បាប់ L'Hospital ដើម្បីកំណត់ $\phi(t;r_1,r_2)$ កាលណា $r_2\to r_1$ ដោយមានចម្លើយទីពីរក្នុងករណីឫសស្មើគ្នា ។

22.

បើ $ar_2+br+c=0$ មានឫសស្មើ $r_1$ បង្ហាញថា

$$L\left[e^{rt}\right]=a\left(e^{rt}\right)''+b\left(e^{rt}\right)'+ce^{rt}=a(r-r_1)^2e^{rt} \qquad (i)$$

នៅផ្នែកខាងស្តាំនៃសមីការ $(i)$ គឺសូន្យ ពេល $r=r_1$ គឺថា $\exp(r_1t)$ ជាចម្លើយនៃ $L[y]=ay''+by'+cy=0$

សមីការឌីផេរ៉ង់ស្យែល $(i)$ ដែលតម្លៃ $r$ ហើយផ្លាស់ប្តូរឌីផេរ៉ង់ស្យែលជាមួយតម្លៃ $r$ នឹងតម្លៃ $r_1$ ដូចនេះបង្ហាញថា

$$\frac{\partial}{\partial r}L\left[e^{rt}\right]=L\left[\frac{\partial}{\partial r}e^{rt}\right]=L\left[e^{rt}\right]=ate^{rt}\left(r-r_1\right)^2+2ae^{rt}\left(r-r_1\right) \qquad (ii)$$

ដែលផ្នែកខាងស្តាំនៃសមីការ $(ii)$ គឺសូន្យ ពេល $r=r_1$ រួមបញ្ចូលទាំង $\exp(r_1t)$ ជាចម្លើយមួយផងដែរនៃ $L[y]=0$

ក្នុងលំហាត់ 23 ដល់ 30 ប្រើវិធីសាស្រ្តការបង្រួមនៃលំដាប់ ដើម្បីរកចម្លើយទីពីរដែលផ្តល់ដោយសមីការឌីផេរ៉ង់ស្យែល

23. $t^2y''-4ty'+6y=0, \quad t>0; \quad y_1(t)=t^2$
24. $t^2y''+2ty'-2y=0, \quad t>0; \quad y_1(t)=t$
25. $t^2y''+3ty'+y=0, \quad t>0; \quad y_1(t)=t^{-1}$
26. $t^2y''-t(t+2)y'+(t+2)y=0, \quad t>0; \quad y_1(t)=t$
27. $xy''-y'+4x^3y=0, \quad x>0; \quad y_1(x)=\sin x^2$
28. $(x-1)y''-xy'+y=0, \quad x>1; \quad y_1(x)=e^x$
29. $x^2y''-(x-0.1875)y=0, \quad x>0; \quad y_1(x)=x^{1/4}e^{2\sqrt{x}}$
30. $x^2y''+xy'+\left(x^2-0.25\right)y=0, \quad x>0; \quad y_1(x)=x^{-1/2}\sin x$
31. សមីការឌីផេរ៉ង់ស្យែល $xy''-(x+N)y'+Ny=0$

ដែល $N$ ជាអាំងតេក្រាលមិនអវិជ្ជមាន ដែលបានពិភាក្សាដោយអ្នកនិពន្ធជាច្រើន។ ហេតុផលមួយទៀត វាគឺគួរឱ្យចាប់អារម្មណ៍ដែលថា ចម្លើយអិចស្ប៉ូណង់ស្យែល និងចម្លើយជាពហុធា ។

a) ផ្ទៀងផ្ទាត់ចម្លើយមួយគឺ $y_1(x)=e^x$

b) បង្ហាញថាចម្លើយទីពីរមានទម្រង់ $y_2(x)=ce^x\int x^Ne^{-x}dx$ ។ គណនា $y_2(x)$ ចំពោះ $N=1$ និង $N=2$ ដែល $c=-1/N!$

$$y_2(x)=1+\frac{x}{x!}+\frac{x^2}{2!}+...+\frac{x^N}{N!}$$

ចំណាំថា $y_2(x)$ ជាតួដំបូង $N+1$ ក្នុង $x=0$ ចំពោះស៊េរីតៃល័រ $e^x$ គឺចំពោះ $y_1(x)$

32. សមីការឌីផេរ៉ង់ស្យែល

$$y''+\delta\left(x'y+y\right)=0$$

ផ្ទៀងផ្ទាត់ $y_1(x)=\exp\left(-\delta x^2/2\right)$ ជាចម្លើយមួយ និងរកចម្លើយទូទៅក្នុងទម្រង់នៃអាំងតេក្រាល

33. វិធីសាស្រ្តលំហាត់20 អាចបញ្ចូលសមីការលំដាប់ពីរ ជាមួយមេគុណអថេរ។ បើ $y_1$

ជាចម្លើយមិនមែនជាចម្លើយនៃ $y''+p(t)y'+q(t)y=0$ បង្ហាញថាចម្លើយទីពីរ $y_2$ ផ្ទៀងផ្ទាត់

$(y_2/y_1)'=W(y_1,y_2)/y_1^2$ ដែល $W(y_1,y_2)$ ជា Wronskian នៃ $y_1$ និង $y_2$ ។ បន្ទាប់មកប្រើទម្រង់ Abel សមីការ(8)ផ្នែក3.3 កំណត់ $y_2$

ក្នុងលំហាត់ 34ដល់37 ប្រើវិធីសាស្ត្រនៃលំហាត់ កំណត់ចម្លើយមិនអាស្រ័យដែលផ្តល់ដោយសមីការ

34. $t^2y''+3ty'+y=0,\quad t>0;\quad y_1(t)=t^{-1}$

35. $ty''-y'+4t^3y=0,\quad t>0;\quad y_1(t)=\sin(t^2)$

## ៣.៦. សមីការមិនអូម៉ូសែននិង វិធីសាស្ត្រនៃមេគុណមិនកំណត់

បើយើងត្រឡប់ទៅមើលសមីការមិនអូម៉ូហ្សែន

$$L[y]=y''+p(t)y'+q(t)y=g(t) \qquad (1)$$

ដែល $p,q$ និង $g$ ត្រូវបានអោយអនុគមន៍នៅលើចន្លោះបើក $I$ ។ សមីការ

$$L[y]=y''+p(t)y'+q(t)y=0, \qquad (2)$$

ដែល $g(t)=0$ ហើយ $p$ និង $q$ គឺដូចនៅក្នុងសមីការ (1) ហៅថា សមីការអូម៉ូសែនត្រូវគ្នានឹងសមីការ (1) ។ លទ្ធផលពីរខាងក្រោម បកស្រាយពីរចនាសម្ព័ន្ធនៃដំណោះស្រាយនៃសមីការមិនអូម៉ូសែន (1) ហើយផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតដំណោះស្រាយទូទៅ។

ទ្រឹស្តីបទ2.6.1៖ បើ $Y_1$ និង $Y_2$ គឺជាចម្លើយពីរនៃសមីការមិនអូម៉ូហ្សែន (1) នោះភាពខុសគ្នារវាង $Y_1-Y_2$ គឺជាដំណោះស្រាយនៃសមីការមិនអូម៉ូសែនត្រូវគ្នា (2) ។ លើសពីនេះផលបូក បើ $Y_1$ និង $Y_2$ គឺជាសំណុំចម្លើយគ្រឹះនៃសមីការ (2) នោះ

$$Y_1(t)-Y_2(t)=c_1y_1(t)+c_2y_2(t), \qquad (3)$$

ដែល $c_1$ និង $c_1$ គឺជាចំនួនថេរ។

ដើម្បីបញ្ជាក់លទ្ធផលនេះ សូមកត់សម្គាល់ថា $Y$ និង $Y_2$ បំពេញសមីការ

$$L[Y_1](t)=g(t),\qquad L[Y_2](t)=g(t) \qquad (4)$$

ដកសមីការទីពីរនៃសមីការនេះចេញពីទី១ យើងបាន

$$L[Y_1](t)-L[Y_2](t)=g(t)-g(t)=0 \qquad (5)$$

ទោះជាយ៉ាងណាក៏ដោយ

$$L[Y_1]-L[Y_2]=L[Y_1-Y_2],$$

ដូចនេះ សមីការ (5) ទៅជា $L[Y_1-Y_2](t)=0, \qquad (6)$

សមីការ (6) បញ្ជាក់ថា $Y_1 - Y_2$ គឺជាដំណោះស្រាយនៃសមីការ (2) ។ ជាចុងក្រោយ ដំណោះស្រាយទាំងអស់នៃសមីការ (2) អាចបង្ហាញជាបន្សំលីនេអ៊ែរនៃសំណុំមូលដ្ឋាននៃដំណោះស្រាយតាមទ្រឹស្តី 2.2.4, តាមដំណោះស្រាយ $Y_1 - Y_2$ អាចមានកស្តុតាងពេញលេញ។ ដូចនេះ សមីការ (3) គឺត្រូវបានដោះស្រាយ។

**ទ្រឹស្តីបទ2.6.2** ចម្លើយទូទៅនៃសមីការមិនអូម៉ូសែន (1) អាចសរសេរជាទម្រង់

$$y = \phi(t) = c_1 y_1(t) + c_2 y_2(t) + Y(t) \qquad (7)$$

ដែល $y_1$ និង $y_2$ គឺជាសំណុំគ្រឹះនៃសមីការអូម៉ូសែនត្រួតស៊ីគ្នា (2) $c_1$ និង $c_2$ គឺជាចំនួនថេរណាមួយ ហើយ $Y$ គឺជាចម្លើយពិសេសនៃសមីការមិនអូម៉ូសែន (1) ។

សម្រាយបញ្ជាក់ទ្រឹស្តីបទ

កត់សម្គាល់ថា សមីការ (3) រក្សាទុកប្រសិនបើយើងកំណត់ $Y$ ជាមួយនឹងដំណោះស្រាយនៃចំនួនថេរ $\phi$ នៃសមីការ (1) ហើយ $y_2$ ជាមួយនឹងចម្លើយពិសេស $Y$ ។ តាមសមីការ (3) យើងបាន

$$\phi(t) - Y(t) = c_1 y_1(t) + c_2 y_2(t) \qquad (8)$$

ដែលសមមូលទៅនឹងសមីការ (7) ។ ដោយ $\phi$ គឺជាចម្លើយថេរនៃសមីការ (1) កន្សោមដែលនៅខាងស្តាំនៃសមីការ (7) រាប់បញ្ចូលចម្លើយទាំងអស់នៃសមីការ (1) ដូចនេះគេហៅថា ចម្លើយទូទៅនៃសមីការ (1) ។

## ៣.៦.១វិធីសាស្ត្រដោះស្រាយ

ដើម្បីដោះស្រាយសមីការមិនអូម៉ូសែន $y'' + p(t)y' + q(t)y = g(t)$ យើងត្រូវធ្វើតាមជំហាន ៣ ខាងក្រោម៖

១. រកចម្លើយទូទៅ $y_c = c_1 y_1(t) + c_2 y_2(t)$ នៃសមីការលីនេអ៊ែរអូម៉ូសែន។ ចម្លើយនេះហៅថា ចម្លើយបំពេញ ដែលកំណត់សរសេរដោយ $y_c(t)$។

២. រកចម្លើយមួយ $y_p(t)$ នៃសមីការមិនអូម៉ូសែន។ ជាទូទៅ ចម្លើយនេះ គឺសំដៅលើសមីការជាក់លាក់មួយមានរាងដូច $g(t)$។

៣. បូកអនុគមន៍ $y(t) = y_p(t) + y_c(t)$ បញ្ចូលគ្នា។

**ចំណាំ៖** ការតាង $y_p(t)$

| អនុគមន៍ $g(t)$ | តាង $y_p(t)$ ដោយ |
|---|---|
| $h_n(t) = a_n t^n + a_{n-1}t^{n-1} + a_{n-2}t^{n-2} + \ldots + a_1 t + a_0$ | $y_p(t) = t^s\left(A_n t^n + A_{n-1}t^{n-1} + A_{n-2}t^{n-2} + \ldots + A_1 t + A_0\right)$ |
| $h_n(t)e^{\alpha t}$ | $y_p(t) = t^s\left(A_n t^n + A_{n-1}t^{n-1} + A_{n-2}t^{n-2} + \ldots + A_1 t + A_0\right)e^{\alpha t}$ |
| $h_n(t)e^{\alpha t}\cos\beta t$<br>$h_n(t)e^{\alpha t}\sin\beta t$ | $y_p(t) = t^s\left(A_n t^n + A_{n-1}t^{n-1} + \ldots + A_1 t + A_0\right)e^{\alpha t}\cos\beta t$<br>$+t^s\left(B_n t^n + B_{n-1}t^{n-1} + \ldots + A_1 t + A_0\right)e^{\alpha t}\sin\beta t$ |

ចំណាំ៖ ដែល $s = 0,1,2,\ldots$ ។បើគ្មានតម្លៃ $y_c(t)$ ដូចគ្នានឹង $g(t)$ នោះ $s = 0$ ។ ប៉ុន្តែបើមានតម្លៃ $y_c(t)$ ណាមួយដូចគ្នានឹង $g(t)$ នោះ $s = 1$

**ឧទាហរណ៍១៖** រកចម្លើយពិសេសនៃ $y''-3y'-4y=3e^{2t}$ (9)

ចម្លើយ

សមីការសម្គាល់ $y''-3y'-4y=0$ គឺ $r^2-3r-4=0$ មានឬស $r_1=-1, r_2=4$

អនុគមន៍ចម្លើយ $y_c=a_1e^{-t}+a_2e^{4t}$

ហើយ $g(t)=3e^{2t}\neq y_c \Rightarrow s=0$ នោះចម្លើយពិសេស $y_p=Ae^{2t}\Rightarrow y_p'=2Ae^{2t}\Rightarrow y_p''=4Ae^{2t}$

យកជំនួសសមីការ(9)យើងទទួលបាន

$$(4A-6A-4A)e^{2t}=3e^{2t}\Rightarrow A=-\frac{1}{2}$$

ចម្លើយពិសេសនៃ (9) គឺ $y_p=-\frac{1}{2}e^{2t}$ (10)

**ឧទាហរណ៍២៖** រកចម្លើយពិសេសនៃ $y''-3y'-4y=2\sin t$ (11)

ចម្លើយ

យើងអាចសន្មតថា

$$y_p(t)=A\sin t+B\cos t$$

ដែល $A$ និង $B$ គឺត្រូវបានកំណត់ នោះ

$$y_p'(t)=A\cos t-B\sin t,\qquad y_p''(t)=-A\sin t-B\cos t$$

ដោយជំនួសកន្សោមទាំងនេះដោយ $y, y'$ និង $y''$ ក្នុងសមីការ (11) ហើយផ្ទុំគ្នា យើងបាន៖

$$(-A+3B-4A)\sin t+(-B-3A-4B)\cos t=2\sin t \qquad (13)$$

$A$ និង $B$ ត្រូវតែបំពេញសមីការ

$$-5A+3B=2,\qquad -3A-5B=0$$

គេបាន $A=-\frac{5}{17}$ និង $B=\frac{3}{17}$ ។

ដូចនេះ ចម្លើយពិសេសនៃសមីការ (11) គឺ $y_p(t)=-\frac{5}{17}\sin t+\frac{3}{17}\cos t$ ។

វិធីសាស្រ្តបានបង្ហាញនៅក្នុងឧទាហរណ៍មុនអាចត្រូវបានប្រើនៅពេលសមីការខាងស្តាំគឺជាពហុធា។ ដូចនេះ ដើម្បីរកចម្លើយជាក់លាក់នៃ

$$y''-3y'-4y=4t^2-1 \qquad (14)$$

ដំបូងសន្មតថា $y_p(t)$ គឺជាពហុធានៃដឺក្រេដូចគ្នាដែលជាតួមិនអូម៉ូសែននោះ $y_p(t)=At^2+Bt+C$ ។

ដើម្បីសង្ខេបការសន្និដ្ឋានរបស់យើងរហូតដល់ចំណុចនេះ ប្រសិនបើតួមិនអូម៉ូសែន $g(t)$ ក្នុងសមីការ (1) គឺជាអនុគមន៍អិចស្ប៉ូណង់ស្យែល $e^{\alpha t}$ នោះគេអាចសន្មត់បានថា $y_p(t)$ គឺសមាមាត្រទៅនឹងអនុគមន៍អិចស្ប៉ូណង់ស្យែលដូចគ្នា។ បើ $g(t)$ គឺជាពហុធា នោះគេសន្មត់ថា $y_p(t)$ គឺជាពហុធានៃដឺក្រេដូចគ្នា។ គោលការណ៍ដូចគ្នានេះ បន្លាយទៅករណីដែល $g(t)$ គឺជាផលគុណនៃ២ចំនួន ឬ៣ នៃប្រភេទអនុគមន៍ទាំងនេះ ដូចនៅក្នុងឧទាហរណ៍បន្ទាប់នឹងបង្ហាញ។

**ឧទាហរណ៍ទី៣៖** រកចម្លើយជាក់លាក់នៃ $y''-3y'-4y=-8e^{t}\cos 2t$ $(15)$

ក្នុងករណីនេះ យើងសន្មត់ថា $y_p(t)$ គឺជាផលគុណនៃ $e^{t}$ ហើយជាបន្សំលីនេអ៊ែរនៃ $\sin t$ និង $\cos t$ គេបាន

$$y_p'(t)=Ae^{t}\cos 2t+Be^{t}\sin 2t$$

កន្សោមពីជគណិតនេះ មានលក្ខណៈស៊ាំញ៉ាំជាងក្នុងឧទាហរណ៍មុនៗ ប៉ុន្តែវាធ្វើតាម

$$y_p'(t)=(A+2B)e^{t}\cos 2t+(-2A+B)e^{t}\sin 2t$$ និង

$$y_p''(t)=(-3A+4B)e^{t}\cos 2t+(-4A-3B)e^{t}\sin 2t$$

ដោយជំនួសកន្សោមទាំងនេះក្នុងសមីការ $(15)$ យើងរកឃើញថា $A$ និង $B$ ត្រូវតែផ្ទៀងផ្ទាត់

$10A+2B=8,\qquad 2A-10B=0$

នោះ $A=\dfrac{10}{13}$ និង $B=\dfrac{2}{13}$

ដូចនេះ ចម្លើយជាក់លាក់នៃសមីការ គឺ $Y(t)=\dfrac{10}{13}e^{t}\cos 2t+\dfrac{2}{13}e^{t}\sin 2t$ ។

ឧបមាថា $g(t)$ គឺជាផលបូកពីរតួ $g(t)=g_1(t)+g_2(t)$ ហើយតាង $Y_1$ និង $Y_2$ គឺជាចម្លើយនៃសមីការ

$$ay''+by'+cy=g_1(t) \qquad (16)$$

និង

$$ay''+by'+cy=g_2(t) \qquad (17)$$

នោះ $Y_1+Y_2$ គឺជាចម្លើយនៃសមីការ $ay''+by'+cy=g(t)$ $(18)$ ។

ដើម្បីដោះស្រាយសមីការទាំងនេះ ជំនួស $zY_1(t)+Y_2(t)$ ដោយ ក្នុងសមីការ $(18)$ ហើយប្រើប្រាស់សមីការ $(16)$ និង $(17)$ ។ ស្រដៀងគ្នា ប្រសិនបើ $g(t)$ គឺជាផលបូកនៃចំនួនកំណត់ណាមួយនៃតួ។ ការអនុវត្តដែលសំខាន់នៃលទ្ធផលនេះគឺសម្រាប់សមីការដែលអនុគមន៍មិនអូម៉ូសែនរបស់ $g(t)$ អាចជាផលបូក អាចជំនួសសមីការសាមញ្ញមួយចំនួន ហើយបន្ថែមចម្លើយទាំងអស់។ ឧទាហរណ៍ខាងក្រោមគឺជាការបកស្រាយនៃដំណើរការ។

**ឧទាហរណ៍ទី៤៖** រកចម្លើយពិសេសនៃ $y''-3y'-4y=3e^{2t}+2\sin t-8e^{t}\cos 2t$ $(19)$

ដោយបំបែកខាងស្តាំនៃសមីការ $(19)$ យើងមានសមីការបានចំនួន៣ខាងក្រោម៖

$y''-3y'-4y=3e^{2t}$

$y''-3y'-4y=2\sin t$

$y''-3y'-4y=-8e^{t}\cos 2t$

ចម្លើយនៃសមីការទាំង៣នេះត្រូវបានរកឃើញនៅក្នុងឧទាហរណ៍ ១, ២ និង ៣ ។

ដូចនេះ ចម្លើយជាក់លាក់នៃសមីការ $(19)$ គឺជាផលបូករបស់វា

$Y(t)=-\dfrac{1}{2}e^{2t}+\dfrac{3}{17}\cos t-\dfrac{5}{17}\sin t+\dfrac{10}{13}e^{t}\cos 2t-\dfrac{2}{13}e^{t}\sin 2t$ ។

## លំហាត់

ក្នុងលំហាត់ពី 1 – 12 រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលដែលឱ្យ។

1. $y''-2y'-3y=3e^{2t}$
2. $y''+2y'+5y=3\sin 2t$
3. $y''-2y'-3y=-3te^{-t}$
4. $y''+2y'=3+4\sin 2t$
5. $y''+9y=6+t^2e^{3t}$
6. $y''+2y'+y=2e^{-t}$
7. $2y''+3y'+y=t^2+3\sin t$
8. $y''+y=3\sin 2t+t\cos 2t$
9. $u''+\omega_0^2u=\cos\omega t;\quad \omega^2\neq\omega_0^2$
10. $u''+\omega_0^2u=\cos\omega_0 t;$
11. $y''+y'+4y=2\sinh t;\quad \left(\sinh t=\dfrac{e^t-e^{-t}}{2}\right)$
12. $y''-y'-2y=\cosh 2t;\quad \left(\cosh t=\dfrac{e^t+e^{-t}}{2}\right)$

ក្នុងលំហាត់ពី 13 – 18 រកចម្លើយតាមតម្លៃដើមដែលបានផ្តល់ឲ្យ។

13. $y''+y'-2y=2t,\qquad y(0)=0,\qquad y'(0)=1$
14. $y''+4y'=t^2+3e^t,\qquad y(0)=0,\qquad y'(0)=2$
15. $y''-2y'+y=te^t+4,\qquad y(0)=1,\qquad y'(0)=1$
16. $y''-2y'-3y=3te^{2t},\qquad y(0)=1,\qquad y'(0)=0$
17. $y''+4y=3\sin 2t,\qquad y(0)=2,\qquad y'(0)=-1$
18. $y''+2y'+5y=4e^{-t}\cos 2t,\qquad y(0)=1,\qquad y'(0)=0$

លំហាត់ពី 19 – 26 កំណត់ទម្រង់ចម្លើយពិសេស $y_p(t)$ នៃសមីការប្រើវិធីនៃមេគុណមិនកំណត់៖

19. $y''+3y'=2t^4+t^2e^{-3t}+\sin 3t,$
20. $y''+y'=t(1+\sin t)$
21. $y''-5y'+6y=e^t\cos 2t+e^{2t}(3t+4)\sin t;$
22. $y''+2y'+2y=3e^{-t}-2e^{-t}\cos t+4e^{-t}t^2\sin t,$
23. $y''-4y'+4y=2t^2+4te^{2t}+t\sin 2t,$
24. $y''+4y=t^2\sin 2t+(6t+7)\cos 2t$
25. $y''+3y'+2y=e^t(t^2+1)\sin 2t+3e^{-t}\cos t+4e^t,$
26. $y''+2y'+5y=3t^2e^{-t}\cos 2t-2te^{-2t}\cos t$

### ៣.៧ បម្រែបម្រួលប៉ារ៉ាម៉ែត្រ (Variation of Parameters)

នៅក្នុងផ្នែកនេះ យើងនឹងបកស្រាយអំពីវិធីមួយទៀតក្នុងការរកចម្លើយពិសេសមួយនៃសមីការមិនអូម៉ូសែន ។ ចំណុចសំខាន់នៃវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រគឺថាវាជាវិធីទូទៅមួយដែលអាចអនុវត្តចំពោះសមីការណាមួយក៏បាន ហើយវាមិនទាមទារការសន្មត់លម្អិតលើទម្រង់នៃចម្លើយរបស់វានោះទេ។ ជាការពិតណាស់ យើងនឹងប្រើវាដើម្បីទាញរករូបមន្តនៃចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទីពីរមិនអូម៉ូសែន។

**ឧទាហរណ៍១៖** រកចម្លើយពិសេសនៃសមីការ $y''+4y=3\csc t$ (1)

យើងសង្កេតឃើញថា សមីការនេះមានទម្រង់ខុសពីសមីការមុនៗដែលមិនអាចប្រើ**វិធីសាស្ត្រមេគុណមិនកំណត់បាន** ដើម្បីរកចម្លើយពិសេសមួយបានទេ ពីព្រោះផ្នែកមិនអូម៉ូសែន $3\csc t$ ជាទម្រង់ផលចែក (មិនមែនជាផលបូក ឬផលគុណ) នៃ $\sin t$ ឬ $\cos t$ ។ ដោយឡែក យើងឃើញថា សមីការអូម៉ូសែនដែលត្រូវនឹងសមីការ (1) គឺ៖

$$y''+4y=0 \quad (2)$$

គេបានចម្លើយទូទៅនៃ (2) គឺ៖

$$y_c(t)=c_1\cos 2t+c_2\sin 2t \quad (3)$$

ដោយប្រើវិធីបម្លែងប៉ារ៉ាម៉ែត្រ យើងជំនួសចំនួនថេរ $c_1,c_2$ ក្នុងសមីការ (3) ដោយអនុគមន៍ $u_1(t),u_2(t)$ រៀងគ្នា ហើយបន្ទាប់មក កំណត់អនុគមន៍ទាំងពីរនេះ គេបាន

$$y=u_1(t)\cos 2t+u_2(t)\sin 2t \quad (4)$$

ជាចម្លើយមួយនៃសមីការមិនអូម៉ូសែន (1) ។

ដើម្បីកំណត់ $u_1$ និង $u_2$ , យើងត្រូវការជំនួស $y$ ពីសមីការ (4) ទៅក្នុងសមីការ (1) ។

ដោយធ្វើឌីផេរ៉ង់ស្យែលលើ (4) យើងបាន៖

$$y'=-2u_1(t)\sin 2t+2u_2(t)\cos 2t+u_1'(t)\cos 2t+u_2'(t)\sin 2t \quad (5)$$

ដោយលទ្ធភាពក្នុងការជ្រើសរើស $u_1$ និង $u_2$ មានច្រើន ដូច្នេះយើងនឹងតម្រូវឲ្យ ពីរតួខាងចុងនៃ (5) ស្មើសូន្យ គេបាន៖

$$u_1'(t)\cos 2t+u_2'(t)\sin 2t=0 \quad (6)$$

គេបានសមីការ (5) ក្លាយទៅជា ៖

$$y'=-2u_1(t)\sin 2t+2u_2(t)\cos 2t \quad (7)$$

ដោយធ្វើឌីផេរ៉ង់ស្យែលលើ (7) គេបាន៖

$$y''=-4u_1(t)\cos 2t-4u_2(t)\sin 2t-2u_1'(t)\sin 2t+2u_2'(t)\cos 2t \quad (8)$$

ជំនួស (4) និង (8) នៅក្នុង (1)៖

$$-2u_1'(t)\sin 2t+2u_2'(t)\cos 2t=3\csc t \quad (9)$$

ដោយប្រើ (6) និង (9) ដើម្បីដោះស្រាយរក $u_1(t)$ និង $u_2(t)$ ៖

តាម (6) គេបាន $u_2'(t)=-u_1'(t)\dfrac{\cos 2t}{\sin 2t}$ (10)

យក (10) ជំនួសក្នុង (9) គេបាន៖

$$u_1'(t)=-\frac{3\csc t\sin 2t}{2}=-3\cos t \quad (11)$$

រួចជំនួសរក $u_2'(t)$ គេបាន៖

$$u_2'(t)=\frac{3\cos t\cos 2t}{\sin 2t}=\frac{3\left(1-2\sin^2 t\right)}{2\sin t}=\frac{3}{2}\csc t-3\sin t \quad (12)$$

ដើម្បីទទួលបាន $u_1(t)$ និង $u_2(t)$ យើងត្រូវធ្វើអាំងតេក្រាលលើ (11) និង (12) គេបាន៖

$$u_1(t) = -3\sin t + c_1 \quad (13) \text{ និង } u_2(t) = \frac{3}{2}\ln\left|\csc t - \cot t\right| + 3\cos t + c_2 \quad (14)$$

ដោយជំនួស (13) និង (14) នៅក្នុង (4) និងធ្វើការសម្រួលកន្សោម គេបាន៖

$$y = 3\sin t + \frac{3}{2}\ln\left|\csc t - \cot t\right|\sin 2t + c_1\cos 2t + c_2\sin 2t \quad (15)$$

គេបាន $Y(t) = 3\sin t + \frac{3}{2}\ln\left|\csc t - \cot t\right|\sin 2t$ ជាចម្លើយពិសេសនៃសមីការ (1) និង $y_c = c_1\cos 2t + c_2\sin 2t$ ជាចម្លើយទូទៅនៃសមីការអូម៉ូសែននៃ (1) និង (15) ជាចម្លើយទូទៅនៃសមីការ (1) ។

## ៣.៧.១ វិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ

ការរកចម្លើយពិសេសនិងចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលមានរាង $y'' + p(t)y' + q(t)y = g(t)$ ដោយប្រើវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ៖

គេមាន $$y'' + p(t)y' + q(t)y = g(t) \quad (16)$$

ដែល $p$ និង $q$ ជាអនុគមន៍ជាប់ ។ យើងសន្មតថា

$$y_c(t) = c_1y_1(t) + c_2y_2(t) \quad (17)$$

ជាសមីការទូទៅនៃសមីការអ៊ូម៉ូសែនរបស់វា ៖

$$y'' + p(t)y' + q(t)y = 0 \quad (18)$$

យើងជំនួសចំនួនថេរ $c_1, c_2$ ដោយអនុគមន៍ $\mu_1(t), \mu_2(t)$ រៀងគ្នា គេបាន៖

$$y = \mu_1(t)y_1(t) + \mu_2(t)y_2(t) \quad (19)$$

ដើម្បីរក $\mu_1(t), \mu_2(t)$ យើងធ្វើដេរីវេ (19) គេបាន៖

$$y' = \mu_1'(t)y_1(t) + \mu_1(t)y_1'(t) + \mu_2'(t)y_2(t) + \mu_2(t)y_2'(t) \quad (20)$$

ដូចនៅក្នុងឧទាហរណ៍ខាងលើ យក ៖

$$\mu_1'(t)y_1(t) + \mu_2'(t)y_2(t) = 0 \quad (21)$$

គេបាន (20) ក្លាយជា $y' = \mu_1(t)y_1'(t) + \mu_2(t)y_2'(t)$ (22)

ដោយធ្វើឌីផេរ៉ង់ស្យែលលើ (22) គេបាន

$$y'' = \mu_1'(t)y_1'(t) + \mu_1(t)y_1''(t) + \mu_2'(t)y_2'(t) + \mu_2(t)y_2''(t) \quad (23)$$

យក (19),(22),(23) ទៅជំនួស (16) គេបាន៖

$$\mu_1(t)\left[y_1''(t) + p(t)y_1'(t) + q(t)y_1(t)\right] + \mu_2(t)\left[y_2''(t) + p(t)y_2'(t) + q(t)y_2(t)\right]$$
$$+\mu_1'(t)y_1'(t) + \mu_2'(t)y_2'(t) = g(t) \quad (24)$$

ដោយ $y_1''(t) + p(t)y_1'(t) + q(t)y_1(t) = 0$ និង $y_2''(t) + p(t)y_2'(t) + q(t)y_2(t) = 0$ (សមីការទូទៅអូម៉ូសែន) នោះ (24) ក្លាយជា $\mu_1'(t)y_1'(t) + \mu_2'(t)y_2'(t) = g(t)$ (25)

ដោយដោះស្រាយប្រព័ន្ធនៃសមីការ (21) និង (25) យើងបាន៖

$$u_1'(t) = -\frac{y_2(t)g(t)}{W(y_1,y_2)(t)} \quad , \quad u_2'(t) = -\frac{y_1(t)g(t)}{W(y_1,y_2)(t)} \qquad (26)$$

ដែល $W(y_1,y_2)(t)$ ជាដេទែមីណង់វ៉ុងគៀន នៃ $y_1$ និង $y_2$ ហើយដោយ $y_1$ និង $y_2$ ជាសំណុំនៃចម្លើយ នោះ $W$ ខុសពីសូន្យជានិច្ច ។ ដោយធ្វើអាំងតេក្រាលលើសមីការ (26)

$$u_1(t) = -\int \frac{y_2(t)g(t)}{W(y_1,y_2)(t)}\,dt + c_1 \ , \quad u_2(t) = -\int \frac{y_1(t)g(t)}{W(y_1,y_2)(t)}\,dt + c_2 \qquad (27)$$

ដោយយក (27) ជួស (19) យើងបានសមីការទូទៅនៃ (16) ។

**ទ្រឹស្តីបទ ២.៧.១៖**

បើមានអនុគមន៍ $p,q$ និង $g$ ជាប់លើចន្លោះបើក $I$ , ហើយបើអនុគមន៍ $y_1,y_2$ ជាចម្លើយមិនអាស្រ័យលីនេអ៊ែរនៃសមីការអូម៉ូសែន $y''+p(t)y'+q(t)y=0$ ដែលត្រូវគ្នានឹងសមីការមិនអូម៉ូសែន $y''+p(t)y'+q(t)y=g(t)$ ។គេបានចម្លើយពិសេសមួយនៃសមីការ $y''+p(t)y'+q(t)y=g(t)$ គឺ៖

$$Y(t) = -y_1(t)\int \frac{y_2(t)g(t)}{W(y_1,y_2)(t)}\,dt + y_2(t)\int \frac{y_1(t)g(t)}{W(y_1,y_2)(t)}\,dt$$

ហើយសមីការទូទៅគឺ៖ $y_c(t) = c_1y_1(t)+c_2y_2(t)+Y(t)$ ។

## លំហាត់

ក្នុងលំហាត់ពី 1 – 4 រកចម្លើយពិសេសនៃសមីការឌីផេរ៉ង់ស្យែលដែលឲ្យដោយប្រើវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ។

1. $y''-5y'+5y=2e^t$
2. $y''-y'-2y=2e^{-t}$
3. $y''+2y'+y=3e^{-t}$
4. $4y''-4y'+y=16e^{t/2}$

ក្នុងលំហាត់ពី 5 – 12 រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលដែលឱ្យដោយប្រើវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ។លំហាត់11-12 $g(t)$ ជាអនុគមន៍ជាប់

5. $y''+y=\tan t; \quad 0<t<\pi/2$
6. $y''+9y=9\sec^2 3t; \quad 0<t<\pi/6$
7. $y''+4y'+4y=t^{-2}e^{-2t}, \quad t>0$
8. $y''+4y=3\csc 2t, \quad 0<t<\pi/2$
9. $4y''+y=2\sec(t/2), \quad -\pi<t<\pi$
10. $y''-2y'+y=e^t/(1+t^2)$
11. $y''-5y'+6y=g(t)$
12. $y''+4y=g(t)$

ក្នុងលំហាត់ពី 13 – 20 បញ្ជាក់ថា $y_1,y_2$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលអូម៉ូហ្សែន រួចរកចម្លើយពិសេសឱ្យដោយសមីការមិនអូម៉ូហ្សែន។

13. $t^2y''-2y=3t^2-1,\qquad t>0,\quad y_1(t)=t^2,\qquad y_2(t)=t^{-1}$

14. $t^2y''-t(t+2)y'+(t+2)y=2t^3,\quad t>0,\quad y_1(t)=t,\qquad y_2(t)=te^t$

15. $ty''-(1+t)y'+y=t^2e^{2t},\qquad t>0,\quad y_1(t)=t+1,\quad y_2(t)=e^t$

16. $(1-t)y''+ty'-y=2(t-1)^2e^{-t},\quad 0<t<1\qquad y_1(t)=e^t,\qquad y_2(t)=t$

17. $x^2y''-3xy'+4y=x^2\ln x,\qquad x>0\quad y_1(t)=x^2,\qquad y_2(t)=x^2\ln x$

18. $x^2y''+xy'+(x^2-0.25)y=3x^{3/2}\sin x,\qquad x>0,\; y_1(t)=x^{-1/2}\sin x,\qquad y_2(t)=x^{-1/2}\cos x$

## ៣.៨. រំញ័រមេកានិច និង អគ្គិសនី ( Chanical And Electrical Vibrations )

ហេតុផលមួយក្នុងចំណោមហេតុផលដែលសមីការលីនេអ៊ែរលំដាប់ទីពីរជាមួយនឹងមេគុណថេរមានតម្លៃសិក្សាគឺថាពួកវាបម្រើជាគំរូគណិតវិទ្យានៃដំណើរការសំខាន់ៗមួយចំនួន។ ផ្នែកសំខាន់ពីរនៃការអនុវត្តគឺនៅក្នុងវិស័យនៃលំយោលមេកានិច និងអគ្គិសនី។ ឧទាហរណ៍ ចលនានៃម៉ាស់នៅលើផ្ទៃរាងមូល រំញ័រ ការយោលបង្វិលនៃអ័ក្ស លំហូរនៃចរន្តអគ្គិសនីនៅក្នុងសៀគ្វីស៊េរីសាមញ្ញ និងបញ្ហារូបវន្តជាច្រើនទៀតត្រូវបានពិពណ៌នាដោយដំណោះស្រាយនៃបញ្ហាតម្លៃក្រោមទម្រង់

$$ay''+by'+cy=g(t)\ ,\ y(0)=y_0\ ,\ y'(0)=y_0' \qquad (1)$$

នេះបង្ហាញពីទំនាក់ទំនងជាមូលដ្ឋានរវាងគណិតវិទ្យា និងរូបវិទ្យា។ បញ្ហាជាច្រើនអាចមានគំរូគណិតវិទ្យាដូចគ្នា។ ដូច្នេះនៅពេលដែលយើងដឹងពីរបៀបដោះស្រាយបញ្ហា (1) វាគ្រាន់តែជាការចាំបាច់ក្នុងការធ្វើការបកស្រាយត្រឹមត្រូវនៃចំនួនថេរ $a$ $b$ និង $c$ និងអនុគមន៍ $y$ និង $g$ ដើម្បីទទួលបានដំណោះស្រាយនៃបញ្ហារូបវន្តផ្សេងៗ។

យើងនឹងសិក្សាអំពីចលនារបស់ម៉ាស់នៅលើផ្ទៃរាងមូលមួយយ៉ាងលម្អិត ពីព្រោះការយល់ដឹងអំពីលក្ខណៈនៃប្រព័ន្ធសាមញ្ញនេះគឺជាជំហានដំបូងក្នុងការស៊ើបអង្កេតលើប្រព័ន្ធរំញ័រដែលស្មុគស្មាញជាងនេះ។ លើសពីនេះ គោលការណ៍ដែលពាក់ព័ន្ធគឺជារឿងធម្មតាសម្រាប់បញ្ហាជាច្រើន។ ពិចារណាម៉ាស់ $m$ ព្យួរនៅលើចុងបញ្ឈរនៃប្រវែងដើម $L$ ដូចបង្ហាញក្នុងរូបភាព 3.8.1 ។ ម៉ាស់លូតបាន $L$ នៃទំពក់ក្នុងទិសដៅធ្លាក់ចុះ (វិជ្ជមាន) ។ មានកម្លាំងពីរដែលធ្វើសកម្មភាពនៅចំណុចដែលម៉ាស់ត្រូវបានភ្ជាប់ទៅនឹងទំពក់សូមមើលរូបភាព 3.8.2 ។ កម្លាំងទំនាញ ឬទម្ងន់នៃម៉ាស់ ធ្វើសកម្មភាពចុះក្រោម និងមានរ៉ិចទ័រ $mg$ ដែល $g$ គឺជាការបង្កើនល្បឿនដោយសារទំនាញ។ វាក៏មានកម្លាំង $F$ ដោយសារតែទំពក់ដែលធ្វើសកម្មភាពឡើងលើ។ ប្រសិនបើយើងសន្មត់ថាការពន្លូត $L$ នៃទំពក់គឺតូចកម្លាំងទំនាញគឺស្មើរតែសមាមាត្រទៅនឹង $L$ នេះត្រូវបានគេស្គាល់






ដូចច្បាប់របស់ Hooke។ ដូច្នេះយើងសរសេរ $F=-kL$ ដែលថេរនៃសមាមាត្រ $k$ ត្រូវបានគេហៅថាថេរនៃផ្ទៃរាងមូល ហើយសញ្ញាដកគឺដោយសារតែការពិតដែលថាកម្លាំងនៃផ្ទៃរាងមូលធ្វើសកម្មភាពក្នុងទិសដៅខាងលើ (អវិជ្ជមាន) ។ ដោយសារម៉ាស់ស្ថិតនៅក្នុងលំនឹង កម្លាំងទាំងពីរមានតុល្យភាពគ្នាទៅវិញទៅមក ដែលមានន័យថា $mg-kL=0$ (2)

សម្រាប់ទម្ងន់ដែលបានផ្តល់ឱ្យ $w=mg$ មួយអាចវាស់ $L$ ហើយបន្ទាប់មកប្រើ $(2)$ ដើម្បីកំណត់ $k$ ។ ចំណាំថា $k$ មានឯកតានៃប្រវែងកម្លាំង។

នៅក្នុងបញ្ហាឌីណាមិកដែលត្រូវគ្នា យើងចាប់អារម្មណ៍ក្នុងការសិក្សាអំពីចលនានៃម៉ាស់ នៅពេលដែលវាត្រូវបានធ្វើសកម្មភាពដោយកម្លាំងខាងក្រៅ ឬត្រូវបានផ្លាស់ទីដំបូង។ តាង $u(t)$ ដែលវាស់វែងជាវិជ្ជមានចុះក្រោម បង្ហាញពីការផ្លាស់ទីរបស់ម៉ាស់ពីទីតាំងលំនឹងរបស់វានៅពេល $t$ សូមមើលរូបភាព 3.8.1 ។ បន្ទាប់មក $u(t)$ គឺទាក់ទងទៅនឹងកម្លាំងដែលធ្វើសកម្មភាពលើម៉ាស់ដែលឆ្លងកាត់ច្បាប់នៃចលនារបស់ញូតុន $mu''(t)=f(t)$ , (3)

ដែល $u''$ គឺជាការបង្កើនល្បឿននៃម៉ាស់ ហើយ $f$ គឺជាកម្លាំងសុទ្ធដែលធ្វើសកម្មភាពលើម៉ាស់។ សង្កេតថាទាំង $u$ និង $f$ គឺជាមុខងារនៃពេលវេលា។ ក្នុងការកំណត់ $f$ មានកម្លាំងបួនដាច់ដោយឡែកដែលត្រូវតែពិចារណា៖

ទម្ងន់ $w=mg$ នៃម៉ាសតែងតែធ្វើសកម្មភាពចុះក្រោម។

កម្លាំងទំនាញ $F_s$ ត្រូវបានគេសន្មត់ថាសមាមាត្រទៅនឹងការពន្លូតសរុប $L+u$ នៃការលូតហើយតែងតែធ្វើសកម្មភាពដើម្បីស្តារទៅទីតាំងធម្មតារបស់វា។ ប្រសិនបើ $L+u>0$ នោះទំនាញបានពង្រីកហើយកម្លាំងត្រូវបានដឹកនាំឡើងលើ។ ក្នុងករណីនេះ $F_s=-k(L+u)$ (4)

ម្យ៉ាងវិញទៀត បើ $L+u<0$ នោះកម្លាំងត្រូវបានបង្ហាប់ពីចម្ងាយ $|L+u|$ ហើយកម្លាំងត្រូវចុះក្រោមត្រូវបានផ្តល់ដោយ $F_s=k|L+u|$ ។ ទោះយ៉ាងណាក៏ដោយនៅពេលដែល $L+u<0$ នោះ $|L+u|=-(L+u)$ ដូច្នេះ $F_s$ ត្រូវបានផ្តល់ឱ្យម្តងទៀតដោយ (4) ។ ដូចនេះ ដោយមិនគិតពីទីតាំងនៃម៉ាស់ កម្លាំងដែលបញ្ចេញត្រូវបានបង្ហាញដោយ (4) ។

កម្លាំងសើម ឬធន់ $F_d$ តែងតែធ្វើសកម្មភាពក្នុងទិសដៅផ្ទុយទៅនឹងទិសដៅនៃចលនារបស់ម៉ាស។ កម្លាំងនេះអាចកើតឡើងពីប្រភពជាច្រើន៖ ការតស៊ូពីខ្យល់ ឬឧបករណ៍ផ្ទុកផ្សេងទៀតដែលម៉ាស់ផ្លាស់ទី ការរលាយថាមពលខាងក្នុងដោយសារការបន្ថែមឬការបង្ហាប់នៃរបស់ណាមួយ ការកកិតរវាងម៉ាស់និងមគ្គុទ្ទេសក៍ (ប្រសិនបើមាន) ដែលរារាំងចលនារបស់វាទៅ វិមាត្រមួយ ឬឧបករណ៍មេកានិច (ផ្ទាំងគ្រប់គ្រង) ដែលផ្តល់កម្លាំងទប់ទល់ទៅនឹងម៉ាស់។ ក្នុងករណីណាក៏ដោយ យើងសន្មត់ថាកម្លាំងទប់ទល់គឺសមាមាត្រទៅនឹងល្បឿន $\left|\frac{du}{dt}\right|$ នៃម៉ាស់។ នេះជាធម្មតាត្រូវបានគេហៅថា viscous damping ។ ប្រសិនបើ $\frac{du}{dt}>0$ នោះ $u$ កើន ដូច្នេះម៉ាស់រំកិលចុះក្រោម។បន្ទាប់មក $F_d$ ត្រូវបានដឹកនាំឡើងលើ ហើយត្រូវបានផ្តល់ដោយ $F_d(t)=-\gamma u'(t)$ (5)

ដែល $\gamma$ ជាថេរវិជ្ជមាននៃសមាមាត្រដែលគេស្គាល់ថាជាថេរ damping ។ ម៉្យាងវិញទៀត ប្រសិនបើ $\frac{du}{dt}>0$ នោះ $u$ ថយចុះ ម៉ាស់កំពុងឡើងលើ ហើយ $F_d$ ចុះក្រោម ។ ក្នុងករណីនេះ $F_d=\gamma|u'(t)|$ ដោយ $|u'(t)|=-u'(t)$ វាដូច $F_d(t)$ ត្រូវបានផ្តល់ឱ្យម្តងទៀតដោយ (5) ។ ដូច្នេះដោយមិនគិតពីទិសដៅនៃចលនានៃម៉ាស់ កម្លាំងតែងតែត្រូវបានបង្ហាញដោយ (5) ។

កម្លាំងអាចមានភាពស្មុគស្មាញបន្តិច ហើយការសន្មត់ ត្រូវបានយកគំរូតាមដោយ (5) អាចបើកចំហចំពោះសំណួរ។ dashpots មួយចំនួនមានលក្ខណៈជា (5) states បើផ្សេងពីនេះនោះមានតិចតួច វាអាចនឹងមិនមានទាំងស្រុង ឬកែតម្រូវថេរ $\gamma$ ដើម្បីប្រហាក់ប្រហែលពួកគេ។ អត្ថប្រយោជន៍សំខាន់នៃការសន្មត់ (5) គឺថាវានាំទៅរកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ (ជាជាងមិនមែនលីនេអ៊ែរ) ។ នៅក្នុងនេះមានន័យថាការវិភាគហ្មត់ចត់នៃប្រព័ន្ធគឺត្រង់ដូចដែលយើងនឹងបង្ហាញនៅក្នុងផ្នែកនេះ និងបន្ទាប់។

កម្លាំងខាងក្រៅដែលបានអនុវត្ត $F(t)$ ត្រូវបានដឹកនាំចុះក្រោម ឬឡើងលើ ដោយសារ $F(t)$ វិជ្ជមាន ឬអវិជ្ជមាន។ នេះអាចជាកម្លាំងមួយដោយសារតែចលនារបស់រ៉ឺស័រត្រូវបានភ្ជាប់ ឬវាអាចជាកម្លាំងដែលអនុវត្តដោយផ្ទាល់ទៅលើម៉ាស់។ ជារឿយៗកម្លាំងខាងក្រៅគឺតាមកាលកំណត់។

ដោយគិតពីកម្លាំងទាំងនេះ ឥឡូវនេះយើងអាចសរសេរឡើងវិញនូវច្បាប់របស់ញូតុន (3) ជា

$$mu''(t)=mg+F_s(t)+F_d(t)+F(t)$$
$$=mg-k\left[L+u(t)\right]-\gamma u'(t)+F(t) \qquad (6)$$

ដោយ $mg-kL=0$ តាមសមីការ (2) វាគោរពតាមសមីការនៃម៉ាសគឺ

$$mu''(t)+\gamma u'(t)+ku(t)=F(t) \qquad (7)$$

ដែល ថេរ $m$ , $\gamma$ , $k$ ជាចំនួនវិជ្ជមាន ។ ចំណាំ សមីការ (7) មានទម្រង់ដូចសមីការ (1)

វាជាការសំខាន់ដែលត្រូវយល់ថាសមីការ (7) គ្រាន់តែជាសមីការប្រហាក់ប្រហែលសម្រាប់ការផ្លាស់ទីរបស់ $u(t)$ ប៉ុណ្ណោះ។ ជាពិសេសសមីការ(4) និង (5) គួរតែត្រូវបានគេមើលថាជាការប្រហាក់ប្រហែលសម្រាប់កម្លាំងទំនាញរ៉ឺស័រ និងកម្លាំងរៀងគ្នា។ នៅក្នុងការទាញយករបស់យើង យើងក៏បានធ្វេសប្រហែសទៅលើម៉ាស់នៃរ៉ឺស័រ នៅក្នុងការប្រៀបធៀបជាមួយនឹងម៉ាស់នៃរូបរាងដែលភ្ជាប់មកជាមួយ។

ការបង្កើតពេញលេញនៃបញ្ហារំញ័រតម្រូវឱ្យយើងបញ្ជាក់លក្ខខណ្ឌដំបូងពីរគឺទីតាំងដំបូង $u_0$ និងល្បឿនដំបូង $v_0$ នៃម៉ាស់ $u(0)=u_0$ , $u'(0)=v_0$ (8)

វាគោរពតាម ទ្រឹស្តីបទ 3.2.1 ដែលលក្ខខណ្ឌទាំងនេះឱ្យដោយបញ្ហានៃគណិតវិទ្យាដែលមានដំណោះស្រាយ ។ នេះគឺស្របជាមួយនឹងការពិចារណារូបរបស់យើងដែលថា ប្រសិនបើម៉ាសត្រូវបានកំណត់ក្នុងចលនាជាមួយនឹងការផ្លាស់ទី និងល្បឿនដំបូងដែលបានផ្តល់ឱ្យនោះ ទីតាំងរបស់វានឹងត្រូវបានកំណត់តែមួយគត់នៅពេលខាងមុខ។ ទីតាំងម៉ាស់ត្រូវបានផ្តល់ឱ្យ (ប្រហែល) ដោយដំណោះស្រាយនៃ (7) លក្ខខណ្ឌដំបូងដែលបានចេញគោរពតាម (8) ។

**ឧទាហរណ៍១:** ម៉ាស់ដែលមានទម្ងន់ 4 ផោនលាតសន្ទឹងលើរ៉ឺស័រ 2 អ៊ិញ។ ឧបមាថាម៉ាស់ត្រូវបានផ្លាស់ទីបន្ថែម 6 អិញ។ ក្នុងទិសដៅអវិជ្ជមាន ។ ម៉ាស់គឺស្ថិតនៅក្នុងឧបករណ៍ផ្ទុក 6 ផោននៅពេលដែលម៉ាស់មានល្បឿន $3\ fit/s$ ។នៅក្រោមការសន្មត់ដែលបានពិភាក្សានៅក្នុងផ្នែកនេះ បង្កើតបញ្ហាតម្លៃដំបូងដែលគ្រប់គ្រងចលនានៃម៉ាស់។

បញ្ហាតម្លៃដំបូងដែលត្រូវការមានសមីការឌីផេរ៉ង់ស្យែល $(7)$ និងលក្ខខណ្ឌដំបូង $(8)$ ដូច្នេះភារកិច្ចរបស់យើងគឺដើម្បីកំណត់ចំនួនថេរផ្សេងៗដែលលេចឡើងក្នុងសមីការទាំងនេះ។ ជំហានដំបូងគឺជ្រើសរើសឯកតារង្វាស់។ ដោយផ្អែកលើបញ្ហាក្នុងការប្រើប្រាស់ភាសាអង់គ្លេសជាជាងប្រព័ន្ធម៉ែត្រនៃឯកតា។ ឯកតាពេលវេលាតែមួយគត់ដែលបានលើកឡើងគឺទីពីរ ដូច្នេះយើងនឹងវាស់ $t$ ជាវិនាទី។ម្យ៉ាងវិញទៀតទាំងហ្វីតនិងអ៊ីញ បង្ហាញជាឯកតានៃប្រវែង។ វាមិនសំខាន់ទេថាមួយណាដែលយើងប្រើ ប៉ុន្តែដោយបានធ្វើការជ្រើសរើស វាសំខាន់ដើម្បីឲ្យស្រប។ ដើម្បីឱ្យច្បាស់លាស់ អនុញ្ញាតឱ្យយើងវាស់ការផ្លាស់ទីរបស់អ្នកជាហ្វីត។

ដោយសារមិនគិតអំពីកម្លាំងទប់ខាងក្រៅ យើងសន្មត់ថា $F(t)=0$ ។ កំណត់ $m$ ចំណាំថា

$$m=\frac{w}{g}=\frac{4\ lb}{32\ ft/\sec^2}=\frac{1}{8}\frac{lb\sec^2}{ft}$$

មេគុណ $\gamma$ គឺត្រូវបានគណនាតាមទម្រង់ $\gamma u'$ គឺស្មើ $6lb$ ពេល $u'$ ស្មើ $ft/\sec$ ។

ដូច្នេះ $\gamma=\dfrac{6lb}{3\ ft/\sec}=2\dfrac{lb\sec}{ft}$

ថេរ $k$ នៃរ៉ឺស័រ រកតាមទម្រង់ដែលម៉ាស់នៃរ៉ឺស័រលូតបាន $2\ inch$ ឬ ដោយ $\dfrac{1}{6\ ft}$ ។

ដូច្នេះ $k=\dfrac{4lb}{\dfrac{1}{6\ ft}}=24\dfrac{lb}{ft}$

ជាលទ្ធផល សមីការ $(7)$ ទៅជា $\frac{1}{8}u''+2u'+24u=0$

ឬ $u''+16u'+192u=0 \qquad (9)$

លក្ខខណ្ឌដំបូងគឺ $u(0)=\frac{1}{2}\quad,\quad u'(0)=0 \qquad (10)$

លក្ខខណ្ឌទីពីរគឺបង្កប់ន័យដោយពាក្យ $(released)$ ក្នុងបញ្ហា ដែលយើងបកប្រែថា ម៉ាសត្រូវបានកំណត់ក្នុងចលនាដោយគ្មានល្បឿនចុងក្រោយ ។

***រំញ័រមិនបាត់បង់ថាមពល ( Undamped Free Vibrations )***

ប្រសិនបើគ្មានកម្លាំងក្រៅ នោះ $F(t)=0$ ក្នុងសមីការ $(7)$ យើងឧបមាថាគ្មានកម្លាំងលូត ដែល $\gamma=0$ នេះគឺជាចំណុចសំខាន់មួយនៃប្រព័ន្ធ កម្រអាចសម្រេចបានក្នុងការអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ បើកម្លាំងលូតកាន់តែតូច ការឧបមាប្រហែលគ្មានតម្លៃ ជាលទ្ធផលមធ្យមខ្លី។ នោះសមីការនៃ $(7)$ មកត្រឹមជា $mu''+ku=0 \qquad (11)$

ដំណោះស្រាយទូទៅនៃសមីការនៃ $(11)$ គឺ $u=A\cos\omega_0 t+B\sin\omega_0 t \qquad (12)$

ដែលមាន $$\omega_0^2 = \frac{k}{m} \qquad (13)$$
ចំនួនថេរ $A$, $B$ អាចគណនាតាមលក្ខខណ្ឌ តាមទម្រង់នៃសមីការ (8) ដែលបានផ្តល់ដោយ ។

ក្នុងការពិភាក្សារកដំណោះស្រាយនៃសមីការ (11) វាមានភាពងាយស្រួលក្នុងការសរសេរសមីការ (12) ក្នុងទម្រង់ $$u = R\cos(\omega_0 t - \delta) \qquad (14)$$
ឬ $$u = R\cos\delta\cos\omega_0 t + R\sin\delta\sin\omega_0 t \qquad (15)$$
ដោយប្រៀបធៀបសមីការ (15) ជាមួយសមីការ (12)

យើងរក $A$ , $B$ , $R$ , $\delta$ គឺទាក់ទងនឹងសមីការ $A = R\cos\delta$ , $B = R\sin\delta$ (16)

ដូច្នេះ $$R = \sqrt{A^2 + B^2} \quad , \quad \tan\delta = \frac{B}{A} \qquad (17)$$
ក្នុងការគណនា $\delta$ គេគិតលើកាជ្រង់ អាចកំណត់ដោយការពិនិត្យសញ្ញានៃ $\cos\delta$ និង $\sin\delta$ ក្នុងសមីការ (16)

ក្រាបនៃសមីការ (14) ឬសមមូលសមីការ (12) ជាធម្មតាសំណុំដំបូងនៃលក្ខខណ្ឌគឺត្រូវបានបង្ហាញក្នុងរូបភាព 3.8.3 ។ ក្រាបនៃ cos រាងជារលកដែលពណ៌ពីខួបឬអាក់ម៉ូនិកធម្មតាម៉ូតនៃម៉ាស់។

ខួបនៃអនុគមន៍គឺ $$T = \frac{2\pi}{\omega_0} = 2\pi\left(\frac{m}{k}\right)^{\frac{1}{2}} \qquad (18)$$
ប្រេកង់នៃរង្វង់ $\omega_0 = \sqrt{\frac{k}{m}}$ គិតជារ៉ាដ្យង់ក្នុងមួយឯកតា ហៅថា **ប្រេកង់ធម្មជាតិ** នៃរំញ័រ។ ការផ្លាស់ទីអតិបរមា $R$ នៃម៉ាស់ពីលំនឹងគឺ **អំព្លីទីត** ។ វិមាត្រប៉ារ៉ាម៉ែត្រ $\delta$ ហៅថា **ផាស** ឬមុំផាស និងរង្វាស់នៃបំលាស់ទីនៃរលកពីទីតាំងធម្មតារបស់វាគឺ $\delta = 0$ ។




ឧទាហរណ៍២៖ ឧបមាថាម៉ាសវត្ថុមួយមានទម្ងន់ $10\ lb$ លូតបាន $2\ inch$ ។ បើម៉ាសផ្លាស់ទីបន្ថែម $2\ inch$ ទៀតដោយចលនានៃល្បឿនចុះក្រោម $1\ ft/\sec$ គណនាទីតាំងនៃម៉ាស់ ខួប អំព្លីទុត និងផាសនៃចលនា ។

ថេរនៃរ៉ឺស័រគឺ $k = 10\ lb/2\ inch = 60\ lb/ft$ ហើយម៉ាស់គឺ $m = \frac{w}{g} = \frac{10}{32\ lb.\sec^2/ft}$

ដូច្នេះ សមីការនៃចលនាកំណត់ដោយ $u''+192u=0$ (19)

ហើយដំណោះស្រាយទូទៅគឺ $u=A\cos\left(8\sqrt{3}t\right)+B\sin\left(8\sqrt{3}t\right)$

ចម្លើយនៃមីការផ្ទៀងផ្ទាត់លក្ខខណ្ឌ $u(0)=\dfrac{1}{6\,ft}$ ហើយ $u'(0)=-1\,ft/\sec$

គឺ $u=\dfrac{1}{6}\cos\left(8\sqrt{3}t\right)-\dfrac{1}{8\sqrt{3}}\sin\left(8\sqrt{3}t\right)$ (20)

ប្រេកង់ធម្មជាតិគឺ $\omega_0=\sqrt{192}\cong 13.856\ rad/\sec$ នោះខួប $T=\dfrac{2\pi}{\omega_0}\cong 0.45345\sec$ អំព្លីទុត $R$ និង ផាស $\delta$ រកតាមសមីការ (17) យើងមាន $R^2=\dfrac{1}{36}+\dfrac{1}{192}=\dfrac{19}{576}$

ដូច្នេះ $R\cong 0.18162\ ft$

ដំណាក់កាលទីពីរនៃសមីការ (17) $\tan\delta=-\dfrac{\sqrt{3}}{4}$ ។ មានដំណោះស្រាយពីរ មួយក្នុងកាជ្រង់ទីពីរ ហើយមួយទៀតក្នុងកាជ្រង់ទីបួន។ បញ្ហាធម្មតា $\cos\delta>0$ , $\sin\delta<0$ ដូចនេះ $\delta$ ក្នុងកាជ្រង់ទីបួន ឱ្យដោយ $\delta=-arc\tan\left(\dfrac{\sqrt{3}}{4}\right)\cong -0.40864\ rad$

ក្រាបនៃចម្លើយរបស់សមីការ (20) គឺ




### *រំញ័រមិនបាត់បង់ថាមពល (Undamped Free Vibrations )*

សមីការឌីផេរ៉ង់ស្យែលនៃម៉ាស់គឺ $mu''+\gamma u'+ku=0$ (21)

យើងចាប់អារម្មណ៍ជាពិសេសលើឥទ្ធិពលនៃបម្រែបម្រួលរបស់ថេរ $\gamma$ សម្រាប់តម្លៃរបស់ម៉ាស់ $m$ ហើយនិងថេររ៉ឺស័រ $k$ ។ឫសរបស់សមីការគឺ

$$r_1\ ,\ r_2=\frac{-\gamma\pm\sqrt{\gamma^2-4km}}{2m}=\frac{\gamma}{2m}\left(-1\pm\sqrt{1-\frac{4km}{\gamma^2}}\right) \qquad (22)$$

ដោយអាស្រ័យ $\gamma^2-4km$ ដំណោះស្រាយ $u$ មួយឱ្យដោយទម្រង់

$$\gamma^2-4km>0\ ,\quad u=Ae^{r_1t}+Be^{r_2t} \qquad (23)$$

$$\gamma^2-4km=0\ ,\quad u=\left(A+Bt\right)e^{-\frac{\gamma t}{2m}} \qquad (24)$$

$$\gamma^2-4km<0\ ,\quad u=e^{-\frac{\gamma t}{2m}}\left(A\cos\mu t+B\sin\mu t\right)\ ,\ \mu=\frac{\left(4km-\gamma^2\right)^{\frac{1}{2}}}{2m}>0 \qquad (25)$$

ដូច្នេះ

1. $m\,,\gamma\,,k>0\ \gamma^2-4km<\ \gamma^2$
2. បើ $\gamma^2-4km\geq 0$ នោះតម្លៃនៃ $r_1\,,r_2$ ឱ្យដោយសមីការ $(22)$ គឺអវិជ្ជមាន
3. បើ $\gamma^2-4km<0$ នោះតម្លៃនៃ $r_1\,,r_2$ ជាកុំផ្លិចហើយផ្នែកពិតជាចំនួនអវិជ្ជមាន

ដូច្នេះ គ្រប់ករណី ដំណោះស្រាយ $u$ ខិតជិត $0$ , $t\to\infty$

ករណីដែលសំខាន់ក្នុងចំណោមបី ពេលកម្លាំងយឺតតូច ។ បើគេតាង $A=R\cos\delta$ , $B=R\sin\delta$ ក្នុងសមីការ $(25)$ នោះយើងទទួលបាន

$$u=Re^{-\frac{\gamma t}{2m}}\cos(\mu t-\delta)\qquad(26)$$

$u$ ផ្លាស់ទីចន្លោះខ្សែកោង $u=\pm Re^{-\frac{\gamma t}{2m}}$ ។ អំព្លីទុតកត្តា $R$ អាស្រ័យលើ $m\,,\gamma\,,k$ ហើយនិងលក្ខខណ្ឌដំបូង ។

ទោះបីជាចលនាមិនខួប ប៉ារ៉ាម៉ែត្រ $\mu$ គណនាប្រេកង់ជាមួយនឹងម៉ាស់ណាមួយលំយោលត្រឡប់ទៅមក ។ សន្និដ្ឋាន $\mu$ ហៅថា quasi frequency ។ ដោយការប្រៀបធៀប $\mu$ ជាមួយប្រេកង់ $\omega_0$ ដែលគ្មានចលនា យើងរកវាដោយ $\dfrac{\mu}{\omega_0}=\dfrac{\frac{\sqrt{4km-\gamma^2}}{2m}}{\sqrt{\frac{k}{m}}}=\left(1-\dfrac{\gamma^2}{4km}\right)^{\frac{1}{2}}\cong 1-\dfrac{\gamma^2}{8km}\qquad(27)$

តម្លៃប៉ាន់ស្មានត្រឹមត្រូវនៅពេលដែល $\dfrac{\gamma^2}{4km}$ តូច ។ តាមរយៈជាមួយសមីការ $(18)$ បរិមាណ $T_d=\dfrac{2\pi}{\mu}$ ហៅថា quasi period ។ វាជាពេលនៅចន្លោះអតិបរមាឬអប្បបរមានៃទីតាំងនៃម៉ាស់ ។ ទំនាក់ទំនងរវាង $T_d$ និង $T$ ឱ្យដោយ

$$\frac{T_d}{T}=\frac{\omega_0}{\mu}=\left(1-\frac{\gamma^2}{4km}\right)^{-\frac{1}{2}}\cong\left(1+\frac{\gamma^2}{8km}\right)\qquad(28)$$



ការប៉ាន់ស្មានត្រឹមត្រូវនៅពេលដែល $\frac{\gamma^2}{4km}$ តូច ។ ដូច្នេះ តម្លៃធ្លាក់តូចកើនឡើង quasi period

សមីការ (27) និង (28) ពង្រឹងសារៈសំខាន់រិមាត្រសមាមាត្រ $\frac{\gamma^2}{4km}$ ។ ពេល $\frac{\gamma^2}{4km}$ តូចនោះ យើងអាចធ្វើឱ្យមានឥទ្ធិពលលើការទម្លាក់ក្នុងការគណនា quasi frequency និង quasi period នៃចលនា ។ $\frac{\gamma^2}{4km}$ កើនឡើង quasi frequency $\mu$ ថយចុះហើយ quasi period $T_d$ កើនឡើង ។ តាមពិតទៅ $\mu \to 0$ ហើយ $T_d \to \infty$ គឺ $\gamma \to 2\sqrt{km}$ ។




**ឧទាហរណ៍**៖ចលនានៃម៉ាស់រ៉ឺស័រមួយប្រព័ន្ធកំណត់ដោយសមីការឌីផេរ៉ង់ស្យែល

$u''+0.125u'+u=0$ (29)

វង្វាស់ $u$ គិតជាហ្វីតហើយ $t$ គិតជាវិនាទី ។ រកប្រេកង់ quasi និង ខួប quasi ស្របពេលដែលម៉ាស់ប៉ះផ្ទាល់ទៅលើទីតាំងលំនឹងរបស់វា ។ ហើយរកថេរពេល $\tau$ ដែល $|u(t)|<0.1$ គ្រប់ $t>\tau$ ។

ដំណោះស្រាយ

$$u=e^{-\frac{t}{16}}\left[A\cos\frac{\sqrt{255}}{16}t+B\sin\frac{\sqrt{255}}{16}t\right]$$

ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌដំបូង យើងយក ដំណោះ $A=2$ , $B=\frac{2}{\sqrt{255}}$ ស្រាយនៃបញ្ហាដំបូងមានតម្លៃ

$$u=e^{-\frac{t}{16}}\left(2\cos\frac{\sqrt{255}}{16}t+\frac{2}{\sqrt{255}}\sin\frac{\sqrt{255}}{16}t\right)$$

$$=\frac{32}{\sqrt{255}}e^{-\frac{t}{16}}\cos\left(\frac{\sqrt{255}}{16}t-\delta\right) \qquad (30)$$




$\tan\delta = \frac{1}{\sqrt{255}}$ នោះ $\delta \cong 0.06254$ ។ បំលាស់ទីនៃម៉ាស់ជាអនុគមន៍ពេល បង្ហាញក្នុងរូបភាព 3.8.7 ។ ប្រេកង់ quasi គឺ $\mu = \frac{\sqrt{255}}{16} \cong 0.998$ ហើយ ខួប quasi គឺ $T_d = \frac{2\pi}{\mu} \cong 6.295\sec$ ។

រូបភាព 3.8.8 បង្ហាញពីក្រាបនៃដំណោះស្រាយរបស់ $40 \le t \le 60$ ក្រាបទាំងអស់នៃ $u = \pm 0.1$ ។ ទម្រង់ក្រាបរបស់វាលេចឡើងដែល $\tau$ អំពី 47.5 ហើយដំណោះស្រាយច្បាស់លាស់ យើងរក $\tau \cong 47.5149\sec$ ។

ដើម្បីរកពេលណាមួយដែលម៉ាស់ប៉ះដំបូងទៅនឹងទីតាំងលំនឹង យើងយោងទៅតាមសមីការ (30) ហើយ $\frac{\sqrt{255}t}{16} - \delta = \frac{\pi}{2}$ រិដ្ឋមានសូន្យតូចបំផុតនៃអនុគមន៍កូស៊ីន ។ នោះដំណោះស្រាយ $t$ ផ្តល់ឱ្យយើងដោយ

$$t = \frac{16}{\sqrt{255}}\left(\frac{\pi}{2} + \delta\right) \cong 1.637\sec$$



**Electric Circuits សៀគ្វីអគ្គិសនី** ឧទាហរណ៍ទី២កើតឡើងពីសមីការឌីផេរ៉ង់ស្យែលលំដាប់ពីរជាមួយនឹងចំនួនថេរ គឺជាគំរូនៃលំហូរនៃអគ្គិសនីសៀគ្វីតជាសេរីបង្ហាញក្នុងរូបភាព 3.8.9 ។ $I$ គិតជាអំពែ $(A)$ ជាអនុគមន៍នៃពេល $t$ ។ រេស៊ីស្តង់ $R$ គិតជាអូម $(ohms)$ កាប៉ាស៊ីតេ $C$ គិតជាផារ៉ាត $(farads)$ និងអាំងឌុចតង់ $L$ គិតជា $(henry)$ គឺវិជ្ជមាន ហើយឧបមាថាស្គាល់ចំនួនថេរ ។ $E$ $(volts)$ ឱ្យដោយអនុគមន៍នៃពេល ។ ក្នុងបរិមាណរូបវិទ្យាផ្សេងទៀតដែលពិភាក្សាគឺ $Q$ $(coulombs)$ លើកាប៉ាស៊ីតេនៃពេល $t$ ។ ទំនាក់ទំនងរវាង $Q$ និង $I$ គឺ

$$I=\frac{dQ}{dt} \qquad (31)$$




លំហូរនៃសៀគ្វីគោរពតាមច្បាប់ទីពីរ *Kirchhoff* ក្នុងសៀគ្វីបិទ តង់ស្យុងអគ្គិសនីស្មើនឹងផលបូកនីមួយៗនៃតង់ស្យុងដែលរត់ទៅតាមសៀគ្វី។យោងទៅលើច្បាប់បឋមនៃអគ្គិសនី យើងស្គាល់ថា

តង់ស្យុងទម្លាក់ទៅតាមរេស៊ីស្តង់គឺ $IR$

តង់ស្យុងទម្លាក់ទៅតាមកាប៉ាស៊ីតេគឺ $\frac{Q}{C}$

តង់ស្យុងទម្លាក់ទៅតាមអាំងឌុចតង់គឺ $L\frac{dI}{dt}$

ដូច្នេះ តាមតាមច្បាប់ *Kirchhoff*

$$L\frac{dI}{dt}+RI+\frac{1}{C}Q=E(t) \qquad (32)$$

ឯកតា $1\,volt=1\,ohm\cdot 1\,ampere=1coulomb/1\,farard=1henry\cdot 1ampere/1\sec$

ជំនួស $I$ ពីសមីការ (31) យើងផ្តល់សមីការឌីផេរ៉ង់ស្យែល

$$LQ''+RQ'+\frac{1}{C}Q=E(t) \qquad (33)$$

សម្រាប់បន្ទុកអគ្គិសនី $Q$ លក្ខខណ្ឌដើមគឺ

$$Q(t_0)=Q_0 \quad , \quad Q'(t_0)=I(t_0)=I_0 \qquad (34)$$

ជាជម្រើសយើងអាចផ្តល់សមីការឌីផេរ៉ង់ស្យែលសម្រាប់ចរន្ត $I$ ដោយការធ្វើឌីផេរ៉ង់ស្យែលសមីការ (33) ធៀបនឹង $t$ ហើយជំនួស $\frac{dQ}{dt}$ ពីសមីការ (31) ។ ជាលទ្ធផលគឺ

$$LI''+RI'+\frac{1}{C}I=E'(t) \qquad (35)$$

លក្ខខណ្ឌដើម

$I(t_0)=I_0 \quad , \quad I'(t_0)=I_0^{'} \qquad (36)$

ពីសមីការ (32) វាដើរតាម

$$I_0^{'}=\frac{E(t_0)-RI_0-\left(\frac{I}{C}\right)Q_0}{L} \qquad (37)$$

ដូច្នេះ $I_0^{'}$ គឺគណនាដោយបន្ទុកអគ្គិសនីដើមនិងចរន្តដើមណាមួយគឺជាបរិមាណរង្វាស់នៃរូបវិទ្យា

## ៣.៩. កម្លាំងលំញ័រ (Forced Vibrations)

ពិចារណាក្នុងករណីដែលកម្លាំងខួបក្រៅ $F_0\cos\omega t$ ដែល $w>0$ គឺអនុវត្តចំពោះប្រព័ន្ធម៉ាសរ៉ូស័រ (spring-mass)។ គេបានសមីការចលនាគឺ

$$mu''+yu'+ku=F_0\cos\omega t \qquad (1)$$

ដំបូងឧបមាថាគ្មានដាម(damping) នោះសមីការ(1)ប្រែទៅជា

$$mu''+ku=F_0\cos\omega t \qquad (2)$$

បើ $\omega_0=\sqrt{k/m}\neq\omega$ នោះដំណោះស្រាយជាទូទៅនៃសមីការ(2)គឺ

$$u=c_1\cos\omega_0 t+c_2\sin\omega_0 t+\frac{F_0}{m\left(\omega_o^2-\omega^2\right)}\cos\omega t \qquad (3)$$

អថេរ $c_1$ និង $c_2$ ត្រូវបានកំណត់ដោយលក្ខខណ្ឌដើម។ ជាទូទៅ ចលនាដែលកើតពីផលបូកនៃចលនាខួបពីរនៃប្រេកង់ខុសគ្នា ( $\omega_0$ និង $\omega$ )និងអំព្លីទុត មានការចាប់អារម្មណ៍ជាពិសេសចំនួនពីរករណីៈ Beats ឧបមាថាដំបូងម៉ាសគឺសល់ ដូចនេះ $u(0)=0$ និង $u'(0)=0$ ។ នោះអថេរ $c_1$ និង $c_2$ ក្នុងសមីការ (3)គេបាន

$$c_1=-\frac{F_0}{m\left(\omega_0^2-\omega_0\right)}, \quad c_2=0 \qquad (4)$$

ដំណោះស្រាយនៃសមីការ(2)គឺ

$$u=\frac{F_0}{m\left(\omega_0^2-\omega_0\right)}\left(\cos\omega t-\cos\omega_0 t\right) \qquad (5)$$

នេះគឺជាផលបូកនៃអនុគមន៍ខួបពីរនៃខួបខុសគ្នា ប៉ុន្តែមានអំព្លីទុតដូចគ្នា។ ប្រើប្រាស់លក្ខណៈត្រីកោណមាត្រសម្រាប់ $\cos(A\pm B)$ដែល $A=(\omega_0+\omega)t/2$ និង $B=(w_0-w)t/2$ ។

យើងអាចសរសេរសមីការ(5)ក្នុងទម្រង់

$$u=\left[\frac{2F}{m\left(\omega_0^2-\omega^2\right)}\sin\frac{(\omega_0-\omega)t}{2}\right]\sin\frac{(\omega_0+\omega)t}{2} \qquad (6)$$

បើ $|\omega_0-\omega|$ តូច នោះ $\omega_0+\omega$ គឺធំជាង $|\omega_0-\omega|$ ។ $\sin(\omega_0+\omega)t/2$ គឺជាអនុគមន៍លំយោលលឿនប្រៀបធៀបជាមួយ $\sin(\omega_0-\omega)t/2$ ។ ដូចនេះ ចលនាគឺជាលំយោលលឿនជាមួយប្រេកង់ តែអំព្លីទុតស៊ីនុសសូអ៊ីតផ្លាស់ប្តូរយឺត

$$\frac{2F_0}{m\left(\omega_0^{\,2}-\omega^2\right)}\sin\frac{\left(\omega_0-\omega\right)t}{2}$$

ផ្នែកនៃចលនានេះ មានបម្រែបម្រួលខួបនៃអំព្លីទុត ហៅថា Beat។ បាតុភូតនេះកើតឡើងនៅក្នុងសូរស័ព្ទ ពេលដែលចំណុចរបត់ពីរមានប្រេកង់ជិតស្មើគ្នាត្រូវបានបន្លឺឡើងក្នុងពេលដំណាលគ្នា។ ក្នុងករណីនេះ បម្រែបម្រួលខួបនៃអំព្លីទុតគឺវាច្បាស់លាស់ចំពោះត្រចៀកដែលគ្មានជំនួយ។ នៅក្នុងអេឡិចត្រូនិចបម្រែបម្រួលនៃអំព្លីទុតជាមួយពេលវេលាត្រូវបានហៅថាម៉ូឌុលអំព្លីទុត ( amplitude modulation)។ ក្រាបនៃ $u$ ដូចដែលបានឱ្យក្នុងសមីការ (6) ក្នុងករណីធម្មតាត្រូវបានបង្ហាញក្នុងរូបភាព3.9.1។

រូបភាព3.9.1 Beat $u''+u=0.5\cos 0.8t, u\left(0\right)=0, u'\left(0\right)=0;\ u=2.77778\sin 0.1t\sin 0.9t$




**អនុភាព** ដូចក្នុងឧទាហរណ៍ទី២ ពិចារណាក្នុងករណី $\omega=\omega_0$ នោះប្រេកង់នៃអនុគមន៍កម្លាំងគឺដូចគ្នាទៅនឹងប្រេកង់ដើមនៃប្រព័ន្ធ។ នោះក្រុមមិនអូម៉ូសែន $F_0\cos\omega t$ គឺជាដំណោះស្រាយនៃសមីការអូម៉ូសែន។ ក្នុងករណីនេះ ដំណោះស្រាយនៃសមីការ$(2)$គឺ

$$u=c_1\cos\omega_0 t+c_2\sin\omega_0 t+\frac{F_0}{2m\omega_0}t\sin\omega_0 t \qquad (7)$$

ពីព្រោះតែក្រុម $t\sin\omega_0 t$ ដំណោះស្រាយ (7) សន្មតថាខួបនឹងក្លាយជាមិនទ័ល $t\to\infty$ ដោយមិនគិតតម្លៃ$c_1$ និង $c_2$ ក្នុងរូប3.9.2សម្រាប់ឧទាហរណ៍សាមញ្ញ។ ជាក់ស្តែងមិនទ័ល លំយោលមិនកើតឡើង។ ពេលនោះ $u$ ប្រែជាធំ ម៉ូដែលគណិតវិទ្យាក្នុងសមីការ$(1)$ មានមូលដ្ឋានគឺគ្មានសុពលភាពខ្ពស់ដោយការសន្មតថាកម្លាំងរ៉ូស័រ អាស្រ័យលីនេអ៊ែរលើការផ្លាស់ទីដែលទាមទា$u$ តូច។ ប្រសិនការដាមរួមបញ្ចូលក្នុងម៉ូដែលសន្មតថាខួបទ័ល។ យ៉ាងណាមិញឆ្លើយតបទៅនឹងអនុគមន៍ Input ប្រហែលជាធំបន្តិចប្រសិនបើដាមតូចគឺនៅជិត។ បាតុភូតនេះ ត្រូវបានស្គាល់ថាជា**អនុភាព**។

អនុភាពអាចល្អឬអាក្រក់អាស្រ័យលើកាលៈទេសៈ។ វាត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការរចនានៃរចនាសម្ព័ន្ធអគារ ឬស្ពានដែលជាកន្លែងអាចបង្កើតអស្ថិរភាពដែលអាចឱ្យបរាជ័យនៃរចនាសម្ព័ន្ធ។




រូបភាព 3.9.2 អនុភាព $u''+u=0.5\cos t, u(0)=0, u'(0)=0; u=0,25t\sin t$

***កម្លាំងលំញ័រដែលដាម*** (Forced Vibrations with Damping) ខួបនៃប្រព័ន្ធម៉ាសរ៉ឺស័រដែលដាមនិងអនុគមន៍ខួប $F_o\cos\omega t$ អាចកំណត់តាមរបៀបធ្វើបែបត្រង់ៗងាយៗ ទោះបីជាការគណនាវែងបន្តិច។ ដំណោះស្រាយនៃសមីការ $(1)$ គឺ

$$u=c_1e^{r_1t}+c_2e^{r_2t}+R\cos(\omega t-\delta),\ r_1\neq r_2 \qquad (8)$$

ដែល
$$R=\frac{F_0}{\Delta},\quad \cos\delta=\frac{m\left(\omega_0^{\ 2}-\omega^2\right)}{\Delta},\quad \sin\delta=\frac{\gamma\omega}{\Delta} \qquad (9)$$

និង
$$\Delta=\sqrt{m^2\left(\omega_0^{\ 2}-\omega^2\right)^2+\gamma^2\omega^2} \qquad (10)$$

នៅក្នុងសមីការ (8) $r_1$ និង $r_2$ គឺជាការរនៃការផ្តុំអនុគមន៍សម្គាល់ក្នុងសមីការ $(1)$ ពួកវាប្រហែលជាចំនួនពិតអវិជ្ជមាន និងកុំផ្លិចឆ្លាស់ដែលផ្នែកពិតអវិជ្ជមាន។ ក្នុងករណីនេះ ទាំង $\exp(r_1t)$ និង $\exp(r_2t)$ ខិតជិត0 , $t\to\infty$។ ដូចនេះ $t\to\infty$

$$u\to U(t)=\frac{F_0}{\sqrt{m^2\left(\omega_0^{\ 2}-\omega^2\right)^2+\gamma\omega^2}}\cos(\omega t-\delta) \qquad (11)$$

សម្រាប់ហេតុផលនេះ $u_c(t)=c_1e^{r_1t}+c_2e^{r_2t}$ ត្រូវបានហៅថាដំណោះស្រាយបណ្តោះអាសន្ន (transient solution) ,$U(t)$ដែលតាងឱ្យលំយោលនឹងមានប្រេកង់ដូចគ្នានឹងកម្លាំងក្រៅត្រូវបានហៅថាដំណោះស្រាយស្ថេតនឹង( steady-state solution) ឬកម្លាំងឆ្លើយតប ( forced response)។ ដំណោះស្រាយបណ្តោះអាសន្នជួយយើងឱ្យផ្ទៀងផ្ទាត់លក្ខខណ្ឌដើមត្រូវបានគាំទ្រ។ ការបង្កើនពេលវេលាក្នុងប្រព័ន្ធដោយបំលាស់ទីដើមនិងល្បឿនត្រូវបាត់បង់ដោយកម្លាំងដាម និងចលនា នោះក្លាយជា

ការឆ្លើយតបក្នុងប្រព័ន្ធទៅកម្លាំងក្រៅ។ ដោយគ្មានការជាមឥទ្ធិពលនៃលក្ខខណ្ឌដើមស្ថិតនៅគ្រប់ពេល។

វាពិតជាគួរឱ្យចាប់អារម្មណ៍ដើម្បីស្វែងរករបៀបដែលអំព្លីទុត $R$ នៃលំយោលស្ថេតនឹង (steady-state oscillation) ផ្តោតលើប្រេកង់ $\omega$ នៃកម្លាំងក្រៅ។ សម្រាប់រំញោចប្រេកង់ទាបនោះ $\omega \to 0$ តាមសមីការ $(9)$ និង $(10)$ ដែល $R \to F_0 / k$ ។ សម្រាប់រំញោចប្រេកង់ខ្ពស់ សមីការ $(9)$ និង $(10)$ កំណត់ថា $R \to 0, \omega \to \infty$ ។ តម្លៃមធ្យមនៃ $\omega$ អំព្លីទុតមានតម្លៃអតិបរមា។ ដើម្បីរកចំណុចអតិបរមា យើងអាចញែកឱ្យឃើញ $R$ ចំពោះ $\omega$ និងកំណត់លទ្ធផលឱ្យស្មើសូន្យ។ វិធីនេះ យើងអាចរកឃើញអំព្លីទុតអតិបរមាកើតឡើងពេល $\omega = \omega_{\max}$ ដែល

$$\omega_{\max}^2 = \omega_0^2 - \frac{\gamma}{2m^2} = \omega_0^2 \left(1 - \frac{\gamma}{2km}\right) \qquad (12)$$

ចំណាំ $\omega_{\max} < \omega_0$ និង $\omega_{\max}$ ខិតជិត $\omega_0$ ពេល $\gamma$ តូច។ តម្លៃអតិបរមានៃ $R$ គឺ

$$R_{\max} = \frac{F_0}{\gamma\omega_0 \sqrt{1 - \left(\gamma^2 / 4mk\right)}} \cong \frac{F_0}{\gamma\omega_0}\left(1 + \frac{\gamma^2}{8mk}\right) \qquad (13)$$

ការបង្ហាញចុងក្រោយគឺជាការប្រៀបធៀបសម្រាប់ $\gamma$ ។ បើ $\gamma^2 / 2km > 1$ នោះ $\omega_{\max}$ ដូចក្នុងសមីការ $(12)$ គឺនិមិត្ត។ ក្នុងករណីនេះ តម្លៃអតិបរមានៃ $R$ កើតឡើងសម្រាប់ $\omega = 0$ និង $R$ គឺអនុគមន៍ម៉ូណូតូនកើននៃ $\omega$ ។ សម្រាប់ $\gamma$ តូច តាមសមីការ $(13)$ ដែល $R_{\max} \cong F_0 / \gamma\omega_0$ ។ ដូចនេះ អតិបរមាឆ្លើយតបគឺធំជាងអំព្លីទុត $F_0$ នៃកម្លាំងក្រៅនិងតូចជាងតម្លៃនៃ $\gamma$ ធំជាងផលធៀប $R_{\max} / F_0$ ។ រូបភាព3.9.3 មានក្រាហ្វតំណាងនៃ $Rk / F_0$ ជាប់នឹង $\omega / \omega_0$ សម្រាប់តម្លៃបីបួននៃ $\gamma$ ។

មុំផាស $\delta$ អាស្រ័យលើការចាប់អារម្មណ៍លើ $\omega$ ។ សម្រាប់ $\omega$ ជិតសូន្យ តាមសមីការ $(9)$ និង $(10)$ ដែល $\cos\delta \cong 1$ និង $\sin\delta \cong 0$ ។ ដូចនេះ $\delta \cong 0$ ចម្លើយនៅជិតផាសដែលរំញោច មានន័យថាវាកើននិងចុះទាំងអស់ ហើយឧបមាថាជិតអតិបរមានិងអប្បបរមាទាំងអស់។ សម្រាប់ $\omega = \omega_0$ យើងរកថា $\cos\delta = 0$ និង $\sin\delta = 1$ ដូចនេះ $\delta = \frac{\pi}{2}$ ។ ក្នុងករណីនេះ ការឆ្លើយតបយឺតយ៉ាវក្រោយរំញោចដោយ $\frac{\pi}{2}$ នោះកំពូលនៃចម្លើយបាន $\frac{\pi}{2}$ យឺតជាងកំពូលនៃរំញោចហើយស្រដៀងសម្រាប់ជ្រលង។ ចុងក្រោយសម្រាប់ $\omega$ ធំ យើងមាន $\cos\delta \cong -1$ និង $\sin\delta \cong 0$ ។ ដូចនេះ $\delta \cong \pi$ នោះចម្លើយគឺជិតផាស មានន័យថាចម្លើយអប្បបរមាពេលរំញោចគឺអតិបរមានិងផ្ទុយមកវិញ។

ក្នុងរូប3.9.4 យើងបង្ហាញក្រាហ្វនៃដំណោះស្រាយនៃតម្លៃបញ្ហាដើម

$$u'' + 0.125u' + u = 3\cos 2t, \;\; u(0) = 2, \;\; u'(0) = 0$$

ក្រាហ្វនៃអនុគមន៍កម្លាំងត្រូវបានបង្ហាញសម្រាប់ប្រៀបធៀប។ សង្កេតឃើញថាចលនាបណ្តោះអាសន្នដំបូងត្រូវបំផ្លាញដោយកើតឡើង នោះអំព្លីទុតនៃកម្លាំងនឹងឆ្លើយតបគឺខិតជិត $1$ និងផាសក្នុងគ្នាចម្លោះរំញោច (excitation) និងចម្លើយ (response) ខិតជិត $\pi$ ។




រូបភាព3.9.3 កម្លាំងលំញ័រដែលដាម អំព្លីទុតនៃស្ថេតនឹងឆ្លើយតបធៀបនឹងប្រេកង់នៃកម្លាំងជម្រុញ $\Gamma = \gamma^2 / m^2\omega_0^{\ 2}$

រូបភាពខាងលើ កម្លាំងលំញ័រដែលដាម $u'' + 0.125u' + u = 3\cos 2t, u(0) = 2, u'(0) = 0$ បន្ថែមពីនោះ យើងរកថា $\Delta = \sqrt{145}/4 \cong 3.0104$ នោះ $R = F_0 / \Delta \cong 0.9965$ ។ បន្ថែមទៀត $\cos\delta = -3/\Delta \cong -0.9965$ និង $\sin\delta = 1/4\Delta \cong 0.08305$ នោះ $\delta \cong 3.0585$ ។ ដូចនេះ ការគណនាតម្លៃនៃ $R$ និង $\delta$ គឺជិតតម្លៃប៉ាន់ស្មានតាមរយៈក្រាហ្វ។

**លំហាត់**

លំហាត់ទី1ដល់4 បង្ហាញផលគុណនៃអនុគមន៍ត្រីកោណមាត្រពីរនៃប្រេកង់ខុសគ្នា។



1. $\cos 9t-\cos 7t$
2. $\sin 7t-\sin 6t$
3. $\cos \pi t+\cos 2\pi t$
4. $\sin 3t+\sin 4t$
5. ម៉ាសទម្ងន់ $4lb$ ពន្លាតរ៉ូស័រ $1.5in$ ។ ម៉ាសត្រូវបានប្តូរជា $2in$ ក្នុងទិសដៅវិជ្ជមានពីទីតាំងលំនឹងរបស់វា ហើយបញ្ចេញដោយគ្មានល្បឿនដើម។ សន្មតថាគ្មានដាមហើយម៉ាសត្រូវបានធ្វើសកម្មភាពដោយកម្លាំងក្រៅនៃ $2\cos 3t\ lb$ ។ បង្កើតបញ្ហាតម្លៃដើមដែលបកស្រាយពីខួបនៃម៉ាស។
6. ម៉ាស $5kg$ ពន្លាតរ៉ូស័រ $10cm$ ។ ម៉ាសត្រូវបានធ្វើសកម្មភាពដោយកម្លាំងក្រៅ $10\sin(t/2)N$ និងផ្លាស់ទីល្មមក្នុងកម្លាំងកកិត $2N$ នៅពេលល្បឿននៃម៉ាសគឺ $3cm/\sec$ ។ បង្កើតបញ្ហាតម្លៃដើមដែលបកស្រាយពីខួបនៃម៉ាស។
7. a. រកដំណោះស្រាយនៃលំហាត់ទី5។

   b. ដៅក្រាបនៃដំណោះស្រាយ។

   c. បើគេឱ្យកម្លាំងក្រៅត្រូវបានជំនួសដោយកម្លាំង $4\sin \omega t$ នៃប្រេកង់ $\omega$ រកតម្លៃនៃ $\omega$ ពេលអនុភាពកើតឡើង។
8. a. រកដំណោះស្រាយនៃបញ្ហាតម្លៃដើមក្នុងលំហាត់ទី6។

   b. កំណត់ចម្លើយទូទៅបណ្តោះអាសន្ន និងចម្លើយជាក់លាក់។

   c. សង់ក្រាបនៃចម្លើយជាក់លាក់។

   d. បើគេឱ្យកម្លាំងក្រៅត្រូវបានជំនួសដោយកម្លាំង $2\cos \omega t$ នៃប្រេកង់ $\omega$ រកតម្លៃនៃ $\omega$ ដែលកម្លាំងឆ្លើយតបគឺអតិបរមា។
9. បើប្រព័ន្ធម៉ាសរ៉ូស័រគ្មានដាមជាមួយម៉ាស $6lb$ និងរ៉ូស័រ $1lb/in$ ពេលនោះកំណត់ខួប $t=0$ ដោយកម្លាំងក្រៅ $4\cos 7t\ lb$ ។ កំណត់ទិសដៅម៉ាសពេលផ្សេងទៀតនិងគូសក្រាបនៃបំលាសើទីធៀបនឹង $t$ ។
10. ម៉ាស $8lb$ ពន្លាតរ៉ូស័រ $6in$ ។ ប្រព័ន្ធត្រូវបានធ្វើសកម្មភាពដោយកម្លាំងក្រៅ $8\sin 8t\ lb$ ។ បើម៉ាសត្រូវបានទាញទម្លាក់ $3in$ និងលែងចេញ កំណត់ទិសដៅម៉ាសពេលផ្សេងទៀត។ កំណត់ពេលដំបូងបួនដងខណៈពេលល្បឿនម៉ាសស្មើសូន្យ។
11. រ៉ូស័រត្រូវបានពន្លាត $6in$ ដោយទម្ងន់ម៉ាស $8lb$ ។ ម៉ាសត្រូវបានភ្ជាប់នឹងទម្រ ដែលមានការកម្លាំងទប់ $0.25lb-\sec/\ ft$ និងត្រូវបានធ្វើសកម្មភាពដោយកម្លាំងក្រៅ $4\cos 2t\ lb$ ។

a. កំណត់ ចម្លើយជាក់លាក់ត្រូវនឹងប្រព័ន្ធ។

b. បើគេជំនួសម៉ាសដោយម៉ាស $m$ កំណត់តម្លៃនៃ $m$ សម្រាប់អំព្លីទុតនៃចម្លើយជាក់លាក់អប្បបរមា។

12. ប្រព័ន្ធម៉ាសរ៉ូស័រមានផ្ទុករ៉ូស័រ។ ម៉ាសត្រូវបានភ្ជាប់ទៅនឹងរ៉ូស័រនិងចលនាកើតឡើងក្នុងសារធាតុរាវ viscousដែលផ្តល់នូវភាពធន់ជាលេខស្មើនឹងទំហំនៃល្បឿនភ្លាមៗ។ បើប្រព័ន្ធត្រូវបានដឹកនាំដោយកម្លាំងក្រៅ $3\cos 3t - 2\sin 3t\ N$ កំណត់ ចម្លើយជាក់លាក់។ បង្ហាញចម្លើយរបស់អ្នកក្នុងទម្រង់ $R\cos(\omega t - \delta)$។

13. ប្រាប់ព័ត៌មានលម្អិតក្នុងការកំណត់ ចម្លើយជាក់លាក់ តាមសមីការ $(11)$ គឺអតិបរមា។ បង្ហាញថា $\omega_{\max}^2$ និង $R_{\max}$ ដែលឱ្យក្នុងសមីការ $(12)$ និង $(13)$។

14. a. បង្ហាញថាផាសនៃកម្លាំងឆ្លើយតបនៃសមីការផ្ទៀងផ្ទាត់។

b. ដៅផាស $\delta$ ដូចអនុគមន៍នៃកម្លាំងប្រេកង់ $\omega$ សម្រាប់កម្លាំងឆ្លើយតបនៃ $u'' + 0.125u' + u = 3\cos\omega t$។

15. រកដំណោះស្រាយនៃបញ្ហាតម្លៃដើម $u'' + u = F(t),\ u(0) = 0,\ u'(0) = 0$

ដែល $F(t) = \begin{cases} F_0 t, & 0 \le t \le \pi \\ F_0(2\pi - t), & \pi < t \le 2\pi \\ 0, & 2\pi < t \end{cases}$

ចាត់ទុករាល់ចន្លោះពេលដាច់ដោយឡែកពីគ្នា និងផ្គូផ្គងដំណោះស្រាយក្នុងចន្លោះពេលផ្សេងៗគ្នាដោយឱ្យ $u$ និង $u'$ ជាអនុគមន៍នៃ $t$។

16. សៀគ្វីនៃសេរីមានកាប៉ាស៊ីតេ $0.25\times10^{-6}F$ រេស៊ីស្តង់ $5\times10^{3}\Omega$ អាំងឌុចទ័រ $1H$។ កាប៉ាស៊ីតេដំបូងគឺសូន្យ។ បើថ្ម $12V$ ត្រូវបានភ្ជាប់ទៅនឹងសៀគ្វីនិងសៀគ្វីបិទខណៈ $t = 0$។ កំណត់កាប៉ាស៊ីតេខណៈ $t = 0.001\sec$, $t = 0.01\sec$, ពេល $t$ និងលីមីត $t \to \infty$។

17. ពិចារណាប្រព័ន្ធលំញ័រ បកស្រាយដោយបញ្ហាតម្លៃដើម (initial value problem)

$$u'' + \frac{1}{4}u' + 2u = 2\cos\omega t,\quad u(0) = 0,\ u'(0) = 2$$

a. កំណត់ផ្នែកដំណោះស្រាយចម្លើយជាក់លាក់។ ។

b. រកអំព្លីទុត $A$ នៃដំណោះស្រាយចម្លើយជាក់លាក់ ក្នុងក្រុម $\omega$។

c. ដៅ $A$ ធៀប $\omega$។

d. រកតម្លៃអតិបរមានៃ $A$ និងប្រេកង់ $\omega$ ដែលកើតឡើង។

18. ពិចារណាកម្លាំងតែប្រព័ន្ធគ្មានដាម បកស្រាយដោយបញ្ហាតម្លៃដើម (initial value problem)

$u'' + u = 3\cos \omega t, \quad u(0) = 0, \;\; u'(0) = 0$

a. រកដំណោះស្រាយនៃ

b. ដៅដំណោះស្រាយ $u(t)$ ធៀបនឹង $t$ សម្រាប់ $\omega = 0.7, \; \omega = 0.8$ និង $\omega = 0.9$ ។ ស្រាយពីរបៀបចម្លើយ $u(t)$ ប្តូរជា $\omega$ ប្រែប្រួលក្នុងចន្លោះពេលនេះ។ តើមានអ្វីកើតឡើងពេល $\omega$ តម្លៃកាន់តែខិតជិត $1$ ? ចំណាំថាប្រេកង់ដើមនៃប្រព័ន្ធគ្មានកម្លាំងគឺ $\omega_0 = 1$ ។

19. ពិចារណាប្រព័ន្ធកម្លាំង បកស្រាយដោយបញ្ហាតម្លៃដើម (initial value problem)

$u'' + u = 3\cos \omega t, \quad u(0) = 1, \;\; u'(0) = 1$

a. រកដំណោះស្រាយសម្រាប់ $\omega \neq 1$

b. ដៅដំណោះស្រាយ $u(t)$ ធៀបនឹង $t$ សម្រាប់ $\omega = 0.7, \; \omega = 0.8$ និង $\omega = 0.9$ ។ ធៀបលទ្ធផលជាមួយលំហាត់ទី១៨ បកស្រាយពីឥទ្ធិពលនៃលក្ខខណ្ឌដើមមិនសូន្យ។

20. សម្រាប់បញ្ហាតម្លៃដើម (initial value problem)ក្នុងលំហាត់ទី១៨ ដៅធៀបសម្រាប់ $\omega = 0.7, \; \omega = 0.8$ និង $\omega = 0.9$ ។ គូសដៅផាសនៃដំណោះស្រាយសម្រាប់តម្លៃ $\omega$ ។ ប្រើចន្លោះពេលគឺគ្រប់គ្រាន់ នោះផាសលិចឡើងជិតខ្សែកោង។ ត្រូវប្រាកដថាខ្សែកោងជាមួយនឹងព្រួញដើម្បីបង្ហាញទិសដៅត្រូវបានឆ្លងកាត់នៅពេល $t$ កើនឡើង។

លំហាត់២១ដល់២៣ដោះស្រាយបញ្ហាតម្លៃដើម (initial value problem)ក្នុងលំហាត់នីមួយៗខាងក្រោម

a. ដៅអនុគមន៍កម្លាំង $F(t)$ ធៀបនឹង $t$ និងដៅដំណោះស្រាយ $u(t)$ ធៀបនឹង $t$ នៅលើអ័ក្សតែមួយ។ ប្រើចន្លោះពេល $t$ ដូចនេះ initial transient ត្រូវបានលុបចោល។ សង្កេតទំនាក់ទំនងចន្លោះអំព្លីទុតនិងផាសនៃក្រុមកម្លាំងនិង អំព្លីទុតនិងផាសនៃអនុភាព។ ចំណា $\omega_0 = \sqrt{k/m} = 1$

b. គូសដៅផាស (phase plot) ដែល plot $u'$ ធៀបនឹង $u$ ។

21. $F(t) = 3\cos t$

22. $F(t) = 3\cos 3t$

23. $F(t) = 3\cos(0.3t)$

# ជំពូកទី៤ សមីការឌីផេរ៉ង់ស្យែលលំដាប់ខ្ពស់

ទ្រឹស្តីបទ និងវិធីសាស្ត្រ នៃដំណោះស្រាយដែលបានមាននៅក្នុងជំពូកមុន សម្រាប់សមីការលីនេអ៊ែរលំដាប់ទីពីរ ឈានទៅសមីការលីនេអ៊ែរនៃលំដាប់ទីបី និងខ្ពស់ជាងនេះ។ នៅក្នុងជំពូកនេះ យើងសង្ខេបអំពីលក្ខណៈទូទៅ ដោយយកចំណុចពិសេសនៃករណីទាំងនោះ ដែលមានករណីថ្មីកើតឡើងដោយសារស្ថានភាពផ្សេងៗគ្នាកាន់តែច្រើនដែលអាចកើតឡើងសម្រាប់សមីការនៃលំដាប់ខ្ពស់ ។

## ៤.១ ទ្រឹស្តីបទទូទៅនៃសមីការលីនេអ៊ែរលំដាប់ $n$

ទ្រឹស្តីទូទៅនៃសមីការលីនេអ៊ែរលំដាប់ទី $n$ មានទម្រង់ដូចៈ

$$P_0(t)\frac{d^ny}{dx^n}+P_1(t)\frac{d^{n-1}y}{dx^{n-1}}+\ldots+P_{n-1}(t)\frac{dy}{dx}+P_n(t)=G(t) \qquad (1)$$

យើងសន្មតថាអនុគមន៍ $P_0,\ldots,P_n$ និង $G$ ជាអនុគមន៍តម្លៃពិតចន្លោះ $I:\alpha<t<\beta$ និង $P_0$ គឺគ្មានសូន្យក្នុងចន្លោះនេះទេ ។ រួចចែកសមីការ (1) ដោយ $P_0(t)$ យើងទទួលបាន

$$L[y]=\frac{d^ny}{dt^n}+P_1(t)\frac{d^{n-1}y}{dt^{n-1}}+\ldots+P_{n-1}(t)\frac{dy}{dt}+P_n(t)y=g(t) \qquad (2)$$

សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ $L$ នៃលំដាប់ $n$ ដែលកំណត់ដោយសមីការ(2)គឺស្រដៀងគ្នាទៅនឹងសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ពីរដែលបានណែនាំក្នុងជំពូកទី៣ ។ ទ្រឹស្តីគណិតវិទ្យាដែលទាក់ទងនឹងសមីការ(2)គឺស្រដៀងគ្នាទាំងស្រុងគ្នាទៅនិងសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ពីរ។ សម្រាប់ការអះអាងនេះយើងគ្រាន់តែបញ្ជាក់ចម្លើយសម្រាប់លំហាត់លំដាប់ $n$ ។

ភស្តុតាងនៃលទ្ធផលភាគច្រើនគឺស្រដៀងគ្នាទៅនឹងសមីការលំដាប់ 2 ហើយជាធម្មតាត្រូវបានទុកជាលំហាត់ ។ សមីការ (2) ទាក់ទងនឹងដេរីវេទី $n$ នៃ $y$ ជាមួយ $t$ ដូចនេះ គេបានជាទូទៅ $n$ ត្រូវបានដោះស្រាយក្នុងសមីការរួម(2)

$$y(t_0)=y_0 \quad y'(t_0)=y'_0 \;\ldots, y^{(n-1)}(t_0)=y_0^{(n-1)} \qquad (3)$$

**ទ្រឹស្តីបទ ៣.១.១៖** ប្រសិនបើអនុគមន៍ $P_1,P_2,\ldots,P_n$ និង $g$ ជាប់នៅលើចន្លោះបើក $I$ នោះមានចម្លើយពិតប្រាកដ $y=\varphi(t)$ នៃសមីការឌីផេរ៉ង់ស្យែល (2) នោះផ្ទៀងផ្ទាត់តាមលក្ខខណ្ឌ (3) ។ ដំណោះស្រាយនេះមានសំណុំចន្លោះ $I$ ។

**សមីការអូម៉ូសែន៖**ដូចគ្នានៅក្នុងសមីការលំដាប់ទី២ ដែល ដំបូងយើងត្រូវពិភាក្សាអំពីសមីកាអូម៉ូសែននេះ ។

$$L[y]=y^{(n)}+P_1(t)y^{(n-1)}+\ldots+P_{n-1}(t)y'+P_n(t)y=0. \qquad (4)$$

ប្រសិនបើអនុគមន៍ $y_1,y_2,\ldots,y_n$ វាជាចម្លើយរបស់សមីការ (4) បន្ទាប់មកធ្វើការសរសេរជាបន្សំលីនេអ៊ែរ

$$L[y]=c_1y_1(t)+c_2y_2(t)+\ldots+c_ny_n(t), \qquad (5)$$

ដែល $c_1,...,c_n$ ជាចំនួនថេរ គឺជាចម្លើយសមីការ(4)ផងដែរ វាជាចំនួនធម្មជាតិដែលជាធម្មតាមានចោទការសួរថា តើដំណោះស្រាយនៃសមីការ(4)អាចត្រូវបានបង្ហាញថាជាបន្សំលីនេអ៊ែរនៃ $y_1,...,y_n$ នេះនឹងក្លាយជាការពិត ប្រសិនបើមិនគិតពីលក្ខខណ្ឌដំបូង (3) ដែលត្រូវបានបង្កើត គឺមានទម្រង់ជ្រើសរើសជាចំនួនថេរ $c_1,...,c_n$ ដូច្នេះ វាជាបន្សំលីនេអ៊ែរ (5) បំពេញលក្ខខណ្ឌដើម។ ជាពិសេសសម្រាប់ការជ្រើសរើសណាមួយនៃ $t_0$ ក្នុង $I$ និងសម្រាប់ការជ្រើសរើសណាមួយនៃ $y_0, y'_0,..., y^{(n-1)}{}_0$, យើងកំណត់បាន $c_1,...,c_n$ ដូចនេះៈ

$$\begin{aligned} c_1y_1(t_0)+\ldots+c_ny_n(t_0)&=y_0 \\ c_1y_1'(t_0)+\ldots+c_ny_n'(t_0)&=y_0' \\ &\vdots \\ c_1y^{(n-1)}{}_1(t_0)+\ldots+c_ny^{(n-1)}{}_n(t_0)&=y^{(n-1)}{}_0 \end{aligned} \qquad (6)$$

ផ្ទៀងផ្ទាត់សមីការ (6) អាចជាដំណោះស្រាយតែមួយសម្រាប់ចំនួនថេរ $c_1,...,c_n$ ដែលជាដេទេមីណង់នៃមេគុណមិនមែនសូន្យ។ ម្យ៉ាងទៀត ប្រសិនបើដេទេមីណង់នៃមេគុណមិនមែនសូន្យ បន្ទាប់មកគេអាចជ្រើសរើសតម្លៃដាច់ខាតនៃ $y_0, y'_0,..., y_0^{(n-1)}$ ។ដូចសមីការ (6) មិនមានដំណោះស្រាយទេ។ ដូច្នេះលក្ខខណ្ឌចាំបាច់នឹងគ្រប់គ្រាន់សម្រាប់ភាពមានចម្លើយនៃសមីការណាមួយ។ សមីការ (6) សម្រាប់តម្លៃនៃ $y_0, y'_0,..., y_0^{(n-1)}$ ប្រើវ៉ុងគៀន

$$W(y_1,\ldots,y_n)=\begin{vmatrix} y_1 & y_2 & \cdots & y_n \\ y_1' & y_2' & \cdots & y_n' \\ \vdots & \vdots & & \vdots \\ y^{(n-1)}{}_1 & y^{(n-1)}{}_2 & \cdots & y^{(n-1)}{}_n \end{vmatrix} \qquad (7)$$

គឺមិនមានសូន្យ នៅពេល $t=t_0$ ។ ចាប់តាំងពី $t_0$ នៅត្រង់ចំណុចណាមួយនៃចន្លោះ $I$ វាគឺចាំបាច់ហើយមានលក្ខខណ្ឌគ្រប់គ្រាន់នៅពេល $W(y_1,y_2,...,y_n)$ អាចមិនសូន្យនៅត្រង់ចំណុចណាមួយនៃចន្លោះនោះ។ សម្រាប់សមីការលីនេអ៊ែរលំដាប់ទីពីរ វាអាចត្រូវបានបង្ហាញប្រសិនបើ $y_1,y_2,...,y_n$ គឺតម្លៃសូន្យសម្រាប់គ្រប់ $t$ ក្នុងចន្លោះ $I$ ឬផ្សេងទៀត គឺមិនមានតម្លៃសូន្យនៅទីនោះ។ មើលលំហាត់ទី20 ។ ដូច្នេះយើងបានទ្រឹស្តីបទដូចខាងក្រោម ។

**ទ្រឹស្តីបទ ៣.១.២៖** ប្រសិនបើអនុគមន៍ $p_1,p_2,...,p_n$ ជាប់នៅលើចន្លោះបើក $I$ ។ ប្រសិនបើអនុគមន៍ $y_1,y_2,...,y_n$ ជាចម្លើយនៃសមីការ $y^{(n)}+P_1(t)y^{(n-1)}+...+P_{n-1}(t)y'+P_n(t)y=0$ ហើយបើ $W(y_1,y_2,...,y_n)(t)\neq 0$ សម្រាប់ចំណុចមួយក្នុង $I$ នោះគ្រប់ចម្លើយនៃសមីការ ត្រូវបានបង្ហាញជាទម្រង់បន្សំលីនេអ៊ែរនៃដំណោះស្រាយ $y_1,y_2,...,y_n$ ។

សំណុំនៃដំណោះស្រាយ សមីការ (4) ដែលមិនសូន្យ ជាសំណុំមូលដ្ឋាននៃដំណោះស្រាយ (fundamental set of solutions) ។ អត្ថិភាពនៃសំណុំមូលដ្ឋាននៃដំណោះស្រាយ ជាមូលដ្ឋាន ត្រូវបានបង្ហាញយ៉ាងជាក់លាក់ដូចគ្នាទៅនឹងសមីការលីនេអ៊ែរលំដាប់ទី 2 (ទ្រឹស្តីបទ 3.2.5)។ ចាប់តាំងពីដំណោះស្រាយទាំងអស់របស់សមីការ (4) មានទម្រង់ដូចសមីការ (5) យើងប្រើដំណោះស្រាយទូទៅ ដើម្បីឈានទៅរកបន្សំលីនេអ៊ែរនៃដំណោះស្រាយសំណុំណាមួយនៃសមីការ (4) ។ កាពិភាក្សា

អំពីអាស្រ័យលីនេអ៊ែរនិងមិនអាស្រ័យលីនេអ៊ែរដែលបានផ្តល់ឱ្យក្នុងផ្នែក 3.3 ក៏មានលក្ខណៈទូទៅផង ដែរ។ អនុគមន៍ $f_1, f_2, ..., f_n$ ជាដំណោះស្រាយនៃសមីការ (4) បន្ទាប់មកវាបានត្រូវបានបង្ហាញ លក្ខខណ្ឌចាំបាច់និងគ្រប់គ្រាន់សម្រាប់អាស្រ័យលីនេអ៊ែរក្នុង $I$ ។ ប្រសិនសិនបើគេមានសំណុំថេរនៃ $k_1$ , $k_2$ ,..., $k_n$ មិនសូន្យទាំងអស់ ដូចនេះ $k_1 f_1 + k_2 f_2 + ... + k_n f_n = 0$ (8) ។
សម្រាប់ $t$ ទាំងអស់នៅ $I$ ក្នុងអនុគមន៍ $f_1, ..., f_n$ ត្រូវបានគេនិយាយថាមិនអាស្រ័យលីនេអ៊ែរលើ $I$ ប្រសិនបើមិនមានអាស្រ័យលីនេអ៊ែរ។ ប្រសិន $y_1, ..., y_n$ ជាដំណោះស្រាយនៃសមីការ (4) បន្ទាប់មក វាបានត្រូវបានបង្ហាញលក្ខខណ្ឌចាំបាច់និងគ្រប់គ្រាន់សម្រាប់អាស្រ័យលីនេអ៊ែរ $W(y_1, ..., y_n)(t_0) \neq 0$ សម្រាប់ $t_0$ ក្នុង $I$ (សូមមើលលំហាត់ 25) ។
ដូច្នេះ ដំណោះស្រាយជាមូលដ្ឋាននៃសមីការ (4) គឺអាស្រ័យលីនេអ៊ែរ ហើយអាស្រ័យសំណុំលីនេអ៊ែរនៃ $n$ ដំណោះស្រាយនៃ សមីការ (4) បង្កើតបានជាសំណុំមូលដ្ឋាននៃដំណោះស្រាយ។
**សមីការមិនអូម៉ូសែនៈ** ឥឡូវនេះពិចារណាសមីការមិនអូម៉ូហ្សែន (2)
$L[y] = y^{(n)} + p_1(t) y^{(n-1)} + \ldots + p_n(t) y = g(t)$
ប្រសិន $Y_1$ និង $Y_2$ ជាដំណោះស្រាយពីរនៃសមីការ (2) បន្ទាប់មកវាធ្វើតាមលីនេអ៊ែរការីលី $L$
$L[y] = y^{(n)} + p_1(t) y^{(n-1)} + \ldots + p_n(t) y = g(t)$
ដូច្នេះភាពខុសគ្នានៃដំណោះស្រាយទាំងពីរនៃសមីការមិនអូម៉ូសែន (2) គឺជាដំណោះស្រាយនៃសមី-ការមិនអូម៉ូសែន(4) ចាប់តាំងពីដំណោះស្រាយនៃភាពដូចគ្នាណាមួយនៃសមីការ មិនអូម៉ូសែនអាច បញ្ជាក់ជាបន្សំលីនេអ៊ែរនៃសំណុំមូលដ្ឋាននៃដំណោះស្រាយ $y_1, ..., y_n$ ដោះស្រាយតាមដំណោះស្រាយណាមួយនៃសមីការ (2) គេអាចសរសេរជា
$$y = c_1 y_1(t) + c_2 y_2(t) + \ldots + c_n y_n(t) + Y(t) \qquad (9)$$
ដែល $Y$ ជាដំណោះស្រាយជាក់លាក់មួយចំនួននៃសមីការមិនអូម៉ូស្សែន (2) បន្សំលីនេអ៊ែរ (9) ត្រូវបានគេហៅថាដំណោះស្រាយទូទៅនៃសមីការមិនអូម៉ូសែន(2) ។ ដូច្នេះបញ្ហាចម្បង គឺដើម្បីកំណត់សំណុំមូលដ្ឋាននៃដំណោះស្រាយ $y_1, ..., y_n$ នៃសមីការមិនអូម៉ូហ្សែន (4) ។
ប្រសិនបើមេគុណថេរ នេះគឺជាលំហាត់សាមញ្ញ។ វាត្រូវបានលើកយកមកនិយាយនៅក្នុងផ្នែកបន្ទាប់។ ប្រសិនបើមេគុណថេរ ជាធម្មតាចាំបាច់ត្រូវប្រើវិធីសាស្ត្រជាលេខដូចជាវិធីក្នុងជំពូកទី 8 ឬវិធីស៊េរីស្រដៀងនឹងវិធីក្នុងជំពូកទី 5 ។ ទាំងអស់នេះមានទំនោរទៅកាន់តែស្មុកស្មាញនៅពេលដែលលំដាប់នៃសមីការកើនឡើង ។ វិធីសាស្ត្រនៃការកាត់បន្ថយលំដាប់ (ផ្នែកទី 3.5) ក៏អនុវត្តន៍ចំពោះសមីការលីនេអ៊ែរលំដាប់ទី 1 ផងដែរ។
ប្រសិនបើ $y_1$ ជាដំណោះស្រាយមួយនៃសមីការ (4) បន្ទាប់មកជំនួស $y = v(t) y_1$ នាំទៅរកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ $n-1$ សម្រាប់ $v'$ (សូមមើលលំហាត់ 26 សម្រាប់ករណីនៅពេលដែល $n=3$ ) ។ ទោះយ៉ាងណាក៏ដោយប្រសិនបើ $n=3$ សមីការដែលកាតបន្ថយគឺខ្លួនវាយ៉ាងហោចណាស់នៃលំដាប់ទី 2 ហើយមានតែកម្រណាស់ដែលវានឹងមានលក្ខណៈសាមញ្ញជាងសមីការដើម។

ដូច្នេះក្នុងការអនុវត្តន៍ជាក់ស្តែងការកាត់បន្ថយលំដាប់គឺកម្រមានប្រយោជន៍សម្រាប់សមីការខ្ពស់ ជាង លំដាប់ទី 2 ។

## ៤.១.១ ការបង្កើតចម្លើយទីពីរចេញពីចម្លើយទីមួយ

សមីការឌីផេរ៉ង់ស្យែលមានទម្រង់៖

$$y''+P(x)y'+Q(x)y=0 \qquad (1)$$

ដែល $P(x)$ និង $Q(x)$ ជាអនុគមន៍ជាប់លើ $I$ មានអនុគមន៍ចម្លើយ $y_1(x)\neq 0$ បានស្គាល់និតិវិធីក្នុង ការរកសមីការទី២ គឺយើងត្រូវកំណត់

$y=u(x)y_1(x)\Rightarrow y'=uy_1'+u'y_1 \quad \Rightarrow y''=uy_1''+u''y_1+2u'y_1'$ ជំនួសសមីការ ( 1 )

$$(uy_1''+u''y_1+2u'y_1')+P(x)(uy_1'+u'y_1)+Q(x)(uy_1)=0$$

$$u\underbrace{\left[y_1''+Py'+Qy\right]}_{0}+y_1u''+\left(2y_1'+Py_1\right)u'=0$$

$$y_1u''+\left(2y_1'+Py_1\right)u'=0$$

តាង $w=u'\Rightarrow w'=u''$ គេបាន

$$y_1w'+\left(2y_1'+Py_1\right)w=0 \qquad (2)$$

$$y_1\frac{dw}{dx}+\left(2y_1'+Py_1\right)w=0 \qquad \Rightarrow \frac{dw}{w}+2\frac{y_1'}{y_1}dx+Pdx=0$$

$$\int\frac{dw}{w}+2\int\frac{y_1'}{y_1}dx+\int Pdx=\int 0$$

$$\ln\left|wy_1^2\right|=-\int Pdx+c$$

$$wy_1^2=c_1e^{-\int Pdx}$$

តែ $w=u'$ នោះ $u=c_1\int\frac{e^{-\int pdx}}{y_1^2}dx+c_2$ យើងជ្រើសរើសយក $c_1=1,\ c_2=0$ យើងបានចម្លើយទី២គឺ

$$y_2=y_1\int\frac{e^{-\int Pdx}}{y_1^2}dx \qquad (3)$$

ឧទាហរណ៍ទី១៖ចូររកចម្លើយទី២នៃសមីការ $x^2y''-3xy'+4y=0$ មានចម្លើយទីមួយ $y_1=x^2$ ។

ចម្លើយ $y_2=x^2\ln x$

## លំហាត់

ក្នុងលំហាត់ទី1-6ចូររកដែនកំណត់នៃសមីការដើម្បីរកចម្លើយ

1. $y^{(4)}+4y'''+3y=t$
2. $ty'''+(\sin t)y''+3y=\cos t$
3. $t(t-1)y^{(4)}+e^ty''+4t^2y=0$
4. $y'''+ty''+t^2y'+t^3y=\ln t$
5. $(x-1)y^{(4)}+(x+1)y''+(tanx)y=0$
6. $\left(x^2-4\right)y^{(6)}+x^2y'''+9y=0$

ក្នុងលំហាត់ទី7-10តើសំណុំអនុគមន៍ខាងក្រោមវាអាស្រ័យឬមិនអាស្រ័យលីនេអ៊ែរ។បើអាស្រ័យលីនេអ៊ែរ ចូររកទំនាក់ទំនងរបស់អនុគមន៍ទាំងនេះ។

7. $f_1(t)=2t-3,\quad f_2(t)=t^2+1,\quad f_3(t)=2t^2-t$

8. $f_1(t)=2t-3,\quad f_2(t)=2t^2+1,\quad f_3(t)=3t^2+t$

9. $f_1(t)=2t-3,\quad f_2(t)=t^2+1,\quad f_3(t)=2t^2-t,\quad f_4=t^2+t+1$

9. $f_1(t)=2t-3,\quad f_2(t)=t^3+1,\quad f_3(t)=2t^2-t,\quad f_4=t^2+t+1$

ក្នុងលំហាត់នីមួយៗពីទី11-16។បង្ហាញថាសំណុំអនុគមន៍ជាចម្លើយសមីការលីនេអ៊ែរ រួចគណនាតាមរ៉ុងគៀន

11. $y'''+y'=0;\quad y_1=1,\ y_2=\sin t,\quad y_3=\cos t$

12. $y^{(4)}+y''=0;\quad y_1=1,\quad y_2=\sin t,\quad y_3=\cos t,\quad y_4=t$

13. $y'''+y''-y'-2y=0;\quad y_1=e^t,\quad y_2=e^{-t},\quad y_3=e^{-2t}$

14. $y^{(4)}+2y'''+y''=0;\quad y_1=1,\ y_2=t,\ y_3=e^{-t},\quad y_4=te^{-t}$

15. $xy'''-y''=0;\quad y_1=1,\quad y_2=x,\quad y_3=x^3$

16. $x^3y'''+x^2y''-2xy'+2y=0;\quad y_1=x,\quad y_2=x^2,\quad y_3=\dfrac{1}{x}$

ក្នុងលំហាត់នីមួយៗពីទី16-24ចូររកចម្លើយទី២នៃសមីការ

17. $y''-4y'+4y=0,\quad y_1=e^{2x}$

18. $y''+2y'+4y=0,\quad y_1=xe^{-x}$

19. $y''+16y=0,\quad y_1=\cos 4x$

20. $y''+9y=0,\quad y_1=\sin 3x$

21. $y''-y=0,\quad y_1=\cosh x$

22. $y''-25y=0,\quad y_1=e^{5x}$

23. $9y''-12y'+4y=0,\quad y_1=e^{2x/3}$

24. $6y''+y'-y=0,\quad y_1=e^{x/3}$

## ៤.២. សមីការអូម៉ូសែនមេគុណថេរ

ពិចារណា សមីការឌីផេរ៉ង់ស្យែលអូម៉ូសែនលីនេអ៊ែរលំដាប់ទី $n$

$$L[y]=a_0y^{(n)}+a_1y^{(n-1)}+\cdots+a_{n-1}y'+a_ny=0,\qquad (1)$$

ដែល $a_0,a_1,...,a_n$ គឺជាចំនួនថេរពិត។ តាមរយៈចំណេះដឹងដែលបានសិក្សាទៅលើសមីការលីនេអ៊ែរលំដាប់ពីរ ដែលមានមេគុណជាចំនួនថេរ ជាធម្មតាត្រូវបានគេរំពឹងទុកថា $y=e^{rt}$ គឺជាចម្លើយនៃសមីការ (1) ជាមួយតម្លៃ $r$ ដែលសមស្រប។ គេបាន

$$L[e^{rt}]=e^{rt}(a_0r^n+a_1r^{n-1}+\cdots+a_{n-1}r+a_n)=e^{rt}Z(r),\qquad (2)$$

សម្រាប់គ្រប់តម្លៃ $r$ ដែល

$$Z(r)=a_0r^n+a_1r^{n-1}+\cdots+a_{n-1}r+a_n\qquad (3)$$

សម្រាប់តម្លៃ $r$ ទាំងនោះ ដែល $Z(r)=0$ នោះ $L[e^{rt}]=0$ និង $y=e^{rt}$ គឺជាចម្លើយនៃសមីការ (1) ។ ពហុធា $Z(r)$ ត្រូវបានហៅថា ពហុធាសម្គាល់ និង សមីការ $Z(r)=0$ ហៅថា សមីការសម្គាល់ នៃសមីការឌីផេរ៉ង់ស្យែល (1) ។

ពហុធាដឺក្រេទី $n$ មានសូន្យ $n$ គេថា $r_1,r_2,...,r_n$ ខ្លះប្រហែលមានតម្លៃស្មើគ្នា ដូចនេះយើងអាចសរសេរពហុធាសម្គាល់ក្រោមទម្រង់

$$Z(r)=a_0(r-r_1)(r-r_2)\cdots(r-r_n) \qquad (4)$$

### ៤.២.១ ករណីឫសជាចំនួនពិតនិងមិនស្មើ

បើឫសនៃសមីការសម្គាល់គឺ ជាចំនួនពិត និងមិនស្មើឫសផ្សេងៗទៀត នោះមានចម្លើយ $n$ ផ្សេងគ្នាគឺ $e^{r_1t},e^{r_2t},...,e^{r_nt}$ នៃសមីការ (1)។ បើអនុគមន៍ទាំងនោះមិនអាស្រ័យលីនេអ៊ែរ នោះចម្លើយទូទៅនៃសមីការ (1) គឺមានទម្រង់

$$y=c_1e^{r_1t}+c_2e^{r_2t}+\cdots+c_ne^{r_nt} \qquad (5)$$

**ឧទាហរណ៍ទី១៖** រកចម្លើយទូទៅនៃ $y''''+y'''-7y''-y'+6y=0$ (6)

រកចម្លើយនៃសមីការដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $y(0)=1$ , $y'(0)=0$ , $y''(0)=-2$ , $y'''(0)=-1$ (7) និងគូសក្រាប

**ចម្លើយ**

យក $y=e^{rt}$, យើងត្រូវរក ដោយដោះស្រាយ សមីការពហុធា

$$r^4+r^3-7r^2-r+6=0 \qquad (8)$$

ឫសនៃសមីការគឺ $r_1=1, r_2=-1, r_3=2$ និង $r_4=-3$

ដូចនេះចម្លើយនៃសមីការ (6) គឺ

$$y=c_1e^{t}+c_2e^{-t}+c_3e^{2t}+c_4e^{-3t} \qquad (9)$$

តាមលក្ខខណ្ឌដើម (7) $c_1,...,c_4$ ត្រូវផ្ទៀងផ្ទាត់ សមីការខាងក្រោម៖

$$\begin{aligned}
c_1+c_2+c_3+c_4&=1,\\
c_1-c_2+2c_3-3c_4&=0,\\
c_1+c_2+4c_3+9c_4&=-2,\\
c_1-c_2+8c_3-27c_4&=-1.
\end{aligned} \qquad (10)$$

ដោយដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែរ យើងបាន

$$c_1=11/8, \quad c_2=5/12, \quad c_3=-2/3, \quad c_4=-1/8$$

ដូចនេះ សមីការដែលផ្ទៀងផ្ទាត់លក្ខខណ្ឌគឺ $y=\frac{11}{8}e^{t}+\frac{5}{12}e^{-t}-\frac{2}{3}e^{2t}-\frac{1}{8}e^{-3t}$ ។ (11)

ក្រាបនៃចម្លើយត្រូវបានបង្ហាញក្នុងរូប 3.2.1




**រូប3.2.1** ដំណោះស្រាយលំហាត់តម្លៃដំបូងនៃលំហាត់ទី(1)

តាមរយៈឧទាហរណ៍ទី១ នីតិវិធីក្នុងការដោះស្រាយសមីការលីនេអ៊ែរឌីផេរ៉ង់ស្យែលលំដាប់ $n$ ដែលមានមេគុណថេរអាស្រ័យលើការស្វែងរកឫសនៃសមីការពហុធាដឺក្រេទី $n$ ។ ប្រសិនបើលក្ខខណ្ឌដើមត្រូវបានផ្តល់អោយ នោះប្រព័ន្ធសមីការនឹងត្រូវបានដោះស្រាយដើម្បីរកតម្លៃប្រាកដនៃចំនួនថេរ $c_1,\dots,c_n$ ។ ខណៈពេលដែលវារឹតតែស្មុគស្មាញ នៅពេលដែល $n$ កើនឡើង។ យើងអាចដោះស្រាយដោយគ្មានបញ្ហាដោយការប្រើប្រាស់ម៉ាស៊ីនគណនាឬកុំព្យូទ័រ។

សម្រាប់ពហុធាដឺក្រេទី៣ និងទី៤ វាមានរូបមន្តស្រដៀងគ្នាទៅនឹងការដោះស្រាយសមីការដឺក្រេទី២ ប៉ុន្តែស្មុគស្មាញជាង ដែលបង្ហាញពីលក្ខណៈដូចគ្នានឹងក្បួនដោះស្រាយរកឫសដែលអាចប្រើប្រាស់ម៉ាស៊ីនគណនាឬកុំព្យូទ័រ។ ពេលខ្លះវារួមបញ្ចូលការដោះស្រាយសមីការឌីផេរ៉ង់ស្យែល ដូចនេះដំណើរការនៃការដាក់ជាកត្តារបស់ពហុធាសម្គាល់ និងចម្លើយនៃសមីការឌីផេរ៉ង់ស្យែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិ។

ប្រសិនបើយើងជួបបញ្ហាក្នុងការដាក់ពហុធាសម្គាល់ជាផលគុណកត្តាដោយការគណនាដោយផ្ទាល់ ខាងក្រោមនេះគឺជាលទ្ធផលដែលពេលខ្លះវាមានអត្ថប្រយោជន៍។ សន្មតថាពហុធា

$$a_0r^n + a_1r^{n-1} + \cdots + a_{n-1}r + a_n = 0 \qquad (12)$$

ដែលមានមេគុណជាចំនួនគត់។ បើ $r = p/q$ គឺជាចំនួនសនិទានដែល $p$ និង $q$ គ្មានតួចែករួម នោះ $p$ ត្រូវតែជាតួចែកនៃ $a_n$ និង $q$ ត្រូវតែជាតួចែកនៃ $a_0$ ។ សម្រាប់ឧទាហរណ៍ ក្នុងសមីការ (8) តួចែកនៃ $a_0$ គឺ $\pm 1$ និងតួចែកនៃ $a_n$ គឺ $\pm 1, \pm 2, \pm 3,$ និង $\pm 6$ ។ ដូចនេះឫសជាចំនួនសនិទានដែលអាចកើតមានគឺ $\pm 1, \pm 2, \pm 3,$ និង $\pm 6$ ។ ដោយធ្វើតេស្តសាកល្បងឫសទាំងនេះ យើងរកឃើញថា $1, -1, 2$ និង $-3$ គឺជាឫសពិតប្រាកដ។ ក្នុងករណីនេះគ្មានឫសផ្សេង ពីព្រោះពហុធាមានដឺក្រេ៤។ ប្រសិនបើឫសខ្លះជាចំនួនអសនិទានឬចំនួនកុំផ្លិច ដូចនេះវិធីសាស្ត្រនេះមិនអាចរកបានទេ ប៉ុន្តែយ៉ាងហោចណាស់ដឺក្រេនៃពហុធា គឺត្រូវបានកាត់បន្ថយដោយកត្តាដែលត្រូវនឹងឫសជាចំនួនសនិទាន។

បើឫសនៃសមីការសម្គាល់ គឺជាចំនួនពិត និងខុសគ្នា យើងបានឃើញថាចម្លើយទូទៅនៃសមីការ (5) គឺជាផលបូកនៃអនុគមន៍អ៊ិចស្បូណង់ស្យែល។ ចំពោះ $t$ មានតម្លៃធំ ចម្លើយនឹងត្រូវបានបង្ហាញដោយតួដែលផ្ទៀងផ្ទាត់ទៅនឹងឫសពិជគណិតធំ។ បើឫសនេះវិជ្ជមាន នោះចម្លើយនឹងក្លាយជាអ៊ិចស្បូណង់ស្យែលមិនទល់ បើឫសជាចំនួនអវិជ្ជមាន នោះចម្លើយនឹងនាំអ៊ិចស្បូណង់ស្យែលខិតជិតសូន្យ។ ចុងក្រោយ បើឫសធំបំផុតស្មើ 0 នោះចម្លើយសម្រាប់ $t$ នឹងមានតម្លៃធំ ត្រូវបានគណនាដោយឫសបន្ទាប់ធំបំផុត។

## ៤.២.២ ករណីឫសជាចំនួនកុំផ្លិច (Complex Roots)

បើសមីការសម្គាល់មានឫសជាចំនួនកុំផ្លិចត្រូវបានលេចឡើងតាមទម្រង់គូ $\lambda \pm i\mu$ ដោយមេគុណ $a_0,\ldots,a_n$ ជាចំនួនពិត។ យើងដឹងថាគ្មានឫសដូចគ្នា ចម្លើយទូទៅនៃសមីការ (1) គឺនៅតែជាទម្រង់នៃសមីការ (4) ម្យ៉ាងទៀតវាដូចជាសមីការដែលមានលំដាប់២(ក្នុងផ្នែក3.4) យើងអាចជំនួសចម្លើយនៃតម្លៃចំនួនកុំផ្លិច $e^{(\lambda+i\mu)t}$ និង $e^{(\lambda-i\mu)t}$ ដោយចម្លើយតម្លៃពិត(real-valued solutions)

$$e^{\lambda t}\cos\mu t \quad , \quad e^{\lambda t}\sin\mu t \qquad (13)$$

ដែលមានផ្នែកពិត និងផ្នែកនិមិត្តនៃ $e^{(\lambda+i\mu)t}$ ។ ដូចនេះ ទោះបីឫសខ្លះនៃសមីការសម្គាល់ គឺជាចំនួនកុំផ្លិច វានៅតែអាចទៅរួចដើម្បីរកចម្លើយទូទៅនៃសមីការ (1) ដូចជាបន្សំលីនេអ៊ែរនៃចម្លើយតម្លៃពិត (real-valued solutions)។

**ឧទាហរណ៍ទី២៖** រកចម្លើយទូទៅនៃ $y^{(4)}-y=0$ (14) និងចម្លើយនៃសមីការដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដើម $y(0)=7/2, y'(0)=-4, y''(0)=5/2, y'''(0)=-2$ (15)
និងគូសក្រាបរបស់វា។

**ចម្លើយ**

ជំនួស $y$ ដោយ $e^{rt}$ យើងបានសមីការសម្គាល់កំណត់ដោយ

$$r^4-1=(r^2-1)(r^2+1)=0$$

ដូចនេះឫសសមីការគឺ $r_1=1, r_2=-1, r_3=i, r_4=-i$ និងអនុគមន៍ចម្លើយទូទៅនៃសមីការ(14) គឺ

$$y=c_1e^t+c_2e^{-t}+c_3\cos t+c_4\sin t$$

ក្រាបនៃចម្លើយនេះនឹងត្រូវបានបង្ហាញនៅក្នុងរូបភាព 3.2.2

បើយើងដាក់លក្ខខណ្ឌដើម (15) យើងបាន $c_1=0, \quad c_2=3, \quad c_3=1/2, \quad c_4=-1$
ដូចនេះ ចម្លើយនៃសមីការដែលផ្ទៀងផ្ទាត់លក្ខខណ្ឌគឺ

$$y=0e^t+3e^{-t}+\frac{1}{2}\cos t-\sin t$$

$$y=3e^{-t}+\frac{1}{2}\cos t-\sin t \qquad (16)$$ ។

ក្រាបនៃចម្លើយត្រូវបានបង្ហាញក្នុងរូប3.2.3




មេគុណក្នុងសមីការ $y=\frac{1}{32}e^{t}+\frac{95}{32}e^{-t}+\frac{1}{2}\cos t-\frac{17}{16}\sin t$ (17)

ខុសតែបន្តិចពីសមីការ (16) តែតួនៃសមីការអ៊ិចស្ប៉ូណង់ស្យែលកើន ទោះជាតម្លៃមេគុណតូច 1/32 វាបង្ហាញចម្លើយដោយចំនួនដង $t$ ធំជាងមុន 4 ទៅ 5 ដង នេះគឺបានឃើញយ៉ាងច្បាស់ក្នុងរូប 3.2.3 ដែលបង្ហាញក្រាបនៃចម្លើយទាំងពីរ (16)និង (17) ។

រូប3.2.2 រូបនៃសមីការចម្លើយ(16)រូប3.2.3 នៃសមីការចម្លើយ (ខ្សែកោងស្រាល) និង (17) (ខ្សែកោងដិត)




## ៤.២.៣ ករណីឫសឌុប(Repeated Root)

បើឫសនៃសមីកាសម្គាល់ គឺមិនផ្សេងគ្នា មានន័យថាបើឫសខ្លះដូចគ្នា នោះចម្លើយ (5) គឺពិតជាមិនមែនជាចម្លើយទូទៅនៃសមីការ (1) ។ រំលឹកឡើងវិញ បើ $r_1$ ជាឫសឌុបសម្រាប់សមីការលីនេអ៊ែរលំដាប់២ $a_0y''+a_1y'+a_2y=0$ នោះចម្លើយពីរនៃលីនេអ៊ែរមិនអាស្រ័យគឺ $e^{r_1t}$ បើ $te^{r_1t}$ សម្រាប់សមីការឌីផេរ៉ង់ស្យែលដែលមានលំដាប់ $n$ ប្រសិនបើឫសនៃ $Z(r)=0$ នោះ $r_1=r_2=.....=r_s$ ដែល $s\le n$ នោះ

$$e^{r_1t},te^{r_1t},t^2e^{r_1t},\ldots,t^{s-1}e^{r_1t} \qquad (18)$$

ដែលត្រូវនឹងចម្លើយនៃសមីការ បើកាន់តែច្បាស់សូមមើលចំណុច(២.៣.១)គឺ $y_2 = y_1\int \frac{e^{-\int Pdx}}{y_1^2}dx$ ។

បើឫសជាចំនួនកុំផ្លិច $\lambda+i\mu$ ឌុប $s$ ដង និងកុំផ្លិចឆ្លាស់ $\lambda-i\mu$ ឌុប $s$ ដែរ។ ដើម្បីផ្ទៀងផ្ទាត់ចម្លើយតម្លៃចំនួនកុំផ្លិច $2s$ នេះ យើងអាចរកចម្លើយតម្លៃពិត $2s$ ដោយកត់សម្គាល់ថា ផ្នែកពិត និងផ្នែកនិមិត្តនៃ $e^{(\lambda+i\mu)t}, te^{(\lambda+i\mu)t}, \dots, t^{s-1}e^{(\lambda+i\mu)t}$ គឺជាចម្លើយអាស្រ័យលីនេអ៊ែរនៃអនុគមន៍ ៖

$$e^{\lambda t}\cos\mu t\ ,\ e^{\lambda t}\sin\mu t\ ,\ te^{\lambda t}\cos\mu t\ ,\ te^{\lambda t}\sin\mu\ ,$$
$$\dots,\ t^{s-1}e^{\lambda t}\cos\mu t\ ,\ t^{s-1}e^{\lambda t}\sin\mu t.$$

ដូចនេះ ចម្លើយទូទៅនៃសមីការ (1) អាចត្រូវបានបង្ហាញជាបន្សំលីនេអ៊ែរ នៃតម្លៃពិត $n$ ។ ពិនិត្យមើលឧទាហរណ៍ខាងក្រោម៖

**ឧទាហរណ៍ទី៣៖** រកចម្លើយទូទៅនៃ $y^{(4)}+2y''+y=0$ (19)

**ចម្លើយ**

យើងបាន សមីការសម្គាល់គឺ

$$r^4+2r^2+1=(r^2+1)(r^2+1)=0$$

ឫសនៃ $r$ គឺ $r=i,i,-i,-i$ ដូចនេះចម្លើយទូទៅនៃសមីការ (19) គឺ

$$y=c_1\cos t+c_2\sin t+c_3t\cos t+c_4t\sin t$$

ក្នុងការគណនាឫសនៃសមីការសម្គាល់វាមានសារៈសំខាន់ដើម្បីបង្ហាញ ឫសគូបឫឫសទី៤ ឫក៏ឫសកាន់តែធំ នៃចំនួន(ចំនួនកុំផ្លិចដែលអាចទៅរួច)។ វាអាចងាយស្រួលដោយប្រើប្រាស់ រូបមន្ត Euler $e^{it}=\cos t+i\sin t$ និងច្បាប់នៃពិជគណិតដែលបានផ្តល់អោយក្នុងផ្នែក 2.4 វាត្រូវបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។

**ឧទាហរណ៍ទី៤៖** រកចម្លើយទូទៅនៃសមីការ $y^{(4)}+y=0$ (20)

យើងបានសមីការសម្គាល់ $r^4+1=0$

ដើម្បីដោះស្រាយសមីការ យើងត្រូវគណនាឫសទី៤ នៃ $-1$ ។ គិតថា $-1$ គឺជាចំនួនកុំផ្លិច $-1+0i$ វាមានម៉ូឌុល $1$ និងមុំប៉ូលែ $\pi$ ។ គេបាន

$$-1=\cos\pi+i\sin\pi=e^{i\pi}$$

ម្យ៉ាងទៀត មុំគឺត្រូវបានកំណត់ត្រឹមតែ ពហុគុណនៃ $2\pi$ ។ គេបាន

$$-1=\cos(\pi+2m\pi)+i\sin(\pi+2m\pi)=e^{i(\pi+2m\pi)}$$

ដែល $m$ ស្មើសូន្យ ឫសចំនួនគត់វិជ្ជមាន ឫ អវិជ្ជមាន។ គេបាន

$$(-1)^{1/4}=e^{i(\pi/4+m\pi/2)}=\cos\left(\frac{\pi}{4}+\frac{m\pi}{2}\right)+i\sin\left(\frac{\pi}{4}+\frac{m\pi}{2}\right)$$

ឫសទី៤ ទាំងបួននៃ $-1$ ទទួលបានដោយយក $m=0,1,2$ និង $3$ ពួកវាគឺ

$$\frac{1+i}{\sqrt{2}},\frac{-1+i}{\sqrt{2}},\frac{-1-i}{\sqrt{2}},\frac{1-i}{\sqrt{2}}$$

វាងាយស្រួលដើម្បីផ្ទៀងផ្ទាត់ តម្លៃផ្សេងទៀតនៃ $m$ យើងទទួលបានមួយក្នុងចំណោមឫសទាំង៤

ជាឧទាហរណ៍ បើ $m=4$ យើងបាន $\frac{(1+i)}{\sqrt{2}}$

ដូចនេះចម្លើយទូទៅនៃសមីការ (20) គឺ

$$y = e^{t/\sqrt{2}}(c_1\cos\frac{t}{\sqrt{2}} + c_2\sin\frac{t}{\sqrt{2}}) + e^{-t/\sqrt{2}}(c_3\cos\frac{t}{\sqrt{2}} + c_4\sin\frac{t}{\sqrt{2}}) \qquad (21)$$

**សន្និដ្ឋាន** យើងកត់សម្គាល់ថា បញ្ហានៃការរកឫសនៃសមីការសំគាល់ ប្រហែលជាមិនត្រង់ៗនោះទេ ទោះបីជាមានកុំព្យូទ័រជាជំនួយ។ ផ្ទុយពីនេះវាមានការលំបាកប្រសិនបើឫសពីរស្មើគ្នា ឬក៏មានតម្លៃប្រហាក់ប្រហែលគ្នា។ រំលឹកឡើងវិញថា ទម្រង់នៃចម្លើយទូទៅគឺខុសគ្នាក្នុងករណីទាំងពីរនេះ។ បើមេគុណ $a_0, a_1, ..., a_n$ ក្នុងសមីការទី (1) គឺជាចំនួនកុំផ្លិចចម្លើយនៃសមីការនេះនៅតែជាទម្រង់ (4) ។ ក្នុងករណីនេះ ទោះជាឫសនៃសមីការសម្គាល់គឺ ជាទូទៅ ចំនួនកុំផ្លិច និងចំនួនកុំផ្លិចប្រាសមិន មែនជាឫសនៃសមីការ។ ចម្លើយដែលត្រូវនឹងវាគឺ តម្លៃកុំផ្លិច។

## លំហាត់

ក្នុងលំហាត់ 1 ដល់ 6 សរសេរ ចំនួនកុំផ្លិចខាងក្រោមជាទម្រង់ $R(\cos\theta + i\sin\theta) = \mathrm{Re}^{i\theta}$

1. $1+i$ 2. $-1+\sqrt{3}i$ 3. $-3$

4. $-i$ 5. $\sqrt{3}-i$ 6. $-1-i$

ក្នុងលំហាត់ 7 ដល់ 10 តាមនិតិវិធីសាស្ត្រដែលបានបង្ហាញក្នុងឧទាហរណ៍៤ ដើម្បីកំណត់ឫស ចំពោះចំនួនកុំផ្លិចដែលបានអោយខាងក្រោម៖

7. $1^{1/3}$ 8. $(1-i)^{1/2}$

9. $1^{1/4}$ 10. $[2(\cos\pi/3 + i\sin\pi/3)]^{1/2}$

ក្នុងលំហាត់ 11 ដល់ 28 រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់ឱ្យ៖

11. $y''' - y'' - y' + y = 0$ 12. $y''' - 3y'' + 3y' - y = 0$

13. $2y''' - 4y'' - 2y' + 4y = 0$ 14. $y^{iv} - 4y''' + 4y'' = 0$

15. $y^{vi} + y = 0$ 16. $y^{iv} - 5y'' + 4y = 0$

17. $y^{vi} - 3y^{iv} + 3y'' - y = 0$ 18. $y^{vi} - y'' = 0$

19. $y^{v} - 3y^{iv} + 3y''' - 3y'' + 2y' = 0$ 20. $y^{iv} - 8y' = 0$

21. $y^{viii} + 8y^{iv} + 16y = 0$ 22. $y^{iv} + 2y'' + y = 0$

23. $y''' - 5y'' + 3y' + y = 0$ 24. $y''' + 5y'' + 6y' + 2y = 0$

25. $18y''' + 21y'' + 14y' + 4y = 0$ 26. $y^{iv} - 7y''' + 6y'' + 30y' - 36y = 0$

27. $12y^{iv} + 31y''' + 75y'' + 37y' + 5y = 0$ 28. $y^{iv} + 6y''' + 17y'' + 22y' + 14y = 0$

ក្នុងលំហាត់ 29 ដល់ 36 រកចម្លើយនៃសមីការតាមលក្ខខណ្ឌដើម ដែលបានឱ្យ និងគូសក្រាបនៃសមីការចម្លើយ។ តើចម្លើយទៅជាយ៉ាងណា ពេល $t \to \infty$?

29. $y''' + y' = 0;$ $y(0)=0$ , $y'(0)=1$ , $y''(0)=2$

30. $y^{iv} + y = 0;$ $y(0)=0$ , $y'(0)=1$ , $y''(0)=-2$ , $y'''(1)=0$

31. $y^{iv} - 4y''' + 4y'' = 0;$ $y(1)=-1$ , $y'(1)=2$ , $y''(1)=0$ , $y'''(1)=0$

32. $y''' - y'' + y' - y = 0;$ $y(0)=2$ , $y'(0)=-1, y''(0)=-2$

33. $2y^{iv} - y''' - 9y'' + 4y' + 4y = 0;$ $y(0)=-2$ , $y'(0)=0$ , $y''(0)=-2$ , $y'''(0)=0$

34. $4y''' + y' + 5y = 0;$ $y(0)=2$ , $y'(0)=1$ , $y''(0)=-1$

35. $6y''' + 5y'' + y' = 0;$ $y(0)=-2$ , $y'(0)=2$ , $y''(0)=0$

36. $y^{iv} + 6y''' + 17y'' + 22y' + 14y = 0;$ $y(0)=1$ , $y'(0)=-2$ , $y''(0)=0$ , $y'''(0)=3$

37. បង្ហាញថាចម្លើយទូទៅនៃសមីការ $y^{iv} - y = 0$ អាចសរសេរជាទម្រង់

$$y = c_1 \cos t + c_2 \sin t + c_3 \cosh t + c_4 \sinh t$$

គណនាចម្លើយដែលផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដើម $y(0)=0, y'(0)=0, y''(0)=1$ ។ ហេតុអ្វីបានជាវាមានភាពងាយស្រួលដោយប្រើចម្លើយ $\cosh t$ និង $\sinh t$ ជាជាង $e^t$ និង $e^{-t}$ ?

38. យើងមានសមីការ $y^{iv} - y = 0$

ប្រើរូបមន្ត Abel ដើម្បីរក រ៉ុងគៀន នៃសំណុំគ្រឹះចម្លើយនៃសមីការដែលអោយ។

គណនា The Wronskian នៃចម្លើយ $e^t$ , $e^{-t}$ , $\cos t$ , និង $\sin t$ ។

គណនា The Wronskian នៃចម្លើយ $\cosh t$ , $\sinh t$ , $\cos t$ , និង $\sin t$ ។

39. យើងមាន ប្រព័ន្ធ spring-mass ដូចបានបង្ហាញក្នុង**រូប3.2.4** ដែលមានម៉ាស២ព្យួរពីរ៉ឺស័រ ដែលមាន ថេររ៉ឺស័រ3 និង 2 រៀងគ្នា។ សន្មតថាគ្មាន damping ក្នុងប្រព័ន្ធ។

បង្ហាញថាការជំនួស (displacements) $u_1$ និង $u_2$ នៃម៉ាសពីទីតាំងលំនឹងផ្ទៀងផ្ទាត់និងសមីការ

$$u_1'' + 5u_1 = 2u_2, \quad u_2'' + 2u_2 = 2u_1 \qquad \text{(i)}$$

ដោះស្រាយសមីការ $(i)$ ទីមួយ សម្រាប់ $u_2$ និងជំនួសក្នុង សមីការទី២ នោះគេបាន សមីការលំដាប់៤ សម្រាប់ $u_1$ : $u_1^{iv} + 7u_1'' + 6u_1 = 0$ (ii)

រកចម្លើយទូទៅនៃសមីការ (ii) ។




**រូប3.2.4** ប្រព័ន្ធ spring-mass ដឺក្រេសេរី២

គេឱ្យលក្ខខណ្ឌដើម

$$u_1(0)=1\,,\ u_1'(0)=0\ ,\ u_2(0)=1\ ,\ u_2''(0)=0 \qquad (iii)$$

ប្រើសមីការដំបូង នៃសមីការ $(i)$ និងលក្ខខណ្ឌដើម $(iii)$ ដើម្បីរកតម្លៃសម្រាប់ $u_1''(0)$ និង $u_2'''(0)$ រួច បង្ហាញថាចម្លើយនៃសមីការ $(ii)$ ដែលផ្ទៀងផ្ទាត់និងលក្ខខណ្ឌដើមទាំង៤ លើ $u_1$ គឺ $u_1(t)=\cos t$ ។ បង្ហាញថាចម្លើយដែលត្រូវនឹង $u_2$ គឺ $u_2(t)=2\cos t$ ។

ឥឡូវនេះសន្មតថាលក្ខខណ្ឌដើមគឺ $u_1(0)=-2, u_1'(0)=0, u_2(0)=1, u_2'(0)=0$ (iv)

ធ្វើដូចគ្នា $(c)$ ខាងលើបង្ហាញថាចម្លើយដែលផ្ទៀងផ្ទាត់គឺ $u_1(t)=-2\cos\sqrt{6}t$ និង

សង្កេតចម្លើយដែលទទួលបានក្នុង $(c)$ និង $(d)$ ពិពណ៌នាវិធីពីរផ្សេងគ្នានៃរំញ័រ។ ដំបូងប្រេកង់នៃចលនាគឺ 1 និងម៉ាសទាំងពីរផ្លាស់ទីក្នុងរយៈពេលខួបឡើងនិងចុះដូចទាំងពីរ។ ចលនាទី២មាន ប្រេកង់ $\sqrt{6}$ ហើយម៉ាសទាំងពីរផ្លាស់ប្តូរចេញពីខួប មួយផ្លាស់ទីចុះ មួយទៀតផ្លាស់ទីឡើងផ្ទុយគ្នា។ សម្រាប់លក្ខខណ្ឌដើមចលនានៃម៉ាសជាបន្សំនៃ mode ទាំងពីរនេះ។

40. ក្នុងលំហាត់យើងគ្រោង វិធីមួយដើម្បីបង្ហាញថា បើ $r_1,....,r_n$ គឺពិតនិងខុសគ្នានោះ $e^{r_1t},...,e^{r_nt}$ មិនអាស្រ័យលីនេអ៊ែរ លើ $-\infty<t<+\infty$ ។ ដើម្បីបង្ហាញ យើងសន្មត់ទំនាក់ទំនងលីនេអ៊ែរ៖

$$c_1e^{r_1t}+\cdots+c_ne^{r_nt}=0, \quad -\infty<t<\infty \qquad \text{(i)}$$

និងបង្ហាញថាគ្រប់ចំនួនថេរគឺសូន្យ។

គុណ សមីការ $(i)$ ដោយ $e^{-r_1t}$ និងបែងចែកជាមួយតម្លៃនៃ $t$ នោះគេបាន

$$c_2(r_2-r_1)e^{(r_2-r_1)t}+\cdots+c_n(r_n-r_1)e^{(r_n-r_1)t}=0$$

គុណលទ្ធផលនៃផ្នែក $(a)$ ដោយ $e^{-(r_2-r_1)t}$ បែងចែកជាមួយតម្លៃនៃ $t$ ដើម្បីបាន

$$c_3(r_3-r_2)(r_3-r_1)e^{(r_3-r_2)t}+\cdots c_n(r_n-r_2)(r_n-r_1)e^{(r_n-r_2)t}=0$$

បន្តនីតិវិធីពីផ្នែក $(a)$ និង $(b)$ នៅទីបំផុត យើងបានទទួលបាន

$$c_n(r_n-r_{n-1})\cdots(r_n-r_1)e^{(r_n-r_{n-1})t}=0$$

ដូចនេះ $c_n=0$ គេបាន $c_1e^{r_1t}+\cdots+c_{n-1}e^{r_{n-1}t}=0$

ធ្វើឡើងវិញនៅការបង្ហាញខាងលើ ដើម្បីបង្ហាញថា $c_{n-1}=0$ ។ តាមវិធីស្រដៀងគ្នានោះ $c_{n-2}=\cdots=c_1=0$ នោះអនុគមន៍ $e^{r_1t},...,e^{r_nt}$ មិនអាស្រ័យលីនេអ៊ែរ។

## ៤.៣. វិធីសាស្ត្រមេគុណមិនកំណត់

ដំណោះស្រាយពិសេស $y$ នៃជាតុមិនសុទ្ធលំដាប់ $n$ សមីការបន្ទាត់ក្នុងករណីមេគុណថេរ

$$L[y]=a_0y^{(n)}+a_1y^{(n-1)}+\cdots+a_{n-1}y'+a_ny=g(t) \qquad (1)$$

វាអាចអនុវត្តបានដោយវិធីសាស្ត្រនៃការកំណត់មេគុណនេះ ដោយ $g(t)$ គឺជារូបមន្តសមស្រប។ ខណៈពេលដែលវិធីសាស្ត្រនៃការកំណត់មេគុណមិនជាទូទៅដូចទៅនឹងវិធីសាស្ត្របម្រែបម្រួលប៉ារ៉ាម៉ែត្រ ដែលនឹងបកស្រាយនៅក្នុងផ្នែកបន្ទាប់ វាគឺពិតជាងាយស្រួលនៅពេលដែលយើងអាចអនុវត្តបាន។

លំដាប់ទី២នៃសមីការបន្ទាប់ នៅពេលដែលសមីការបន្ទាត់ឌីផេរ៉ង់ស្យែលមានមេគុណថេរបង្កើត $L$ គឺអនុវត្តនៅប៉ូលីណូម៉ាល់ $A_0t^m + A_1t^{m-1} + \cdots + A_m$ អនុគមន៍អិចស្ប៉ូណង់ស្យែល $e^{\alpha t}$ អនុគមន៍ស៊ីនុស $\sin\beta t$ ឬក៏អនុគមន៍កូស៊ីនុស $\cos\beta t$ ដូចនេះវាគឺជាអនុគមន៍ពហុធា អនុគមន៍អិចស្ប៉ូណង់ស្យែល ឬអនុគមន៍សមីការបន្ទាត់ដែលបង្កើតឡើងដោយស៊ីនុស កូស៊ីនុស ឬគោរពទៅតាមលក្ខខណ្ឌ។
ដូចនេះបើ $g(t)$ គឺជាផលបូកនៃអនុគមន៍ពហុធា អនុគមន៍អិចស្ប៉ូណង់ស្យែល អនុគមន៍ស៊ីនុស អនុគមន៍កូស៊ីនុស ឬអ្វីផ្សេងទៀតដែលដូចទៅនឹងអនុគមន៍ យើងអាចគិតវាមានភាពងាយស្រួលក្នុង $Y(t)$ ដោយការជ្រើសរើសជាតុផ្សំដែលអាចទៅរួចនៃអនុគមន៍អិចស្ប៉ូណង់ស្យែលជាដើម បានធ្វើផលគុណដោយចំនួនដែលបានកំណត់ថេរ។ នៅពេលចំនួនថេរត្រូវបានកំណត់ដូចនេះអនុគមន៍ (1) ត្រូវបានកំណត់។
ភាពខុសគ្នានៅក្នុងការប្រើប្រាស់វិធីសាស្ត្រក្នុងការរកលំដាប់ខ្ពស់នៃសមីការដើម មកពីលក្ខណៈពិតនៃឬសនៃលក្ខណៈពហុធាអាចមានផលគុណធំជាង២ ។ ដូច្នេះ គោលបំណងលក្ខខណ្ឌនៃជាតុមិនសុទ្ធ គឺជាផ្នែកមួយនៃដំណោះស្រាយ ដែលយើងត្រូវធ្វើផលគុណដោយមានលំដាប់ស្វ័យគុណខ្ពស់នៃ $t$ ដើម្បីឱ្យវាមានលក្ខណៈខុសពីគ្នាក្នុងដំណោះស្រាយនៃសមីការដែលត្រូវគ្នាដូចគ្នាបេះបិត។

**ឧទាហរណ៍ទី១៖** រកចម្លើយទូទៅនៃ $y''' - 3y'' + 3y' - y = 4e^t$ (2)

ចម្លើយ

សមីការសម្គាល់សម្រាប់ជាតុសុទ្ធដែលត្រូវគ្នាទៅនឹងសមីការទី (2) គឺ

$r^3 - 3r^2 + 3r - 1 = (r-1)^3$ មានឬសត្រួតគ្នារហូតបី $r_1 = r_2 = r_3 = 1$

ចម្លើយទូទៅនៃសមីការអូម៉ូសែនគឺ $y_c(t) = c_1e^t + c_2te^t + c_3t^2e^t$ (3)

ដើម្បីរកចម្លើយពិសេស $Y(t)$ នៃសមីការទី (2) យើងបានដោយសន្មត់ថា $Y(t) = Ae^t$ ។ គួរចំណាំថា ដោយសារ $e^t$ , $te^t$ និង $t^2e^t$ ជាចម្លើយទាំងអស់របស់សមីការអូម៉ូសែនដូចគ្នា យើងត្រូវគុណ $Y(t) = Ae^t$ ដោយ $t^3$ ។
នោះការសន្មតចុងក្រោយរបស់យើងគឺ $Y(t) = At^3e^t$ ដែល $A$ គឺជាមេគុណដែលអាចកំណត់បាន។ ដើម្បីរកចម្លើយត្រឹមត្រូវរបស់ $A$ យើងធ្វើដេរីវេ $Y(t)$ ចំនួនបីដង ហើយជំនួស $y$ ដោយដេរីវេរបស់វាទៅក្នុងសមីការ (2) ហើយប្រមូលលក្ខខណ្ឌទាំងអស់នៅក្នុងលទ្ធផលនៃសមីការ។ តាមវិធីនេះ យើងទទួលបាន

$6Ae^t = 4e^t$ នោះ $A = \frac{2}{3}$ ហើយចម្លើយពិសេសគឺ

$$Y(t) = \frac{2}{3}t^3e^t \qquad (4)$$

ចម្លើយទូទៅនៃសមីការទី (2) គឺជាផលបូកនៃ $y_c(t)$ ដែលបានមកពីសមីការទី (3) និង $Y(t)$ បានមកពីសមីការទី (4) ។

$$y(t) = y_c(t) + Y(t)$$

$$y(t) = c_1e^t + c_2te^t + c_3t^2e^t + \frac{2}{3}t^4e^t$$

ឧទាហរណ៍ទី២៖ រកចម្លើយពិសេសនៃសមីការ $y^{(4)}+2y''+y=3\sin t-5\cos t$ (5) ។

ចម្លើយ

ចម្លើយទូទៅនៃសមីការអូម៉ូសែនត្រូវបានរកឃើញនៅក្នុងឧទាហរណ៍ទី (3) នៃផ្នែក 3.2 ។ ពេលគឺ

$$y_c(t)=c_1\cos t+c_2\sin t+c_3t\cos t+c_4t\sin t \qquad (6)$$

ដែលត្រូវគ្នាទៅនឹងឫសនៃ $r=i$ , $i$ , $-i$ និង $-i$ នៃសមីការសម្គាល់។

ការសន្មត់ដំបូងរបស់យើងសម្រាប់ចម្លើយពិសេសមួយគឺ $Y(t)=A\sin t+B\cos t$ ប៉ុន្តែយើងត្រូវគុណ $Y(t)=A\sin t+B\cos t$ នេះដោយ $t^2$ ដើម្បីធ្វើវាឱ្យខុសគ្នាពីចម្លើយទាំងអស់របស់សមីការអូម៉ូសែន។ ចុងក្រោយយើងតាងគឺ

$$Y(t)=At^2\sin t+Bt^2\cos t$$

បន្ទាប់មកយើងដេរីវេ $Y(t)$ ចំនួនបួនដង ជំនួសទៅក្នុងសមីការឌីផេរ៉ង់ស្យែល (4) ហើយបាន

$$-8A\sin t-8B\cos t=3\sin t-5\cos t$$

នោះ $A=-\frac{3}{8}$ , $B=\frac{5}{8}$ ហើយចម្លើយពិសេសនៃសមីការទី (4) គឺអនុគមន៍ចម្លើយ

$$y(t)=c_1\cos t+c_2\sin t+c_3t\cos t+c_4t\sin t-\frac{3}{8}t^2\sin t+\frac{5}{8}t^2\cos t$$

ឧទាហរណ៍ទី៣៖ រកកចម្លើយពិសេសនៃ $y'''-4y'=t+3\cos t+e^{-2t}$ (8)

ដំបូងយើងត្រូវបង្ហាញសមីការអូម៉ូសែន។ សមីការលក្ខខណ្ឌគឺ $r^3-4r=0$ ហើយឫសរបស់វាគឺ $0$ , $\pm 2$ ដូច្នេះ

$$y_c(t)=c_1+c_2e^{2t}+c_3e^{-2t}$$

យើងអាចសរសេរសមីការពិសេសនៃសមីការ (8) គឺជាផលបូកសមីការទូទៅនៃសមីការឌីផេរ៉ង់ស្យែល

$$y'''-4y'=t\ , \quad y'''-4y'=3\cos t\ , \quad y'''-4y'=e^{-2t}$$

ជម្រើសដំបូងរបស់យើងនៃសមីការពិសេសគឺ $Y_1(t)$ នៃសមីការដំបូងគឺ $A_0t+A_1$ ប៉ុន្តែនៅពេលចំនួនថេរគឺជាចម្លើយនៃសមីការអូម៉ូសែន យើងគុណវាដោយ $t$ នោះ $Y_1(t)=t(A_0t+A_1)$

សម្រាប់សមីការទីពីរ យើងជ្រើសរើស

$$Y_2(t)=B\cos t+C\sin t$$

ហើយមិនចាំបាច់កែប្រែជម្រើសដំបូងនេះទេ ព្រោះតម្លៃ $\cos t$ និង $\sin t$ មិនមែនជាចម្លើយនៃសមីការអូម៉ូសែនឡើយ។ ចុងក្រោយសម្រាប់សមីការទី៣ តម្លៃ $e^{-2t}$ គឺជាចម្លើយនៃសមីការអូម៉ូសែន យើងសន្មត់ថា $Y_3(t)=Ete^{-2t}$

តម្លៃថេរត្រូវបានកំណត់ដោយការជំនួសទៅក្នុងសមីការឌីផេរ៉ង់ស្យែលតែមួយគត់។

$A_0=-\frac{1}{8}$ , $A_1=0$ , $B=0$ , $C=-\frac{3}{5}$ និង $E=\frac{1}{8}$ នោះចម្លើយពិសេសនៃសមីការទី (8) គឺ

$$Y(t)=-\frac{1}{8}t^2-\frac{3}{5}\sin t+\frac{1}{8}te^{-2t} \qquad (9)$$

## លំហាត់

ក្នុងលំហាត់ 1ដល់ 8 កំណត់រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់អោយៈ

1. $y'''-y''-y'+y=2e^{-t}+3$

2. $y^{iv}-y=3t+\cos t$

3. $y'''+y''+y'+y=e^{-t}+4t$

4. $y'''-y'=2\sin t$

5. $y^{iv}-4y''=t^2+e^t$

6. $y^{iv}+2y''+y=3+\cos 2t$

7. $y^{iv}+y'''=t$

8. $y^{iv}+y'''=\sin 2t$

ក្នុងលំហាត់ 9ដល់ 12 កំណត់រកចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់អោយតាមលក្ខខណ្ឌដើម រួចគូសក្រាបៈ

9. $y'''+4y'=t, \quad y(0)=y'(0)=0, \quad y''(0)=1$

10. $y^{iv}+2y''+y'=3t+4, \quad y(0)=y'(0)=0, \quad y''(0)=y'''(0)=1$

11. $y'''-3y''+2y'=t+e^t, \quad y(0)=1, \quad y'(0)=-\dfrac{1}{4}, \quad y''(0)=-\dfrac{3}{2}$

12. $y^{iv}+2y'''+y''+8y'-12y=12\sin t-e^{-t}, \quad y(0)=3, \quad y'(0)=0, \quad y''(0)=-1, \quad y'''(0)=2$

ក្នុងលំហាត់ 13ដល់ 18 កំណត់រកចម្លើយមួយ $Y(t)$ នៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់អោយតាមវិធីសាស្ត្រមេគុណមិនកំណត់ៈ

13. $y'''-2y''+y'=t^3+2e^t$

14. $y'''-y'=te^{-t}+2\cos t$

15. $y^{iv}-2y''+y=e^t+\sin t$

16. $y^{iv}+4y''=\sin 2t+te^t+4$

17. $y^{iv}-y'''-y''+y'=t^2+4+t\sin t$

18. $y^{iv}-2y'''+2y''=3e^t+2te^{-t}+e^{-t}\sin t$

## ៤.៤ វិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ

វិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រនៃការកំណត់ដំណោះស្រាយដោយឡែកមួយនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរមិនអូម៉ូសែនលំដាប់ទី$n$

$$L[y]=y^{(n)}+p_1(t)y^{(n-1)}+...+P_{n-1}(t)y=g(t) \qquad (1)$$

គឺជាផ្នែកបន្ថែមមួយលើទ្រឹស្តីបទសម្រាប់សមីការឌីផេរ៉ង់ស្យែលលំដាប់ទីពីរ។

ឧបមាថា យើងដឹងសំណុំចម្លើយដែលជាមូលដ្ឋានគ្រឹះនៃដំណោះស្រាយ $y_1, y_2, ..., y_n$ នៃសមីការអូម៉ូសែន។ ចម្លើយទូទៅបន្ទាប់នៃសមីការអូម៉ូសែនគឺ

$$y_c(t)=c_1y_1(t)+c_2y_2(t)+...+c_ny_n(t) \qquad (2)$$

ទ្រឹស្តីបទនៃបម្រែបម្រួលប៉ារ៉ាម៉ែត្រ សម្រាប់ការកំណត់រកចម្លើយពិសេសមួយនៃឧទាហរណ៍ (1) ពឹងផ្អែកលើលទ្ធភាពនៃការកំណត់ $n$ អនុគមន៍ $u_1, u_2, ..., u_n$ នោះ $Y(t)$ នៃទម្រង់

$$Y(t)=u_1(t)y_1(t)+u_2(t)y_2(t)+...+u_n(t)y_n(t) \qquad (3)$$

$$Y'=(u_1y_1'+u_2y_2'+...+u_ny_n')+(u_1'y_1+u_2'y_2+...+u_n'y_n) \qquad (4)$$

លក្ខខណ្ឌមុនៗដែលយើងដាក់នោះគឺកំណត់

$$u'_1y_1+u'_2y_2+...+u'_ny_n=0 \qquad (5)$$

$$Y'' = (u_1 y_1'' + u_2 y_2'' + \ldots + u_n y_n'') + (u_1' y_1' + u_2' y_2' + \ldots + u_n' y_n')$$

លក្ខខណ្ឌមុនៗដែលយើងដាក់នោះគឺកំណត់ $(u_1' y_1' + u_2' y_2' + \ldots + u_n' y_n') = 0$ (5*)

$$Y''' = (u_1 y_1''' + u_2 y_2''' + \ldots + u_n y_n''') + (u_1' y_1'' + u_2' y_2'' + \ldots + u_n' y_n'')$$

លក្ខខណ្ឌមុនៗដែលយើងដាក់នោះគឺកំណត់ $(u_1' y_1'' + u_2' y_2'' + \ldots + u_n' y_n'') = 0$ (5**)

យើងបន្តដំណើរការនេះស្រដៀងៗគ្នា ដោយដេរីវេទី $n-1$ នៃ $Y$ គេបាន

$$Y^{(m)} = u_1 y_1^{(m)} + u_2 y_2^{(m)} + \ldots + u_n y_n^{(m)}, \quad m = 0,1,2,\ldots,n-1 \qquad (6)$$

ហើយតាម $n-1$ លក្ខខណ្ឌនៅលើអនុគមន៍ $u_1, \ldots, u_n$:

$$u'_1 y_1^{(m-1)} + u'_2 y_2^{(m-1)} + \ldots + u'_n y_n^{(m-1)} = 0 \quad m = 1,2,3,\ldots,n-1 \quad (7)$$

ដេរីវេទី $n$ នៃ $Y$ គឺ

$$Y^{(n)} = (u_1 y_1^{(n)} + \ldots + u_n y_n^{(n)}) + (u'_1 y_1^{(n-1)} + \ldots + u'_n y_n^{(n-1)}) \qquad (8)$$

ចុងក្រោយយើងដាក់កំណត់ថា $Y$ ត្រូវតែជាដំណោះស្រាយនៃឧទហរណ៍ (1) នៅលើការជំនួសសម្រាប់ដេរីវេនៃ $Y$ ពីឧទាហរណ៍ (6) និង (8) ដែលប្រមូលកន្សោម និងការប្រើប្រាស់ពិតថា $L[y_i] = 0$, $i = 1, 2, \ldots, n$ យើងបាន

$$u'_1 y_1^{(n-1)} + u'_2 y_2^{(n-1)} + \ldots + u'_n y_n^{(n-1)} = g \qquad (9)$$

តាមសមីការ(5),(5*),(5**),(7) (9) គូជាមួយ $n-1$ សមីការ (7) ឱ្យ $n$ ក្នុងដំណាលគ្នាលីនេអ៊ែគ្មានសមីការពីជគណិតអូម៉ូសែនសម្រាប់ $u_1', u_2', \ldots, u_n'$

$$\begin{aligned}
y_1 u'_1 + y_2 u'_2 + \ldots + y_n u'_n &= 0,\\
y_1 u'_1 + y'_2 u'_2 + \ldots + y_n u'_n &= 0,\\
y_1 u'_1 + y''_2 u'_2 + \ldots + y_n u'_n &= 0,\\
&\vdots\\
y_1^{(n-1)} u'_1 + \ldots + y_n^{(n-1)} u'_n &= g,
\end{aligned} \qquad (10)$$

ប្រើប្រាស់រូបមន្ត Cramer យើងកំណត់ថាដំណោះស្រាយនៃប្រព័ន្ធសមីការ (10) គឺ

$$W(y_1, y_2, \ldots, y_n) = \begin{vmatrix} y_1 & y_2 & \cdots & y_n \\ y_1' & y_2' & \cdots & y_n' \\ \vdots & \vdots & \ddots & \vdots \\ y_1^{n-1} & y_2^{n-1} & \cdots & y_n^{n-1} \end{vmatrix} \neq 0$$

$$W_1(t) = \begin{vmatrix} 0 & y_2 & \cdots & y_n \\ 0 & y_2' & \cdots & y_n' \\ \vdots & \vdots & \ddots & \vdots \\ g & y_2^{n-1} & \cdots & y_n^{n-1} \end{vmatrix}, W_2(t) = \begin{vmatrix} y_1 & 0 & \cdots & y_n \\ y_1' & 0 & \cdots & y_n' \\ \vdots & \vdots & \ddots & \vdots \\ y_1^{n-1} & g & \cdots & y_n^{n-1} \end{vmatrix}, W_m(t) = \begin{vmatrix} y_1 & y_2 & \cdots & 0 \\ y_1' & y_2' & \cdots & 0 \\ \vdots & \vdots & \ddots & \vdots \\ y_1^{n-1} & y_2^{n-1} & \cdots & g \end{vmatrix}$$

យើងទាញបានចម្លើយ $u_1'(t), u_2'(t), u_3'(t), \ldots, u_m'(t)$ គឺ

$$u'_m(t) = \frac{g(t) W_m(t)}{W(t)} \quad , \quad m = 1, 2, \ldots, n \qquad (11)$$

ចម្លើយដោយផ្នែកគឺ $$Y(t)=\sum_{m=1}^{n} y_m(t)\int_{t_0}^{t}\frac{g(s)W_m(s)}{W(s)}ds \qquad (12)$$

ដែល $t_0$ គឺរើសតម្លៃណាក៏បាន។ កំឡុងពេលនិតិវិធី គឺត្រង់ការគណនានៃពីជគណិតពាក់ព័ន្ធក្នុងការកំណត់ $Y(t)$ ពីឧទាហរណ៍ (12) កាន់តែស្មុគស្មាញដូចកំណើន $n$ ។ ក្នុងករណីខ្លះការគណនាប្រហែលជាសម្រួលទៅវិសាលភាពខ្លះដោយប្រើប្រាស់អត្តសញ្ញាណ Abel

$$W(t)=W(y_1,...,y_n)(t)=c\,e^{\left[-\int p_1(t)dt\right]}$$

តម្លៃថេរនៃ $c$ អាចត្រូវបានកំណត់ដោយការវាយតម្លៃ $W$ នៅចំណុចងាយស្រួលមួយចំនួន។

**ឧទាហរណ៍ទី១៖** មាន $y_1(t)=e^t, y_2(t)=te^t$ និង $y_3(t)=e^{-t}$ គឺចម្លើយនៃសមីការអូម៉ូសែនដែលត្រូវគ្នាទៅនឹង

$$y'''-y''-y'+y=g(t) \qquad (13)$$

ចូរកំណត់ចម្លើយដោយផ្នែកពិសេសមួយនៃសមីការ (13)

ចម្លើយ

ដំបូងយើងមាន

$$W(t)=W(e^t,te^t,e^{-t})=\begin{vmatrix} e^t & te^t & e^{-t} \\ e^t & (t+1)e^t & -e^{-t} \\ e^t & (t+2)e^t & e^{-t}\end{vmatrix}$$

$$W(t)=e^t\begin{vmatrix} 1 & t & 1 \\ 1 & t+1 & -1 \\ 1 & t+2 & 1\end{vmatrix}$$

យកជួរដេកទី២ ដកជួរដេកទី១

យកជួរដេកទី៣ ដកជួរដេកទី១ យើងទទួលប

$$W(t)=e^t\begin{vmatrix} 1 & t & 1 \\ 0 & 1 & -2 \\ 0 & 2 & 0\end{vmatrix}=e^t\begin{vmatrix} 1 & -2 \\ 2 & 0\end{vmatrix}=4e^t$$

$$W(t)=4e^t\neq 0$$

បន្ទាប់មក

$$W_1(t)=\begin{vmatrix} 0 & te^t & e^{-t} \\ 0 & (t+1)e^t & -e^{-t} \\ 1 & (t+2)e^t & e^{-t}\end{vmatrix}$$

ការប្រើប្រាស់ ដែលតូចបានផ្តុំគ្នាជាមួយជួរឈរ យើងទទួលបាន

$$W_1(t)=\begin{vmatrix} te^t & e^{-t} \\ (t+1)e^t & -e^{-t}\end{vmatrix}=-2t-1$$

ក្នុងមធ្យោបាយស្រដៀងគ្នាមួយ

$$W_2(t)=\begin{vmatrix} e^t & 0 & e^{-t} \\ e^t & 0 & -e^{-t} \\ e^t & 1 & e^{-t} \end{vmatrix} = -\begin{vmatrix} e^t & e^{-t} \\ e^t & -e^{-t} \end{vmatrix} = 2$$

និង

$$W_3(t)=\begin{vmatrix} e^t & te^t & 0 \\ e^t & (t+1)e^t & 0 \\ e^t & (t+2)e^t & 1 \end{vmatrix} = \begin{vmatrix} e^t & te^t \\ e^t & (t+1)e^t \end{vmatrix} = e^{2t}$$

ការជំនួសលទ្ធផលនេះក្នុងឧទាហរណ៍ (12) យើងមាន

$$Y(t)=e^t\int_{t_0}^{t}\frac{g(s)(-1-2s)}{4e^s}ds+te^t\int_{t_0}^{t}\frac{g(s)(2)}{4e^s}ds+e^{-t}\int_{t_0}^{t}\frac{g(s)\,\mathrm{e}^{2s}}{4e^s}ds$$
$$=\frac{1}{4}\int_{t_0}^{t}\{e^{t-s}[-1+2(t-s)]+e^{-(t-s)}\}g(s)ds$$

## លំហាត់

ក្នុងលំហាត់ទី 1 ដល់ 6 ការប្រើប្រាស់វិធីសាស្ត្រនៃបម្រែបម្រួលប៉ារ៉ាម៉ែត្រដើម្បីកំណត់ដំណោះស្រាយទូទៅនៃការផ្តល់ឱ្យសមីការឌីផេរ៉ង់ស្យែល។

1. $y'''+y'=\tan t,\quad 0<\mathrm{t}<\pi$ 2. $\mathrm{y}'''-y'=\mathrm{t}$

3. $y'''-2y''-y'+2\mathrm{y}=e^{4t}$ 4. $y'''+y'=\sec t,\ -\pi/2<t<\pi/2$

5. $y'''-y''-y'+\mathrm{y}=\mathrm{e}^{-t}\sin t$ 6. $y^{iv}+2y''+y=\sin t$

នៅក្នុងលំហាត់ទី 7 និង 8 រកដំណោះស្រាយទូទៅនៃការផ្តល់ឱ្យសមីការឌីផេរ៉ង់ស្យែល។ ចេញពីចម្លើយរបស់អ្នកក្នុងកន្សោមនៃអាំងតេក្រាលមួយឬច្រើន។

7. $y'''-y''+y'-y=\sec t,\quad -\pi/2<t<\pi/2$

8. $y'''-y'=\csc t,\qquad 0<t<\pi$

នៅក្នុងលំហាត់ទី 9 ដល់ 12 រកដំណោះស្រាយនៃចំណោទតម្លៃដើមដែលបានផ្តល់ឱ្យ។ បន្ទាប់មកដៅចំណុចនៅលើក្រាហ្វនៃដំណោះស្រាយ

9. $y'''+y'=\sec t \qquad y(0)=2\ ,\ y'(0)=1\ ,\ y^{n}(0)=-2$

10. $y^{iv}+2y^{n}+y=\sin t \qquad y(0)=2\ ,\ y'(0)=0\ ,\ y''(0)=-1\ ,\ y'''(0)=1$

11. $y'''-y''+y'-y=\sec t \qquad y(0)=2\ ,\ y'(0)=-1\ ,\ y''(0)=1$

12. $y'''-y'=\csc t \qquad y(\pi/2)=2\ ,\ y'(\pi/2)=1\ ,\ y''(\pi/2)=-1$

13. ឱ្យ $x, x^2$ និង $\frac{1}{x}$ គឺដំណោះស្រាយនៃសមីការអូម៉ូសែនដែលត្រូវគ្នានឹង

$$x^3y'''+x^2y''-2xy'+2\mathrm{y}=2\mathrm{x}^4,\quad x>0$$

កំណត់ដំណោះស្រាយពិសេសមួយ។

14. រករូបមន្តមួយដែលពាក់ព័ន្ធអាំងតេក្រាល សម្រាប់ដំណោះស្រាយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល $y'''-y''+y'-\mathrm{y}=g(t)$

15. រករូបមន្តមួយដែលពាក់ព័ន្ធអាំងតេក្រាល សម្រាប់ដំណោះស្រាយពិសេសមួយនៃសមីការ

ឌីផេរ៉ង់ស្យែល $y^{iv}-y=g(t)$
ដូច្នេះ អនុគមន៍ $\sin t$ , $\cos t$ , $\cot t$ , $\tan t$ ទម្រង់នៃសំណុំដែលជាមូលដ្ឋានគ្រឹះនៃដំណោះស្រាយសមីការអូម៉ូសែន។
16. រករូបមន្តមួយដែលពាក់ព័ន្ធអាំងតេក្រាល សម្រាប់ដំណោះស្រាយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល $y'''-3y''+3y'-y=g(t)$
បើ $g(t)=t^{-2}e^{t}$ កំណត់ $Y(t)$
17. រករូបមន្តមួយដែលពាក់ព័ន្ធអាំងតេក្រាល សម្រាប់ដំណោះស្រាយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល $x^3y'''-3x^2y''+6xy'-6y=g(x),\quad x>0$
ដូច្នេះ ផ្ទៀងផ្ទាត់មើលថា $x$ , $x^2$ , $x^3$ គឺដំណោះស្រាយសមីការមិនអូម៉ូសែន។

## ៤.៥ សមីការ អឺលែរ ( Euler Equation )

សមីការឌីផេរ៉ង់ស្យែលមានទម្រង់៖ $x^2y''+axy'+by=0$ (1)
ហៅថា សមីការអ៊ឺលែរ ដែល $a,b$ ជាចំនួនថេរ។ ទម្រង់ចម្លើយរបស់សមីការ(1) គឺ
$y(x)=c_1y_1(x)+c_2y_2(x)$ ដែល $y_1,y_2$ មានភាពអាស្រ័យលីនេអ៊ែរគ្នា ហើយ $y_1,y_2$ មានទម្រង់

$$y=x^r \qquad (2)$$

យើងធ្វើដេរីវេ $y',y''$ គេបាន $y=x^r$, $y'=rx^{r-1}$, $y''=r(r-1)x^{r-2}$ សមីការ(1)៖

$$x^2\left[r(r-1)x^{r-2}\right]+ax\left(rx^{r-1}\right)+bx^r=0$$

$$r(r-1)x^r+arx^r+bx^r=0$$

$$r^2+(a-1)r+b=0 \qquad (3)$$

សមីការខាងលើជាសមីការសម្គាល់ មានឫសដូចខាងក្រោម៖

$$r_1,r_2=\frac{-(a-1)\pm\sqrt{(a-1)^2-4b}}{2} \qquad (4)$$

សមីការ(3)អាចមានឫស ជាចំនួនពិតពីរផ្សេងគ្នា ជាពិចំនួនតពីរដូចគ្នា និង ជាចំនួនកុំផ្លិចឆ្លាស់។

### ៤.៥.១ មានឫសជាចំនួនពិតពីរផ្សេងគ្នា

ប្រសិនបើសមីការ(3)មានឫស ជាចំនួនពិតពីរផ្សេងគ្នា $r_1\neq r_2$ នោះ $y_1=x^{r_1},y_2=x^{r_2}$ ហើយ $W(y_1,y_2)=(r_2-r_1)^{r_1+r_2-1}\neq 0$ វាអាស្រ័យលីនេអ៊ែរគ្នា ដូចនេះចម្លើយទូទៅគឺ

$$y(x)=c_1x^{r_1}+c_2x^{r_2} \quad , \quad c_1,c_2\in\mathbb{R} \qquad (5)$$

ឧទាហរណ៍១៖ដោះស្រាយសមីការ $2x^2y''+3xy'-y=0,\quad x>0$ (7)
ចម្លើយ
ដោះស្រាយសមីការ $2x^2y''+3xy'-y=0\Rightarrow x^2y''+\frac{3}{2}xy'-\frac{1}{2}y=0$
សមីការស្គាល់ $r^2+\left(\frac{3}{2}-1\right)r-\frac{1}{2}=0 \quad \Rightarrow r^2+\frac{1}{2}r-\frac{1}{2}=0$
ឫសសមីការ $r_1=\frac{1}{2},r_2=-1$

ដូចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1x^{1/2}+c_2x^{-1}, \qquad c_1,c_2\in\mathbb{R} \qquad (8)$

ឧទាហរណ៍២៖ដោះស្រាយសមីការ $x^2\dfrac{d^2y}{dx^2}-2xy'-4y=0$

ចម្លើយ

ដោះស្រាយសមីការ $x^2\dfrac{d^2y}{dx^2}-2xy'-4y=0$

សមីការស្គាល់ $r^2-3r-4=0$

ឫសសមីការ $r_1=4, r_2=-1$

ដូចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1x^4+c_2x^{-1}, \qquad c_1,c_2\in\mathbb{R}$

### ៤.៥.២. មានឫសជាចំនួនពិតពីរដូចគ្នា

ប្រសិនបើសមីការ(3)មានឫស ជាចំនួនពិតពីរដូចគ្នា $r_1=r_2$ នោះ $y_1=x^{r_1}$ ហើយយើងទាញរកចម្លើយទី២គឺ $y_2=x^{r_1}\ln x$ ដូចនេះចម្លើយទូទៅគឺ

$$y(x)=c_1x^{r_1}+c_2x^{r_2}\ln x \qquad (9)$$

ឧទាហរណ៍៣៖ដោះស្រាយសមីការ $x^2y''+5xy'+4y=0, \qquad x>0 \qquad (10)$

ចម្លើយ

ដោះស្រាយសមីការ $x^2y''+5xy'+4y=0, \quad x>0$

សមីការស្គាល់ $r^2+(5-1)r+4=0 \quad \Rightarrow r^2+4r+4=0$

ឫសសមីការ $r_1=r_2=-2$

ចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1x^{-2}+c_2x^{-2}\ln x, \quad c_1,c_2\in\mathbb{R} \qquad (11)$

ឧទាហរណ៍៤៖ដោះស្រាយសមីការ $4x^2\dfrac{d^2y}{dx^2}+8x\dfrac{dy}{dx}+y=0$

ចម្លើយ

ដោះស្រាយសមីការ $4x^2\dfrac{d^2y}{dx^2}+8x\dfrac{dy}{dx}+y=0 \quad \Rightarrow x^2\dfrac{d^2y}{dx^2}+2x\dfrac{dy}{dx}+\dfrac{1}{4}y=0$

សមីការស្គាល់ $r^2+(2-1)r+\dfrac{1}{4}=0 \quad \Rightarrow r^2+r+\dfrac{1}{4}=0$

ឫសសមីការ $r_1=r_2=\dfrac{1}{2}$

ដូចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1x^{\frac{1}{2}}+c_2x^{\frac{1}{2}}\ln x, \quad c_1,c_2\in\mathbb{R}$

**ចំណាំ៖** បើសមីការមានឫសត្រួតគ្នាចំនួន $k$ នោះចម្លើយគឺ

$$y=c_1x^r+c_2x^r\ln x+\ldots+c_kx^r(\ln x)^{k-1} \quad ; \qquad c_1,c_2\ldots c_k\in\mathbb{R}$$

### ៤.៥.៣ មានឬសជាចំនួនកុំផ្លិចឆ្លាស់

ប្រសិនបើសមីការ(3)មានឫស ជាចំនួនកុំផ្លិច $r_1=\alpha+\beta i,\quad r_2=\alpha-\beta i$ នោះ $y_1=x^{\alpha+\beta i},\quad y_2=x^{\alpha-\beta i}$ ហើយយើងទាញ

$$y_1=x^{\alpha+\beta i}=e^{(\alpha+\beta i)\ln x}=e^{\alpha\ln x}e^{i\beta\ln x}=x^{\alpha}\left[\cos(\beta\ln x)+i\sin(\beta\ln x)\right],\quad x>0$$

$$y_2=x^{\alpha-\beta i}=e^{(\alpha-\beta i)\ln x}=e^{\alpha\ln x}e^{i(-\beta\ln x)}=x^{\alpha}\left[\cos(\beta\ln x)-i\sin(\beta\ln x)\right],\qquad x>0$$

ដូចនេះចម្លើយទូទៅគឺ $y(x)=x^{\alpha}\left[c_1\cos(\beta\ln x)+c_2\sin(\beta\ln x)\right],\quad x>0 \qquad (12)$

**ឧទាហរណ៍៥៖**ដោះស្រាយសមីការ $x^2y''+xy'+y=0,\qquad x>0 \qquad (13)$ ។

ចម្លើយ

ដោះស្រាយសមីការ $x^2y''+xy'+y=0,\qquad x>0$

សមីការស្គាល់ $r^2+(1-1)r+1=0 \qquad \Rightarrow r^2+1=0$

ឫសសមីការ $r_1=-i,\ r_2=i$

ចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1\cos(\ln x)+c_2\sin(\ln x),\ c_1,c_2\in\mathbb{R} \qquad (14)$

**ឧទាហរណ៍៦៖**ដោះស្រាយសមីការ $4x^2y''+17y=0,\qquad y(1)=-1,\qquad y'(1)=-\frac{1}{2}$ ។

ចម្លើយ

$y=x^{1/2}\left[c_1\cos(2\ln x)+c_2\sin(2\ln x)\right],\qquad c_1,c_2\in\mathbb{R}$

$y=-x^{1/2}\cos(2\ln x)$

**ឧទាហរណ៍៧៖**ដោះស្រាយសមីការ $x^3y'''+5x^2y''+7y'+8y=0$

ចម្លើយ

$y=c_1x^{-2}+c_2\cos(2\ln x)+c_3\sin(2\ln x),\qquad c_1,c_2,c_3\in\mathbb{R}$

**ឧទាហរណ៍៨៖**ដោះស្រាយសមីការ $x^2y''-3xy'+3y=2x^4e^x$

ចម្លើយ

$x^2y''-3xy'+3y=0$ មានចម្លើយ $y_c=Ax+Bx^3$ ហើយចម្លើយផ្នែកមួយទៀត $y_p=u_1y_1+u_2y_2$ បម្លែងសមីការដើម $y''-\frac{3}{x}y'+\frac{3}{x^2}y=2x^2e^x$ នោះ $P(x)=\frac{3}{x},g(x)=2x^4e^x,y_1=x,y_2=x^3$ តាមវិធីបម្រែបម្រួលប៉ារ៉ាម៉ែត្រ៖

$$w=\begin{vmatrix}x & x^3\\ 1 & 3x^2\end{vmatrix}=2x^3,\quad w_1=\begin{vmatrix}0 & x^3\\ 2x^2e^x & 3x^2\end{vmatrix}=-2x^5e^x,\quad w_2=\begin{vmatrix}x & 0\\ 1 & 2x^2e^x\end{vmatrix}=2x^2e^x$$

$$u_1'=\frac{w_1}{w}=\frac{-2x^5e^x}{2x^3}=-x^2e^x \qquad \Rightarrow u_1=-x^2e^x+2xe^x-2e^x$$

$$u_2'=\frac{w_2}{w}=\frac{2x^3e^x}{2x^3}=e^x \qquad \Rightarrow u_2=e^x$$

ចម្លើយផ្នែកមួយ $y_p=u_1y_1+u_2y_2=\left(-x^2e^x+2xe^x-2e^x\right)x+e^xx^3=2x^2e^x-2xe^x$

ចម្លើយទូទៅមួយ $y=y_c+y_p=Ax+Bx^3+2x^2e^x-2xe^x$

ចំណាំ ៖សមីការ $(x-x_o)^2y''+\alpha(x-x_o)y'+\beta y=0$ យើងតាង $t=x-x_0$

មានអនុគមន៍ចម្លើយទូទៅ $y=(x-x_0)^r$

## ៤.៤ មេគុណមិនកំណត់និងវិធីសាស្ត្រធ្វើឱ្យសូន្យ ( Undetermined Coefficients-Annihilator Approach )

យើងបានដឹងរួចមកហើយថា សមីការឌីផេរ៉ង់ស្យែលលំដាប់ទី $n$ មានទម្រង់៖

$$a_ny^{(n)}+a_{n-1}y^{(n-1)}+a_{n-2}y^{(n-2)}+....+a_2y''+a_1y'+a_0y=g(x)$$

សមីការខាងលើ អាចសរសេរមកជាទម្រង់ខាងក្រោម៖

$$a_nD^ny+a_{n-1}D^{n-1}y+a_{n-2}D^{(n-2)}y+....+a_2D^2y+a_1Dy+a_0y=g(x) \qquad (1)$$

ដែល $y^{(n)}=\dfrac{d^ny}{dx^n}=D^ny, \quad y^{(n-1)}=\dfrac{d^{n-1}y}{dx^{n-1}}=D^{n-1}y,......,y''=\dfrac{d^2y}{dx^2}=D^2y, \quad y'=\dfrac{dy}{dx}=Dy$

សមីការ(1)អាចសរសេរជាទម្រង់ខ្លី $L(y)=g(x)$ ដែល $L$ តាងដោយកន្សោមលីនេអ៊ែរដីក្រេទី $n$ ឬពហុធា គេបាន៖

$$L(y)=a_nD^ny+a_{n-1}D^{n-1}y+a_{n-2}D^{(n-2)}y+....+a_2D^2y+a_1Dy+a_0y \qquad (2)$$

ឧទាហរណ៍៖ចូរសរសេរសមីការ $y''+5y'+6y=g(x)$ ជាទម្រង់សមីការ(1)

ចម្លើយ $D^2y+5Dy+6y=g(x)$

### លំហាត់

ក្នុងលំហាត់ 1ដល់ 12 កំណត់រកចម្លើយទូទៅនៃសមីការអ៊ឺលែរដែលបានផ្តល់អោយ៖

1. $x^2y''+4xy'+2y=0$
2. $(x+1)^2y''+3(x+1)y'+0.75y=0$
3. $x^2y''-3xy'+4y=0$
4. $x^2y''+3xy'+5y=0$
5. $x^2y''-xy'+y=0$
6. $(x-1)^2y''+8(x-1)y'+12y=0$
7. $x^2y''+6xy'-y=0$
8. $2x^2y''-4xy'+6y=0$
9. $x^2y''-5xy'+9y=0$
10. $(x-2)^2y''+5(x-2)y'+8y=0$
11. $x^2y''+2xy'+4y=0$
12. $x^2y''-4xy'+4y=0$

ក្នុងលំហាត់ 13ដល់ 16 កំណត់រកចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់អោយតាមលក្ខខណ្ឌដើម។ សង់ក្រាបរួចពណ៌នាពេល $x\to 0$

13. $2x^2y''+xy'-3y=0, \quad y(1)=1, \quad y'(1)=4$
14. $4x^2y''+8xy'+17y=0 \quad y(1)=2, \quad y'(1)=-3$
15. $x^2y''-3xy'+4y=0 \quad y-(1)=2, \quad y'(-1)=3$
16. $x^2y''+3xy'+5y=0 \quad y(1)=1, \quad y'(1)=-1$

ក្នុងលំហាត់ 17ដល់ 22 កំណត់រកចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែលដែលបានផ្តល់អោយ៖

17. $xy''-4y'=x^4$,

18. $2x^2y''+5xy'+y=x^2-x$

19. $x^2y''-xy'+y=2x$

20. $x^2y''-2xy'+2y=x^4e^x$

21. $x^2y''+xy'-y=\ln x$

22. $x^2y''+xy'-y=\dfrac{1}{x+1}$

## ៤.៤.១ ការដាក់ផលគុណកត្តា

ក្នុងសមីការឌីផេរ៉ង់ស្រែល$(1)$មានពហុធា

$L(y)=a_nD^ny+a_{n-1}D^{n-1}y+a_{n-2}D^{(n-2)}y+....+a_2D^2y+a_1Dy+a_0y$

ដែលយើងអាចបំបែកពហុធាជាផលគុណកត្តាដែលមានលក្ខណៈដូចខាងក្រោម៖

1. $L(y)$ អាចដាក់ជាផលគុណកត្តាជីក្រេទាប
2. $L(y)$ មានលក្ខណៈត្រឡប់

ឧទាហរណ៍១៖ ចូរដាក់កន្សោមខាងក្រោមជាផលគុណកត្តា៖

1. $L(y)=D^2+D$
2. $L(y)=D^2-1$
3. $L(y)=D^2+5D+6$
4. $L(Y)=D^2+4D+4$
5. $L(y)=D^2+1$

ចម្លើយ

ដាក់កន្សោមខាងក្រោមជាផលគុណកត្តា

1. $L(y)=D^2+D=D(D+1)=(D+1)D$
2. $L(y)=D^2-1=(D+1)(D-1)=(D-1)(D+1)$
3. $L(y)=D^2+5D+6=(D+2)(D+3)=(D+3)(D+2)$
4. $L(y)=D^2+4D+4=(D+2)^2$
4. $L(y)=D^2+1$មិនអាចដាក់ជាកត្តាដោយប្រើចំនួនពិតបានទេ។

ឧទាហរណ៍២៖សមីការឌីផេរ៉ង់ស្យែល $y''+4y'+4y=0$ យើអាចសសេរបាន

$D^2y+4Dy+4y=0$

$(D^2+4D+4)y=0$

$(D+2)^2y=0$

យើងបង្រួមលំដាប់បានដោយតាង $w=(D+2)y$ គេបាន

$(D+2)w=0 \quad \Rightarrow w'+2w=0$

## ៤.៤.២ វិធីសាស្ត្រធ្វើឱ្យសូន្យ

### ១.ការីឌីផេរ៉ង់ស្យែល $D^{n+1}$ ធ្វើឱ្យសូន្យប្រភេទអនុគមន៍៖

$1, \quad x, \quad x^2, ..........., x^n \qquad (1)$

$c_0 + c_1x + c_2x^2 + .... + c_nx^n \qquad (2)$

ឧទាហរណ៍១៖ រកការីឌីរ៉ង់ស្យែល ដែលធ្វើអោយអនុគមន៍ខាងក្រោមស្មើសូន្យ៖

$a/\ 2023 \qquad b/\ 4x \qquad c/\ -7x^4 \qquad d/2023+2x^3-7x^5$

ចម្លើយ

$a/\ 2023$ យើងសង្កេតឃើញតម្លៃ $n=0$ នោះការីឌីរ៉ង់ស្យែលគឺ $D(2023)=0$

$b/\ 4x$ យើងសង្កេតឃើញតម្លៃ $n=1$ នោះការីឌីរ៉ង់ស្យែលគឺ $D^2(4x)=0$

$c/\ -7x^4$ យើងសង្កេតឃើញតម្លៃ $n=4$ នោះការីឌីរ៉ង់ស្យែលគឺ $D^5(-7x^4)=0$

$d/2023+2x^3-7x^5$ យើងសង្កេតឃើញតម្លៃ $n=5$ នោះការីឌីរ៉ង់ស្យែលគឺ
$D^6(2023+2x^3-7x^5)=0$

### ២.ការីឌីផេរ៉ង់ស្យែល $(D-\alpha)^{n+1}$ ធ្វើឱ្យសូន្យប្រភេទអនុគមន៍៖

$e^{\alpha x}, \quad xe^{\alpha x}, \quad x^2e^{\alpha x}, ..........., x^ne^{\alpha x} \qquad (3)$

$c_0e^{\alpha x} + c_1xe^{\alpha x} + c_2x^2e^{\alpha x} + .... + c_nx^ne^{\alpha x} \qquad (4)$

ឧទាហរណ៍២៖ រកការីឌីរ៉ង់ស្យែល ដែលធ្វើអោយអនុគមន៍ខាងក្រោមស្មើសូន្យ៖

$a/\ 2023e^{4x} \qquad b/\ 4xe^{-2x} \qquad c/\ -7x^4e^x \qquad d/2x^3e^{-x}-7x^5e^{-x}$

ចម្លើយ

$a/\ 2023e^{4x}$ យើងសង្កេតឃើញតម្លៃ $n=0, \quad \alpha=4$ នោះការីឌីរ៉ង់ស្យែលគឺ $(D-4)(2023e^{4x})=0$

$b/\ 4xe^{-2x}$ យើងសង្កេតឃើញតម្លៃ $n=1, \quad \alpha=-2$ នោះការីឌីរ៉ង់ស្យែលគឺ $(D+2)^2(4xe^{-2x})=0$

$c/\ -7x^4e^x$ យើងសង្កេតឃើញតម្លៃ $n=4, \quad \alpha=1$ នោះការីឌីរ៉ង់ស្យែលគឺ $(D-1)^5(-7x^4e^x)=0$

$d/\ 2x^3e^{-x}-7x^5e^{-x}$ យើងសង្កេតឃើញតម្លៃ $n=5, \quad \alpha=-1$ នោះការីឌីរ៉ង់ស្យែលគឺ
$(D+1)^6(2x^3e^{-x}-7x^5e^{-x})=0$

ឧទាហរណ៍៣៖ រកការីឌីរ៉ង់ស្យែល ដែលធ្វើអោយអនុគមន៍ខាងក្រោមស្មើសូន្យ៖

$a/e^{4x}-e^x \qquad b/\ 4xe^{-2x}+5e^x \qquad c/\ -7x^4e^x+x^2 \qquad d/2x^3e^{-x}-7x^5e^x+x$

ចម្លើយ

$a/\ e^{4x}-e^x$ យើងសង្កេតឃើញ $e^{4x}$ មានតម្លៃ $n=0, \quad \alpha=4$ និង $e^x$ មានតម្លៃ $n=0, \quad \alpha=1$
នោះការីឌីរ៉ង់ស្យែលគឺ $(D-4)(D-1)(e^{4x}-e^x)=0$

$b/\ 4xe^{-2x}+5e^x$ យើងសង្កេតឃើញ $xe^{-2x}$ មានតម្លៃ $n=1, \quad \alpha=-2$ និង $5e^x$ មានតម្លៃ $n=0, \quad \alpha=1$
នោះការីឌីរ៉ង់ស្យែលគឺ $(D+2)^2(D-1)(4xe^{-2x}+5e^x)=0$

$c/ -7x^4e^x + x^2$ យើងសង្កេតឃើញ $-7x^4e^x$ មានតម្លៃ $n=4, \quad \alpha=1$ និង $x^2$ មានតម្លៃ $n=2$ នោះការីឌីរ៉ង់ស្យែលគឺ $D^3(D-1)^5\left(-7x^4e^x+x^2\right)=0$

$d/ 2x^3e^{-x} - 7x^5e^x + x$ យើងសង្កេតឃើញ $2x^3e^{-x}$ មានតម្លៃ $n=3, \quad \alpha=-1$ និង $7x^5e^x$ មានតម្លៃ $n=5, \quad \alpha=1$ និង $x$ មានតម្លៃ $n=1$ នោះការីឌីរ៉ង់ស្យែលគឺ $D^2\left(D+1\right)^4(D-1)^6\left(2x^3e^{-x}-7x^5e^x+x\right)=0$

### ៣.ការីឌីផេរ៉ង់ស្យែល $\left(D^2-2\alpha D+\alpha^2+\beta^2\right)^{n+1}$ ធ្វើឱ្យសូន្យប្រភេទអនុគមន៍៖

$$e^{\alpha x}\cos\beta x,\quad xe^{\alpha x}\cos\beta x,\quad x^2e^{\alpha x}\cos\beta x,..........,x^ne^{\alpha x}\cos\beta x \qquad (5)$$

$$e^{\alpha x}\sin\beta x,\quad xe^{\alpha x}\sin\beta x,\quad x^2e^{\alpha x}\sin\beta x,..........,x^ne^{\alpha x}\sin\beta x \qquad (6)$$

ឧទាហរណ៍៤៖ រកការីឌីរ៉ង់ស្យែល ដែលធ្វើអោយអនុគមន៍ខាងក្រោមស្មើសូន្យ៖

$a/ e^x\cos x$ $\quad b/ 4x\sin 3x$ $\quad c/ -7x^4e^x\cos x$ $\quad d/\sin x+2x^3e^{-x}+x$

ចម្លើយ

$a/ e^x\cos x$ យើងសង្កេតឃើញតម្លៃ $n=0, \quad \alpha=1, \quad \beta=1$ នោះការីឌីរ៉ង់ស្យែលគឺ $\left(D^2+2D+2\right)\left(e^x\cos x\right)=0$

$b/ 4x\sin 3x$ យើងសង្កេតឃើញតម្លៃ $n=1, \quad \alpha=0, \quad \beta=3$ នោះការីឌីរ៉ង់ស្យែលគឺ $\left(D^2+9\right)^2\left(4x\sin 3x\right)=0$

$c/ -7x^4e^x\cos x$ យើងសង្កេតឃើញតម្លៃ $n=4, \quad \alpha=1, \quad \beta=1$ នោះការីឌីរ៉ង់ស្យែលគឺ $\left(D^2-2D+2\right)^5\left(-7x^4e^x\cos x\right)=0$

$d/\sin x+2x^3e^{-x}+x$ យើងសង្កេតឃើញតម្លៃការីឌីរ៉ង់ស្យែលគឺ $\left(D^2+1\right)\left(D+1\right)^4\left(D^2\right)\left(\sin x+2x^3e^{-x}+x\right)=0$

## ៤.៤.៣ អនុវត្តសមីការឌីផេរ៉ង់ស្យែល

ឧទាហរណ៍៥៖រកចម្លើយទូទៅនៃសមីការ $y''+3y'+2y=4x^2$ $\qquad (1)$

ចម្លើយ

មាន $y''+3y'+2y=4x^2$ យើងអាចបម្លែងបាន

$$D^2y+3Dy+2y=4x^2$$

$$\left(D^3\right)\left(D^2+3D+2\right)y=D^3\left(4x^2\right)$$

$$\left(D^3\right)\left(D^2+3D+2\right)y=0 \qquad (2)$$

សមីការ(2)ជំនួសដោយសមីការសម្គាល់

$r^3\left(r^2+3r+2\right)=0$ មានឫស $r_1=-1, r_2=-2, \quad r_3=r_4=r_5=0$

អនុគមន៍ចម្លើយទូទៅគឺ $y=y_c+y_p=\underbrace{c_1e^{-x}+c_2e^{-2x}}_{y_c}+\underbrace{A+Bx+Cx^2}_{y_p}$ $\qquad (3)$

យើងត្រូវបន្តរកតម្លៃមេគុណ $A,B,C$ ដោយរក $y_p', \quad y_p''$ ជំនួសមីការ(1)យនឹងទទួលបានតម្លៃ៖

$A=7, \quad B=-6, \quad C=2$

ដូចនេះ អនុគមន៍ចម្លើយទូទៅគឺ $y=c_1e^{-x}+c_2e^{-2x}+7-6x+2x^2$ $c_1,c_2\in\mathbb{R}$ (4)

**ឧទាហរណ៍៦៖**រកចម្លើយទូទៅនៃសមីការ $y''-3y'=8e^{3x}+4\sin x$ (5)

ចម្លើយ

មាន $y''-3y'=8e^{3x}+4\sin x$ យើងអាចបម្លែងបាន

$$D^2y-3Dy=8e^{3x}+4\sin x$$

$$(D-3)(D^2+1)(D^2-3D)y=(D-4)(D^2+1)(8e^{3x}+4\sin x)$$

$$(D-3)(D^2+1)(D^2-3D)y=0 \quad (6)$$

សមីការ(6)ជំនួសដោយសមីការសម្គាល់

$(r-3)(r^2+1)(r^2-3r)=0$ មានឫស $r_1=0,\ r_2=3,\ r_3=3,$ $r_4=0+i, r_5=0-i$

អនុគមន៍ចម្លើយទូទៅគឺ $y=y_c+y_p=\underbrace{c_1+c_2e^{-3x}}_{y_c}+\underbrace{Axe^{3x}+B\cos x+C\sin x}_{y_p}$ (7)

យើងត្រូវបន្តរកតម្លៃមេគុណ $A,B,C$ ដោយរក $y_p'$, $y_p''$ ជំនួសមីការ(1)យនឹងទទួលបានតម្លៃ៖

$A=8/3,\quad B=6/5,\quad C=-2/5$

ដូចនេះ អនុគមន៍ចម្លើយទូទៅគឺ

$$y=c_1+c_2e^{3x}+\frac{8}{3}xe^{3x}+\frac{6}{5}\cos x-\frac{2}{5}\sin x \qquad c_1,c_2\in\mathbb{R} \quad (8)$$

ប្រតិបត្តិ

រកចម្លើយទូទៅនៃសមីការ

a. $y''+y'=x\cos x-\cos x$

$$\left(y=c_1\cos x+c_2\sin x+\frac{1}{4}x\cos x-\frac{1}{2}x\sin x+\frac{1}{4}x^2\sin x\right)$$

b. $y''+8y=5x-2e^{-x}$ ,

$$\left(y=c_1\cos 2\sqrt{2}x+c_2\sin 2\sqrt{2}x+\frac{5}{8}x+\frac{2}{9}e^{-x}\right)$$

**ចំណាំ៖**

វិធីសាស្ត្រខាងលើមិនអាចអនុវត្តចំពោះសមីការលីនេអ៊ែរ

$$a_ny^{(n)}+a_{n-1}y^{(n-1)}+a_{n-2}y^{(n-2)}+....+a_0y=g(x)$$

ប្រសិនបើ $g(x)=\ln x,\quad g(x)=\frac{1}{x},\quad g(x)=\tan x,\quad g(x)=\sin^{-1}x$ បានឡើយ។

## លំហាត់

ក្នុងលំហាត់1-10ចូរសរសេរសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរជាទម្រង់ $L(y)=g(x)$ និងដាក់ជាផលគុណកត្តាអង្គខាងឆ្វេង៖

1. $9y''-4y=\sin x$
2. $y''-5y=x^2-2x$
3. $y''-4y'-12y=x-6$
4. $2y''-3y'-2y=1$
5. $y'''+10y''+25y'=e^x$
6. $y'''+2y''-13y'+10y=xe^{-x}$
7. $y'''+4y'=e^x\cos 2x$
8. $y'''+4y''+3y'=x^2\cos x-3x$
9. $y^{(4)}+8y'=4$
10. $y^{(4)}-8y''+16y=\left(x^2-2x\right)e^{4x}$

ក្នុងលំហាត់11-14 ចូរបញ្ជាក់ថាការីឌីផេរ៉ង់ស្យែលធ្វើឲ្យសូន្យអនុគមន៍ដែលបានផ្តល់៖

11. $D^4,\quad y=19x^3-2x$
12. $2D-1,\quad y=4e^{x/2}$
13. $(D-2)(D+5),\quad y=e^{2x}+3e^{-5x}$
14. $D^2+64,\quad y=2\cos 8x+5\sin 8x$

ក្នុងលំហាត់15-26 ចូររកការីឌីផេរ៉ង់ស្យែលធ្វើឲ្យសូន្យអនុគមន៍ដែលបានផ្តល់៖

15. $1+6x-2x^2$
16. $x^3(1-5x)$
17. $1+7e^{2x}$
18. $x+3xe^{6x}$
19. $\cos 2x$
20. $1+\sin x$
21. $13x+9x^2-\sin 4x$
22. $8x-\sin x+10\cos 5x$
23. $e^{-x}+2xe^x-x^2e^x$
24. $\left(2-e^x\right)^2$
25. $3+e^x\cos 2x$
26. $e^{-x}\sin x-e^{2x}\cos x$

ក្នុងលំហាត់27-34 ចូររកអនុគមន៍ដែលត្រូវនឹងការីឌីផេរ៉ង់ស្យែលធ្វើឲ្យសូន្យខាងក្រោម៖

27. $D^5$
28. $D^2-4d$
29. $(D-3)(2D+3)$
30. $D^2-9D-36$
31. $D^2+5$
32. $D^2-6D+10$
33. $D^3-10D^2+25D$
34. $D^2(D-5)(D-7)$

ក្នុងលំហាត់35-44 ចូររកអនុគមន៍ចម្លើយសមីការឌីផេរ៉ង់ស្យែលមេគុណមិនកំណត់៖

35. $y''-9y=54$
36. $2y''-7y'+5y=-29$
37. $y'''+2y''+y'=10$
38. $y'''+y''=8x^2$
39. $y''+2y'+2y=5e^{6x}$
40. $y''+6y''+8y=3e^{-2x}+2x$
41. $y''-2y'+5y=e^x\sin x$
42. $y'''-y''+y'-y=xe^x-e^{-x}+7$
43. $2y'''-3y''-3y'=\left(e^x+e^{-x}\right)^2$
44. $y^{(4)}-2y'''+y''=10$

ក្នុងលំហាត់45-49ចូររកអនុគមន៍ចម្លើយសមីការឌីផេរ៉ង់ស្យែលមេគុណមិនកំណត់តាមលក្ខខ័ណ្ឌដើម ៖

45. $y''-64y=16,\quad y(0)=1,\quad y'(0)=0$

46. $y''-5y'=x-2,\quad y(0)=0,\quad y'(0)=4$

47. $y''+5y'-6y=10e^{x},\quad y(0)=1,\quad y'(0)=1$

48. $y'''-2y''+y'=xe^{x}1+5,\quad y(0)=2,\quad y'(0)=2,\quad y''(0)=-1$

49. $y^{(4)}-y'''=x+e^{x}16,\quad y(0)=0,\quad y'(0)=0,\quad y''(0)=0,\quad y'''(0)=0$

# ឯកសារយោង


1. វចនានុក្រម គណិតវិទ្យា អង់គ្លេស-ខ្មែរ ,RUPP (2017)
2. វចនានុក្រម សម្ដេចសង្ឃ ជួន ណាត
3. លោកគ្រូ លី ស្រួច: គណនាឌីផេរ៉ង់ស្យែល ២ ,RUPP (2018)
4. លោកគ្រូ លាវ ផារុន និង យឹម អយុវឌ្ឍន៍
5. John K. Hunter, Bruno Nachtergaele:
   Applied Analysis, University of California at Davis September 12, 2000
6. Léonard Todjihounde:
   Calcul différentiel, CEPAD 2004.
7. HENRY CARTAN:
   CALCUL DIFFÉRENTIEL, HERMANN, PARIS 1971.
8. Jacqueline Lelong-Ferrand, Jean-Marie Arnaudiès:
   Cours de mathématiques, Dunod, Paris, 2001.
9. Paul Dawkins:
   DIFFERENTIAL EQUALTION, PAUL DAWKINS,2007.
10. -William E.Boyce, Richard C.DiPrima:
    Elementary Differential Equaltions and Boundary Value Problems,New York,2001, 7 edition.